# ជំពូកទី៩

# ការវិភាគសេដ្ឋកិច្ច និងតម្លៃបរិស្ថាន

Draft

# ជំពូកទី៩៖ ការវិភាគសេដ្ឋកិច្ច និងតម្លៃបរិស្ថាន

## ៩.១. សេចក្តីផ្តើម

ការវិភាគសេដ្ឋកិច្ច ជាវិធីសាស្រ្តមួយដែលផ្តល់ព័ត៌មានមូលដ្ឋានសម្រាប់ជាជំនួយដល់ការធ្វើសេចក្តីសម្រេចចិត្តផ្នែកសេដ្ឋកិច្ចលើគម្រោងស្នើសុំ។ ជាទូទៅការវិភាគសេដ្ឋកិច្ច ត្រូវបានធ្វើឡើងមុនពេលអនុញ្ញាតឱ្យអនុវត្តគម្រោងស្នើសុំនោះ (Boardman et al. 2006)។ ការប៉ាន់ស្មានពីផលចំណេញ និងថ្លៃចំណាយ ជាទូទៅត្រូវបានធ្វើឡើង ដោយប្រើប្រាស់តម្លៃនៅលើទីផ្សារ។ ដូច្នេះផលចំណេញ និងថ្លៃខាតបង់លើធនធានបរិស្ថាន-សង្គមដែលពុំមានតម្លៃនៅលើទីផ្សារ តែងតែត្រូវបានគេមើលរំលង ឬមិនត្រូវបានគេគិតគូរឱ្យបានគ្រប់ជ្រុងជ្រោយនៅក្នុងការវិភាគសេដ្ឋកិច្ចនោះទេ។

គម្រោងវិនិយោគសម្រាប់អភិវឌ្ឍន៍ដំណាំកសិ-ឧស្សាហកម្ម របស់ក្រុមហ៊ុន SK Plantation (Cambodia) Pte. Ltd. ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាអនុញ្ញាត ហើយផែនការមេសម្រាប់ការអភិវឌ្ឍរបស់ក្រុមហ៊ុន ក៏ត្រូវបានទទួលការឯកភាពជាគោលការណ៍ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមរយៈលិខិតលេខ ៦២១៣ កសក ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៦។ ការវិភាគសេដ្ឋកិច្ច ត្រូវបានរៀបចំរួចរាល់នៅក្នុងផែនការមេគម្រោង ដែលបានឯកភាពនោះ។ នៅផ្នែកខាងក្រោម នៃជំពូកនេះ យើងលើកឡើងយកមកបង្ហាញនូវលទ្ធផលសង្ខេបនៃការវិភាគសេដ្ឋកិច្ចនោះ។

យើងក៏បានសិក្សាបន្ថែមអំពីតម្លៃសេដ្ឋកិច្ច ដែលត្រូវបាត់បង់ដោយសារផលប៉ះពាល់បរិស្ថាន-សង្គមអវិជ្ជមាននៃសកម្មភាពគម្រោង។ លទ្ធផលនៅក្នុងជំពូកទី៧ បង្ហាញថា ផលប៉ះពាល់អវិជ្ជមានសំខាន់បំផុតនៃគម្រោងវិនិយោគនេះ គឺការបាត់បង់ធនធានព្រៃឈើ និងផលប្រយោជន៍ទាំងផ្ទាល់និងប្រយោល ដែលមនុស្សទទួលបានពីសេវាកម្មប្រព័ន្ធអេកូឡូស៊ីព្រៃឈើ។ នៅក្នុងជំពូកនេះ យើងលើកយកមកបង្ហាញអំពីលទ្ធផលនៃការវាយតម្លៃជាសាច់ប្រាក់ នៃផលប្រយោជន៍ព្រៃឈើដែលបាត់បង់ដោយសារការប្រែក្លាយផ្ទៃដីព្រៃឈើទៅជាផ្ទៃដីកសិកម្ម (ដំណាំកសិ-ឧស្សាហកម្ម) ក្នុងកិច្ចដំណើរការគម្រោងវិនិយោគនេះ។ ការវាយតម្លៃនេះ ផ្តល់នូវលទ្ធផលជាមូលដ្ឋានសម្រាប់ការប៉ាន់ស្មានទំហំនៃមូលនិធិបរិស្ថាន-សង្គម ដែលក្រុមហ៊ុនម្ចាស់គម្រោងត្រូវចំណាយដើម្បីស្តារបរិស្ថានឡើងវិញ និង/ឬប៉ះប៉ូវទៅលើផលប៉ះពាល់អវិជ្ជមានទាំងនោះ។

Draft

## ៩.២. ការវិភាគសេដ្ឋកិច្ច៖ ផលចំណេញ-ខាតនៃគម្រោង

តារាង៩.១ បង្ហាញពីលទ្ធផលសង្ខេបនៃរបាយការណ៍ចំណេញ-ខាត ក្នុងរយៈពេល ២០ឆ្នាំដំបូងនៃការវិនិយោគរបស់ក្រុមហ៊ុន។ របាយការណ៍ខាត (–) កើតមានឡើងចាប់ពីឆ្នាំទី១ រហូតដល់ឆ្នាំទី៥។ ក្រុមហ៊ុននឹងខាតបង់ទឹកប្រាក់ចំនួន ៣.៦០៧.៣៤៩ ដុល្លារអាមេរិក នៅឆ្នាំទី១ និងឆ្នាំទី២, ចំនួន ២.៩៩៤.៣៨៤ ដុល្លារអាមេរិក នៅឆ្នាំទី៣, និងចំនួន ២.១៧៤.៩៧៣ ដុល្លារអាមេរិក នៅឆ្នាំទី៤ និងឆ្នាំទី៥។ នៅឆ្នាំទី៦ ក្រុមហ៊ុននឹងទទួលប្រាក់ចំណេញតិចតួច ចំនួន ១៤៨.២២៣ ដុល្លារអាមេរិក។ ប្រាក់ចំណេញនឹងកើនឡើងខ្ពស់រហូតដល់ចំនួន ២.៣៣៤.៨៧០ ដុល្លារអាមេរិក នៅឆ្នាំទី៦ ហើយប្រាក់ចំណេញនេះនឹងបន្តកើនឡើងរហូតដល់ជាង ១០លានដុល្លារអាមេរិកក្នុងមួយឆ្នាំចាប់ពីឆ្នាំទី១១ តទៅ។

តារាង៩.១៖ សង្ខេបរបាយការណ៍ចំណេញ-ខាត (ដុល្លារអាមេរិក)

| **របាយការណ៍ចំណេញ-ខាត** | **ទឹកប្រាក់** | **របាយការណ៍ចំណេញ-ខាត** | **ទឹកប្រាក់** |
|---|---|---|---|
| របាយការណ៍ខាតឆ្នាំទី _១ & ២ | -3,607,349 | របាយការណ៍ចំណេញឆ្នាំទី _១២ | 12,282,881 |
| របាយការណ៍ខាតឆ្នាំទី _៣ | -2,994,384 | របាយការណ៍ចំណេញឆ្នាំទី _១៣ | 14,867,530 |
| របាយការណ៍ខាតឆ្នាំទី _៤ & ៥ | -2,174,973 | របាយការណ៍ចំណេញឆ្នាំទី _១៤ | 16,004,998 |
| របាយការណ៍ចំណេញឆ្នាំទី _៦ | 148,223 | របាយការណ៍ចំណេញឆ្នាំទី _១៥ | 16,841,986 |
| របាយការណ៍ចំណេញឆ្នាំទី _៧ | 2,334,870 | របាយការណ៍ចំណេញឆ្នាំទី _១៦ | 15,932,830 |
| របាយការណ៍ចំណេញឆ្នាំទី _៨ | 3,861,921 | របាយការណ៍ចំណេញឆ្នាំទី _១៧ | 15,101,026 |
| របាយការណ៍ចំណេញឆ្នាំទី _៩ | 5,774,829 | របាយការណ៍ចំណេញឆ្នាំទី _១៨ | 14,337,865 |
| របាយការណ៍ចំណេញឆ្នាំទី _១០ | 7,455,447 | របាយការណ៍ចំណេញឆ្នាំទី _១៩ | 13,548,114 |
| របាយការណ៍ចំណេញឆ្នាំទី _១១ | 10,231,276 | របាយការណ៍ចំណេញឆ្នាំទី _២០ | 13,060,564 |

ប្រភព៖ ផែនការមេនៃគម្រោងវិនិយោគ របស់ក្រុមហ៊ុន SK Plantation (Cambodia) Pte Ltd
(ឯកភាពដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៦)

ផ្អែកតាមការវិភាគសេដ្ឋកិច្ចនៅក្នុងផែនការមេដូចបង្ហាញក្នុងតារាងខាងលើ លំហូរសាច់ប្រាក់ (ចំណេញ-ខាត) របស់ក្រុមហ៊ុន (ដោយកំណត់យកអត្រាអបហារ ឬ Discounted Rate ១២%) អាចបង្កើតជាតម្លៃបច្ចុប្បន្នសុទ្ធ (Net Present Value ឬ NPV) សរុបប្រមាណ ៧.៥៥៨.៩៤៧ ដុល្លារអាមេរិក (ឬជាមធ្យមប្រមាណ ៣៧៧.៩៤៧ ដុល្លារអាមេរិក/ឆ្នាំ) ក្នុងរយៈពេលឆ្នាំ២០ដំបូង។ ប្រាក់ចំណេញសុទ្ធប្រចាំឆ្នាំជាមធ្យមច្បាស់ជានឹងកើនឡើងគួរឱ្យកត់សម្គាល់ក្នុងរយៈពេលវិនិយោគដែលនៅសេសសល់ (ពីឆ្នាំទី២១ ដល់ ៥០) ពីព្រោះថ្លៃចំណាយ (ដូចជា សម្រាប់ហេដ្ឋរចនាសម្ព័ន្ធ គ្រឿងចក្រ ទព្វសំភារៈការិយាល័យ) នឹងថយចុះយ៉ាងខ្លាំង។

## ៩.៣. ការវាយតម្លៃសេដ្ឋកិច្ចនៃសេវាកម្មប្រព័ន្ធអេកូឡូស៊ីព្រៃឈើ

ព្រៃឈើផ្តល់ផលប្រយោជន៍ជាច្រើនដល់មនុស្ស តាមរយៈសេវានៃមុខងារប្រព័ន្ធអេកូឡូស៊ីព្រៃឈើ ឬ Ecosystem Services (Millennium Ecosystem Assessment 2003, Saarikoski et al. 2015)។ ការប្រែក្លាយផ្ទៃដីព្រៃឈើទៅជាផ្ទៃដីកសិកម្ម បានរួមចំណែកធ្វើឱ្យមានបម្រែបម្រួលអវិជ្ជមានលើសេវាកម្មប្រព័ន្ធអេកូឡូស៊ីចម្បងៗចំនួន ០៥គឺ៖

- ការបាត់បង់ឱកាសទទួលបានផលឈើ និងអនុផលព្រៃឈើ ទៅតាមកំណើនប្រចាំឆ្នាំ (ការដកហូតផល-អនុផលព្រៃឈើដោយនិរន្តរភាព)
- ការថយចុះនូវសេវាកម្មអភិរក្សទឹក៖ ព្រៃឈើមានតួនាទីធ្វើនិយ័តកម្មលំហូរទឹក (Hydrological flow regulation) និងស្ទាក់-ស្តុកទឹក (Water retention and storage) ដែលធ្វើឱ្យជារទឹកក្នុងប្រព័ន្ធស្ទឹង-អូរធម្មជាតិមានលំនឹង
- ការថយចុះនូវសេវាកម្មអភិរក្សដី៖ ព្រៃឈើមានតួនាទីទប់ស្កាត់ការហូរច្រោះដី ដែលអាចនាំឱ្យដីខ្សោះជីជាតិ និងលែងប្រើប្រាស់បានសម្រាប់ការដាំដុះ
- ការបាត់បង់នូវសេវាកម្មស្តុក និងស្រូបកាបូន។

Draft

តម្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ីព្រៃឈើសរុប ជាទូទៅជាផលបូកនៃតម្លៃសេវាកម្មទាំងអស់ ប៉ុន្តែការគណនាបែបនេះ នាំឱ្យមានការរាប់ឌុប (Double Counting) រវាងតម្លៃផល-អនុផលព្រៃឈើ និងតម្លៃកំណើនកាបូនប្រចាំឆ្នាំ។ បើយើងដកហូតផល-អនុផលព្រៃឈើទៅតាមកំណើនជីវម៉ាស (ការដកហូតដោយនិរន្តរភាព) នោះស្តុកកាបូននឹងមិនប្រែប្រួល (មិនមានកំណើនកាបូន) ទេ។ ផ្ទុយទៅវិញ បើយើងអភិរក្សព្រៃឈើដោយមិនដកហូតផល-អនុផលព្រៃឈើ នោះស្តុកកាបូននឹងកើនឡើង ហើយយើងក៏អាចទទួលបាននូវផលប្រយោជន៍បន្ថែមពីការលក់កាបូនដែលកើនឡើងប្រចាំឆ្នាំដោយសារការអភិរក្ស ជាពិសេសតាមរយៈកម្មវិធី Reduced emissions from deforestation and forest degradation ឬ REDD+។ ទីតាំងគម្រោង មិនមែនជាតំបន់ការពារធម្មជាតិដែលមានសារៈសំខាន់ការអភិរក្សនោះទេ ដូច្នេះលទ្ធភាពទទួលបានឥណទានកាបូនពីការអភិរក្សធនធានព្រៃឈើនៅក្នុងទីតាំងគម្រោង គឺមានតិចតួចបំផុត។ ដោយហេតុផលនេះ គួបផ្សំនឹងភាពចាំបាច់នៃផល-អនុផលព្រៃឈើចំពោះសហគមន៍មូលដ្ឋានក្នុងតំបន់សិក្សា (សូមអានជំពូកទី៥ ផ្នែកសេដ្ឋកិច្ចសង្គម) ក្នុងការសិក្សានេះ យើងសម្រេចជ្រើសយកតម្លៃផល-អនុផលព្រៃឈើ (ក្នុងចំណោមជម្រើសទាំងពីរដែលបានពិភាក្សា) មកធ្វើការវិភាគ។

ដោយឡែកក្នុងបរិបទនៃគម្រោងវិនិយោគនេះ ផ្ទៃដីព្រៃឈើក្នុងទីតាំងគម្រោងនឹងត្រូវបំលែងទៅជាដីកសិកម្ម ដែលធ្វើឲ្យកាបូនស្តុកក្នុងព្រៃឈើដែលមាននៅក្នុងទីតាំងនេះ នឹងត្រូវបញ្ចេញទៅក្នុងបរិយាកាស។ ដូច្នេះ ក្នុងការសិក្សានេះ ក្រុមការងារក៏បូកបញ្ចូលនូវតម្លៃស្តុកកាបូនផងដែរ។

កំណើននៃការហូរច្រោះដីដោយសារការបំលែងដីព្រៃទៅជាដីកសិកម្ម បង្កឱ្យមានផលប៉ះពាល់ពីរយ៉ាងគឺៈ ការថយចុះគុណភាពដី និងការកើនឡើងនូវភក់និងកករដីក្នុងប្រព័ន្ធផ្លូវទឹកធម្មជាតិ ដែលជាហេតុធ្វើឱ្យមានបម្រែបម្រួលទាំងប្រព័ន្ធជលសាស្ត្រ និងគុណភាពទឹក (Guo et al. 2001)។ ជាទូទៅ ម្ចាស់កសិដ្ឋាន (ម្ចាស់គម្រោងអភិវឌ្ឍន៍ ក្នុងករណីកំពុងសិក្សា) ជាអ្នករ៉ាប់រងផ្ទាល់លើការកែលំអរគុណភាពដី ដើម្បីបង្កើនទិន្នផលកសិកម្ម ហើយការចំណាយទាំងអស់នេះត្រូវបានរាប់បញ្ចូលក្នុងតម្លៃប្រតិបត្តិការការសិដ្ឋាន (គម្រោង) រួចហើយ។ ដូច្នេះ ការរាប់បញ្ចូលតម្លៃនៃការធ្លាក់ចុះគុណភាពដីដោយសារការហូរច្រោះ ក្នុងការគណនាតម្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ីព្រៃឈើសរុប ក៏ប្រឈមនឹងបញ្ហារាប់ឌុបដែរ។ ដោយឡែក តម្លៃខូចខាតដែលបង្កឡើងដោយសារកំណើនកករដី/ភក់ក្នុងប្រព័ន្ធផ្លូវទឹក អាចត្រូវបានយកទៅរាប់បញ្ចូលជាមួយតម្លៃនៃការខូចខាតដោយសារបម្រែបម្រួលអវិជ្ជមានលើសេវាកម្មអភិរក្សទឹក។

ជាសរុប ក្នុងការសិក្សាវាយតម្លៃនេះ យើងមិនបានរាប់បញ្ចូលតម្លៃនៃការធ្លាក់ចុះគុណភាពដីដោយសារការហូរច្រោះ និងតម្លៃកំណើនកាបូនប្រចាំឆ្នាំទេ ដើម្បីចៀសវាងការរាប់ឌុប ដែលជាបញ្ហាមួយនៃការជជែកវែកញែករវាងអ្នកវិទ្យាសាស្ត្រសិក្សាវាយតម្លៃសេដ្ឋកិច្ចនៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី (Wallace 2007)។ ពោលគឺយើងបានធ្វើការប៉ាន់ស្មានពីការបាត់បង់ ឬធ្លាក់ចុះនៃតម្លៃផល-អនុផលព្រៃឈើ តម្លៃស្តុកកាបូន និងសេវាកម្មអភិរក្សទឹក (ដោយរាប់បញ្ចូលទាំងសេវាកម្មធ្វើនិយ័តកម្មលំហូរទឹក ស្ទាក់និងស្តុកទឹក កាត់បន្ថយកំណើនកករដី/ភក់) តែប៉ុណ្ណោះ។ វិធីសាស្ត្រផ្ទេរតម្លៃ (Benefit Transfer ឬ Value Transfer) ដែលត្រូវបានបំផុសឱ្យយកមកប្រើប្រាស់ដោយកម្មវិធីបរិស្ថានពិភពលោក ឬ UNEP (Brander 2013) ត្រូវបានយកមកប្រើប្រាស់ក្នុងការប៉ាន់ស្មានតម្លៃនេះ។ ការផ្ទេរតម្លៃ (Value Transfer) ជារួមត្រូវបានគេធ្វើឡើងជា ០៤ជំហាន៖ (១) ពិពណ៌នាអំពីគម្រោង (គោលនយោបាយ) ដែលកំពុងសិក្សា (២) ជ្រើសរើសព័ត៌មានពីការសិក្សាផ្សេងទៀតដែលស្រដៀងគ្នា (៣) ផ្ទេរតម្លៃពីការសិក្សានោះមកគណនាតម្លៃពាក់ព័ន្ធនឹងគម្រោងដែលកំពុងសិក្សា (៤) រាយការណ៍ពីលទ្ធផល។ ជំពូកនានាខាងដើម រៀបរាប់អំពីគម្រោងដែលកំពុងសិក្សា។ នៅខាងក្រោមនេះ ជាលទ្ធផលនៃការសិក្សាកន្លងមកដែលស្រដៀងគ្នា និងលទ្ធផលនៃការប៉ាន់ស្មានពីការធ្លាក់ចុះនៃតម្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ីដោយសារគម្រោងកំពុងសិក្សា។

Draft

ការប្រែក្លាយដីព្រៃឈើទៅជាដីកសិកម្មក្នុងដំណើរការគម្រោងនេះ នឹងធ្វើឱ្យធ្លាក់ចុះសេវាកម្មប្រព័ន្ធអេកូឡូស៊ីដូចបានពិភាក្សាខាងលើ ប៉ុន្តែទន្ទឹមនឹងនេះ ធនធានឈើឈរ (លទ្ធផលនៃការប៉ាន់ស្មានតាមរយៈការធ្វើសារពើភ័ណ្ឌព្រៃឈើ មានបង្ហាញនៅក្នុងជំពូកទី៥ ផ្នែកជីវសាស្ត្រ) នឹងត្រូវដកហូតទាំងស្រុង។ ផលចំណេញដែលទទួលបានពីការធ្វើអាជីវកម្មឈើឈរនោះ នឹងផ្តល់ជាប្រាក់ចំណូលចូលរដ្ឋតាមរយៈការបង់សួយសារ ដូច្នេះវាជាផលចំណេញសម្រាប់សេដ្ឋកិច្ចជាតិ។ តម្លៃនៃផលចំណេញនេះក៏នឹងលើកយកមកបង្ហាញនៅក្នុងជំពូកនេះផងដែរ។

### ៩.៣.១. តម្លៃនៃកំណើនផល និងអនុផលព្រៃឈើដែលបាត់បង់

ដើម្បីធ្វើការប៉ាន់ស្មានពីតម្លៃនៃកំណើនផល និងអនុផលព្រៃឈើដែលបាត់បង់ យើងពឹងផ្អែកលើវិធីសាស្ត្រផ្ទេរតម្លៃ។ ផ្អែកតាមការស្រាវជ្រាវ យើងបានរកឃើញតែការសិក្សាមួយគត់ (Hansen and Top 2006) ដែលបានធ្វើការគណនាតម្លៃនៃផលឈើនៅក្នុងប្រទេសកម្ពុជា តាមរយៈលទ្ធផលនៃការធ្វើសារពើភ័ណ្ឌព្រៃឈើដោយផ្ទាល់ និងបានគិតគូរពីការចំណាយលើការប្រមូលផលឈើ។ លទ្ធផលនៃការសិក្សានោះ (តារាង9.2) ជាផលចំណេញសេដ្ឋកិច្ចសុទ្ធ ដែលទទួលបានពីការគ្រប់គ្រងព្រៃឈើ និងដកហូតផលឈើប្រកបដោយនិរន្តរ-ភាព។ របាយការណ៍របស់ Cambodia REDD+ Taskforce Secretariat (2014) បង្ហាញថា មានការសិក្សាអំពីតម្លៃនៃផលឈើចំនួន ០៦ ផ្សេងទៀត នៅក្នុងប្រទេសកម្ពុជា។ ប៉ុន្តែតាមការពិនិត្យ ការសិក្សាទាំងនោះ មិនផ្អែកលើលទ្ធផលនៃការធ្វើសារពើភ័ណ្ឌព្រៃឈើដោយផ្ទាល់ និងបានគិតគូរពីការចំណាយលើការប្រមូលផលឈើឱ្យបានគ្រប់ជ្រុងជ្រោយ ដូចជាការសិក្សារបស់ Hansen & Top (2006) នោះទេ។ ការសិក្សាមួយផ្សេងទៀត របស់ Yem, Top & Lic (2011) ក៏បានធ្វើការប៉ាន់ស្មានតម្លៃនៃផល-អនុផលព្រៃឈើ ដែលបាត់បង់ដោយសារការប្រែក្លាយដីព្រៃជាដីដាំដំណាំកៅស៊ូដែរ ប៉ុន្តែការសិក្សានេះបានប្រើប្រាស់លទ្ធផលរបស់ Hansen and Top (2006) ។

តារាង៩.២៖ តម្លៃនៃផល-អនុឈើដែលសិក្សាដោយ Hansen & Top (2006)

| ប្រភេទព្រៃ | តម្លៃ (ដុល្លារឆ្នាំ2006/ហ.ត/ឆ្នាំ) | |
|---|---|---|
| | ផលឈើ | អនុផលព្រៃឈើ |
| ព្រៃស្រោង | 33.82 | 2.38 |
| ព្រៃពាក់កណ្តាលស្រោង | 10.32 | 4.56 |
| ព្រៃល្បោះ | -4.96 | 7.3 |
| **សម្គាល់៖** តម្លៃទាំងនេះ ត្រូវបានប៉ាន់ស្មានក្នុងករណីគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព និងប្រើប្រាស់អត្រាអបហារ (Discounted Rate) 10% | | |

ដើម្បីប៉ាន់ស្មានតម្លៃនៃផល និងអនុផលព្រៃឈើដែលបានបាត់បង់ដោយសារគម្រោងកំពុងសិក្សា យើងពឹងផ្អែកលើលទ្ធផលនៃការសិក្សារបស់ (Hansen and Top 2006)។ ដោយអនុវត្តតាមគោលការណ៍ណែនាំរបស់ UNEP (Brander 2013) យើងធ្វើការកែតម្រូវតម្លៃនៃផល និងអនុផលព្រៃឈើទាំងនេះ ទៅតាមឆ្នាំសិក្សា (២០០៦ – ២០១៥)[a] ដោយប្រើរូបមន្ត Eq.1 ។ ការកែតម្រូវទៅតាមឆ្នាំសិក្សានេះ ត្រូវបានធ្វើឡើង ដោយហេតុថា អតិផរណាធ្វើឱ្យកម្រិតនៃតម្លៃជាទូទៅនៅក្នុងប្រទេសមួយមានការកើនឡើងទៅតាមពេលវេលា ដូច្នេះថវិកាក្នុងចំនួនណាមួយមានតម្លៃថោកជាងក្នុងពេលអនាគតនៅពេលប្រើប្រាស់សម្រាប់ទិញជំនិញអ្វីមួយ។

[a] ការសិក្សាធ្វើឡើងក្នុងឆ្នាំ២០១៦-១៧ ប៉ុន្តែទិន្នន័យដែលត្រូវការសម្រាប់ការកែតម្រូវ (GDP, GDP Inflator) មានត្រឹមឆ្នាំ២០១៥

Draft

$$WTP'_p = WTP_s(\frac{D_p}{D_s}) \quad \text{(Eq.1)}$$

ដោយ៖

$WTP'_p$ = តម្លៃនៃការស្ម័គ្រចិត្តចំណាយដើម្បីបញ្ចៀសការបាត់បង់សេវាណាមួយនៅឆ្នាំកំពុងសិក្សា

$WTP_s$ = តម្លៃនៃការស្ម័គ្រចិត្តចំណាយដើម្បីបញ្ចៀសការបាត់បង់ណាមួយនៅឆ្នាំសិក្សាកន្លងមក

$D_p$ = GDP deflator index នៅតំបន់សិក្សាក្នុងឆ្នាំកំពុងសិក្សា

$D_s$ = GDP deflator index នៅតំបន់សិក្សាក្នុងឆ្នាំសិក្សាកន្លងមក

តារាង៩.៣ បង្ហាញពីលទ្ធផលនៃការកែតម្រូវនេះ និងតម្លៃដែលបានខាតបង់ដោយសារបាត់បង់ផ្ទៃដីព្រៃឈើក្នុងកិច្ចដំណើរការគម្រោងវិនិយោគនេះ។ យើងមិនបានធ្វើការប៉ាន់ស្មានតម្លៃផលឈើដែលបាត់បង់ដោយសារការបាត់បង់ព្រៃល្បោះទេ ដោយសន្មត់ថា ព្រៃល្បោះមិនត្រូវបានគេអាជីវកម្មឈើនោះទេ ព្រោះមិនចំណេញបើផ្អែកតាមលទ្ធផលរបស់ (Hansen and Top 2006)។ ជារួម គម្រោងបានធ្វើឱ្យបាត់បង់ផល និងអនុផលព្រៃឈើក្នុងតម្លៃសរុបប្រមាណ ៨៨.៩៨៦ដុល្លារ/ឆ្នាំ ដែលក្នុងនោះ តម្លៃនៃផលឈើមានចំនួន ៣១.៥៥៨ដុល្លារ/ឆ្នាំ និងតម្លៃនៃអនុផលព្រៃឈើមានចំនួន ៥៧.៤២៨ដុល្លារ/ឆ្នាំ។ តម្លៃទាំងនេះគឺជាតម្លៃខាតបង់ប្រចាំឆ្នាំដោយសារបាត់បង់ឱកាសក្នុងការដកហូតផល-អនុផលក្រោមការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព (Opportunity Cost)។

តារាង៩.៣៖ តម្លៃនៃផលឈើដែលនឹងបាត់បង់ដោយសារគម្រោង

| ប្រភេទព្រៃ | តម្លៃ (ដុល្លារឆ្នាំ2015/ហ.ត/ឆ្នាំ) | | តម្លៃដែលបាត់បង់សរុប (ដុល្លារឆ្នាំ2015/ឆ្នាំ) | | |
|---|---|---|---|---|---|
| | ផល | អនុផល | ផល | អនុផល | សរុប |
| ព្រៃស្រោង | 47.17 | 3.32 | 25,899 | 1,823 | 27,722 |
| ព្រៃពាក់កណ្ដាលស្រោង | 14.39 | 6.36 | 5,658 | 2,500 | 8,159 |
| ព្រៃល្បោះ | -6.92 | 10.18 | | 53,105 | 53,105 |
| សរុប | | | 31,558 | 57,428 | 88,986 |

**សម្គាល់៖**

Cambodia GDP deflator index 2015 = 170.7

Cambodia GDP deflator index 2006 = 122.4[b]

ព្រៃឈើបាត់បង់៖ ស្រោង (549.11 ហ.ត), ពាក់កណ្ដាលស្រោង (393.16 ហ.ត) និងល្បោះ (5,216.32 ហ.ត)

Draft

### ៩.៣.២. តម្លៃស្តុកកាបូន

លទ្ធផលនៃការប៉ាន់ស្មានជីវម៉ាស់ឈើ និងកាបូន នៅក្នុងជំពូកទី៥ (ផ្នែកធនធានជីវសាស្ត្រ) បង្ហាញថា ព្រៃឈើដែលមាននៅក្នុងទីតាំងគម្រោង មានកាបូនស្តុកសរុបប្រមាណ ៣៥៥.៨៤៦,៩៤ តោន។ បរិមាណកាបូនស្តុកនេះ គឺបានមកពីការប៉ាន់ស្មានចេញពីព្រៃស្រោង ព្រៃពាក់កណ្ដាលស្រោង និងព្រៃល្បោះ ដែលមានក្នុងទីតាំងគម្រោងក្នុងពេលចុះធ្វើសារពើភ័ណ្ឌព្រៃឈើ កាលពីខែមីនា ឆ្នាំ២០១៦។ ព្រៃផ្សេងទៀត (ដូចជា ព្រៃគម្លោតស្ងួត និងព្រៃគម្លោតស្ងួតបៃតង) ដែលមាននៅក្នុងទីតាំងគម្រោង មិនត្រូវបានធ្វើសារពើភ័ណ្ឌនោះទេ ដូច្នេះបរិមាណកាបូនស្តុក ក៏មិនត្រូវបានធ្វើកាប៉ាន់ស្មានដែរ។

---

[b] ទិន្នន័យ (GDP deflator) មានប្រភពមកពីគេហទំព័ររបស់ធនាគារពិភពលោក៖ http://data.worldbank.org/indicator/NY.GDP.DEFL.ZS?locations=KH

តារាង៩.៤៖ បរិមាណស្តុកកាបូនក្នុងព្រៃឈើក្នុងទីតាំងគម្រោង

| ប្រភេទព្រៃ | ផ្ទៃដី (ហ.ត) | កាបូនស្តុក (តោន/ហ.ត) | | | កាបូនស្តុកសរុប (តោន) |
|---|---|---|---|---|---|
| | | លើដី (AGB) | ក្រោមដី(BGB) | សរុប (AGB+BGB) | |
| ព្រៃស្រោង | 549.11 | 3.93 | 0.86 | 4.79 | 2,630.24 |
| ព្រៃពាក់កណ្តាលស្រោង | 393.16 | 13.85 | 3.05 | 16.90 | 6,644.40 |
| ព្រៃល្បោះ | 5,216.32 | 54.46 | 11.98 | 66.44 | 346,572.30 |
| **សរុប** | | | | **88.13** | **355,846.94** |

តាមការសិក្សាស្រាវជ្រាវរបស់ Nophea (2003) បង្ហាញថា ការគណនាលើតម្លៃសេដ្ឋកិច្ចនៃកាបូន ត្រូវធ្វើឡើងដោយគិតគូរលើសុវត្ថិភាពគម្របព្រៃឈើនៅក្នុងទីតាំងអនុវត្តគម្រោង មានន័យថាក្នុងរយៈពេលជាក់លាក់មួយនៃការអនុវត្តគម្រោងឥណទានកាបូន គឺត្រូវធានាបាននូវទីតាំងព្រៃមួយដែលបង្កើនលទ្ធភាពស្រូបឧស្ម័នកាបូនិចពីបរិយាកាសមានការកើនឡើងជាលំដាប់។ ក្នុងន័យនេះ យើងអាចធ្វើការសន្មត់បានថា ធនធានព្រៃឈើ ក៏ដូចជាគម្របព្រៃឈើដែលមាននៅក្នុងទីតាំងគម្រោង នឹងត្រូវបានបាត់បង់ស្ទើរតែទាំងស្រុងដោយសារសកម្មភាពរបស់គម្រោង។ ដូច្នេះនៅពេលដែលគម្រោងដំណើរ បរិមាណកាបូនស្តុកដែលមាននៅក្នុងទីតាំងគម្រោង នឹងត្រូវបានបំភាយទៅបរិយាកាសវិញស្ទើរតែទាំងស្រុង ទៅតាមលក្ខខ័ណ្ឌ និងដំណាក់កាលនៃការឈូសឆាយព្រៃឈើ។

យោងទៅតាមតម្លៃកាបូននៅលើទីផ្សារស្ម័គ្រចិត្តបានបង្ហាញឲ្យដឹងថា កាបូន១តោន គឺមានតម្លៃជាទឹកប្រាក់ប្រមាណ ៥ ដុល្លារ/តោន។ ដូច្នេះប្រសិនបើគម្រោងនេះធ្វើការឈួសឆាយដីព្រៃ ក៏ដូចជាធនធានព្រៃឈើ ឬគម្របព្រៃឈើ នោះនឹងត្រូវបំភាយកាបូនប្រមាណ ៣៥៥.៨៤៦,៩៤ តោន ដែលមានតម្លៃជាទឹកប្រាស់សរុបប្រមាណ ១.៧៧៩.២៣៥ ដុល្លារ។ ប្រសិនបើយើងបែងចែកតម្លៃនៃកាបូនស្តុកស្មើៗគ្នាទៅតាមឆ្នាំនីមួយៗនៃរយៈវិនិយោគ ៥០ឆ្នាំ នោះគម្រោងអភិវឌ្ឍន៍នេះអាចនឹងធ្វើឲ្យបំភាយកាបូនទៅបរិយាកាសវិញ ដែលមានតម្លៃជាមធ្យមប្រមាណ **៣៥.៥៨៥ ដុល្លារ/ឆ្នាំ**។

### ៩.៣.៣. ការធ្លាក់ចុះនៃតម្លៃសេវាកម្មអភិរក្សទឹក

ក្រុមការងារបានស្រាវជ្រាវឃើញឯកសារចំនួន ០២ ពាក់ព័ន្ធនឹងតម្លៃនៃសេវាកម្មអភិរក្សទឹកផ្តល់ដោយព្រៃឈើ ដែលស្រដៀងគ្នានឹងការសិក្សានេះគឺ៖ ការសិក្សារបស់ (Hansen and Top 2006) និងការសិក្សារបស់ (Guo et al. 2001)។ ការសិក្សារបស់ (Hansen and Top 2006) ធ្វើឡើងក្នុងបរិបទនៃការប្រែក្លាយដីព្រៃទៅជាដីកសិកម្ម នៅក្នុងខេត្តរតនគិរី មណ្ឌលគិរី ក្រចេះ កំពង់ធំ និងពោធិសាត់ នៃប្រទេសកម្ពុជា ចំណែកឯការសិក្សារបស់ (Guo et al. 2001) ធ្វើឡើងក្នុងបរិបទនៃតម្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ីផ្តល់ដោយព្រៃឈើក្នុងកម្រិតតំបន់ (Xingshan County) នៃប្រទេសចិន។ ជាក់ស្តែង ការសិក្សារបស់ (Hansen and Top 2006) មានភាពស្រដៀងបំផុតទៅនឹងការសិក្សាក្នុងពេលបច្ចុប្បន្ន ប៉ុន្តែតម្លៃនៃសេវាកម្មអភិរក្សទឹកក្នុងការសិក្សានេះ ត្រូវបានប៉ាន់ស្មានតាមរយៈវិធី-សាស្ត្រ Value Transfer ដោយប្រើប្រាស់លទ្ធផលរបស់ (Guo et al. 2001)។ ដោយមូលហេតុនេះគួបផ្សំនឹងកម្រិតគុណភាពដែលអាចជឿជាក់បាននៃឯកសាររបស់ (Guo et al. 2001) ដែលត្រូវបានបោះពុម្ពផ្សាយដោយ និពន្ធវិទ្យាសាស្ត្រអន្តរជាតិមួយ (*Ecological Economics Journal*) នោះយើងបានសម្រេចជ្រើសរើសយកលទ្ធផលនៃការសិក្សារបស់ (Guo et al. 2001) មកធ្វើជាមូលដ្ឋានក្នុងការប៉ាន់ស្មានតម្លៃសេដ្ឋកិច្ចដែលត្រូវបាត់បង់ដោយសារការធ្លាក់ចុះនៃសេវាកម្មអភិរក្សទឹក ជាមួយនឹងព្រៃឈើដែលនឹងបាត់បង់ដោយសារគម្រោងនេះ។

Draft

តារាង៩.៥ (កូឡោនទី២) សង្ខេបពីលទ្ធផលនៃការសិក្សារបស់ (Guo et al. 2001) អំពីតម្លៃនៃសេវាកម្មប្រព័ន្ធអេកូឡូស៊ីព្រៃឈើពាក់ព័ន្ធនឹងការអភិរក្សទឹកដូចបកស្រាយខាងលើ។ ដោយអនុវត្តតាមគោលការណ៍ណែនាំរបស់ UNEP (Brander 2013) យើងធ្វើការកែតម្រូវតម្លៃនៃសេវាកម្មពាក់ព័ន្ធនឹងការអភិរក្សទឹកនេះ ទៅតាមឆ្នាំសិក្សា ពីឆ្នាំ១៩៩៧ (ឆ្នាំសិក្សាចាស់) មកឆ្នាំ២០១៥ (ឆ្នាំសិក្សាបច្ចុប្បន្ន)[c] ដោយប្រើរូបមន្ត Eq.1 ខាងលើ។ បន្ទាប់មកដោយអនុវត្តតាមគោលការណ៍ណែនាំរបស់ UNEP ដដែល យើងក៏បានធ្វើការកែតម្រូវតម្លៃពាក់ព័ន្ធនឹងសេវាកម្មអភិរក្សទឹកទាំងនេះ ទៅតាមភាពខុសគ្នារវាងប្រាក់ចំណូលប្រជាជនក្នុងតំបន់សិក្សាកន្លងមក (ប្រទេសចិន) និងប្រជាជនក្នុងតំបន់កំពុងសិក្សា (ប្រទេសកម្ពុជា) ដើម្បីប៉ាន់ស្មានតម្លៃនៃសេវាកម្មទាំងនេះដែលបានបាត់បង់ជាមួយព្រៃឈើ។ ការកែតម្រូវទៅតាមភាពខុសគ្នានៃប្រាក់ចំណូល ត្រូវបានធ្វើឡើង ដោយហេតុថា តម្រូវការទំនិញនិងសេវាកម្មស្ទើរតែទាំងអស់ (រួមទាំងសេវាកម្មប្រព័ន្ធអេកូឡូស៊ី) មានការប្រែប្រួលទៅតាមប្រាក់ចំណូល។ ជាទូទៅ កាលណាប្រាក់ចំណូលកើនឡើង តម្រូវការក៏មានការកើនឡើងដែរ ហើយចំនួនទឹកប្រាក់ដែលស្ម័គ្រចិត្តចំណាយ (Willingness to pay – WTP) ដើម្បីទទួលបាន ឬចៀសវាងការបាត់បង់សេវាកម្មនោះ ក៏មានការកើនឡើងដែរ។

$$WTP'_p = WTP_p\left(\frac{Y_p}{Y_s}\right)^E \quad \text{(Eq.2)}$$

ដោយ៖

$WTP'_p$ = តម្លៃនៃការស្ម័គ្រចិត្តចំណាយដើម្បីបញ្ចៀសការបាត់បង់សេវាណាមួយនៅតំបន់គម្រោងក្នុងឆ្នាំកំពុងសិក្សា

$WTP_p$= តម្លៃនៃការស្ម័គ្រចិត្តចំណាយដើម្បីបញ្ចៀសការបាត់បង់សេវាណាមួយនៅតំបន់សិក្សាកន្លងមក (តំបន់ផ្សេងដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា) ក្នុងឆ្នាំកំពុងសិក្សា

$Y_p$ = GDP per capita នៅតំបន់គម្រោងក្នុងឆ្នាំដែលតម្លៃនៃការស្ម័គ្រចិត្តចំណាយត្រូវសិក្សា

$Y_s$ = GDP per capita នៅតំបន់សិក្សាកន្លងមកក្នុងឆ្នាំដែលតម្លៃនៃការស្ម័គ្រចិត្តចំណាយត្រូវបានសិក្សា

$E$= Income elasticity នៃការស្ម័គ្រចិត្តចំណាយដើម្បីបញ្ចៀសការបាត់បង់សេវា

Draft

លទ្ធផលនៃការកែតម្រូវទាំងពីរលើកខាងលើ មានបង្ហាញនៅក្នុងកូឡោនទី៣ នៃតារាង៩.៥។ តម្លៃសេវាកម្មទាំងនេះ គឺជាតម្លៃដែលត្រូវបាត់បង់ដោយសារការបាត់បង់ព្រៃធម្មជាតិទូទៅ។

តារាង៩.៥៖ តម្លៃសេវាកម្មអភិរក្សទឹកផ្តល់ដោយព្រៃឈើ

| សេវាកម្មអភិរក្សទឹក | តម្លៃសេវាកម្ម (ដុល្លារអាមេរិក/ឆ្នាំ/ហិកតា) | |
|---|---|---|
| | គិតជាដុល្លារ (ឆ្នាំ១៩៩៧)[a] | គិតជាដុល្លារ (ឆ្នាំ២០១៥) |
| និយ័តកម្មលំហូរទឹក | 67.31 | 50.18 |
| ស្ទាក់ និងស្តុកទឹក | 4.04 | 3.01 |
| កាត់បន្ថយកំណើនកករដី/ភក់ | 56.73 | 42.29 |
| សរុប | 128.08 | 95.47 |
| **សម្គាល់៖** | China GDP per capita 2015 = 8,027.7<br>China GDP deflator index 2015 = 113.6 | |

[c] ការសិក្សាធ្វើឡើងក្នុងឆ្នាំ២០១៦-១៧ ប៉ុន្តែទិន្នន័យដែលត្រូវការសម្រាប់ការកែតម្រូវ (GDP, GDP Inflator) មានត្រឹមឆ្នាំ២០១៥

| | |
|---|---|
| [a] ផ្អែកតាមលទ្ធផលនៃការសិក្សារបស់(Guo et al. 2001)<br>Cambodia GDP per capita 2015 = 1,158.7[d]<br>Cambodia GDP deflator index 2015 = 170.7<br>Income elasticity of WTP = 0.43[e] | China GDP deflator index 1997 = 66.3 |

ដូចនៅក្នុងការសិក្សារបស់ (Hansen and Top 2006) យើងសន្មត់ថា៖

- ព្រៃក្រាស់ ដូចជាព្រៃស្រោង និងព្រៃពាក់កណ្តាលស្រោង ផ្តល់សេវាកម្មពាក់ព័ន្ធនឹងការអភិរក្សទឹក (និយ័តកម្មទឹកហូរ ស្ទាក់និងស្តុកទឹក និងកាត់បន្ថយកំណើនកករដី/ភក់) បានល្អ។ ដូច្នេះតម្លៃនៃសេវាកម្មអភិរក្សទឹករបស់ព្រៃស្រោង និងព្រៃពាក់កណ្តាលស្រោង ត្រូវបានសន្មត់ថាមានតម្លៃស្មើនឹងនៃតម្លៃសេវាកម្មនេះ ដែលផ្តល់ដោយព្រៃធម្មជាតិទូទៅនៅក្នុងការសិក្សារបស់ (Guo et al. 2001)។

- ព្រៃល្បោះ មានគម្របព្រៃមិនសូវក្រាស់ ដូច្នេះមិនអាចផ្តល់សេវាកម្មអភិរក្សទឹកបានល្អដូចព្រៃស្រោង និងព្រៃពាក់កណ្តាលស្រោងទេ។ ដូចជាការសន្មត់របស់ (Hansen and Top 2006) តម្លៃនៃសេវាកម្មអភិរក្សទឹកផ្តល់ដោយព្រៃល្បោះ ត្រូវបានសន្មតថាស្មើនឹងពាក់កណ្តាល (៥០%) នៃតម្លៃសេវាកម្មនេះ ដែលផ្តល់ដោយព្រៃស្រោង និងព្រៃពាក់កណ្តាលស្រោង។

- ចំការដំណាំរយៈពេលវែង ដូចជា កៅស៊ូ ដូង កាកាវ និងអាកាស្យាសេណេហ្គាល់ ក៏ផ្តល់សេវាកម្មអភិរក្សទឹកដែរ ប៉ុន្តែតម្លៃសេវាកម្មអភិរក្សទឹករបស់វាមិនអាចស្មើនឹងព្រៃស្រោង និងព្រៃពាក់កណ្តាលស្រោងទេ។ តាមការសង្កេត ស្ថានភាពគ្របដីនៃចំការកៅស៊ូចាប់ពីពេលមានកន្សោមស្លឹកពេញឡើងទៅ និងស្ថានភាពគម្របដីនៃព្រៃល្បោះ មានលក្ខណៈប្រហាក់ប្រហែលគ្នា។ ដូច្នេះ ក្នុងការសិក្សានេះ យើងសន្មត់ថា តម្លៃសេវាកម្មអភិរក្សទឹកផ្តល់ដោយចំការកៅស៊ូ ស្មើនឹងតម្លៃសេវាកម្មនេះផ្តល់ដោយព្រៃល្បោះ។ ដោយឡែក ស្ថានភាពគម្របដីនៃចំការដូង កាកាវ និងអាកាស្យាសេណេហ្គាល់ ហាក់ដូចជាមិនអាចផ្តល់សេវាអភិរក្សទឹកដូចព្រៃល្បោះឡើយ។ នៅក្នុងការសិក្សានេះ យើងសន្មត់ថា តម្លៃសេវាកម្មអភិរក្សទឹកផ្តល់ដោយចំការដូង កាកាវ និងអាកាស្យាសេណេហ្គាល់ ស្មើនឹងពាក់កណ្តាលនៃតម្លៃសេវាកម្មនេះផ្តល់ដោយព្រៃល្បោះ។

ការសន្មត់ខាងលើ នាំឱ្យយើងទទួលបានលទ្ធផលដូចបង្ហាញក្នុងតារាង៩.៦ (កូឡោនទី៣)។ ក្នុងទំហំផ្ទៃដីព្រៃឈើដែលបាត់បង់ដូចបង្ហាញក្នុងកូឡោនទី១នៃតារាង៩.៦ (សូមអានជំពូកទី៥ ផ្នែកធនធានជីវសាស្ត្រ) សេវាកម្មអភិរក្សទឹកដែលត្រូវធ្លាក់ចុះដោយសារការប្រែក្លាយដីព្រៃធម្មជាតិ (ព្រៃស្រោង ព្រៃពាក់កណ្តាលស្រោង និងព្រៃល្បោះ) ទៅជាចំការដំណាំកសិ-ឧស្សាហកម្ម មានតម្លៃប្រមាណ ២៣៥.០០៤ដុល្លារ/ឆ្នាំ (កូឡោនទី៤)។ តម្លៃនេះ ជាផលដករវាង តម្លៃសេវាកម្មអភិរក្សទឹកសរុបផ្តល់ដោយព្រៃឈើទាំងបីប្រភេទដែលមាននៅក្នុងទីតាំងគម្រោងក្នុងពេលបច្ចុប្បន្ន និងតម្លៃសេវាកម្មអភិរក្សទឹកផ្តល់ដោយចំការដំណាំរយៈពេលវែង ដូចជា កៅស៊ូ ដូង កាកាវ និងអាកាស្យាសេណេហ្គាល់ដែលត្រូវដាំតាមរយៈគម្រោងនេះ។

Draft

[d] ទិន្នន័យ (GDP deflator និង GDP per capita) មានប្រភពមកពីគេហទំព័ររបស់ធនាគារពិភពលោក៖ http://data.worldbank.org/indicator/NY.GDP.PCAP.CD

[e] កម្រិតនៃ Income elasticity of WTP (0.48) ជាកម្រិតដែល Brander (2013) ប្រើប្រាស់សម្រាប់កែតម្រូវតម្លៃនៃការស្ម័គ្រចិត្តចំណាយដើម្បីលើកកំពស់គុណភាពបរិស្ថាន ទៅតាមភាពខុសគ្នានៃប្រាក់ចំណូល (ដែលលើកយកមកបង្ហាញនៅក្នុងឯកសារគោលការណ៍ណែនាំរបស់ UNEP ស្តីពីវិធីសាស្ត្រ Value Transfer)

តារាង៩.៦៖ តម្លៃនៃសេវាកម្មអភិរក្សទឹកដែលធ្លាក់ចុះ

| ប្រភេទគម្របដី | ផ្ទៃដីបាត់បង់ (ហ.ត) | តម្លៃសេវាកម្ម (ដុល្លារ/ហ.ត/ឆ្នាំ) | តម្លៃសេវាកម្មដែលបាត់បង់ (ដុល្លារ/ឆ្នាំ) |
|---|---|---|---|
| សេវាកម្មបាត់បង់ | | | 338,976 |
| ព្រៃស្រោង | 549.11 | 95.47 | 52,426 |
| ព្រៃពាក់កណ្តាលស្រោង | 393.16 | 95.47 | 37,537 |
| ព្រៃល្បោះ | 5,216.32 | 47.74 | 249,013 |
| សេវាកម្មកើតឡើងវិញ | | | 103,972 |
| ចំការកៅស៊ូ | 400 | 47.74 | 19,095 |
| ចំការដូង កាកាវ និងអាកាស្យាសេណេហ្គាល់ | 3,556 | 23.87 | 84,877 |
| **សរុប** | | | **235,004** |

## ៩.៣.៤. តម្លៃឈើឈរដែលត្រូវដកហូតទាំងស្រុង

ការប៉ាន់ស្មានតំលៃឈើឈរនៅក្នុងតំបន់ដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ត្រូវបានធ្វើឡើងដោយផ្អែកតាមលទ្ធផលនៃការធ្វើសារពើភ័ណ្ឌព្រៃឈើ និងថ្លៃសួយសារលើឈើឈរ ដែលបានកំណត់នៅក្នុងប្រកាសរួមលេខ ១២៧៦ សហវ.ប្រក ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ២០០៩ រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេសាទ។ សារពើភ័ណ្ឌព្រៃឈើនេះ (សូមអានជំពូកទី៥ ផ្នែកជីវសាស្ត្រ) ត្រូវបានធ្វើឡើងដោយក្រុមការងាររបស់រដ្ឋបាលព្រៃឈើ ដើម្បីប៉ាន់ស្មានតម្លៃឈើឈរដែលត្រូវដកហូតទាំងស្រុងមុននឹងអនុញ្ញាតឱ្យក្រុមហ៊ុនធ្វើការឈូសឆាយដើម្បីដាំដុះ។ លទ្ធផលបង្ហាញថា ធនធានព្រៃឈើនៅក្នុងទីតាំងគម្រោងមានចំនួន ៦.១៥៨,៥៨ ហិកតា (ព្រៃស្រោង ៥៤៩,១១ហិកតា, ព្រៃពាក់កណ្តាលស្រោង ៣៩៣,១៦ហិកតា, និងព្រៃល្បោះ ៥២១៦,៣២ ហិកតា)។ ធនធានឈើឈរនៅក្នុងព្រៃទាំងនេះ រួមមាន៖ អុសចម្រុះប្រភេទ, កូនឈើចម្រុះប្រភេទ និងកូនឈើដែលមានអង្កត់ផ្ចិត (D = ១៥-៣០ស.ម) មានប្រមាណ ៧៤៩.៨៣០ ម៣ ដែលគិតជាទឹកប្រាក់សរុបប្រហែលជា ២.២៩៤.៦៩០ ដុល្លារ។ ដោយឡែកប្រភេទឈើប្រណិត ឈើមូលដែលមានអង្កត់ផ្ចិត (D = ១៥-៣០ ស.ម) និងមូលដែលមានអង្កត់ផ្ចិតធំជាង ៣០ ស.ម ឡើងទៅ សរុបមានប្រមាណ ៤៦.៧៤២ ម៣ ដែលគិតជាទឹកប្រាក់សរុបប្រហែលជា ៣.១៨១.៩៩៣ ដុល្លារ។ ដូច្នេះ តម្លៃឈើឈរសរុបដែលប៉ាន់ស្មានក្នុងទីតាំងគម្រោងសរុបជាទឹកប្រាកទាំងអស់ គឺប្រមាណ ៥.៤៧៦.៦៨៣ ដុល្លារ ដូចបង្ហាញនៅតារាង៩.៧។

តារាង៩.៧៖ តម្លៃប៉ាន់ស្មាននៃឈើឈរដែលមានក្នុងទីតាំងគម្រោង

| ប្រភេទផលឈើ | ប្រភេទឈើ | តម្លៃ/ឯកត្តា (រៀល/ម៣) | បរិមាណ (ម៣) | តម្លៃសរុប (រៀល) |
|---|---|---|---|---|
| អុសចម្រុះ | - | 6,500 | 74,444 | 483,884,895 |
| កូនឈើចម្រុះ | ឈើប្រណិត(D<១៥ស.ម) | 10,000 | 5,134 | 51,344,400 |
| | ឈើគ្រប់ប្រភេទ(D<១៥ ស.ម) | 2,000 | 214,569 | 429,137,300 |
| កូនឈើអង្កត់ផ្ចិត (D = ១៥-៣០ ស.ម) | ឈើលេខ១ | 20,000 | 192,311 | 3,846,229,800 |

Draft

| | | | | |
|---|---|---|---|---|
| | ឈើលេខ២ | 17,000 | 208,793 | 3,549,489,330 |
| | ឈើលេខ៣ និងក្រៅលំដាប់ថ្នាក់ | 15,000 | 54,578 | 818,673,600 |
| **សរុប** | | | **749,830** | **9,178,759,325** |
| **គិតជាដុល្លារ (អត្រា ១ដុល្លា= ៤០០០ រៀល)** | | | | **2,294,690** |
| | | **(ដុល្លារ/ម៣)** | **(គិតជា ម៣)** | **(គិតជាដុល្លារ)** |
| ឈើមូល (D = ១៥-៣០ ស.ម) | ឈើប្រណិត | 110.00 | 2,705 | 297,552 |
| | នាងនួន | 247.50 | 161 | 39,870 |
| ឈើមូល (D > ៣០ ស.ម) | ឈើប្រណិត | 192.50 | 1,461 | 281,148 |
| | ឈើលេខ១ | 82.50 | 18,625 | 1,536,530 |
| | ឈើលេខ២ | 55.00 | 13,550 | 745,270 |
| | ឈើលេខ៣ និងក្រៅលំដាប់ថ្នាក់ | 27.50 | 10,241 | 281,623 |
| **សរុប** | | | **46,742** | **3,181,993** |
| **សរុបរួម** | | | | **5,476,683** |

**សម្គាល់៖** តម្លៃ/ឯកតា គឺផ្អែកតាមប្រកាសរួមលេខ ១២៧៦ សហវ.ប្រក ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ២០០៩ រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេសាទ ស្តីអំពីការកំណត់ថ្លៃសួយសារលើឈើឈរដើម្បីបង់ចំណូលថវិការដ្ឋ

Draft

## ៩.៤. ពិភាក្សា និងសន្និដ្ឋាន

ការសម្រេចចិត្តរបស់រាជរដ្ឋាភិបាលក្នុងការផ្តល់ដីសម្បទានសេដ្ឋកិច្ចចំនួន ៦.០៥៩,២៧ ហិកតា (ដែលក្នុងនោះមានព្រៃស្រោង ៥៤៩,១១ហិកតា, ព្រៃពាក់កណ្តាលស្រោង ៣៩៣,១៦ហិកតា, និងព្រៃល្បោះ ៥.២១៦,៣២ហិកតា) សម្រាប់វិនិយោគដាំដំណាំកសិ-ឧស្សាហកម្ម (ដូង កាកាវ អាកាស្យាសេណេហ្គាល់ កៅស៊ូ និងដំណាំកសិ-ឧស្សាហកម្មផ្សេងទៀត) គឺជាជម្រើសមួយដែលជំរុញឱ្យមានការធ្វើអាជីវកម្មធនធានឈើឈរដែលមាននៅក្នុងទីតាំងនេះទាំងស្រុងដោយខានមិនបាន (ធ្វើអាជីវកម្មបានតែម្តងគត់)។ តាមការប៉ាន់ស្មាន ធនធានឈើឈរទាំងនេះមានតម្លៃសរុបប្រមាណ ៥.៤៧៦.៦៨៣ ដុល្លារ។ ការធ្វើអាជីវកម្មឈើឈរទាំងស្រុងដើម្បីយកដីអភិវឌ្ឍន៍ដំណាំកសិ-ឧស្សាហកម្មនេះ នឹងធ្វើឱ្យធ្លាក់ចុះនូវសេវាកម្មប្រព័ន្ធអេកូឡូស៊ីដែលផ្តល់ដោយព្រៃឈើ ក្នុងតម្លៃសរុបប្រមាណ ៣៥៩.៥៧៥ដុល្លារ/ឆ្នាំ (Opportunity Cost)។ ក្នុងករណីដែលព្រៃឈើត្រូវបានគ្រប់គ្រងប្រកបដោយនិរន្តរភាពនោះ សេវាកម្មអេកូឡូស៊ីព្រៃឈើទាំងនេះ នឹងផ្តល់ផលប្រយោជន៍ដល់មនុស្សជាច្រើនឆ្នាំ ដែលយើងមិនអាចប៉ាន់ស្មានបាន។

បើយើងពិចារណាលើបម្រែបម្រួលតម្លៃសេដ្ឋកិច្ចដោយសារការបាត់បង់ព្រៃឈើ តាមរយៈគម្រោងវិនិយោគនេះ ក្នុងរយៈពេល ៥០ឆ្នាំ (ដែលជារយៈពេលនៃការវិនិយោគរបស់ក្រុមហ៊ុនផ្តល់ដោយរាជរដ្ឋាភិបាល) នោះយើងសង្កេតឃើញថា គម្រោងវិនិយោគនេះនឹងធ្វើឱ្យមានបម្រែបម្រួលផល-សេវាកម្មប្រព័ន្ធអេកូឡូស៊ីព្រៃឈើ ដែលអាចនឹងនាំឱ្យខាត់បង់តម្លៃសេដ្ឋកិច្ចប្រមាណ ១២.៥០២.០៤៧ដុល្លារ ក្នុងរយៈពេល ៥០ឆ្នាំ (ឬជាមធ្យម ២៥០.០៤១

ដុល្លារ/ឆ្នាំ) ដូចបង្ហាញសង្ខេបក្នុងតារាង៩.៨។ តម្លៃនេះ ជាតម្លៃដែលបាត់បង់ដោយសារបាត់បង់ឱកាសទទួលបានផលប្រយោជន៍ពីព្រៃឈើ (ក្នុងលក្ខណៈអរូបី) ក្នុងករណីដែលព្រៃឈើនោះត្រូវបានគ្រប់គ្រងដោយនិរន្តរភាព។

តារាង៩.៨៖ តម្លៃខាត់បង់សរុបដោយសារបម្រែបម្រួលសេវាកម្មប្រព័ន្ធអេកូឡូស៊ី

| ផល-សេវាកម្មដែលប្រែប្រួល | តម្លៃ (ដុល្លារ/ឆ្នាំ) | តម្លៃសរុប (ដុល្លារ) |
|---|---|---|
| សេវាកម្មប្រព័ន្ធអេកូឡូស៊ីដែលខូចខាត | 359,575 | 17,978,730 |
| ផល-អនុផលព្រៃឈើ | 88,986 | 4,449,297 |
| ស្តុកកាបូន | 35,585 | 1,779,235 |
| សេវាកម្មអភិរក្សទឹក | 235,004 | 11,750,198 |
| ឈើឈរដែលត្រូវដកហូត (ចំណេញ) | 109,533.65 | 5,476,683 |
| សរុប | 250,041 | 12,502,047 |

ការគ្រប់គ្រងព្រៃឈើឱ្យមាននិរន្តរភាព ជាទូទៅត្រូវការថវិកាជាច្រើន ដែលយើងមិនអាចធ្វើការប៉ាន់ស្មានបានក្នុងស្ថានភាពបច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជា។ ជាក់ស្តែង ព្រៃឈើក្នុងតំបន់ការពារធម្មជាតិ ដែលត្រូវបានការពារដោយច្បាប់ និងមានថវិកា/ធនធានជាច្រើនសម្រាប់គ្រប់គ្រង ក៏នៅមិនទាន់អាចធានាបាននូវនិរន្តរភាពផង។ ម្យ៉ាងវិញទៀត ព្រៃឈើក្នុងតំបន់គម្រោងក្នុងពេលបច្ចុប្បន្ន ក៏បាននិងកំពុងទទួលរងនូវការកាប់រានធ្វើចំការពីសំណាក់ប្រជាជន និងជនឆ្លៀតឱកាសនានា។ ដូច្នេះ ព្រៃឈើក្នុងតំបន់គម្រោង ក៏ប្រហែលជាត្រូវបានកាប់បំផ្លាញ ឬធ្វើឱ្យសឹករេចរឹលតាមប្រការណាមួយដោយជៀសមិនរួច បើទោះជាមិនមានវត្តមានគម្រោងក៏ដោយ។ តម្លៃខាតបង់ដូចបានប៉ាន់ស្មានខាងលើ ក៏ប្រហែលជាបាត់បង់ជាមួយព្រៃឈើទាំងនោះដែរ ដោយមិនបានទាំងផ្តល់អត្ថប្រយោជន៍សេដ្ឋកិច្ច (ដែលមានតម្លៃបច្ចុប្បន្នប្រមាណ ៣៧៧.៩៤៧ដុល្លារ/ឆ្នាំ) ពីគម្រោងវិនិយោគនេះ។ ការខូចខាតបរិស្ថាន ក៏ប្រហែលជាមានតម្លៃខ្ពស់ជាងតម្លៃប៉ាន់ស្មានខាងលើ ប្រសិនបើព្រៃឈើត្រូវបានកាប់បំផ្លាញ ហើយទុកដីចោលនៅទំនេរដោយគ្មានការដាំដុះ ក្នុងខណៈដែលគ្មានគម្រោង។

ប្រទេសកម្ពុជាមិនទាន់មានការដាក់ពន្ធទៅលើសេវាកម្មប្រព័ន្ធអេកូឡូស៊ី (Payment for Ecosystem Services) នៅឡើយទេ។ បើទោះជាយ៉ាងនេះក្តី យើងមិនគួរបំភ្លេចចោលនូវផលប៉ះពាល់អវិជ្ជមាន ដែលនឹងបង្កឡើងដោយសកម្មភាពគម្រោងនេះនោះទេ។ ដើម្បីក្លាយជាក្រុមហ៊ុនមួយដែលមានការទទួលខុសត្រូវខ្ពស់ ក្រុមហ៊ុន SK Plantation (Cambodia) Pte Ltd បានបង្កើតឡើងនូវមូលនិធិបរិស្ថាន-សង្គមមួយ ដើម្បីជាការប៉ះប៉ូវដល់ផលប៉ះពាល់បរិស្ថាន-សង្គមអវិជ្ជមានដែលនៅសេសសល់បន្ទាប់ពីបានអនុវត្តតាមផែនការគ្រប់គ្រងបរិស្ថាន (ដូចមានបង្ហាញនៅក្នុងជំពូកទី៨) ឱ្យសមស្របទៅនឹងតម្លៃនៃការខូចខាត ហើយក្រុមហ៊ុននៅអាចរក្សាបាននូវដំណើរការអាជីវកម្ម ឬវិនិយោគរបស់ខ្លួន។

Draft

# ជំពូកទី១០

# សន្និដ្ឋាន

# និងអនុសាសន៍

Draft

# ជំពូកទី១០៖ សន្និដ្ឋាន និងអនុសាសន៍

ការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ សម្រាប់គម្រោងវិនិយោគដំណាំកសិឧស្សាហកម្ម របស់ក្រុមហ៊ុន SK Plantation (Cambodia) Pte, Ltd. បានបង្ហាញថា ការអភិវឌ្ឍដំណាំចំរុះដូចជា៖ ដូង កាកាវ អាកាស្យាសេណោហ្គាល់ និងដំណាំកសិឧស្សាហកម្មផ្សេងៗទៀត អាចរួមចំណែកផ្តល់ផលប្រយោជន៍យ៉ាងច្រើនដល់សេដ្ឋកិច្ចសង្គមតាមរយៈ៖ ការជំរុញនូវសកម្មភាពផលិតកម្ម និងការនាំចេញផលិតផលកសិឧស្សាហកម្ម ការបង្កើតការងារ និងមុខរបរបន្ថែមដល់ប្រជាជនកម្ពុជា ជាពិសេសប្រជាជនមូលដ្ឋាន និងជនជាតិដើមភាគតិចក្នុងតំបន់ជនបទដែលពុំសូវមានចលករសេដ្ឋកិច្ច (ធ្វើជាបុគ្គលិក-កម្មករគម្រោង និងជំរុញសកម្មភាពសេដ្ឋកិច្ចជុំវិញតំបន់) ផ្តល់ចំណូលដល់រដ្ឋតាមរយៈពន្ធលើប្រាក់ចំណូលរបស់ក្រុមហ៊ុន ពន្ធលើប្រាក់បៀវត្សរបស់បុគ្គលិក និងកម្មករគម្រោង លើកកម្ពស់ការយល់ដឹងរបស់បុគ្គលិក និងកម្មករកម្ពុជា អំពីបច្ចេកទេសក្នុងការដាំដុះ ថែទាំ ប្រមូលផល និងកែច្នៃផលិតផលកសិ-ឧស្សាហកម្មជាច្រើនប្រភេទ ព្រមទាំងជួយគាំទ្រដល់សកម្មភាពអភិវឌ្ឍន៍មូលដ្ឋានតាមរយៈមូលនិធិបរិស្ថាន-សង្គម។ ក្នុងតម្លៃអត្រាអតិបរមា (discount rate) ១២% នោះផលចំណេញសេដ្ឋកិច្ចសុទ្ធដែលកើតចេញពីការវិនិយោគនេះ (Net Present Value – NPV) មានចំនួនប្រមាណ សរុបប្រមាណ ៧.៥៥៨.៩៤៧ ដុល្លារអាមេរិក (ឬជាមធ្យមប្រមាណ ៣៧៧.៩៤៧ ដុល្លារអាមេរិក/ឆ្នាំ) ក្នុងរយៈពេលឆ្នាំ២០ដំបូង។ ប្រាក់ចំណេញសុទ្ធប្រចាំឆ្នាំជាមធ្យមច្បាស់ជានឹងកើនឡើងគួរឱ្យកត់សម្គាល់ក្នុងរយៈពេលវិនិយោគដែលនៅសេសសល់ (ពីឆ្នាំទី២១ ដល់ ៥០) ពីព្រោះថ្លៃចំណាយ (ដូចជា សម្រាប់ហេដ្ឋារចនាសម្ព័ន្ធ គ្រឿងចក្រ សំភារៈការិយាល័យ) នឹងថយចុះយ៉ាងខ្លាំង។

ជាពិសេសកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញនេះបានបង្ហាញថា៖

- ក្រុមហ៊ុនទទួលបានដីសម្បទានពីរាជរដ្ឋាភិបាលទំហំ ៦៥០៩,២៧ហិកតា ដែលក្រុមហ៊ុនគ្រោងនឹងធ្វើការឈូសឆាយ ដាំដុះ និងប្រើប្រាស់សម្រាប់សាងសង់ហេដ្ឋារចនាសម្ព័ន្ធគម្រោង ដូចជា ទីស្នាក់ការក្រុមហ៊ុន ផ្លូវថ្នល់ ការដ្ឋាន និងផ្ទះកម្មករជាដើម។ ផ្ទៃដីដែលទទួលបាននេះ (១០ក្បាលដី) ត្រូវបានមន្ទីរពាក់ព័ន្ធ និងអាជ្ញាធរខេត្តឯកភាពឱ្យចុះបញ្ជីជាដីឯកជនរបស់ រដ្ឋ។ ក្នុងនាមក្រសួង មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ខេត្ត ក៏បានចេញបណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុទាំង១០ក្បាលដីនេះ កាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ ។
- ផ្ទៃដីដាំដុះមានទំហំ ៦.១២៦ ហិកតា (ដីសម្បទានដែលក្រុមហ៊ុនទទួលបានចំនួន ៦.៥០៩ ហិកតា ប៉ុន្តែផ្ទៃដីចំនួន ៣៨៣ ហិកតា ទៀត នឹងត្រូវប្រើប្រាស់សម្រាប់កសាងហេដ្ឋារចនាសម្ព័ន្ធគម្រោង) ត្រូវបានបែងចែកជា ៤អនុតំបន់ តាមឆ្នាំដាំដុះ ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២៣។
- ការប្រើប្រាស់ជី និងថ្នាំគីមីកសិកម្ម អាចធ្វើឱ្យគុណភាពដី ត្រូវរងផលប៉ះពាល់ ក៏ប៉ុន្តែយើងនៅមិនទាន់ដឹងច្បាស់ថា ដី ឬថ្នាំគីមីកសិកម្មទាំងនោះនឹងមានឥទ្ធិពលវិជ្ជមាន ឬអវិជ្ជមានយ៉ាងណាដល់គុណភាពដីនាពេលអនាគតឡើយ។ ប៉ុន្តែក្រុមហ៊ុននឹងជ្រើសរើសមកប្រើប្រាស់ក្នុងការដាំដុះនូវជី និងថ្នាំគីមីកសិកម្មមួយចំនួន ដែលបានអនុញ្ញាតដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប៉ុណ្ណោះ។ដូចគ្នានេះដែរ ក្រុមហ៊ុនបានជ្រើសរើសធ្វើការដាំដុះដំណាំកសិឧស្សាហកម្មជាច្រើនប្រភេទ (ដូង កាកាវ អាកាស្យាសេណោហ្គាល់ កៅស៊ូ និងដំណាំយុទ្ធសាស្ត្រជាច្រើនប្រភេទទៀត) អាចនឹងបន្ថយឥទ្ធិពលអវិជ្ជមានដល់គុណភាពដីនាពេលបញ្ចប់គម្រោង។ ទោះជាយ៉ាងនេះក្តី ក្រុមហ៊ុនត្រូវធ្វើការពិនិត្យ និងតាមដានឱ្យបានខ្ជាប់ខ្ជួន ជាមួយស្ថាប័នជំនាញពាក់ព័ន្ធ ទៅលើបម្រែបម្រួលនៃគុណភាពដីទៅលើផ្ទៃដីប្រើប្រាស់របស់ក្រុមហ៊ុន។
- ការប្រើប្រាស់ជី និងថ្នាំគីមីកសិកម្មខុសលក្ខណៈបច្ចេកទេស ដែលលើសពីលទ្ធភាពស្រូបយករបស់កៅស៊ូ និងរុក្ខជាតិទ្រនាប់ដី ជាពិសេសនៅរដូវវស្សា គឺជាប្រភពបំពុលទឹកក្នុងកម្រិតមធ្យម និងធ្ងន់ធ្ងរ ហើយអាចមានជា

Draft

ញឹកញាប់ក្នុងកំឡុងពេលប្រតិបត្តិគម្រោង។ ការគ្រប់គ្រងសំណល់ជី និងថ្នាំគីមីកសិកម្ម ដូចជាសំណល់ដប ឬធុងថ្នាំកសិកម្ម មិនបានត្រឹមត្រូវល្អ ដោយធ្វើការបោះចោលសំណល់គ្រោះថ្នាក់ទាំងនោះនៅក្បែរមាត់ទឹកអូរ ឬប្រឡាយ ក៏ជាប្រភពធ្វើឱ្យគុណភាពទឹកថយចុះ និងរងការបំពុលដែរ។ ការបំពុលដែលអាចកើតឡើងទាំងនេះ ក្រុមហ៊ុនអាចទប់ស្កាត់បានទាំងស្រុង ប្រសិនបើក្រុមហ៊ុនអនុវត្តទៅតាមវិធានការកាត់បន្ថយ និងគ្រប់គ្រងបរិស្ថាន ដែលបានស្នើឡើងនៅក្នុងរបាយការណ៍នេះ ឱ្យបានត្រឹមត្រូវ។

- ក្នុងដំណាក់កាលបោះបង្គោលព្រំប្រទល់ដំបូងនៅលើដីរបស់ក្រុមហ៊ុន ក្រុមហ៊ុនធ្លាប់បានសហការជាមួយអាជ្ញាធរក្នុងការដោះស្រាយបញ្ហាដីធ្លីជាមួយប្រជាជនមូលដ្ឋាន ដើម្បីឆ្លើយតបទៅនឹងបញ្ហាទំនាស់ដីធ្លី តាមរយៈការកាត់ចេញនូវដីទំនាស់ និងដីដែលពាក់ព័ន្ធនានាពីប្លង់ដីវិនិយោគ (ផ្ទៃដីរក្សាទុក ដីទ្រនាប់មាត់អូរ ដីបំរុងទុកសម្រាប់សម្បទានសង្គមកិច្ច ដីព្រៃសហគមន៍ ដីកប់ខ្មោច ដីព្រៃអ្នកតា ដីទីទួលសុវត្ថិភាពជាដើម។ល។)។ នាពេលថ្មីៗនេះ (ខែមីនា ឆ្នាំ២០១៧) ក្រុមហ៊ុនក៏បានសហការជាមួយអាជ្ញាធរខេត្តរតនគិរី អាជ្ញាធរខេត្តស្ទឹងត្រែង និងសហគមន៍ជនជាតិដើមភាគតិចភូមិរំពាត់ ក្នុងការចុះធ្វើការផ្ទៀងផ្ទាត់ និងបោះបង្គោលព្រំ ដើម្បីបញ្ចប់បញ្ហាទំនាស់ដីធ្លីដែលកើតមានឡើងដោយសារភាពមិនច្បាស់លាស់នៃព្រំប្រទល់ខេត្តទាំងពីរ ក៏ដូចជាព្រំប្រទល់ដីសហគមន៍ជនជាតិដើមភាគតិចភូមិរំពាត់ដែលស្ថិតនៅក្នុងខេត្តស្ទឹងត្រែង (ទីតាំងគម្រោងស្ថិតនៅក្នុងខេត្តរតនគិរី)។

- ទោះជាយ៉ាងនេះក្តី ការសិក្សាបង្ហាញថា អ្នកផ្តល់សម្ភាសន៍ប្រមាណតែ ២៤% ប៉ុណ្ណោះសម្តែងការមិនពេញចិត្តចំពោះដំណើរការគម្រោង ប៉ុន្តែអ្នកផ្តល់សម្ភាសន៍រហូតដល់ ៥៦% គាំទ្រចំពោះដំណើរការគម្រោង ក្នុងនោះ ២៦% គាំទ្រដោយគ្មានលក្ខខណ្ឌ និង ៣០% គាំទ្រដោយមានលក្ខខណ្ឌ/សំណូមពរខ្លះៗចំពោះក្រុមហ៊ុន (១) សូមកុំឲ្យមានការប៉ះពាល់ដីចំការរបស់ប្រជាជន និងផ្តល់សំណងសមរម្យ ប្រសិនបើមានការប៉ះពាល់ ២) ស្នើសុំឲ្យធ្វើមណ្ឌលសុខភាព ៣) ស្នើសុំផ្លូវពីភូមិរំពាត់ទៅឃុំត្រពាំងក្រហម នៃខេត្តរតនគិរី ៤) ស្នើសុំឲ្យក្រុមហ៊ុនកំណត់ព្រំប្រទល់ឲ្យបានត្រឹមត្រូវ និងមានការចូលរួមពីប្រជាជន និងអាជ្ញាធរមូលដ្ឋាន ៥) ស្នើសុំឲ្យធ្វើសាលារៀន ៦) ស្នើសុំឲ្យធ្វើស្ពាន ៧) ស្នើសុំឲ្យក្រុមហ៊ុនជ្រើសរើសប្រជាជនមូលដ្ឋានជាបុគ្គលិក និង៨) ស្នើសុំអណ្តូងទឹក)។ លទ្ធផលទាំងនេះតម្រូវឲ្យក្រុមហ៊ុនមានការប្រុងប្រយ័ត្នខ្ពស់នៅពេលធ្វើការឈូសឆាយដី ហើយត្រូវយកចិត្តទុកដាក់ក្នុងការដោះស្រាយផលប៉ះពាល់ដោយហ្មត់ចត់ ប្រសិនបើមាននៅសេសសល់។ ក្រុមហ៊ុនត្រូវពិភាក្សារកដំណោះស្រាយលើបញ្ហាទំនាស់ដីធ្លី ដោយផ្ទាល់ជាមួយសហគមន៍ និងប្រជាជនមូលដ្ឋាន ក្រោមការសម្របសម្រួលរបស់អាជ្ញាធរមូលដ្ឋាន និងស្ថាប័នជំនាញនានា។ ក្រុមហ៊ុនក៏នឹងជួយឧបត្ថម្ភដល់ការរៀបចំផែនការប្រើប្រាស់ដី និងកម្មវិធីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន នៅក្នុងឃុំដែលទីតាំងគម្រោងស្ថិតនៅក្បែរ (ឃុំប៉ង់ ឃុំហាតប៉ក់ ឃុំភ្នំកុក ឃុំតឺន និងឃុំត្រពាំងក្រហម រួមទាំងឃុំតាឡាតដែលនៅក្រោមខ្សែទឹក) ដើម្បីជួយរួមចំណែកលើកកម្ពស់ការចិញ្ចឹមជីវិត និងសេដ្ឋកិច្ចមូលដ្ឋាន និងធានាលទ្ធភាពក្នុងការប្រើប្រាស់ដីរបស់ប្រជាសហគមន៍ក្នុងពេលអនាគត់ ក្នុងខណៈដែលកំណើនប្រជាជននៅតែបន្ត ចំណែកឯដីធ្លីដែលអាចប្រើប្រាស់បានរិតតែរួមតូច ដោយសារផលប៉ះពាល់ជាបណ្តុំនៃគម្រោងវិនិយោគនានានៅក្នុងតំបន់តែមួយ។

- ការបាត់បង់ធនធានព្រៃឈើ បានកើតមានឡើងនៅជុំវិញ និងក្នុងតំបន់គម្រោងតាំងពីមិនទាន់មានវត្តមានគម្រោងមកម្ល៉េះ និងកើតឡើងនៅទីតាំងផ្សេងទៀតនៅក្នុងខេត្តរតនគិរីព្រមគ្នាជាមួយនឹងការបាត់បង់ក្នុងការវិនិយោគគម្រោងនេះ។ ផ្ទៃដីព្រៃឈើដែលនឹងបាត់បង់ក្នុងគម្រោងនេះ (៥២៦៤, ៦១ ហ.ត)[1] គ្រាន់តែជាចំណែកតូចមួយ (ប្រមាណ ៥.៦%) នៃផ្ទៃដីព្រៃឈើដែលបានបាត់បង់ក្នុងតំបន់នោះ ក្នុងចន្លោះឆ្នាំ ២០០២-២០១៦ ប៉ុណ្ណោះ។ ទោះជាយ៉ាងនេះក្តី ព្រៃឈើដែលបាត់បង់ដោយសារគម្រោងនេះ និងគម្រោងអភិវឌ្ឍន៍ទាំង

Draft

[1] ក្នុងផ្ទៃដីគម្រោងទំហំ ៦៥០៩,២៧ហ.ត មានដីគ្មានគម្របព្រៃទំហំ ១ ២៤៤ហ.ត ស្រាប់

អស់ក្នុងតំបន់ គួបផ្សំនឹងព្រៃឈើដែលបាត់បង់ដោយសារការទន្ទ្រានយកដីពីសំណាកប្រជាជនក្នុងមូលដ្ឋាន និងជនឆ្លៀតឱកាសមួយចំនួន ពិតជាមានទំហំធំធេងគួរឱ្យព្រួយបារម្ភ។ វិធានការកាត់បន្ថយផលប៉ះពាល់ជាបណ្ដុំនេះ ហួសពីសមត្ថភាពរបស់ក្រុមហ៊ុន ក្នុងការដោះស្រាយតែឯកឯង។ រដ្ឋាភិបាលអាចប្រើប្រាស់ឧបករណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ដើម្បីរៀបចំ/កែសម្រួលផែនការប្រើប្រាស់ដី ឬរកវិធានការកាត់បន្ថយការបាត់បង់ធនធានព្រៃឈើ ដែលមានសារៈសំខាន់សម្រាប់ការអភិរក្សជីវៈចម្រុះ និងអាចធានាបាននូវលំហូរសេវាកម្មប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ ជាពិសេសសេវាកម្មការពារទីជំរាល និងប្រភពទឹកស្អាត។

- ការបាត់បង់ព្រៃឈើក្នុងកិច្ចដំណើរការគម្រោងនេះ និងគម្រោងវិនិយោគផ្សេងទៀត គួបផ្សំនឹងកត្តាគម្រាមកំហែងជាច្រើនក្នុងតំបន់ (ជាពិសេសការបរបាញ់) អាចនឹងធ្វើឱ្យបាត់បង់ទីជម្រកសត្វ និងអាចបង្កឲ្យសត្វព្រៃជាច្រើនប្រភេទ (ថនិកសត្វ៥៣, ល្មូន៩៦, និងបក្សី២០៤) មានការថយចុះ ក្នុងនោះមានប្រភេទសត្វព្រៃដែលកំពុងរងគ្រោះថ្នាក់ជិតផុតពូជប្រមាណ១២ប្រភេទ (ថនិកសត្វ៦, ល្មូន២, និងបក្សី៤) និងប្រភេទសត្វព្រៃដែលមានដោយកម្រ៤០ប្រភេទ (ថនិកសត្វ១៧, ល្មូន៤, និងបក្សី១៩)។ ការបាត់បង់ទីជម្រកសត្វ និងប្រភេទសត្វនានាដែលអាចកើតឡើងទាំងនេះ ក្រុមហ៊ុនអាចទប់ស្កាត់បានស្ទើរតែទាំងស្រុង ប្រសិនបើក្រុមហ៊ុនអនុវត្តទៅតាមវិធានការកាត់បន្ថយ និងគ្រប់គ្រងបរិស្ថាន ដែលបានស្នើឡើងនៅក្នុងរបាយការណ៍នេះ ឱ្យបានត្រឹមត្រូវ។

- ព្រៃឈើដែលអាចនឹងបាត់បង់នៅពេលគម្រោងចាប់ដំណើរការ ក៏អាចរួមចំណែកធ្វើឱ្យមានបម្រែបម្រួលសេវាកម្មប្រព័ន្ធអេកូឡូស៊ីសំខាន់ៗដូចជា៖ ផល-អនុផលព្រៃឈើ សេវាកម្មស្តុកកាបូន និងសេវាកម្មអភិរក្សទឹក។ បម្រែបម្រួលនេះ ធ្វើឱ្យខាតបង់ផលប្រយោជន៍សេដ្ឋកិច្ច ដែលមានតម្លៃសរុប (ជាលក្ខណៈអរូបី) ប្រមាណ ៣៥៩.៥៧៥ដុល្លារអាមេរិក/ឆ្នាំ (Opportunity Cost)។ ក្នុងស្ថានភាពនៃការបាត់បង់ព្រៃឈើក្នុងតំបន់ដូចបានបង្ហាញខាងលើ តម្លៃបរិស្ថាននេះ ក៏ប្រហែលជាត្រូវបាត់បង់ជាមួយព្រៃឈើ ទោះជាមិនមានវត្តមានគម្រោងនេះក្តី។ ការខូចខាតបរិស្ថាន ក៏ប្រហែលជាមានតម្លៃខ្ពស់ជាងតម្លៃប៉ាន់ស្មានខាងលើ ប្រសិនបើព្រៃឈើត្រូវបានកាប់បំផ្លាញ ហើយទុកដីចោលនៅទំនេរដោយគ្មានការដាំដុះ ក្នុងខណៈដែលគ្មានគម្រោង។

- ដើម្បីធានាបាននូវការគ្រប់គ្រងបរិស្ថាន និងកាត់បន្ថយនូវផលប៉ះពាល់នានា ក៏ដូចជាដើម្បីជាការប៉ះប៉ូវដល់ផលប៉ះពាល់អវិជ្ជមានកន្លងមក ក្រុមហ៊ុនត្រូវអនុវត្តនូវវិធានការការពារបរិស្ថានចំនួន៨៖ ១) ការដោះស្រាយវិវាទដីធ្លីជាមួយប្រជាជន និងសហគមន៍មូលដ្ឋាន, ២) ការគ្រប់គ្រងការឈូសឆាយ សាងសង់ និងដាំដុះ, ៣) ការលើកកម្ពស់សុខមាលភាពបុគ្គលិក-កម្មករ, ៤) ការគ្រប់គ្រងសំណល់ និងប្រភពបំពុលផ្សេងៗ, ៥)ការគ្រប់គ្រងការប្រើប្រាស់ដី និងថ្នាំគីមីកសិកម្ម, ៦) ការរួមចំណែកអភិវឌ្ឍន៍មូលដ្ឋាន និងលើកកម្ពស់សុខមាលភាពសង្គម, ៧) ការចូលរួមការពារ និងស្តារឡើងវិញនូវធនធានធម្មជាតិ និង ៨) ការគ្រប់គ្រងបញ្ហាទូទៅ ព្រមទាំងកម្មវិធីបំពាក់បំប៉ន និងកម្មវិធីត្រួតពិតនិត្យបរិស្ថានផងដែរ។ ក្រុមហ៊ុនត្រូវជ្រើសរើសបុគ្គលិកផ្នែកបរិស្ថានមួយរូបបន្ថែម និងវិភាជថវិកាសរុបប្រមាណ ៣.០៣៨.០០០ ដុល្លារអាមេរិក ឬជាមធ្យមប្រចាំឆ្នាំចំនួន ៦០.៧៦០ ដុល្លារអាមេរិក សម្រាប់ចំណាយលើការអនុវត្តផែនការគ្រប់គ្រងបរិស្ថាននេះ ក្នុងកំឡុងពេល ៥០ឆ្នាំសម្រាប់ការវិនិយោគនេះ។

- ក្រុមហ៊ុនម្ចាស់គម្រោងត្រូវសហការជិតស្និទ្ធជាមួយក្រសួងបរិស្ថាន, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងសុខាភិបាល ស្ថាប័នជំនាញ និងអាជ្ញាធរពាក់ព័ន្ធនានា ដើម្បីអនុវត្តឲ្យបានត្រឹមត្រូវតាមផែនការគ្រប់គ្រងបរិស្ថាន ព្រមទាំងធ្វើការកែតម្រូវក្នុងករណីចាំបាច់ ដើម្បីលើក

Draft

កម្ពស់ប្រសិទ្ធភាព និងប្រសិទ្ធផលនៃការអនុវត្តផែនការនេះ។ ផលប្រយោជន៍ ដែលប្រជាជននឹងទទួលបានពីសកម្មភាពនានាក្រោមផែនការគ្រប់គ្រងបរិស្ថាន (ជាពិសេសការជួយអភិវឌ្ឍន៍មូលដ្ឋាន) ពិតជានឹងអាចបង្កើនភាពសុខដុមរមណីយកម្មរវាងក្រុមហ៊ុន និងសហគមន៍មូលដ្ឋាន និងឈានទៅសម្រេចគោលដៅចម្បងនៃការវិនិយោគនេះគឺ រួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចកសិកម្មប្រកបដោយនិរន្តភាព និងជួយកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។

| | |
|---|---|
| រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែតុលា ឆ្នាំ២០១៧ | រាជធានីភ្នំពេញ ថ្ងៃទី ២ ខែ តុលា ឆ្នាំ២០១៧ |
| SK Plantation Pte., Ltd. | ក្រុមហ៊ុន អ ស៊ី ប៊ី ស៊ី ស៊ី |
| **ប្រធានក្រុមហ៊ុន** | **ឋ.ក្រុមប្រឹក្សាភិបាលក្រុមហ៊ុន** |
| | **នាយកគ្រប់គ្រង** |
| S K PLANTATION (CAMBODIA) PTE LTD | RCBCC Co., Ltd KINGDOM OF CAMBODIA |
| NARAYAN PODDAR | **ឆួន កល្យាណ** |

# ឯកសារយោង

Draft

# ឯកសារយោង


- គោលនយោបាយស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច ឆ្នាំ២០០៩
- ច្បាប់ភូមិបាល ឆ្នាំ២០០១
- ច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ឆ្នាំ២០០១
- ច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម ឆ្នាំ២០១២
- ច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ ឆ្នាំ២០០៨
- ច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧
- ច្បាប់ស្តីពីកិច្ចការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
- ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ១៩៩៦
- ច្បាប់ស្តីពីកិច្ចការពារបេតិកភ័ណ្ឌវប្បធម៌ ឆ្នាំ១៩៩៦
- ច្បាប់ស្តីពីជលផល ឆ្នាំ២០០៦
- ច្បាប់ស្តីពីជីវសុវត្ថិភាព ឆ្នាំ២០០៨
- ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ឆ្នាំ២០០៨
- ច្បាប់ស្តីពីព្រៃឈើ ឆ្នាំ២០០២
- ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៤
- ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៣
- និទានុលេខន៍ជលផល (២០១៥) ក្រសួងកសិកម្មរុក្ខប្រម៉ាញ់ និងនេសាទ
- បទបញ្ជាលេខ ០០១ បប របស់រាជរដ្ឋាភិបាលចុះថ្ងៃទី ៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីវិធានការពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច
- ទិន្នន័យធនធានគម្របព្រៃឈើឆ្នាំ ២០០២ ២០០៦និង២០១០ របស់នាយកដ្ឋានគ្រប់គ្រងទីជម្រាល និងវាយតម្លៃគម្របព្រៃឈើ នៃរដ្ឋបាលព្រៃឈើ
- ប្រកាសលេខ ០២០ប្រកកសក ស្តីពីចំណាត់ថ្នាក់ និ.ងបញ្ជីឈ្មោះប្រភេទសត្វព្រៃ ចុះថ្ងៃទី ២៥ ខែមករា ឆ្នាំ ២០០៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ប្រកាសលេខ ០៨៩ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីប្រភេទឈើក្នុងលំដាប់ថ្នាក់ និងទំហំអប្បរមាអនុញ្ញាតឲ្យកាប់រំលំ
- ប្រកាសស្តីពីគោលការណ៍ណែនាំទូទៅក្នុងការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ ឆ្នាំ២០០៩
- ប្រកាសអន្តរក្រសួងមហាផ្ទៃ-បរិស្ថាន ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងនៅក្នុងខេត្តក្រុងនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៣
- ប្រភេទត្រីទឹកសាបសំខាន់ៗនៅប្រទេសកម្ពុជា៖ រៀបរៀងដោយលោក ចាន់ សុខហេង នៅឆ្នាំ២០០៨
- ពិធីការបច្ចេកទេសសារពើភ័ណ្ឌវាយតម្លៃប៉ាន់ស្មានធនធានព្រៃឈើនៅក្នុងសម្បទានដីសេដ្ឋកិច្ច ខែតុលា ឆ្នាំ ២០១១ រៀបរៀងដោយលោក ប៊ុន វណ្ណា
- មគ្គុទេសក៏នៅតំបន់វាលធ្លោះទៅស្គាល់សត្វស្លាបនៃប្រទេសកម្ពុជា៖ រៀបរៀងដោយលោក តាន់ សេដ្ឋា និង លោក កូលីន កូល នៅឆ្នាំ២០០៣


Draft

- យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ឆ្នាំ២០១៤-២០១៨
- របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង លើគម្រោងវិនិយោគសម្រាប់អភិវឌ្ឍន៍ដំណាំកៅស៊ូ របស់ក្រុមហ៊ុន Hoang Anh Oyadav ឆ្នាំ២០១៣
- សត្វស្លាបប្រទេសកម្ពុជា៖ រៀបរៀងដោយលោក ស៊ុន ហ៊ាន, លោក សេង គឹមហ៊ត់, លោក កែវ សុម៉ាលីស្ស លោក ហេង នាថមុនី និង លោក Colin Poole នៅឆ្នាំ១៩៩៨
- សារធាតុ POPs ទាំង ១០ ប្រភេទថ្មីនៃអនុសញ្ញាស្តុកខូម៖ រៀនរៀងដោយផ្នែកគម្រោងពង្រឹងសមត្ថភាព រៀបចំបច្ចុប្បន្នភាពព័ត៌មានផែនការអនុវត្តជាតិ នៃនាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន ក្រសួងបរិស្ថាន
- សៀវភៅទិន្នន័យឃុំឆ្នាំ ២០១៦
- សេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាលស្តីពីគោលនយោបាយដីធ្លី ឆ្នាំ២០០៩
- អនុក្រឹត្យស្តីពីការកែសម្រួលអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច ឆ្នាំ២០០៨
- អង្គការ IUCN (International Union for Conservation of Nature) ស្តីអំពីការកំណត់ចំណាត់ថ្នាក់ប្រភេទសត្វព្រៃនៅក្នុងពិភពលោក
- អនុក្រឹត្យស្តីពីការកំណត់ប្រភេទផល ផលិតផលជលផលដែលកំពុងរងគ្រោះថ្នាំ ឆ្នាំ២០០៩
- អនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ ឆ្នាំ២០០៥
- អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ ឆ្នាំ២០០៧
- អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង ឆ្នាំ១៩៩៩
- អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង ឆ្នាំ២០០០
- អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹក ឆ្នាំ១៩៩៩
- អនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឆ្នាំ១៩៩៩
- អនុក្រឹត្យស្តីពីដីសម្បទានសេដ្ឋកិច្ច ឆ្នាំ២០០៥
- អនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច ឆ្នាំ២០០៣
- អនុក្រឹត្យលេខ ១២៣ អនក្របក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីអំពីការកំណត់ប្រភេទជលផល . នៅកម្ពុជា របស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ
- អនុក្រឹត្យលេខ ៥៣ អនក្រ បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០៦.ស្តីអំពីការធ្វើពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពងរងគ្រោះថ្នាក់)CITES: Convention on International Trade Endangered Species of Wild Fauna and Flora (

Boardman, A.E, Greenberg, D.H, Vining, A.R & Weimer, D.L (Eds.). 2006. *Cost-Benefit Analysis: Concepts and Practice* (Third ed.) New Jersey, USA: Pearson Education, Inc.

Brander, L. 2013. Guidance Manual on Value Transfer Methods for Ecosystem Services. United Nations Environment Programme (UNEP), Publishing Services Section, UNON, Bairobi-Kenya. Available: http://www.gwp.org/Global/ToolBox/References/Guidance%20Manual%20on%20Value%20Transfer%20Methods%20for%20Ecosystem%20Services%20(UNEP,%202013).pdf

Burt, R. 2004. Soil Survey Laboratory Methods Manual: Soil Survey Investigations Report No. 42 Version 4.0 November 2004. United States Department of Agriculture. 735 pages. Avalable: http://mazinger.sisib.uchile.cl/repositorio/lb/ciencias_agronomicas/u20084111111ssir_42_v4.pdf

Cambodia Database. 2014. Commune Data. http://db.ncdd.gov.kh/cdbonline (Accessed on February 26th, 2014)

Cambodia REDD+ Secretariat, 2014. Valuation of Forest Ecosystems in Cambodia (Lessons Learned), *REDD+ Cambodia.* Available: http://www.cambodia-redd.org/wp-content/uploads/2014/07/11-Information-on-forest-valuation-in-Cambodia.pdf

CARDI, Undated. Soil Types GIS Dataset. Cambodian Agricultural Research and Development Institute (from Crocker, 1962). Phnom Penh, Cambodia.

Cornell Waste Management Institute, 2004. Compost quality fact sheet #4: Testing Composts. Available: http://www.manuremanagement.cornell.edu/Pages/General_Docs/Fact_Sheets/compostfs4.pdf

Cornell Waste Management Institute, 2010. Contaminants in Soils: An Overview of Key Topics. Available: http://cwmi.css.cornell.edu/soil_contaminants_overview.pdf

Crocker CD. 1962. The general soil map of the Kingdom of Cambodia and the exploratory survey of the soils of Cambodia. Joint publication. Phnom Penh (Cambodia): Royal Cambodian Government Soil Commission/USAID.

FA, (n.d). Forest Cover 2002 2006 and 2010 GIS Dataset. Forest Administration. Phnom Penh, Cambodia.

FA, June 2004, Inventory Handbook

FAO, 2003 .GIS Data sources.

Guo, Z., Xiao, X., Gan, Y. and Zheng, Y. (2001), Ecosystem functions, services, and their values – a case study in Xingshan County, China. *Ecological Economics* 38 (1): 141-154.

Hansen, K and Top, N. (2006) "Natural Forest Benefits and Economic Analysis of Natural Forest Conversion in Cambodia". Cambodia Development Resource Institute (CDRI): Working Paper 3. ISSN 1560-9197 / ISBN-13: 978-99950-52-14-0. Available: http://www.cdri.org.kh/webdata/download/wp/wp33e.pdf

IPCC Fourth Assessment Report: Climate Change 2007. Available: http://www.ipcc.ch/publications_and_data/ar4/syr/en/figure-spm-3.html

JICA, 2005. Land Use 2002 GIS Dataset. Japan International Cooperation Agency. Phnom Penh, Cambodia.

Draft

June 2004, Forest Planning Handbook

Kapos, V., Ravilious, C., Leng, C., Bertzky, M., Osti, M., Clements, T., Dickson, B (2010) *Carbon, biodiversity and ecosystem services: Exploring co-benefits.* Cambodia. UNEP-WCMC, Cambridge, UK. Available: file:///C:/Users/DELL/Downloads/Cambodia_report_100924_FINAL%20(1).pdf

Kemker, C., 2013 "Dissolved Oxygen." *Fundamentals of Environmental Measurements.* Fondriest Environmental, Inc. 19 Nov. 2013. Available: http://www.fondriest.com/ environmental-measurements/parameters/water-quality/dissolved-oxygen/.

Luch, Likanan. 2012. "A Role of Remittances for Smoothing Variations in Household Income in Rural Cambodia." The Journal of Rural Problems 48 (2): 10-21.

MAFF, (n.d). Forest Cover 2002 GIS Dataset. Ministry of Agriculture, Forestry and Fisheries. Phnom Penh, Cambodia.

MAFF, Undated. Soil Fertility GIS Dataset. Ministry of Agriculture, Forestry and Fisheries. Phnom Penh, Cambodia.

Millennium Ecosystem Assessment. 2005. Ecosystems and Human Well-being: Synthesis. Washington, DC. Island Press.

MIME, Undated. Geology GIS Dataset. Ministry of Industry, Mines and Energy. Phnom Penh, Cambodia.

Ministry of Agriculture, Forestry and Fisheries, 2010. Soil Classification.

MoP, 2009. Administrative GIS Dataset. Ministry of Planning. Phnom Penh, Cambodia.

MRC (Mekong River Commission), 1992-93 & 1996-97. GIS Dataset.

NIS. 2014. NIS: CSES Table 2013. Accessed 3 18, 2015. http://www.nis.gov.kh/index.php/en/find-statistic/social-statistics/cses/cses-tables.html.

Open Development Cambodia, Undated. Community Fishery GIS Dataset. Phnom Penh, Cambodia. http://www.opendevelopmentcambodia.net (Accessed on February 26th, 2014)

Open Development Cambodia, Undated. Soil Type GIS Dataset. Phnom Penh, Cambodia. http://www.opendevelopmentcambodia.net (Accessed on February 26th, 2014)

Roongtawanreongsri, S., Sawangchote, P., Bumrungsri, S. and Suksaroj, C., 2014. "Economic Benefits of Management Options for Kho Hong Hill, South Thailand". *WorldFish (ICLARM) – Economy and Environment Program for Southeast Asia (EEPSEA)*, Philippines, Available: http://www.eepsea.org/pub/rr/2014-RR11_Saowalak,etal_web.pdf

Draft

Updated National Implementation Plan for the Stockholm Convention with its Associated Action Plans for all 22 POPs. (2015). Project Coordination Unit, Review and Update of the National Implementation Plan for the Stockholm Convention on POPs in the Kingdom of Cambodia.

Yamane, Taro. 1967. Statistics: An Introductory Analysis, 2nd Ed., New York: Harper and Row.

Yem, D., Top, N. and Lic, V., 2011. "Rubber Plantation Development in Cambodia: At What Cost?" Cambodia Development Resource Institute (CDRI). Available: https://surumer.uni-hohenheim.de/fileadmin/einrichtungen/surumer/Rubber_Plantation_Development_in_Cambodia.pdf

Brander, Luke, Roy Brouwer, and Alfred Wagtendonk. 2013. "Economic valuation of regulating services provided by wetlands in agricultural landscapes: A meta-analysis." *Ecological engineering* no. 56:89-96.

Burt, Rebecca. 2004. Soil Survey Laboratory Methods Manual: Soil Survey Investigations. Report No. 42. United States Department of Agriculture.

CWMI. 2009. Testing Composts, Compost Quality Fact Sheet Vol. 4. http://cwmi.css.cornell.edu/soilquality.htm: Cornell Waste Managment Institute, Cornell University.

Keller, Gerald, ed. 2005. *Statistics for Management and Economics*. 7th ed. USA: Thomson South-Western.

Peres, Carlos A. 1999. "General guidelines for standardizing line-transect surveys of tropical forest primates." *Neotropical primates* no. 7 (1):11-16.

Robson, C, ed. 2002. *Real World Research, 2nd edn.* UK: Blackwell Publishing.

Yamane, Taro. 1967. *Elementary sampling theory*. Englewood Cliffs, N.J.: Prentice-Hall.

Draft

# ឧបសម្ព័ន្ធ៖
# ឯកសារពាក់ព័ន្ធនឹងក្រុមហ៊ុន

Draft

Payment Receipt

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
អគ្គនាយកដ្ឋានពន្ធដារ
GENERAL DEPARTMENT OF TAXATION
លេខ/ N° PTM2017036075 អពជ



# ប័ណ្ណពន្ធប៉ាតង់ ឆ្នាំ ២០១៧
## អ្នកជាប់ពន្ធមធ្យម

ឈ្មោះសហគ្រាស៖ អេស ខេ ផ្លេនថេសិន (ខេមបូឌា) ភីធីអ៊ី អិលធីឌី
លេខអត្តសញ្ញាណកម្មសារពើពន្ធ៖ K002-107011387
ចុះបញ្ជីនៅ៖ អគ្គនាយកដ្ឋានពន្ធដារ ស្ថិតនៅក្រោមការគ្រប់គ្រង៖ សាខាពន្ធដារខណ្ឌចំការមន
ទម្រង់ទ្រាយសហគ្រាស៖ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត
សកម្មភាពអាជីវកម្មបន្ទាប់បន្សំ៖ កសិកម្ម (ដាំដុះដំណាំកាកាវ ដូង និងអាកាស្យា...)
អាសយដ្ឋានសហគ្រាស៖ #១៩៩E១ ផ្លូវ ៦៣ កែងផ្លូវ ៣០៦ សង្កាត់ បឹងកេងកងទី ១ ខណ្ឌ ចំការមន រាជធានីភ្នំពេញ
ឈ្មោះម្ចាស់សហគ្រាស៖ SURENDRA KUMAR PODDAR សញ្ជាតិ៖ ឥណ្ឌា

លេខ: 3291 ល.ប
បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម។
រាជធានីភ្នំពេញ, ថ្ងៃទី 30 MAR 2017
ត.ប អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ
នាយករងរដ្ឋបាល
ហុក_ហួលីម

**PATENT TAX 2017**
Medium Taxpayer

Company's name : **SK PLANTATION (CAMBODIA) PTE. LTD.**
Tax Identification Number (TIN) : K002-107011387
Registered at : General Department of Taxation Under : CHAMKAR MON TAX BRANCH
Additional bussiness activity(ies) : Agriculture (theobroma cocoa, cocos nucifera and gum arabic plantation)
Forms of business : Private limited company
Owner's name : **SURENDRA KUMAR PODDAR** Nationality: Indian

ទឹកប្រាក់ពន្ធប៉ាតង់ ២០១៧
១.២០០.០០០ រៀល

លេខ SN : 000435218

អគ្គនាយកដ្ឋានពន្ធដារ
General Department of Taxation
បោះពុម្ពដោយ / Printed by
ធនាគារ អេស៊ីលីដា / ACLEDA Bank Plc.

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែមីនា ឆ្នាំ២០១៧
Phnom Penh, 21 March 2017

បញ្ជាក់ ៖ ប័ណ្ណប៉ាតង់នេះត្រូវដាក់តាំង ឬព្យួរ នៅទីកន្លែងប្រកបអាជីវកម្ម។
Note : This patent tax must be hanged or displayed at the company's office.

Draft

Payment Receipt

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
អគ្គនាយកដ្ឋានពន្ធដារ
GENERAL DEPARTMENT OF TAXATION
លេខ/ N° PTM2017036075 អពដ



# ប័ណ្ណពន្ធប៉ាតង់ ឆ្នាំ ២០១៧
## អ្នកជាប់ពន្ធមធ្យម

ឈ្មោះសហគ្រាស៖ អេស ខេ ផ្លេនថេសិន (ខេមបូឌា) ភីធីអ៊ី អិលធីឌី
លេខអត្តសញ្ញាណកម្មសារពើពន្ធ៖ K002-107011387
ចុះបញ្ជីនៅ៖ អគ្គនាយកដ្ឋានពន្ធដារ ស្ថិតនៅក្រោមការគ្រប់គ្រង៖ សាខាពន្ធដារខណ្ឌចំការមន
ទម្រង់គតិយុត្តសហគ្រាស៖ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត
សកម្មភាពអាជីវកម្មបន្ទាប់បន្សំ៖ កសិកម្ម (ដាំដុះដំណាំកាកាវ ដូង និងអាកាស្យាសេណេហ្គាល់)
អាសយដ្ឋានសហគ្រាស៖ #១៩៩E១ ផ្លូវ ៦៣ កែងផ្លូវ ៣០៦ សង្កាត់ បឹងកេងកងទី ១ ខណ្ឌ ចំការមន រាជធានីភ្នំពេញ
ឈ្មោះម្ចាស់សហគ្រាស៖ SURENDRA KUMAR PODDAR សញ្ជាតិ៖ ឥណ្ឌា

លេខ: 3008 ... ល.ប
ត្រឹមត្រូវតាមច្បាប់ដើម។
24 MAR 2017

**PATENT TAX 2017**
Medium Taxpayer

Company's name : **SK PLANTATION (CAMBODIA) PTE. LTD.**
Tax Identification Number (TIN) : K002-107011387
Registered at : General Department of Taxation Under : CHAMKAR MON TAX BRANCH
Additional bussiness activity(ies) : Agriculture (theobroma cocoa, cocos nucifera and gum arabic plantation)
Forms of business : Private limited company
Owner's name : **SURENDRA KUMAR PODDAR** Nationality: Indian

ហ៊ុក-ហ៊ុលីម

ទឹកប្រាក់ពន្ធប៉ាតង់ ២០១៧
១.២០០.០០០ រៀល
លេខ SN : 000435218

អគ្គនាយកដ្ឋានពន្ធដារ
General Department of Taxation
បោះពុម្ពដោយ Print
ធនាគារ អេស៊ីលីដា ភីអិលស៊ី
ACLEDA Bank Plc.

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែមីនា ឆ្នាំ២០១៧
Phnom Penh, 21 March 2017

បញ្ជាក់ ៖ ប័ណ្ណប៉ាតង់នេះត្រូវដាក់តាំង ឬព្យួរ នៅទីកន្លែងប្រកបអាជីវកម្ម។
Note : This patent tax must be hanged or displayed at the company's office.

New

# លក្ខន្តិកៈក្រុមហ៊ុន

# MEMORANDUM AND ARTICLES OF ASSOCIATION

## អេស ខេ ផ្លេនថេសិន (ខេមបូឌា) ភីធីអ៊ី អិលធីឌី

## SK PLANTATION (CAMBODIA) PTE. LTD.

Draft

K PLANTATION (CAMBODIA) PTE. LTD.

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត-ដើមទុន ២០០,០០០,០០០ រៀល

## លក្ខន្តិកៈ

# ក្រុមហ៊ុន អេស ខេ ផ្លេនថេសិន (ខេមបូឌា) ភីធីអ៊ី អិលធីឌី

## ARTICCLES OF INCORPORATION

## Of

## SK PLANTATION (CAMBODIA) PTE. LTD.

**ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត**

**ដើមទុន : ២០០,០០០,០០០ រៀល**

ក្រសួងពាណិជ្ជកម្ម
នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម
ជំពូក ... ចូលទុកលេខ: 00003485
កាលបរិច្ឆេទតម្កល់: 26.04.2016 ម៉ោង 14"20'
លក្ខណ... មន្ត្រីផ្ទៀងផ្ទាត់:...

១. **នាមករណ៍ក្រុមហ៊ុន** : ឈ្មោះក្រុមហ៊ុនជាភាសាខ្មែរគឺ **ក្រុមហ៊ុន អេស ខេ ផ្លេនថេសិន (ខេមបូឌា) ភីធីអ៊ី អិលធីឌី** និងឈ្មោះជាភាសាអង់គ្លេសគឺSK Plantation (Cambodia) Pte.Ltd.(ពីនេះតទៅហៅថា "**ក្រុមហ៊ុន**")។

២. **ទម្រង់ក្រុមហ៊ុន** : ក្រុមហ៊ុននេះជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត ដែលបានបង្កើតឡើងក្រោមច្បាប់ពាណិជ្ជកម្មរបស់ព្រះរាជាណាចក្រកម្ពុជា។

៣. **កម្មវត្ថុអាជីវកម្ម** : កម្មវត្ថុអាជីវកម្មរបស់ក្រុមហ៊ុនរួមមាន:

- វិនិយោគលើវិស័យកសិកម្ម : ការដាំដំណាំ ចិញ្ចឹមសត្វ អភិវឌ្ឍន៍ និងធ្វើប្រតិបត្តិការដាំដំណាំ។
- ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ អាហារណ នីហារណ ទំនិញគ្រប់ប្រភេទ-នាំចូលឱសថ សំភារៈបរិក្ខារពេទ្យ គ្រប់ប្រភេទ។
- ការជួលដាក់ឃ្លាំងនូវផលិតផលទំនិញគ្រប់ប្រភេទការជួលសំភារៈទំនិញគ្រប់ប្រភេទ។



Upoddar.

អេស ខេ ផ្លេនថេសិន (ខេមបូឌា) ភីធីអ៊ី អិលធីឌី
S K PLANTATION (CAMBODIA) PTE. LTD.

- ប្តូរប្រាក់ ផលិតផល ទិញលក់គ្រឿងអលង្ការ។
- មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ។
- បើកសាលារៀន។
- ភ្នាក់ងារពាណិជ្ជកម្ម-តំណាងពាណិជ្ជកម្ម។
- សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុពាណិជ្ជកម្ម។
- បោះពុម្ពផ្សាយ។
- ផលិតខ្សែភាពយន្ត វីដេអូស៊ីឌី។
- ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស សេវាបញ្ជូន និងចែកចាយទំនិញ។
- សាងសង់ ជួសជុល អាគារ ស្ពាន ផ្លូវ។
- ទេសចរណ៍ សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត។
- វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ-សិប្បកម្ម។
- ចូលរួមក្នុងសកម្មភាពពាណិជ្ជកម្មស្របច្បាប់ដែលទាក់ទងនឹងកម្មវត្ថុអាជីវកម្មដែលបាន ពោលខាងលើ។
- ចូលរួមជាមួយក្រុមហ៊ុនដែលមានស្រាប់ ឬទើបបង្កើតថ្មី ហើយដែលជាក្រុមហ៊ុន មានការទាក់ទងដោយផ្ទាល់ក្តី ឬមិនផ្ទាល់ក្តីទៅនឹងកម្មវត្ថុអាជីវកម្មរបស់ក្រុមហ៊ុន រួមទាំងការ ចូលរួម បង្កើតក្រុមហ៊ុនថ្មី និងចូលរួមក្នុងសកម្មភាពសហប្រតិបត្តិការផ្សេងៗ ដើម្បីធ្វើឱ្យ កម្មវត្ថុអាជីវកម្មខាងលើរីកចំរើន។

៤. **ទីស្នាក់ការចុះបញ្ជី:** លេខ ១៩៩E1 ផ្លូវលេខ ៦៣ កែងផ្លូវលេខ ៣០៦ សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

៥. **រយៈពេល** :រយៈពេលនៃក្រុមហ៊ុនគឺពុំមានការកំណត់ ដោយចាប់ផ្តើមពីថ្ងៃចុះបញ្ជីនៅ ក្រសួងពាណិជ្ជកម្មក្នុងព្រះរាជាណាចក្រកម្ពុជា។

ក្រុមហ៊ុនត្រូវបញ្ចប់តាមសេចក្តីសំរេចរបស់ម្ចាស់ភាពហ៊ុនយោងតាមច្បាប់ដែលនៅ

ជាធរមាន។



U Poddar

K PLANTATION (CAMBODIA) PTE LTD

Draft

## ឧបសម្ព័ន្ធ ២

## ដើមទុន ភាគហ៊ុន និង ម្ចាស់ភាគហ៊ុន

៦. **ភាគហ៊ុន និង ដើមទុនភាគហ៊ុន** :ដើមទុនចុះបញ្ជីដំបូងសរុបរបស់ក្រុមហ៊ុនមានចំនួន ២០០.០០០.០០០រៀល (ពីររយលានរៀល) ចែកជា ៥០.០០០ (ប្រាំម៉ឺន) ភាគហ៊ុន ដែលភាគហ៊ុននីមួយៗមានតម្លៃចារឹកលើប័ណ្ណចំនួន ៤.០០០ (បួនពាន់) រៀល។ភាគហ៊ុន នៃ ដើមទុន នេះត្រូវទិញយកទាំងអស់ និងបង់ឱ្យគ្រប់ចំនួនទៅតាម ការតំរូវនៃ ច្បាប់កម្ពុជា។

៧. **ម្ចាស់ភាគហ៊ុន និង ការកាន់កាប់ភាគហ៊ុន** :ឈ្មោះ និងអាសយដ្ឋានម្ចាស់ភាគហ៊ុន របស់ភាគហ៊ុន។ ("**ម្ចាស់ភាគហ៊ុន**") គឺ:

ក- ក្រុមហ៊ុន SK PLANTATION PTE. LTD. ជាក្រុមហ៊ុនឯកជនទទួលខុស ត្រូវមានកំរិត ដែលបានបង្កើតឡើងក្រោមច្បាប់របស់សាំងហ្គាពួរ មានអត្តលេខចុះ បញ្ជីលេខ 200801110K ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៨ ដែលមានអាសយដ្ឋាន ចុះបញ្ជីនៅ 1, North Bridge Road, #18-07 High Street Centre, Singapore 179094 កាន់កាប់ភាគហ៊ុនចំនួន ៤៩៥០០ ភាគហ៊ុនត្រូវជា ៩៩% នៃភាគហ៊ុនទាំងអស់ក្នុង ក្រុមហ៊ុន ដែលតំណាងដោយ លោក SURENDRA KUMAR PODDAR ជាពលរដ្ឋឥណ្ឌា កាន់លិខិតឆ្លងដែនឥណ្ឌាលេខ K7996826 ចេញថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១២ និងជាពលរដ្ឋស្នាក់នៅអចិន្ត្រៃយ៍នៅប្រទេសសិង្ហបុរី ដែលមានលេខអត្តសញ្ញាណប័ណ្ណ សាំងហ្គាពួរ លេខ S89721671ស្នាក់នៅ 193 Meyer Road, #05-08, Aalto, Singapore 437981។

ខ-លោក SURENDRA KUMAR PODDAR ជាពលរដ្ឋឥណ្ឌា កាន់លិខិតឆ្លងដែន ឥណ្ឌាលេខ K7996826 ចេញថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១២ និងជាពលរដ្ឋស្នាក់ នៅអចិន្ត្រៃយ៍ នៅប្រទេសសិង្ហបុរី ដែលមានលេខអត្តសញ្ញាណប័ណ្ណសាំងហ្គាពួរ លេខ S89721671 ស្នាក់នៅ 193 Meyer Road, #05-08, Aalto, Singapore 437981 កាន់កាប់ ភាគហ៊ុនចំនួន ៥០០ ភាគហ៊ុនត្រូវជា ១% នៃភាគហ៊ុនទាំងអស់ក្នុងក្រុមហ៊ុន ។



S K PLANTATION (CAMBODIA) PTE. LTD.

Draft

៨. **វិញ្ញាបនប័ត្រភាគហ៊ុន** :ភាគហ៊ុនទាំងឡាយរបស់ក្រុមហ៊ុន ត្រូវចុះក្នុងវិញ្ញាបនប័ត្រភាគហ៊ុនដែលមានឈ្មោះត្រាផ្លូវការរបស់ក្រុមហ៊ុន និងហត្ថលេខានៃអភិបាលយ៉ាងតិច ១ (មួយ) រូប ត្រូវបោះ និងចុះលើវិញ្ញាបនប័ត្រនីមួយៗ។ វិញ្ញាបនប័ត្រភាគហ៊ុន ត្រូវបញ្ជាក់ពីថ្នាក់របស់ភាគហ៊ុន និងកិច្ចព្រមព្រៀងម្ចាស់ភាគហ៊ុនទាក់ទងនឹងភាគហ៊ុនប្រសិនបើមាន។

៩. **សៀវភៅបញ្ជីភាគហ៊ុន**:ក្រុមហ៊ុនត្រូវរក្សាបញ្ជីម្ចាស់ភាគហ៊ុនជាលាយលក្ខណ៍ អក្សរនៅក្នុង "**សៀវភៅបញ្ជីភាគហ៊ុន**"សៀវភៅបញ្ជីភាគហ៊ុន ត្រូវកត់ត្រាចំណុចពិសេសរបស់ ម្ចាស់ ភាគហ៊ុន និង ការផ្ទេរការដាក់បន្ទុកនិងការកែប្រែណាមួយលើភាគហ៊ុន។ មានតែបុគ្គល ឬអង្គភាពដែលបានចុះបញ្ជីជាម្ចាស់ភាគហ៊ុននៅក្នុងសៀវភៅបញ្ជីភាគហ៊ុនប៉ុណ្ណោះ ទើបជាម្ចាស់ភាគហ៊ុនរបស់ក្រុមហ៊ុន។

១០. **នីតិវិធីផ្ទេរ**:រាល់ការផ្ទេរភាគហ៊ុន ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងត្រូវចុះហត្ថលេខាដោយអ្នកផ្ទេរនិងអ្នកទទួល។
អ្នកផ្ទេរត្រូវចាត់ទុកថានៅតែជាអ្នកកាន់កាប់ភាគហ៊ុនដដែលរហូតទាល់តែរាល់ពត៌មានចាំបាច់ទាំងអស់អំពីអ្នកទទួលការផ្ទេរ និងភាគហ៊ុនដែលបានផ្ទេរត្រូវបាន កត់ត្រាចូលក្នុងសៀវភៅបញ្ជីភាគហ៊ុនរួច រាល់ការផ្ទេរភាគហ៊ុនទាំងអស់ ត្រូវចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម មុននឹងចូលជាធរមាន។

១១.**ភារកិច្ចអ្នកទទួលភាគហ៊ុន**:អ្នកផ្ទេរត្រូវធ្វើយ៉ាងណាអោយអ្នកទទួលយកការផ្ទេរនោះយល់ព្រមជាលាយលក្ខណ៍អក្សរក្រោយបានច្បាស់លាស់ថា នឹងទទួលយកភារកិច្ចដែលមាននៅក្នុងលក្ខន្តិកៈក្រុមហ៊ុន និងកិច្ចព្រមព្រៀងដទៃទៀតដែលបានចុះហត្ថលេខារវាងបណ្តាម្ចាស់ភាគហ៊ុន។

Draft

## ជំពូក ៣

## មហាសន្និបាតម្ចាស់ភាគហ៊ុន

១២. **មហាសន្និបាត** :មហាសន្និបាតម្ចាស់ភាគហ៊ុនត្រូវប្រព្រឹត្តិធ្វើឡើងនៅក្នុងរយៈពេល ១២ (ដប់ពីរ) ខែគិតចាប់ពីកាលបរិច្ឆេទចុះបញ្ជីក្រុមហ៊ុនមក និងយ៉ាងហោចណាស់ធ្វើឡើងនៅរៀងរាល់ ១២ (ដប់ពីរ) ខែម្តង។ រាល់មហាសន្និបាតម្ចាស់ភាគហ៊ុនត្រូវប្រព្រឹត្តិធ្វើឡើង



PLANTATION (CAMBODIA) PTE. LTD.

នៅការិយាល័យចុះបញ្ជីរបស់ក្រុមហ៊ុន ឬទីកន្លែងទាំងឡាយណាដែលស្ថិតនៅក្នុង ឬក្រៅប្រទេសកម្ពុជាដែលម្ចាស់ភាគហ៊ុនបានបោះឆ្នោតសំរេចជាឯកច្ឆ័ន។

១៣. **សេចក្ដីជូនដំណឹង** :យ៉ាងហោចណាស់ ២០ (ម្ភៃ) ថ្ងៃមុនមហាសន្និបាតនិមួយៗ សេចក្ដីជូនដំណឹងត្រូវផ្ដល់ជូនទៅរាល់ម្ចាស់ភាគហ៊ុនដែលមានចុះឈ្មោះក្នុងសៀវភៅ បញ្ជីភាគហ៊ុន។

សេចក្ដីជូនដំណឹងត្រូវផ្ដល់ជូនទៅរាល់ម្ចាស់ភាគហ៊ុនតាមការប្រគល់ដល់ដៃដែលមានកត់ត្រាទុកតាមប៉ុស្តិ៍ តាមទូរសារ ឬតាមអ៊ីម៉ែល យោងទៅតាមសភាពជាក់ស្ដែង។ សេចក្ដីជូនដំណឹងត្រូវបញ្ជាក់ពីទីកន្លែង ថ្ងៃ និងម៉ោងប្រជុំ ព្រមទាំងប្រភេទការងារជំនួញ ដែលត្រូវពិភាក្សានាពេលនោះ។

ពេលចូលរួមក្នុងមហាសន្និបាតត្រូវចាត់ទុកជាការបោះបង់សិទ្ធិចំពោះសេចក្ដីជូនដំណឹង។

១៤.**គោលបំណងមហាសន្និបាត**:មហាសន្និបាតម្ចាស់ភាគហ៊ុនត្រូវធ្វើឡើងក្នុងគោលបំណងពិនិត្យឡើងវិញនូវដំណើការអាជីវកម្មជាទូទៅរបស់ក្រុមហ៊ុន និងគោលបំណងផ្សេងទៀតដែលតំរូវដោយច្បាប់ យោងទៅតាមការសំរេចរបស់ក្រុមប្រឹក្សាភិបាល។

១៥. **ចំនួនកូរ៉ុម** :រាល់មហាសន្និបាត ចំនួនកូរ៉ុមត្រូវមានម្ចាស់ភាគហ៊ុន ឬតំណាងរបស់គេដែលកាន់កាប់ភាគហ៊ុនភាគច្រើនរបស់ក្រុមហ៊ុន។

១៦. **សេចក្ដីសំរេច** :ការសំរេចរបស់ម្ចាស់ភាគហ៊ុនត្រូវភ្ជាប់កាតព្វកិច្ចលើក្រុមហ៊ុន លុះត្រាតែការសំរេចនោះធ្វើឡើងតាមសេចក្ដីសំរេចរបស់ម្ចាស់ភាគហ៊ុន។

រាល់សេចក្ដីសំរេចរបស់ម្ចាស់ភាគហ៊ុនតំរូវអោយមានសំលេងឆ្នោតវិជ្ជមានចំនួនភាគច្រើននៃហ៊ុនទាំងអស់ដែលក្រុមហ៊ុនបានបោះចេញ។

ពុំមានសេចក្ដីសំរេចរបស់ម្ចាស់ភាគហ៊ុនត្រូវភ្ជាប់កាតព្វកិច្ចមកលើក្រុមហ៊ុនទេ

វៀរលេងសេចក្ដីសំរេចនោះត្រូវបានអនុម័តតាមរបៀបខាងលើនេះ។

ម្ចាស់ភាគហ៊ុនអាចអនុម័តសេចក្ដីសំរេចដោយមិនចាំបាច់មានការប្រជុំ។

សេចក្ដីសំរេចបែបនេះត្រូវមានសុពលភាពនឹងមានប្រសិទ្ធិភាពអនុវត្តដូចគ្នានឹងសេចក្ដីសំរេចដែលត្រូវបានអនុម័តនៅឯកិច្ចប្រជុំម្ចាស់ភាគហ៊ុនដែរ ប្រសិន បើសេចក្ដីសំរេច

Draft



K PLANTATION (CAMBODIA) PTE LTD.

នោះត្រូវបានចុះហត្ថលេខាដោយម្ចាស់ភាគហ៊ុនទាំងអស់ឬអ្នកតំណាង។ ហត្ថលេខា របស់ម្ចាស់ភាគហ៊ុនទាំងអស់អាចធ្វើនៅលើឯកសារតែមួយ ឬអាចនៅលើឯកសារច្រើន ដូចៗគ្នា។ សំរាប់គោលបំណងនៃប្រកាសនេះពាក្យថា "ជាលាយលក្ខណ៍អក្សរ" និង "ចុះហត្ថលេខា" គឺរាប់បញ្ចូលទាំងការយល់ព្រមដោយផ្ញើរតាម តេឡិច ទូរសារ Cable ទូរលេខ ឬអ៊ីម៉ែល។ សេចក្តីសំរេចដែលមានចុះហត្ថលេខាត្រឹមត្រូវនោះ ត្រូវប្រគល់ជូនប្រធាន ហើយដាក់ចូលក្នុងសៀវភៅកំណត់ហេតុរបស់ក្រុមហ៊ុន។

១៧. **អ្នកតំណាង**: ម្ចាស់ភាគហ៊ុនអាចបោះឆ្នោតតាមរយៈអ្នកតំណាងបាន អោយតែសិទ្ធិអំណាចដែលប្រគល់ជូនអ្នកតំណាងនោះបានត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ។ ឯកសារតែងតាំងអ្នកតំណាងត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយម្ចាស់ភាគហ៊ុននោះ ហើយត្រូវមានចំណុចពិសេសខាងក្រោមនេះ :

១៧.១ ចំនួនហ៊ុនកាន់កាប់ដោយម្ចាស់ភាគហ៊ុននោះ។

១៧.២ ឈ្មោះនិងអាសយដ្ឋានពេញលេញរបស់អ្នកតំណាង និង

១៨.៣ កិច្ចប្រជុំមួយ ឬច្រើន ឬរយៈពេលដែលអ្នកតំណាងបានត្រូវតែងតាំង។

១៨. **ការដាក់តំកល់ឯកសាររបស់អ្នកតំណាង** :ប្រសិនបើអ្នកតំណាងស្នើសុំបោះឆ្នោតនៅពេលប្រជុំឯកសារតែងតាំងអ្នកតំណាងត្រូវដាក់ជូនប្រធានក្រុមប្រឹក្សាភិបាលនៅពេល ឬមុនពេលចាប់ផ្តើមកិច្ចប្រជុំ។

Draft

១៩. **សិទ្ធិបោះឆ្នោត** : ក្នុងការបោះឆ្នោតនៅមហាសន្និបាត ម្ចាស់ភាគហ៊ុនម្នាក់ៗត្រូវមានសំលេងឆ្នោតមួយសំរាប់ភាគហ៊ុននីមួយៗដែលខ្លួនកាន់កាប់។
មានតែម្ចាស់ភាគហ៊ុនដែលបានចុះបញ្ជីត្រឹមត្រូវ និងបានបង់ប្រាក់គ្រប់ចំនួនអោយ ទៅក្រុមហ៊ុនតាមចំនួនហ៊ុនរបស់ខ្លួនទេ ទើបមានសិទ្ធិបោះឆ្នោតដោយខ្លួនឯង ឬដោយអ្នកតំណាងក្នុងមហាសន្និបាត។

២០. **ប្រធាន** :ប្រធានក្រុមប្រឹក្សាភិបាលត្រូវធ្វើជាអធិបតីនៅរាល់មហាសន្និបាត។ ប្រសិនបើពុំមានប្រធានទេ ឬប្រសិនបើប្រធានអវត្តមានក្នុងរយៈពេល ១៥ (ដប់ប្រាំ) នាទី ក្រោយពី



K PLANTATION (CAMBODIA)

ម៉ោងណាត់បើកកិច្ចប្រជុំនោះម្ចាស់ភាគហ៊ុន មានវត្តមាននាពេលនោះអាចជ្រើសតាំងអភិបាលមួយរូបឱ្យធ្វើជាប្រធាន។ ប្រសិនពុំមានវត្តមានអភិបាលដើម្បីជ្រើសរើសប្រធានបានទេកិច្ចប្រជុំនោះត្រូវរំសាយចោល។

ប្រធានមិនត្រូវបោះឆ្នោតទេលើកលែងតែប្រធាននោះកាន់សិទ្ធិតំណាងម្ចាស់ភាគហ៊ុនណាម្នាក់ ឬក៏ជាម្ចាស់ភាគហ៊ុន។ ក្នុងករណីណាក៏ដោយ ប្រធានមិនត្រូវមានសំលេង ឆ្នោតឧត្តមានុភាពឡើយ។

## ជំពូក ៤

## អភិបាល

២១. **ក្រុមប្រឹក្សាភិបាល** :ក្រុមហ៊ុនត្រូវគ្រប់គ្រងដោយក្រុមប្រឹក្សាភិបាល។
ក្រុមប្រឹក្សាភិបាលត្រូវមានអភិបាលចំនួន ២ (ពីរ) រូប។
ក្រុមប្រឹក្សាភិបាលពុំចាំបាច់ជាម្ចាស់ភាគហ៊ុនទេ។

២២. **អភិបាល** :ឈ្មោះ និងអាស័យដ្ឋានរបស់អភិបាលដំបូង គឺ :

ប្រធានក្រុមប្រឹក្សាភិបាល : លោក SURENDRA KUMAR PODDAR ជាពលរដ្ឋឥណ្ឌាកាន់លិខិតឆ្លងដែនឥណ្ឌាលេខ K7996826 ចេញថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១២ និងជាពលរដ្ឋស្នាក់នៅអចិន្ត្រៃយ៍នៅប្រទេសសិង្ហបុរីដែលមានលេខអត្តសញ្ញាណប័ណ្ណសាំងហ្គាពួរលេខ S89721671 ស្នាក់នៅ 193 Meyer Road, #05-08, Aalto, Singapore 437981

អភិបាល : លោក NARAYAN PODDAR ជាពលរដ្ឋឥណ្ឌាកាន់លិខិតឆ្លងដែន ឥណ្ឌាលេខ H7613614 ចេញថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០០៩ ស្នាក់នៅ Club Town Enclave Atghara Block South Flat 2E, 20 Chinarpark Kolkata 59, India ។

Draft



K PLANTATION (CAMBODIA) PTE LTD.

Wpoddar.

២៣. **ការដកអភិបាល និង កន្លែងទំនេរ**:ម្ចាស់ភាគហ៊ុនមានសិទ្ធិដកអភិបាលចេញ ពេលណាក៏បានដោយមាន ឬគ្មានមូលហេតុ។ ប្រសិនបើក្នុងក្រុមប្រឹក្សាភិបាល មានតំណែងទំនេរមុនដំណាច់អាណត្តិរបស់អភិបាលពីព្រោះតែការដកចេញ ឬដោយមូលហេតុផ្សេងទៀតនោះម្ចាស់ភាគហ៊ុនត្រូវជ្រើសរើសអភិបាលមួយរូបទៀតដើម្បី បំពេញតំណែងទំនេរសំរាប់អាណត្តិនៅសល់របស់អភិបាលដែលចេញនោះ។

២៤.**អំណាចរបស់ក្រុមប្រឹក្សាភិបាល**:ក្រុមប្រឹក្សាភិបាលត្រូវមានអំណាចទូទៅដើម្បីចាត់ចែង ក្រុមហ៊ុន(លើកលែងតែមានចែងនៅក្នុង ប្រការ៣៥) ដែលរួមមានទាំងអំណាចដើម្បី:

២៤.១ ស្នើតែប្រែលក្ខន្តិកៈរបស់ក្រុមហ៊ុនទៅម្ចាស់ភាគហ៊ុន។

២៤.២ ស្នើទៅម្ចាស់ភាគហ៊ុនសុំទិញ លក់ ជួល ផ្ទេរ ទ្រព្យសម្បត្តិជាចលនវត្ថុ ឬជា អចលនវត្ថុរបស់ក្រុមហ៊ុន (រួមទាំងភាគហ៊ុនរបស់ក្រុមហ៊ុន) និងមានសិទ្ធិសុំ បង្កើតប្រាតិភោគ ការដាក់កំហិតបន្ទុកសិទ្ធិឃាត់ទុកលើទ្រព្យសម្បត្តិទាំងនោះ។

២៤.៣ តែងតាំងនិង/ឬដកបណ្តាមន្ត្រីនិង/ឬអ្នកគ្រប់គ្រងផ្នែកការងារគ្រប់គ្រងប្រចាំថ្ងៃ របស់ក្រុមហ៊ុន និង

២៤.៤ អនុម័តលើរបាយការណ៍សវនកម្ម និងគណនីរបស់ក្រុមហ៊ុន។

២៥. **កិច្ចប្រជុំក្រុមប្រឹក្សាភិបាល**: ក្រុមប្រឹក្សាភិបាលត្រូវរួមប្រជុំយ៉ាងតិច១ (មួយ) ដងក្នុង រយៈពេល៣ (បី) ខែ។ ក្រុមប្រឹក្សាអាចធ្វើការប្រជុំបន្ថែមទៀតតាមការសំរេច របស់ ប្រធានក្រុមប្រឹក្សាភិបាល។ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលត្រូវធ្វើឡើងនៅការិយាល័យ ចុះ បញ្ជីរបស់ក្រុមហ៊ុន ឬទីកន្លែងទាំងឡាយណាដែលស្ថិតនៅក្នុង ឬក្រៅប្រទេស កម្ពុជាដែល សំរេចដោយប្រធានក្រុមប្រឹក្សាភិបាល។

២៦.**ការជ្រើសរើសប្រធាន**: ក្រុមប្រឹក្សាភិបាលអាចជ្រើសរើសអភិបាលមួយរូបអោយធ្វើជា ប្រធានតាមសេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល។

ប្រធានក្រុមប្រឹក្សាភិបាលត្រូវធ្វើអធិបតីនៅរាល់កិច្ចប្រជុំក្រុមប្រឹក្សាភិបាល និងត្រូវមាន



K PLANTATION (CAMBODIA) PTE LTD

Draft

អំណាច និងភារកិច្ចកោះប្រជុំ មានគំនិតផ្តួចផ្តើម និងផ្តល់យោបល់ចំពោះ គោលនយោបាយ របស់ក្រុមហ៊ុន។

២៧. **ការអវត្តមានប្រធាន**:ប្រសិនបើប្រធានអវត្តមាន នោះអភិបាលមួយរូបផ្សេងទៀតដែលជ្រើសតាំងដោយក្រុមប្រឹក្សាភិបាល នឹងត្រូវតែងតាំងអោយធ្វើជាប្រធានអង្គប្រជុំ។

២៨. **សេចក្តីជូនដំណឹង**:កិច្ចប្រជុំក្រុមប្រឹក្សាភិបាលអាចកោះអោយមានឡើងដោយប្រធាន។ សេចក្តីជូនដំណឹង ៧(ប្រាំពីរ) ថ្ងៃមុនយ៉ាងតិចអំពីការប្រជុំ ត្រូវផ្ញើជូនអភិបាល ម្នាក់ៗដោយប្រគល់ផ្ទាល់ដៃមានការកត់ត្រាទុកផ្ញើតាមប៉ុស្តិ៍ឬតាមទូរសារយោងតាមសភាពជាក់ស្តែង។ សេចក្តីជូនដំណឹងទៅកាន់អភិបាលណាមួយអាចត្រូវលះបង់សិទ្ធិដោយអភិបាលនោះបាន ហើយត្រូវចាត់ទុកថាបានលះបង់សិទ្ធិចំពោះសេចក្តីជូនដំណឹងនៅពេលដែលអភិបាលនោះ ឬអ្នកតំណាងរបស់ខ្លួនមានវត្តមាននៅក្នុងកិច្ចប្រជុំ។

២៩.**ចំនួនកូរ៉ុម**:កូរ៉ុមសំរាប់រាល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលត្រូវមានវត្តមាននៃអភិបាលភាគច្រើនចូលរួមដោយខ្លួនឯង ឬដោយតំណាង។

៣០.**សេចក្តីសំរេច**: រាល់សេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាលត្រូវអនុម័តដោយសំលេងភាគច្រើនធម្មតានៃចំនួនអភិបាលដែលមានវត្តមានដោយខ្លួនឯង ឬដោយអ្នកតំណាងក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល វៀរលែងតែមានចែងផ្សេងពីនេះ។ គ្មានសេចក្តីសំរេចណាមួយត្រូវភ្ជាប់កាតព្វកិច្ចលើក្រុមហ៊ុនទេ វៀរលែងតែមានការអនុម័តដូចខាងលើ។ អភិបាលម្នាក់ៗ ឬអ្នកតំណាងរបស់ខ្លួនត្រូវមានសំលេងឆ្នោតមួយ។

៣១.**អ្នកតំណាង**: អភិបាលម្នាក់ៗមានសិទ្ធិតែងតាំងអភិបាលផ្សេងទៀតអោយធ្វើជាតំណាងរបស់ខ្លួនក្នុងពេលប្រជុំក្រុមប្រឹក្សាភិបាល។

ការបញ្ឈប់លែងអោយធ្វើជាតំណាងត្រូវធ្វើជាលាយលក្ខណ៍អក្សរ ប្រគល់ជូនដោយផ្ទាល់ដៃ ឬជាលិខិតអនុសិទ្ធិ ឬលិខិតទូរសារ ផ្ញើជូនប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន។ តំណែងក្នុងនាមជាអ្នកតំណាងត្រូវបញ្ចប់ជាស្វ័យប្រវត្តិប្រសិនបើអភិបាលដែលតែងតាំងអ្នកតំណាងនោះឈប់ធ្វើជាអភិបាលដោយមូលហេតុណាមួយ។

Draft



T. K. PLANTATION (CAMBODIA) PTE. LTD

៣២. **សេចក្តីសំរេចដោយពុំមានកិច្ចប្រជុំ:** ថ្វីបើមានដូចចែងនៅក្នុងប្រការ៣០ ខាងលើ ក្រុមប្រឹក្សាភិបាលអាចអនុម័តសេចក្តីសំរេចដោយពុំចាំបាច់មានកិច្ចប្រជុំក្រុមប្រឹក្សាភិបាល។ សេចក្តីសំរេចប្រភេទនេះ នឹងមានសុពលភាព និងអាចអនុវត្តបានដូចសេចក្តីសំរេចដែលបានអនុម័តដោយអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាលដែរ បើសិនជាអភិបាលទាំងអស់បានចុះហត្ថលេខា។ ហត្ថលេខារបស់អភិបាលអាចស្ថិតនៅលើឯកសារតែមួយ ឬអាចនៅលើឯកសារច្រើនដែលមានទំរង់ដូចៗគ្នាទាំងអស់។ សំរាប់គោលបំណងនៃប្រការនេះពាក្យថា "ជាលាយលក្ខណ៍អក្សរ" និង "មានចុះហត្ថលេខា" ត្រូវគិតទាំងការយល់ព្រមតាម រយៈតេឡិច ទូរសារ តេឡេក្រាម ឬអ៊ីមែលផងដែរ។ សេចក្តីសំរេចដែលមានចុះហត្ថលេខាត្រឹមត្រូវនោះត្រូវប្រគល់ជូនប្រធាន និងដាក់ចូលក្នុងសៀវភៅកំណត់ហេតុរបស់ក្រុមហ៊ុន។

៣៣. **សំណងចំពោះអភិបាល:** អភិបាលមិនត្រូវទទួលខុសត្រូវផ្ទាល់ខ្លួនឡើយចំពោះទង្វើ ឬការខកខានណាមួយលើកលែងតែកិច្ចការណាដែលទាក់ទងនឹងការបោកបន្លំ ឬកំហុសដោយចេតនា។

ក្រុមហ៊ុនត្រូវសងអភិបាលនិងបណ្ណាធិការទាំងអស់របស់ក្រុមហ៊ុនវិញចំពោះរាល់សោហ៊ុយចំណាយចេញដោយអ្នកទាំងនេះទាក់ទងនឹងការការពារ ឬការដោះស្រាយនូវការតវ៉ាការទាមទារ ការប្តឹងផ្តល់ ដែលកើតចេញមកពីអ្នកទាំងនេះដែលបានបំរើការជាអភិបាល និងជាបណ្ណាធិការក្រុមហ៊ុន លើកលែងតែនៅពេលណាដែលអំពើខុសឆ្គងរបស់អភិបាលនោះ ទាក់ទងនឹងការបោកបន្លំ ឬកំហុសដោយចេតនា។

Draft

៣៤. **ការផ្ទេរអំណាច:** អាស្រ័យលើច្បាប់កម្ពុជា ក្រុមប្រឹក្សាភិបាលអាចតែងតាំងសមាជិកម្នាក់ ឬច្រើននាក់របស់ខ្លួន ឬបុគ្គលផ្សេងទៀត ឬអាចតែងតាំងមន្ត្រី ឬបណ្ណាធិការម្នាក់អោយបំពេញការងារក្រុមហ៊ុនក្រោមការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាភិបាល ឬអាចធ្វើលិខិតប្រគល់សិទ្ធិអំណាចដើម្បីប្រគល់ជូនអ្នកនោះនូវអំណាចទាំងឡាយដែលក្រុមប្រឹក្សាយល់ឃើញថាសមស្រប និងក្នុងពេលណាដែលក្រុមប្រឹក្សាយល់ឃើញថាមានប្រយោជន៍។ អំណាចទាំងនេះអាចប្រគល់ជូនដោយស្របទៅនឹង ឬដាច់ដោយឡែកពី ឬជំនួសអំណាចណាមួយ ឬអំណាចទាំងអស់របស់ក្រុមប្រឹក្សាភិបាល ហើយអាចដកហូតផ្លាស់ប្តូរ ឬកែប្រែអំណាចទាំងនោះបានក្នុងពេលណាមួយ។

៣៥.សេចក្ដីសំរេចចាំបាច់: ត្រូវមានសេចក្ដីសំរេចមួយរបស់ក្រុមប្រឹក្សាភិបាលចំពោះមុខក្រុមហ៊ុន ឬអភិបាលណាមួយរបស់ក្រុមហ៊ុន ឬមន្ត្រីទទួលធ្វើនូវកិច្ចការខាងក្រោម នេះក្នុងនាមក្រុមហ៊ុន :

៣៥.១ ចុះកិច្ចសន្យាធានា ឬធ្វើសកម្មភាពដែលបន្ថយដល់អចលនទ្រព្យរបស់ក្រុមហ៊ុន (ដោយគិតទាំងដីផង)។

៣៥.២ ចុះកិច្ចសន្យា ឬកាតព្វកិច្ច ឬការសុំកម្ចីដែលមានតម្លៃលើសពី ៥០.០០០ ដុល្លាអាមេរិក (ប្រាំម៉ឺនដុល្លាអាមេរិក) ឬចំណាយមូលធន ដើម្បីទទួលបាននូវអចលនទ្រព្យសកម្មរបស់ក្រុមហ៊ុន (ដោយគិតទាំងដីផង) ដែលមានតម្លៃលើសពី ៥០.០០០ ដុល្លាអាមេរិក (ប្រាំម៉ឺនដុល្លាអាមេរិក)។

៣៥.៣ ប្រកាសអំពីភាគលាភ ឬផ្ដល់យោបល់លើការចេញភាគហ៊ុនថ្មីៗ ក្នុងក្រុមហ៊ុន ឬការប្ដូរចនាសម្ព័ន្ធមូលធនរបស់ក្រុមហ៊ុន។

៣៥.៤ បង្កើត ឬយល់ព្រមអោយបង្កើតនិក្ខេប សិទ្ធិឃាត់ទុក បន្ទុក ឬការជាប់បន្ទុកផ្សេងលើទ្រព្យសកម្មក្រុមហ៊ុនដែលមានតម្លៃលើសពី៥០.០០០ដុល្លាអាមេរិក (ប្រាំម៉ឺនដុល្លាអាមេរិក)។

៣៥.៥ បង្កើត ចេញ ឬយល់ព្រមអោយបង្កើត ឬអោយចេញភាគហ៊ុន ឬមូលធនកម្ចី ឬផ្ដល់សិទ្ធិជ្រើសរើសស្ដីអំពីភាគហ៊ុន ឬមូលធនកម្ចី។

៣៥.៦ រៀបចំប្រាក់ខែ និងប្រាក់សំណងផ្សេងទៀត និងផលប្រយោជន៍ក្រោមរូបភាពផ្សេងៗជូនមន្ត្រីរបស់ក្រុមហ៊ុន។

៣៥.៧ ស្នើទៅម្ចាស់ភាគហ៊ុនអំពីការតំឡើង ឬបន្ថយដើមទុនចុះបញ្ជី។

៣៥.៨ ការចេញភាគហ៊ុនថ្មី។

៣៥.៩ កំណត់ និងផ្លាស់ប្ដូរថវិកាក្រុមហ៊ុននាពេលណាមួយ។

៣៥.១០ ក្រៅពីមូលនិធិដែលក្រុមហ៊ុនមានសំរាប់បែងចែកភាគលាភដោយស្រប ច្បាប់ លៃទុកប្រាក់បំរុង សំរាប់គោលបំណងសមស្រប ឬលុបចោលប្រាក់បំរុងទុកនេះវិញតាមរបៀបដែលបានបង្កើត។

៣៥.១១ ចុះកិច្ចសន្យា ឬកាតព្វកិច្ចសំដៅដល់ការលក់ ឬផ្ទេរទ្រព្យក្រុមហ៊ុន (ដោយគិតទាំងដីផង) ដែលមានតម្លៃលើសពី ៥០.០០០ ដុល្លាអាមេរិក (ប្រាំម៉ឺនដុល្លាអាមេរិក)។

## ជំពូក ៥

## ប្រាក់ចំណេញ ការបង្កើនទុន ភាគលាភ និង ប្រាក់បំរុង

៣៦. **ប្រាក់បំរុង**: ជារៀងរាល់ឆ្នាំក្រុមហ៊ុនត្រូវលៃទុកជាមូលនិធិបំរុង នូវទឹកប្រាក់ដែលតំរូវដោយ ច្បាប់នៃប្រទេសកម្ពុជា។

៣៧. **ភាគលាភ**:សេចក្តីសំរេចក្រុមប្រឹក្សាភិបាល អាចពិនិត្យបញ្ជាក់ និងចែកភាគលាភជូនម្ចាស់ភាគហ៊ុនដោយក្រុមប្រឹក្សាភិបាល។ ភាគលាភអាចចែកជូនជាសាច់ប្រាក់ទាំងស្រុង ឬមួយភាគ ឬតម្លៃតបស្នងមិនមែនជាសាច់ប្រាក់។ ប្រាក់ចំណេញរក្សាទុកអាចបញ្ចូលជាមួយប្រាក់ចំណេញនៃឆ្នាំសារពើពន្ធដែលជាប់ពាក់ព័ន្ធដើម្បីបែងចែកជាភាគលាភ។

៣៨.**សេចក្តីជូនដំណឹងអំពីភាគលាភ**: សេចក្តីប្រកាសអំពីភាគលាភត្រូវធ្វើតាមលិខិតផ្ញើជូនម្ចាស់ភាគហ៊ុន។

៣៩.**ការខាតបង់**: ប្រសិនបើក្រុមហ៊ុនមានការខាតបង់នោះភាគលាភមិនត្រូវបែងចែកទេរហូតដល់ពេលប្រាក់ខាតបង់ត្រូវបានស្តារឡើងវិញ។

៤០.**ការបង្កើនដើមទុន**:ក្រុមប្រឹក្សាភិបាលអាចបង្កើនដើមទុនក្រុមហ៊ុនដោយចេញភាគហ៊ុនថ្មីៗទៀត ឬដោយតម្លើងតម្លៃចារឹកលើប័ណ្ណភាគហ៊ុនដែលបានចេញរួចហើយ។ ម្ចាស់ភាគហ៊ុនទាំងឡាយត្រូវមានសិទ្ធិទិញភាគហ៊ុនថ្មីតាមសមាមាត្រភាគហ៊ុនដែលខ្លួនកាន់កាប់មុនពេលដែលភាគហ៊ុននោះត្រូវស្នើលក់ជូនម្ចាស់ភាគហ៊ុនផ្សេងទៀត ឬ អនាគតម្ចាស់ ភាគហ៊ុន។

Draft



K PLANTATION (CAMBODIA) PTE. LTD.

## ជំពូក ៦

## សៀវភៅ គណនី និង សវនករ

៤១. **ឆ្នាំសារពើពន្ធ:**ឆ្នាំសារពើពន្ធនៃក្រុមហ៊ុន ចាប់ផ្តើមនៅថ្ងៃទី ១ ខែ មករា ហើយបញ្ចប់នៅថ្ងៃទី ៣១ ខែ ធ្នូ ឬនៅកាលបរិច្ឆេទផ្សេងទៀតតាមការកំណត់របស់ក្រុមប្រឹក្សាភិបាលក្នុងពេលណាមួយ ចំពោះឆ្នាំទីមួយនៃ ប្រតិបត្តិការឆ្នាំសារពើពន្ធត្រូវចាប់ផ្តើម ពីកាលបរិច្ឆេទចុះបញ្ជីក្រុមហ៊ុន ហើយបញ្ចប់នៅថ្ងៃទី ៣១ ខែ ធ្នូ នៃឆ្នាំនោះ។

៤២. **តារាងតុល្យការ:**តារាងតុល្យការ និងគណនីលទ្ធផលនៃក្រុមហ៊ុន ត្រូវរៀបចំឡើង និងត្រូវធ្វើសវនកម្មដោយអនុលោមតាមការអនុវត្តន៍គណនេយ្យអន្តរជាតិដែលបានទទួលស្គាល់ដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនៃប្រទេសកម្ពុជា។

៤៣. **គណនី:**ក្រុមប្រឹក្សាភិបាលត្រូវជំរុញអោយរក្សាទុកនូវបញ្ជីគណនេយ្យត្រឹមត្រូវ និងមានលក្ខណៈពេញលេញដែលកត់ត្រាទឹកប្រាក់ដែលក្រុមហ៊ុនបានទទួលបានចំណាយ និងការលក់ ការទិញទំនិញ សេវាកម្មទាំងឡាយរបស់ក្រុមហ៊ុន ព្រមទាំងអ្វីផ្សេងៗពាក់ព័ន្ធនឹងករណីនៃការទទួល ឬការចំណាយដែលបានកើតឡើង និងកត់ត្រា ទ្រព្យសកម្ម និងបំណុលរបស់ក្រុមហ៊ុន។ សៀវភៅគណនីទាំងនេះ ត្រូវបង្ហាញអោយឃើញនូវភាពត្រឹមត្រូវពិតប្រាកដនៃស្ថានភាពកិច្ចការជំនួញរបស់ក្រុមហ៊ុន និងពន្យល់ពីប្រតិបត្តិការក្រុមហ៊ុន។

៤៤. **ការរក្សាទុកនូវឯកសារហិរញ្ញវត្ថុ:**ក្រុមប្រឹក្សាភិបាលត្រូវជំរុញអោយធ្វើតារាងតុល្យការ និងរបាយការណ៍លទ្ធផលយ៉ាងតិចមួយដងក្នុងរាល់រយៈពេល១២ (ដប់ពីរ) ខែ គិតមកត្រឹមចុងឆ្នាំសារពើពន្ធនីមួយៗរបស់ក្រុមហ៊ុន។ គ្រប់វិញ្ញាបនប័ត្រ សៀវភៅបញ្ជី និងរបាយការណ៍ទាំងអស់របស់ក្រុមហ៊ុនត្រូវរក្សាទុកនៅការិយាល័យចុះបញ្ជីរបស់ក្រុមហ៊ុន ឬនៅកន្លែងផ្សេងទៀតដែលត្រូវសំរេចដោយក្រុមប្រឹក្សាភិបាលក្នុងពេលណាមួយ ហើយត្រូវសរសេរជាភាសារអង់គ្លេស ដោយមានការបកប្រែជាភាសាខ្មែរតាមគំរូ។ ច្បាប់ចំលងនៃរាល់តារាងតុល្យការ និងគណនីលទ្ធផលដែលត្រូវដាក់ជូនក្រុមហ៊ុនពិនិត្យនៅក្នុងមហាសន្និបាតម្ចាស់ភាគហ៊ុន រួមជាមួយរបាយការណ៍របស់អភិបាល និងរបស់អ្នកត្រួតពិនិត្យបញ្ជីរបស់ក្រុមហ៊ុនត្រូវបញ្ជូនទៅម្ចាស់ភាគហ៊ុនទាំងអស់ និងអ្នកត្រួតពិនិត្យបញ្ជីមុនកាលបរិច្ឆេទមហាសន្និបាតនេះ។



Draft

Draft

## ជំពូក ៧

## ការជំរះបញ្ជី

**៤៥. ការជំរះបញ្ជី**:ក្រុមហ៊ុនអាចបញ្ឈប់សកម្មភាពរបស់ខ្លួន ហើយជំរះបញ្ជីបិទក្រុមហ៊ុនតាម សេចក្តីសំរេចពិសេសរបស់ម្ចាស់ភាគហ៊ុនក្រោមលក្ខខណ្ឌណាមួយខាងក្រោមនេះ :

ក-ប្រធានសក្តិដែលបណ្តាលអោយគ្មានលទ្ធភាពអនុវត្តតាមគោលបំណងរបស់ក្រុមហ៊ុន

ឬប្រតិបត្តិការអាជីវកម្មក្រុមហ៊ុន ឬ

ខ- ស្ថានការណ៍ផ្សេងៗទៀតដែលសំរេចដោយក្រុមប្រឹក្សាភិបាល។

ក្រុមហ៊ុនក៏ត្រូវរំលាយដោយអំណាចតុលាការក្នុងមូលហេតុមួយដែលត្រឹមត្រូវ។

**៤៦. នីតិវិធី**:ក្នុងករណីជំរះបញ្ជី ក្រុមប្រឹក្សាភិបាលត្រូវរៀបចំផែនការដើម្បីរំលាយក្រុមហ៊ុន ហើយត្រូវអនុវត្តបន្ទាប់ពីម្ចាស់ភាគហ៊ុនបានអនុម័ត។
នីតិវិធីសំរាប់រំលាយក្រុមហ៊ុននៅក្រៅតុលាការត្រូវអនុវត្តទៅតាមច្បាប់កម្ពុជា។

## ជំពូក ៨

## សេចក្តីផ្សេងៗ

**៤៧. ហត្ថលេខីពេញសិទ្ធិ**:មានតែហត្ថលេខារបស់លោក SURENDRA KUMAR PODDAR ឬ លោក NARAYAN PODDAR ចុះហត្ថលេខារួមគ្នា និងជាមួយត្រារបស់ក្រុមហ៊ុន ទើបអាចភ្ជាប់កាតព្វកិច្ចលើក្រុមហ៊ុនបាន វៀរលែងតែមាន បុគ្គលមួយរូប ឬច្រើនរូប ផ្សេងទៀតទទួលបានការអនុញ្ញាតយ៉ាងជាក់លាក់ពីសេចក្តីសំរេច របស់ក្រុមប្រឹក្សាភិបាល អោយចុះហត្ថលេខាជំនួសក្រុមហ៊ុនតែប៉ុណ្ណោះ។ គ្មានម្ចាស់ ភាគហ៊ុន ឬបណ្ណាធិការ ក្រុមហ៊ុនណាមានអំណាចកាតព្វកិច្ចលើក្រុមហ៊ុនបានឡើយតាម រយៈតួនាទីនេះ។

**៤៨.វិសោធនកម្ម**:ការបន្ថែមឬវិសោធនកម្មលើលក្ខន្តិកៈរបស់ក្រុមហ៊ុនត្រូវទាមទាអោយមាន សេចក្តីសំរេចពីម្ចាស់ភាគហ៊ុន។ រាល់ការកែប្រែទ្រង់ទ្រាយ នាមករណ៍ ឬ អាសយដ្ឋាន

ក៏ដូចជាការធ្វើអនុប្បទានភាគហ៊ុនរបស់ក្រុមហ៊ុនត្រូវចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ឬក៏តាមការតំរូវរបស់ច្បាប់។

៤៩. **ដំណោះស្រាយវិវាទ:** វិវាទដែលកើតឡើងរវាងម្ចាស់ភាគហ៊ុន និង/ឬអភិបាល ត្រូវដោះស្រាយដោយការយោគយល់គ្នាពីបណ្តាភាគី។

បើវិវាទមិនអាចដោះស្រាយបានដោយរបៀបនេះទេ វិវាទនោះត្រូវដាក់ជូនអាជ្ញាកណ្តាល។ ទីកន្លែងនៃមជ្ឈត្តកម្មគឺប្រទេសសិង្ហបុរី។ តុលាការនៃមជ្ឈត្តកម្មនេះត្រូវមានសមាជិក៣ (បី) រូប ភាគីវិវាទនីមួយៗមានសិទ្ធិជ្រើសរើស មជ្ឈត្តករមួយរូប និង មួយរូបទៀតត្រូវសំរេចរើសរួមគ្នា។ ភាសាអង់គ្លេសជាភាសាប្រើប្រាស់នៅក្នុងតុលាការមជ្ឈត្តកម្មនេះ។ សេចក្តីសំរេចនៃមជ្ឈត្តកម្មត្រូវមាន អនុភាពអនុវត្តចំពោះគូភាគី។

កាលបរិច្ឆេទ : 18-04-2016

តាមរយៈនេះ បណ្តាម្ចាស់ភាគហ៊ុន សូមអនុម័តលើលក្ខន្តិកៈ

ក្រសួងពាណិជ្ជកម្ម
នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម
តម្កល់ទុកលេខ: 00002485
កាលបរិច្ឆេទតម្កល់: 26-04-2016 ម៉ោង 14"20'
មន្ត្រីផ្ទៀងផ្ទាត់:

ក្រុមហ៊ុន SK Plantation (Cambodia)Pte.Ltd.

ដោយតំណាងស្របច្បាប់

លោក SURENDRA KUMAR PODDAR

លោក SURENDRA KUMAR PODDAR

SK PLANTATION (CAMBODIA) PTE. LTD.

លោក NARAYAN PODDAR

Draft

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

KINGDOM OF CAMBODIA
NATION RELIGION KING

ក្រសួងពាណិជ្ជកម្ម
MINISTRY OF COMMERCE

លេខ(No) MOC-47867826 ពណ.ចបព

# វិញ្ញាបនបត្រ

## បញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម

## CERTIFICATE OF INCORPORATION

| | | |
|---|---|---|
| នាមករណ៍<br>NAME | : | អេស ខេ ផ្លេនថេសិន (ខេមបូឌា) ភីធីអ៊ី អិលធីឌី<br>SK PLANTATION (CAMBODIA) PTE. LTD. |
| ចុះបញ្ជីក្រោមលេខ<br>REGISTRATION NUMBER | : | 00003485 |
| អត្តលេខចុះបញ្ជីចាស់<br>ORIGINAL REGISTRATION NUMBER | : | Co.2347E/2010 |
| កាលបរិច្ឆេទចុះក្នុងបញ្ជីពាណិជ្ជកម្ម<br>INCORPORATION DATE | : | 24 វិច្ឆិកា 2010<br>24 November 2010 |
| ត្រូវបានទទួលស្គាល់ថាជា:<br>IS ACKNOWLEDGE AS: | : | ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត<br>Private Limited Company |

3292 . .
លេខ: ...................... ល.ប
បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម។
រាជធានីភ្នំពេញ,ថ្ងៃទី 30 MAR 2017
ត.ប អភិបាល [illegible] អភិបាលរាជធានីភ្នំពេញ
នាយក…
ហ៊ុក_ហួលីម

ភ្នំពេញ, 24 វិច្ឆិកា 2010
PHNOM PENH, 24 NOVEMBER 2010
ជ. រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
F. MINISTER OF COMMERCE

ស្ថិតក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ក្រមរដ្ឋប្បវេណី និងក្រមព្រហ្មទណ្ឌ ដែលមានជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

UNDER THE REGULATIONS OF COMMERCIAL RULES AND REGISTER LAW, COMMERCIAL ENTERPRISES LAW, CIVIL CODE AND PENAL CODE OF THE KINGDOM OF CAMBODIA

Draft

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
NATION RELIGION KING

ក្រសួងពាណិជ្ជកម្ម
MINISTRY OF COMMERCE

លេខ(No) MOC-47867826 ពណ.ចបព

# វិញ្ញាបនបត្រ
## បញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម
## CERTIFICATE OF INCORPORATION

| | | |
|---|---|---|
| នាមករណ៍<br>NAME | : | អេស ខេ ផ្លេនថេសិន (ខេមបូឌា) ភីធីអ៊ី អិលធីឌី<br>SK PLANTATION (CAMBODIA) PTE. LTD. |
| ចុះបញ្ជីក្រោមលេខ<br>REGISTRATION NUMBER | : | 00003485 |
| អត្តលេខចុះបញ្ជីចាស់<br>ORIGINAL REGISTRATION NUMBER | : | Co.2347E/2010 |
| កាលបរិច្ឆេទចុះក្នុងបញ្ជីពាណិជ្ជកម្ម<br>INCORPORATION DATE | : | 24 វិច្ឆិកា 2010<br>24 November 2010 |
| ត្រូវបានទទួលស្គាល់ជាៈ<br>IS ACKNOWLEDGE AS: | : | ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត<br>Private Limited Company |

លេខ: 2007 ល.ប
បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម។
រាជធានីភ្នំពេញ ថ្ងៃទី 24 MAR 2017
ត.ប អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ

ហុក_ឡូលីម

ស្ថិតក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ក្រមរដ្ឋប្បវេណី និងក្រមព្រហ្មទណ្ឌ ដែលមានជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

UNDER THE REGULATIONS OF COMMERCIAL RULES AND REGISTER LAW, COMMERCIAL ENTERPRISES LAW, CIVIL CODE AND PENAL CODE OF THE KINGDOM OF CAMBODIA

ភ្នំពេញ, 24 វិច្ឆិកា 2010
PHNOM PENH, 24 NOVEMBER 2010
ជ. រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
F. MINISTER OF COMMERCE

Draft



THIS PASSPORT IS VALID FOR ALL COUNTRIES
EXCEPT THE FOLLOWING:

PASSPORT REPUBLIC OF SINGAPORE

Type: PA
Country Code: SGP
Passport No: E6270968C
Name: SURENDRA KUMAR PODDAR
Sex: M
Nationality: SINGAPORE CITIZEN
Date of birth: 08 FEB 1989
Place of birth: INDIA
Date of issue: 20 SEP 2016
Date of expiry: 20 SEP 2021
Modifications: SEE PAGE 2
Authority: MINISTRY OF HOME AFFAIRS
National ID No: S8972167I

PASGPSURENDRA<KUMAR<PODDAR<<<<<<<<<<<<<<<<<<<
E6270968C4SGP8902085M2109206S8972167I<<<<<62

T K PLANTATION (CAMBODIA)
PTE. LTD

# មាតិកា

ទំព័រ


**សេចក្តីផ្តើម** ........ 4

**ជំពូក I អធិប្បាយទូទៅពាក់ព័ន្ធនឹងក្រុមហ៊ុន និងតំបន់សម្បទាន** ........ 6

**១-ស្ថានភាពទូទៅនៃក្រុមហ៊ុន** ........ 6

១.១-ទីតាំងរដ្ឋបាលនៃក្រុមហ៊ុនៈ ........ 6

១.២-ភាគហ៊ុននិងសមាជិកហ៊ុនៈ ........ 6

១.៣-ទីតាំងភូមិសាស្ត្រ និងព្រំប្រទល់ដីសម្បទាន ........ 6

១.៤-ស្ថានាភាពច្បាប់ នៃតំបន់សម្បទាន ........ 8

១.៥-ប្រវត្តរបស់ដីសម្បទាន ........ 9

**២- លក្ខណៈអាកាសធាតុ** ........ 10

២.១-របបទឹកភ្លៀង ........ 10

២.២-សីតុណ្ហភាព ........ 11

២.៣-សំណើមបរិយាកាស ........ 11

២.៤-កំដៅថ្ងៃ ........ 12

**៣-ស្ថានភាពដី និងប្រភេទដី** ........ 12

៣.១-ស្ថានភាពប្រភេទដី ........ 12

៣.២-ស្ថានភាពប្រភេទដីជាតិដី ........ 12

**៤-ស្ថានភាពសេដ្ឋកិច្ច** ........ 13

៤.១-វិស័យសេដ្ឋកិច្ច និងពាណិជ្ជកម្ម ........ 13

៤.២-វិស័យកសិកម្ម ........ 13

៤.៣-វិស័យសាធារណៈ និង ដឹកជញ្ជូន ........ 14

៤.៤-វិស័យទេសចរណ៍ ........ 15

**៥-ស្ថានភាពសង្គមកិច្ច** ........ 15

៥.១-វិស័យអប់រំ ........ 15

៥.២-វិស័យសុខាភិបាល ........ 15

**៦-ស្ថានភាពព្រៃក្នុងតំបន់ដីសម្បទាន** ........ 15

**ជំពូក II ផែនការរៀបចំ និងការគ្រប់គ្រងនៃសម្បទាន** ........ 18


Draft

**១-គោលបំណង នៃការធ្វើវិនិយោគ** ........ 18

**២- កម្មវត្ថុ នៃការប្រើប្រាស់ដីសម្បទាន** ........ 19

**៣-ឧស្សនធានការគ្រប់គ្រងដីសម្បទាន** ........ 19

**៤-ប្រព័ន្ធ នៃការគ្រប់គ្រងដីសម្បទាន** ........ 21

៤.១-រចនាសម្ព័ន្ធ នៃការគ្រប់គ្រងដីសម្បទាន ........ 21

៤.២-ផែនការបែងចែកផ្ទៃដីសម្រាប់ផលិតកម្ម ........ 22

៤.៣-ការបែងចែកតំបន់ដាំដុះក្នុងតំបន់ដីសម្បទាន ........ 24

៤.៤-កម្មវិធីប្រើប្រាស់ដីតាមបណ្តាអនុតំបន់ ........ 29

៤.៥-ការដាំដុះកៅស៊ូ ........ 30

៤.៦-ការដាំដំណាំកាការ ........ 33

៤.៧-ការដាំដំណាំអាកាស្យាសេណោហ្គាល់ ........ 39

៤.៧-ផែនការបែងចែក និងរៀបចំដីដាំដុះ ........ 41

**៥-ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ** (Infrastructure Development) ........ 44

៥.១-ប្រពន្ធ័ផ្លូវ (Road Network) ........ 44

៥.២-ប្រពន្ធ័ស្រោចស្រព (Irrigation System) ........ 47

៥.៣-រោងចក្រកែច្នៃផលិតផល (Processing Factory) ........ 48

៥.៤-ទីតាំងទំហំផ្ទៃដីសម្រាប់ហេដ្ឋារចនាសម្ព័ន្ធ (Infrastructure Development) ........ 48

**ជំពូក III គម្រោងចំណាយសម្រាប់ការវិនិយោគ** ........ 50

**១-ការគណនាថ្លៃដើមផលិតកម្មដំណាំកៅស៊ូក្នុង 01 ហិកតា** ........ 50

**២-ការគណនាថ្លៃដើមផលិតកម្មដូងក្នុង 01 ហិកតា** ........ 50

**៣-ការគណនាថ្លៃដើមផលិតកម្មអាកាស្យាសេណោហ្គាល់ក្នុង 01 ហិកតា** ........ 50

**៤-ការគណនាថ្លៃដើមផលិតកម្មសណ្តែកសៀងក្នុង 01 ហិកតា** ........ 51

**៥-ការគណនាថ្លៃដើមផលិតកម្មស្រូវក្នុង 01 ហិកតា** ........ 51

**៣-ផែនការចំណាយផលិតកម្មដាំដុះ និងកែច្នៃ** ........ 52

៣.១-ចំណាយអថេរ (Variable Costs) ........ 52

៣.២-ចំណាយថេរ (Fixed Costs) ........ 52

**៤-ការចំណាយលើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ** ........ 53

Draft

**៥-មធ្យោបាយ និងទព្វសម្ភារៈឧបករណ៍សម្រាប់ដំណើរការ** ........ 53

៥.១-ទព្វសម្ភារៈមធ្យោបាយផលិតកម្ម (Equipment) ........ 53

៥.២-កំលាំងពលកម្ម (Labors) ........ 55

**ជំពូក IV ការវិភាគសេដ្ឋកិច្ចនៃការវិនិយោគ** ........ 57

**១-ទុនវិនិយោគ និងការវិភាគលំហូរសាច់ប្រាក់** ........ 57

១-១-ទុនវិនិយោគ និងការចំណាយ (Capital Investment and Costs) ........ 57

១.២-ការចំណាយសម្រាប់រយៈពេល ២០ ឆ្នាំ (Investment Costs for 20 Years) ........ 58

១.៣-ការវិភាគលំហូរសាច់ប្រាក់ (Cash Flow Analysis) ........ 59

**២-របាយការណ៍ចំណូល និងចំណេញ-ខាត** ........ 59

២.១-របាយការណ៍ចំណូល ........ 59

២.២-របាយការណ៍ចំណេញ-ខាត ........ 62

**៣-ប្រសិទ្ធភាពសេដ្ឋកិច្ច នៃសម្បទាន** ........ 63

**ជំពូក V ការវាយតម្លៃផលប៉ះពាល់បរិស្ថាន-សង្គម** ........ 64

**១-ការវាយតម្លៃផលប៉ះពាល់បរិស្ថាន-សង្គម និងវិធានការកាត់បន្ថយ** ........ 64

១.១-ទិដ្ឋភាពទូទៅ នៃផលប៉ះពាល់ ........ 64

១.២-ផលប៉ះពាល់បរិស្ថាន-សង្គម និងវិធានការកាត់បន្ថយ ........ 65

**២-ការពិនិត្យតាមដានហេតុប៉ះពាល់បរិស្ថាន-សង្គម** ........ 76

២-១-ស្ថានភាពទូទៅ ........ 76

២.២-សកម្មភាពតាមដានត្រួតពិនិត្យ ........ 76

**៣-សេចក្តីសន្និដ្ឋាន** ........ 79


Draft

## សេចក្តីផ្តើម

ប្រទេសកម្ពុជា គឺជាប្រទេសដែលមានខឿនសេដ្ឋកិច្ចជាតិ ពឹងផ្អែកមួយភាគធំលើវិស័យកសិកម្មនៅឡើយហើយមានប្រជាពលរដ្ឋប្រមាណ ៨០ ភាគរយ រស់នៅជនបទហើយដែលក្នុងនោះ ភាគច្រើនលើសលុប ប្រកបរបរកសិកម្មសម្រាប់ចិញ្ចឹមជីវិត។ ក្នុងលក្ខខណ្ឌនៃដំណើរការវិវឌ្ឍន៍សេដ្ឋកិច្ចសង្គមបែបនេះរាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងចាត់ទុកថាវិស័យកសិកម្ម គឺ ជាវិស័យដែលមានអាទិភាពខ្ពស់ នៅក្នុងរបៀបវារៈនៃការអភិវឌ្ឍន៍ប្រទេសជាតិរបស់ខ្លួន។

បច្ចុប្បន្នរាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញ និងអនុវត្តជាបន្តបន្ទាប់នូវគោលនយោបាយយុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍ជាតិ ដោយផ្តោតទៅលើការលើកស្ទួយវិស័យកសិកម្ម និងជនបទដោយកាត់បន្ថយភាពក្រីក្របានក្នុងកម្រិតមួយសមស្រប តាមរយៈការបង្កើនផលិតភាពកសិកម្មធានានូវស្ថេរភាពសន្តិសុខស្បៀង បង្កើតការងារ និងបង្កើនចំណូលប្រចាំគ្រួសារកសិករ ជារួមគឺការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ និងជំរុញឲ្យមានកំណើនសេដ្ឋកិច្ចជាតិ។

ការរីកចំរើននៃវិស័យកសិកម្ម គឺជាកត្តាគន្លឹះសម្រាប់ការកាត់បន្ថយភាពក្រីក្រ ដែលរួមចំណែកយ៉ាងច្រើនក្នុងកំណើនផលិតផលសរុបក្នុងស្រុក (GDP) និងស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច។ ដំណើរការអភិវឌ្ឍន៍គ្រប់វិស័យការគ្រប់គ្រងបែងចែក និងការប្រើប្រាស់ដីធ្លីប្រកបដោយសមធម៌ រួមនឹងការខិតខំដោះស្រាយនូវរាល់បញ្ហាដែលមានចំពោះមុខ និងការទប់ស្កាត់សកម្មភាពរំលោភបំពានយកដីដោយខុសច្បាប់ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព។ ជាមួយគ្នានេះរាជរដ្ឋាភិបាល ខិតខំពង្រឹងបានផ្តល់ឲ្យអ្នកវិនិយោគិននូវការលើកទឹកចិត្តយ៉ាងច្រើនសម្រាប់វិស័យនេះ ដែលនាំឱ្យមានការកើនឡើងយ៉ាងឆាប់រហ័ស នៃការចូលវិនិយោគគ្រប់ផ្នែកទាំងការវិនិយោគផលិតទំនិញនាំចេញ ការផលិតថាមពល ការកសាងហេដ្ឋារចនាសម្ព័ន្ធ ការវិនិយោគផ្នែកទេសចរណ៍ និងជាពិសេសការវិនិយោគលើវិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម ដែលជាសក្តានុពលដ៏សំខាន់បំផុតរបស់កម្ពុជា។ មិនតែប៉ុណ្ណោះវិស័យកសិកម្មបាននិងកំពុងស្រូបទាញបាននូវទុនវិនិយោគទាំងពីអ្នកវិនិយោគក្នុង និងក្រៅប្រទេសកាន់តែធំឡើងជាលំដាប់ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។

ដើម្បីចូលរួមចំណែកឆ្លើយតបនឹងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ឲ្យសម្រេចបាននូវទិសដៅក្នុងការលើកស្ទួយវិស័យកសិកម្ម ខេត្តរតនគិរីក៏មានផែនការ និងគោលដៅដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចខេត្ត សំដៅធ្វើឲ្យមានកំណើនប្រាក់ចំណូលដល់ប្រជាកសិករ តាមរយៈការបង្កើនកាលានុវត្តភាពការងារ ការវិនិយោគឯកជន និងសាធារណៈ និងការពង្រីកផលិតកម្មសេវាកម្ម ប្រកបដោយចីរភាព ការធានាឲ្យមានអភិបាលកិច្ចល្អ ស្ថេរភាពសង្គម ។ ដោយឡែកដើម្បីអនុវត្តយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនិងខេត្ត ដែលបានដាក់ចេញមកឲ្យបានជោគជ័យ ក្រុមហ៊ុនយើងខ្ញុំបានពិនិត្យឃើញថា ការវិនិយោគទុនលើការដាំដុះដំណាំកាកាវ ដូង អាកាស្យា សេណេហ្គាល់ សណ្តែកសៀង ស្រូវ កៅស៊ូ និងដំណាំកសិ-ឧស្សាហកម្មផ្សេងទៀត ដែលមានលក្ខណៈជាចម្ការកសិ-ឧស្សាហកម្ម គឺជាការវិនិយោគមួយសមស្របបំផុតនៅលើទឹកដីនៃខេត្តរតនគិរីនេះ ហើយក៏ជាការឆ្លើយតបនឹងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក៏ដូចជាផែនការ និងគោលដៅដើម្បីអភិវឌ្ឍន៍ សេដ្ឋកិច្ចខេត្តផងដែរ។ម្យ៉ាងវិញទៀតទីតាំងភូមិសាស្ត្រ ស្ថានភាពដីនៅទីនោះអំណោយផល និងអនុគ្រោះច្រើនដល់ការដាំដំណាំទាំងអស់នោះ និងតម្រូវការផលិតផលកែច្នៃបច្ចុប្បន្នកំពុងតែមានតម្រូវការកើនឡើងជាលំដាប់។

Draft

កត្តាទាំងនេះហើយដែលនាំឲ្យក្រុមហ៊ុនឈានទៅធ្វើការវិនិយោគ ដែលជាការធានាដ៏យូរអង្វែងមួយសម្រាប់កិច្ចអភិវឌ្ឍន៍ខេត្ត ទៅលើការប្រើប្រាស់សក្តានុពលព្រមទាំងការលើកកម្ពស់ភាពស្មើគ្នារវាងបុរស និងស្ត្រី។ ទន្ទឹមនឹងនោះក្រុមហ៊ុនក៏មានផែនការកសាងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ក្នុងតំបន់ដីសម្បទានដែលស្នើសុំនេះសម្រាប់បម្រើដល់ការដាំដុះ និងសម្រាប់ដល់ការរស់នៅមួយចំណែករបស់ប្រជាពលរដ្ឋដែលរស់នៅក្បែរតំបន់ដីសម្បទាន របស់ក្រុមហ៊ុនផងដែរ។ ក្រោយពីបានទទួលសម្បទានដីសេដ្ឋកិច្ចដែលមានទំហំ ៦៥០៩,២៧ ហិកតា ស្ថិតនៅក្នុងស្រុកកូនមុំ និងស្រុករ៉ូនសៃ ខេត្តរតនគិរី ក្រុមហ៊ុនបានរៀបចំផែនការមេសម្រាប់ការគ្រប់គ្រង និងប្រើប្រាស់ដីសម្បទាននេះដោយធ្វើការរៀបចំនឹងត្រូវបែងចែកជា **០៥ ជំពូក ៖**

- **ជំពូក I ៖ អធិប្បាយទូទៅពាក់ព័ន្ធនឹងក្រុមហ៊ុន និងតំបន់សម្បទាន**
- **ជំពូក II ៖ ផែនការរៀបចំ និងការគ្រប់គ្រងនៃសម្បទាន**
- **ជំពូក III ៖ គម្រោងចំណាយសម្រាប់ការវិនិយោគ**
- **ជំពូក IV ៖ ការវិភាគសេដ្ឋកិច្ចនៃការវិនិយោគ**
- **ជំពូក V ៖ ការវាយតំលៃផលប៉ះពាល់បរិស្ថាន-សង្គម**

និងមានបរិយាយលម្អិតតាមជំពូកនីមួយៗ ក្រុមហ៊ុនសូមធ្វើការរៀបរាប់ជូនដូចខាងក្រោមនេះ។

Draft

# ជំពូក I អធិប្បាយទូទៅពាក់ព័ន្ធនឹងក្រុមហ៊ុន និងតំបន់សម្បទាន

## ១-ស្ថានភាពទូទៅនៃក្រុមហ៊ុន

### ១.១-ទីតាំងរដ្ឋបាលនៃក្រុមហ៊ុន:

ក្រុមហ៊ុន **អេស ខេ ផ្លេនថេសិន (ខេមបូឌា) ភីធីអ៊ី អិលធីឌី** [SK PLANTATION (CAMBODIA) PTE.LTD] មានទីតាំងស្ថិតនៅផ្ទះលេខ១៩៩ ជាន់ទី១ ផ្លូវលេខ៦៣ កែងផ្លូវលេខ ៣០៦ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា។

ទូរស័ព្ទទំនាក់ទំនងលេខ (៨៥៥) ២៣ ២២១ ២០៥ និង(៨៥៥) ៧៥ ៦៦៨ ៩៧៧៧

ទូរសារលេខ ០២៣ ៦៣៣ ៧៩៥៥៦ ។

### ១.២-ភាគហ៊ុននិងសមាជិកហ៊ុន:

ក្រុមហ៊ុន អេស ខេ ផ្លេនថេសិន (ខេមបូឌា) ភីធីអ៊ី អិលធីឌី [SK PLANTATION (CAM BODIA) PTE.LTD] ជាក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត មានដើមទុនចុះបញ្ជីដែលបង្កើតឡើងដោយការដាក់បញ្ចូលភាគហ៊ុនពីសមាជិកនៃក្រុមហ៊ុនដែលតំណាងដោយលោក សុរិន្ត្រា កុមាបូដា ជនជាតិឥណ្ឌា ឋានៈជាប្រធានក្រុមហ៊ុនមានគណនីលេខ ២៣២១៩៤៣ នៅធនាគារ ANZ Royal Bank Phnom Penh។

### ១.៣-ទីតាំងភូមិសាស្ត្រ និងព្រំប្រទល់ដីសម្បទាន

ក្រុមហ៊ុន **អេស ខេ ផ្លេនថេសិន (ខេមបូឌា) ភីធីអ៊ី អិលធីឌី** [SK PLANTATION (CAMBODIA) PTE.LTD] បានស្នើសុំដីសម្បទានសេដ្ឋកិច្ចពីរាជរដ្ឋាភិបាលកម្ពុជាតាមរយៈឯកឧត្តមអភិបាលខេត្ត និងឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លើផ្ទៃដីចំនួន ៨០០០ ហិកតា ដែលមានទីតាំងស្ថិតឃុំត្រពាំងក្រហម ឃុំតឺន ស្រុកកូនមុំ និងឃុំប៉ុង ឃុំភ្នំកុក ឃុំហាតប៉ក់ ស្រុកវើនសៃ ខេត្តរតនគិរី ដែលមានចង្ងាយប្រមាណ៣០គីឡូម៉ែត្រ ភាគខាងលិចឆៀងខាងជើងពីទីរួមខេត្តរតនគិរី ។

ទីតាំងដីសម្បទានរបស់ក្រុមហ៊ុន (ដូចមានផែនទីទីតាំងភ្ជាប់មកជាមួយជាឧបសម្ព័ន្ធ) មានកូអរដោនេបង្ហាញដូចខាងក្រោម ៖

| ចំណុចគោលព្រំដីសម្បទាន | ចំណុចនិយាមកា | |
|---|---|---|
| | ចំណុចអាប់ស៊ីស (X) | ចំណុចអរដោនេ (Y) |
| A | ៦៧៣៨៣៥ | ១៥១៣៩៥៨ |
| B | ៦៧៦៨៤៥ | ១៥១៧០១៦ |
| C | ៦៧៨៥៤៤ | ១៥២០៥៦០ |
| D | ៦៨០២៤៣ | ១៥២៣៦៦៧ |
| E | ៦៧៩៦៦១ | ១៥២៧៨៩០ |
| F | ៦៨២០៣៩ | ១៥៣០០៧៥ |

Draft

| | | |
|---|---|---|
| G | ៦៨២០៨៨ | ១៥៣២២៣៥ |
| H | ៦៨៥៦៨០ | ១៥៣០១៩៦ |
| I | ៦៨៧៩៣៧ | ១៥៣១១៩១ |
| J | ៦៨៩៥១៥ | ១៥៣៤៦៣៨ |
| K | ៦៩០៩៩៦ | ១៥៣៥៧០៦ |
| L | ៦៩០៤៣៧ | ១៥៣៨០៨៤ |
| M | ៦៩១២៣៨ | ១៥៤២១៨៦ |
| N | ៦៩៥១៤៦ | ១៥៣៩៦៣៨ |
| O | ៦៩៤៥១៥ | ១៥៤២៧៦៩ |
| P | ៦៩៥៣៨៩ | ១៥៤៣៨៨៥ |
| Q | ៦៩៦៤៣៣ | ១៥៤១៦២៨ |
| R | ៦៩៨២៧៧ | ១៥៤២៧៩៣ |
| S | ៧០០៨០៤ | ១៥៤០១១៤ |
| T | ៦៩៧៧១០ | ១៥៣៥៤១១ |
| U | ៦៩៧០១០ | ១៥៣៥១៩៤ |
| V | ៦៩៤៩៥១ | ១៥៣៥០៩៥ |
| W | ៦៩៦០២៧ | ១៥៣៣៣៩៥ |
| X | ៦៩៣៣៤២ | ១៥៣៤០៨៥ |
| Y | ៦៩១៦១៩ | ១៥៣៣០០៤ |
| Z | ៦៩០៦១៣ | ១៥៣០៩៦៥ |
| A1 | ៦៨៩៩២៣ | ១៥២៧១៩៥ |
| B1 | ៦៨១៤៩៤ | ១៥២៣៦៧៥ |
| C1 | ៦៨២៩៣៥ | ១៥២២៣៣៨ |
| D1 | ៦៧៨៤៩៦ | ១៥១៤៨២៨ |
| E1 | ៦៨១២០៤ | ១៥១៤៨៣៦ |
| F1 | ៦៨១១៨៩ | ១៥១២៥២៥ |
| G1 | ៦៨០២៤៦ | ១៥១១៨០១ |
| H1 | ៦៧៩៦៦៧ | ១៥១១៦០៦ |
| I1 | ៦៧៩៥៤៩ | ១៥១០៦៧៦ |
| J1 | ៦៧៩០១០ | ១៥០៩៩៧៥ |
| K1 | ៦៧៧៩៩៥ | ១៥០៩៩៧៩ |
| L1 | ៦៧៧៩៩៤ | ១៥១៣៩១៤ |

Draft

## ១.៤-ស្ថានភាពច្បាប់ នៃតំបន់សម្បទាន

ឯកសារគោលការណ៍ច្បាប់របស់ក្រុមហ៊ុន **អេស ខេ ផ្លេនថេសិន (ខេមបូឌា) ភីធី អ៊ី អិលធីឌី** [SK PLANTATION (CAMBODIA) PTE.LTD] បានទទួលពីរាជរដ្ឋាភិបាលកម្ពុជារួមមាន៖

ក-លិខិតលេខ ៩៤៦៤/១០៧៣កសក.នផ.ផក ចុះថ្ងៃទី២៨ ខែធ្នូឆ្នាំ២០១១ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីសំណើសុំសម្បទានដីសេដ្ឋកិច្ចចំនួន ១០ ០០០ ហិកតា របស់ក្រុមហ៊ុន អេស ខេ ផ្លេនថេសិន (ខេមបូឌា) ភីធីអ៊ី អិលធីឌី [SK PLANTATION (CAMBODIA) PTE.LTD] ដែលមានទីតាំងស្ថិតនៅក្នុងស្រុកកូនមុំ និងស្រុកវ៉ឺនសៃ ខេត្តរតនគិរី សម្រាប់ធ្វើការវិនិយោគដាំដំណាំកៅស៊ូ។

ខ-លិខិតលេខ ១៦០១សជណ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីករណីសំណើសុំសម្បទានដីសេដ្ឋកិច្ចចំនួន ១០ ០០០ ហិកតា របស់ក្រុមហ៊ុន អេស ខេ ផ្លេនថេសិន (ខេមបូឌា) ភីធីអ៊ី អិលធីឌី [SK PLANTATION (CAMBODIA) PTE.LTD] ដែលមានទីតាំងស្ថិតនៅក្នុងស្រុកកូនមុំ និងស្រុកវ៉ឺនសៃ ខេត្តរតនគិរី សម្រាប់ធ្វើការវិនិយោគដាំដំណាំកៅស៊ូ។

គ-លិខិតលេខ១៨៩៨/២០១កសក.នផ.ផក ចុះថ្ងៃទី២៣ខែមីនាឆ្នាំ២០១២ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ស្តីពីសំណើសុំអនុញ្ញាតរៀបចំអនុបយោគលើផ្ទៃដីទំហំ ៨០០០ហិកតា របស់ក្រុមហ៊ុន អេស ខេ ផ្លេនថេសិន (ខេមបូឌា) ភីធីអ៊ី អិលធីឌី [SK PLANTATION (CAMBODIA) PTE.LTD] ពីដីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋមកជាដីទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។

ឃ-អនុក្រឹត្យលេខ ៧១ អនក្រ.បក ចុះថ្ងៃ១៨ ខែឧសភា ឆ្នាំ២០១២ របស់រាជរដ្ឋាភិបាល រាជរដ្ឋាភិបាលកម្ពុជាស្តីពី ការធ្វើអនុបយោគផ្ទៃដីទំហំ ៨០០០ ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រស្រុកកូនមុំ និងស្រុកវ៉ឺនសៃ ខេត្តរតនគិរី សម្រាប់ធ្វើការវិនិយោគដំណាំកៅស៊ូ។

ង-លិខិតលេខ ៥០២៥/៤៨២កសក.នផ.ផក ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១២ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីសំណើសុំធ្វើការចុះបញ្ជីនិងធ្វើចំណាត់ថ្នាក់ដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន អេស ខេ ផ្លេនថេសិន (ខេមបូឌា) ភីធីអ៊ី អិលធីឌី [SK PLANTATION (CAMBODIA) PTE.LTD] លើផ្ទៃដីចំនួន ៨០០០ហិកតា ដែលមានទីតាំងស្ថិតនៅក្នុងស្រុកកូនមុំ និងស្រុកវ៉ឺនសៃ ខេត្តរតនគិរី។

ច-លិខិតលេខ ១៧៥៥សជណ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីករណីរបាយការណ៍ស្តីពី លទ្ធផលនៃកិច្ចប្រជុំរបស់គណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែងនិងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច។

ឆ-លិខិតលេខ៣៥៤៥កសក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៥របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ស្តីពីសំណើសុំសិទ្ធប្រទានពីរាជរដ្ឋាភិបាលដើម្បីចុះហត្ថលេខាលើកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចចំនួន ៦៥០៩,២៧ ហិកតា ជូនក្រុមហ៊ុន អេស ខេ

ផ្លេនថេសិន (ខេមបូឌា) ភីធីអ៊ី អិលធីឌី [SK PLANTATION (CAMBODIA) PTE.LTD] ដែលមានទីតាំងស្ថិតនៅក្នុងស្រុកកូនមុំ និងស្រុកវ៉ឺនសៃ ខេត្តរតនគិរីសម្រាប់ ធ្វើការវិនិយោគដាំដំណាំកៅស៊ូ។

ជ-សិទ្ធិប្រទានលេខ ២៩ សប្រទ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៥ របស់រាជរដ្ឋាភិបាលកម្ពុជា ស្ដីពីការប្រគល់សិទ្ធិពេញសមត្ថភាពជូនឯកឧត្ដមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចុះហត្ថលេខាជាតំណាងរាជរដ្ឋាភិបាលកម្ពុជា និងឯកឧត្ដមបណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះហត្ថលេខាបានឃើញ និងយល់ព្រមលើកិច្ចសន្យាដីសម្បទាន ចំនួន ៦៥០៩,២៧ ហិកតា ស្ថិតនៅក្នុងស្រុកកូនមុំ និងស្រុកវ៉ឺនសៃ ខេត្តរតនគិរី សម្រាប់ធ្វើការវិនិយោគដាំដំណាំកៅស៊ូ ជាមួយក្រុមហ៊ុន អេស ខេ ផ្លេនថេសិន (ខេមបូឌា) ភីធីអ៊ី អិលធីឌី [SK PLANTATION (CAMBODIA) PTE.LTD]។

ឈ-លិខិតលេខ ៥៩៨៩កសក ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៥ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្ដីពីករណីសុំបន្ថែមមុខដំណាំកសិ-ឧស្សាហកម្មលើមុខដំណាំផលិតកម្មចម្បងរបស់ក្រុមហ៊ុនអេស ខេ ផ្លេនថេសិន (ខេមបូឌា) ភីធីអ៊ី អិលធីឌី [SK PLANTATION (CAMBODIA) PTE.LTD] ដែលមានទីតាំងស្ថិតនៅក្នុងស្រុកកូនមុំ និងស្រុកវ៉ឺនសៃ ខេត្តរតនគិរី។

ញ-លិខិតលេខ ១០៣១ សជណ ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៥ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី ស្ដីពីករណីសុំបន្ថែមមុខដំណាំកសិ-ឧស្សាហកម្ម លើមុខដំណាំផលិតកម្មចម្បងរបស់ក្រុមហ៊ុនអេស ខេ ផ្លេនថេសិន (ខេមបូឌា) ភីធីអ៊ី អិលធីឌី [SK PLANTATION (CAMBODIA) PTE.LTD] ដែលមានទីតាំងស្ថិតនៅក្នុងស្រុកកូនមុំ និងស្រុកវ៉ឺនសៃ ខេត្តរតនគិរី។

ដ-កិច្ចសន្យាចុះថ្ងៃទី ខែ ឆ្នាំ២០១ ស្ដីពីការវិនិយោគដាំដំណាំកៅស៊ូ កាកាវ ដូង អាកាស្យាសេណោហ្គាល់ និងដំណាំកសិ-ឧស្សាហកម្មផ្សេងៗទៀត រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រុមហ៊ុន អេស ខេ ផ្លេនថេសិន (ខេមបូឌា) ភីធីអ៊ី អិលធីឌី [SK PLANTATION (CAMBODIA) PTE.LTD]។

## ១.៥-ប្រវត្តរបស់ដីសម្បទាន

តំបន់ដីសម្បទានដែលក្រុមហ៊ុនស្នើសុំមានទីតាំងនៅក្នុងឃុំភ្នំកុក ឃុំហាត់ប៉ក់ ស្រុកវ៉ឺនសៃ និងឃុំតឺន ឃុំត្រពាំងក្រហម ស្រុកកូនមុំ ខេត្តរតនគិរី ដែលសព្វថ្ងៃនេះកំពុងបាត់បង់ធនធានធម្មជាតិ និងពុំសូវមានសកម្មភាពសេដ្ឋកិច្ចខ្លាំងក្លាទេ នៅជុំវិញតំបន់ដីសម្បទាន ការអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ចក្នុងតំបន់នេះមានលក្ខណៈ (តាមទីប្រជុំស្រុក) ប្រហាក់ប្រហែលគ្នា គឺការប្រកបរបរកសិកម្ម (ការធ្វើស្រែ និងដំណាំរួមផ្សំ) និងការរុករកផល-អនុផលព្រៃឈើ។

ក្នុងគោលបំណងចូលរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចកសិកម្ម ក៏ដូចជាជួយរក្សាធនធានធម្មជាតិកំពុងបាត់បង់ក្នុងតំបន់ ក្រុមហ៊ុនយើងខ្ញុំបានពិនិត្យលទ្ធភាពវិនិយោគ ហើយបានស្នើសុំដីសម្បទានពីរាជរដ្ឋាភិបាលកម្ពុជា លើផ្ទៃដីទំហំ ១០ ០០០ ហិកតា សម្រាប់ធ្វើការវិនិយោគដាំ

ដំណាំកាការ ដូង អាកាស្យាសេណេហ្គាល់ សណ្តែកសៀង ស្រូវ កៅស៊ូ និងដំណាំកសិឧស្សាហកម្មផ្សេងទៀត ស្ថិតនៅក្នុងស្រុកកូនមុំ និងស្រុកវឺនសៃ ខេត្តរតនគិរី។

យោងតាមសំណើរបស់ក្រុមហ៊ុន អេស ខេ ផ្លេនថេសិន (ខេមបូឌា) ភីធីអ៊ី អិលធីឌី [SK PLANTATION (CAMBODIA) PTE.LTD] ក្រុមជំនាញបច្ចេកទេសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចុះពិនិត្យជាក់ស្តែងនៅតំបន់ដីដែលស្នើសុំដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរដែនដី និងមន្ត្រីជំនាញមូលដ្ឋាន ពិសេសខណ្ឌរដ្ឋបាលព្រៃឈើរតនគិរី និងមន្ទីរកសិកម្មខេត្តរតនគិរី។ ឆ្លងតាមការពិនិត្យជាក់ស្តែងរបស់ក្រុមការងារចុះសិក្សាវាយតម្លៃជាលទ្ធផលលើផ្ទៃដីដែលក្រុមហ៊ុនស្នើសុំចំនួន ១៧០១៤ ហិកតា អាចផ្តល់ជូនក្រុមហ៊ុនធ្វើការវិនិយោគបានត្រឹមតែចំនួន ៨០០០ ហិកតា ប៉ុណ្ណោះ ដោយធ្វើការកាត់ចេញដីស្រែប្រជាពលរដ្ឋ និងដីផ្សេងៗចំនួន ២៦២៧ហិកតា ផ្ទៃដីសហគមន៍ព្រៃឈើចំនួន ១៧៣ហិកតា ផ្ទៃដីជាន់ព្រៃគុបក្នុងស្រុកចំនួន ២៨៨ ហិកតា ផ្ទៃដីព្រៃស្រោង និងពាក់កណ្តាលស្រោងចំនួន ២១៩១ ហិកតា ផ្ទៃដីព្រៃតំបន់ទ្រនាប់ផ្លូវទឹកចំនួន ២២៩១ហិកតា ផ្ទៃដីត្រៀមបម្រុងសម្រាប់សម្បទានសង្គមកិច្ចចំនួន ៥៩៨ហិកតា និងផ្ទៃដីត្រៀមសម្រាប់អត្រាកំណើនប្រជាពលរដ្ឋនៅពេលអនាគតចំនួន ៨៦០ហិកតា។ តាមរយៈលទ្ធផលសិក្សារបស់ក្រុមការងារឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏បានឯកភាពមតិជំនាញ និងបានស្នើសុំគោលការណ៍ពីរាជរដ្ឋាភិបាល ផ្តល់ដីសម្បទានចំនួន **៨០០០ ហិកតា** សម្រាប់ឲ្យក្រុមហ៊ុនធ្វើការវិនិយោគ។ ក្រោយពីបានការឯកភាពឲ្យបន្តនីតិវិធីតាមរយៈលិខិតលេខ ១៧៥៥សជណ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីករណីរបាយការណ៍ស្តីពីលទ្ធផលនៃកិច្ចប្រជុំរបស់គណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ចរួមមកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានលើកសំណើសុំសិទ្ធិប្រទានពីរាជរដ្ឋាភិបាលដើម្បីចុះកិច្ចសន្យាជាមួយក្រុមហ៊ុន។ រាជរដ្ឋាភិបាលបានប្រគល់សិទ្ធិជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ចុះហត្ថលេខាជាតំណាងរាជរដ្ឋាភិបាលកម្ពុជា និងឯកឧត្តមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះហត្ថលេខាបានឃើញ និងយល់ព្រមលើកិច្ចសន្យាដីសម្បទានជាមួយក្រុមហ៊ុនតាមលិខិតលេខ ២៩សប្រទ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៥ និងបានចុះហត្ថលេខាលើកិច្ចសន្យា ជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៅថ្ងៃទី ខែ ........ឆ្នាំ២០១ ។

## ២- លក្ខណៈអាកាសធាតុ

### ២.១-របបទឹកភ្លៀង

បរិមាណទឹកភ្លៀងដើរតួយ៉ាងសំខាន់លើការលូតលាស់ឬដាំដុះនៃរុក្ខជាតិ និងដំណាំកសិឧស្សាហកម្មនានាដែលត្រូវការបរិមាណទឹកភ្លៀងផ្សេងៗពីគ្នាក្នុងវដ្តជីវិតរបស់វា។ បរិមាណទឹកភ្លៀងមានតួនាទីសំខាន់ក្នុងការកំណត់ទិន្នផល និងបរិមាណផលរបស់ដំណាំឬរុក្ខជាតិនានា។ របបទឹកភ្លៀងនៅប្រទេសកម្ពុជាមានទំនាក់ទំនងយ៉ាងជិតស្និទនឹងរបបខ្យល់មូសុង នៅពេលខ្យល់បក់ពីទិសនីរតី ទៅទិសឦសាន្ត គឺពីខែឧសភា ដល់ខែតុលាដែលខ្យល់នាំទឹកភ្លៀងមកជាមួយ។ យោងតាមទិន្នន័យខាងក្រោមនេះយើងឃើញថា បរិមាណទឹកភ្លៀងជាមធ្យមច្រើនឆ្នាំមានចំនួន ២១៤១,៩មីលីម៉ែត្រ (ប្រភព: Agriculture du Cambodge, TICHIT) និងអាចបញ្ជាក់បានថាតំបន់ដែលស្នើសុំជាតំបន់ខ្ពង់រាបខ្ពស់ក្តៅហើយសើម មានបរិមាណទឹកភ្លៀងគ្រប់គ្រាន់សម្រាប់ជួយដល់ការលូតលាស់រុក្ខជាតិ។

## តារាងបរិមាណទឹកភ្លៀងពង្រាយតាមខែជាមធ្យមប្រចាំឆ្នាំ

| មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|
| 0 | 8 | 17.6 | 106.5 | 231.5 | 283.1 | 433.1 | 369.1 | 504.1 | 149.3 | 34.7 | 12 | 2141.9 |

## តារាងបរិមាណទឹកភ្លៀងខេត្តរតនគិរីពីឆ្នាំ ២០០៦-២០១៤

| ឆ្នាំ | បរិមាណទឹកភ្លៀងគិតជាមីលីម៉ែត្រ | ផ្សេងៗ |
|---|---|---|
| ២០០៦ | ៣,១៨៩.៤ | ស្ថានីយ៍រតនគិរី |
| ២០០៧ | ១,៩៨៦ | ស្ថានីយ៍រតនគិរី |
| ២០០៨ | ២,០៧០.៣ | ស្ថានីយ៍រតនគិរី |
| ២០០៩ | ២,៣៤៨ | ស្ថានីយ៍រតនគិរី |
| ២០១០ | ១,៦៥៩ | ស្ថានីយ៍រតនគិរី |
| ២០១១ | ១,៩៤៧ | ស្ថានីយ៍រតនគិរី |
| ២០១២ | ២,៥០១.៩ | ស្ថានីយ៍រតនគិរី |
| ២០១៣ | ២,៦៨៣.១ | ស្ថានីយ៍រតនគិរី |
| ២០១៤ | ១,៩១៨.៥ | ស្ថានីយ៍រតនគិរី |
| មធ្យមរយៈពេល០៩ ឆ្នាំ២,១៩១.៩ ម.ម | | |

Draft

### ២.២-សីតុណ្ហភាព

សីតុណ្ហភាពរបស់ខេត្តរតនគិរី មានកម្រិតសីតុណ្ហភាពប្រែប្រួលចន្លោះពីកម្រិតអប្បរមាពី ១៩.១០ អង្សាសេ ទៅអតិបរមា ២២.១០ អង្សាសេ។ កម្រិតសីតុណ្ហភាពមធ្យមប្រចាំឆ្នាំមានក្នុងចន្លោះ ២៧,០៦ ទៅ ២៩,៤៩ អង្សាសេ។

យើងឃើញថាសីតុណ្ហភាពមធ្យមប្រចាំឆ្នាំរបស់ខេត្តរតនគិរី មានកម្រិតដែលអាចធ្វើដំណាំលូតលាស់បានជាពិសេសដំណាំកៅស៊ូ និងដំណាំកសិ-ឧស្សាហកម្មផ្សេងៗទៀតព្រោះប្រសិនបើសីតុណ្ហភាពខ្ពស់ជាង៤០អង្សាសេ នោះនឹងបណ្តាលឲ្យស្លឹករុក្ខជាតិក្រៀមតែបើទាបរហូតដល់ ១០ អង្សាសេ នោះធ្វើឲ្យដំណាំរស់បានរយៈពេលខ្លីបើកំដៅថ្ងៃមិនសូវមានគម្លាតធំក្នុងការប្រែប្រួលនោះដំណាំផ្តល់ផលល្អ។

### ២.៣-សំណើមបរិយាកាស

តាមរយៈការសិក្សានិងទិន្នន័យ ទទួលបានពីការកត់ត្រាកន្លងមកពិនិត្យឃើញថាតំបន់គម្រោងវិនិយោគមានសំណើម ៧៩,០ភាគរយ។ សំណើមមានកម្រិតទាបយ៉ាងខ្លាំងនៅរដូវប្រាំងគឺនៅក្នុងខែមករា បន្ទាប់ពីមានខ្យល់មូសុងត្រជាក់បក់ពីទិសខាងជើងឈៀងខាងកើត និងខែមេសាដែលមានកំរិតចន្លោះពី ៦៤,៨ ភាគរយទៅ ៦៧,៥ ភាគរយ ក្នុង ១ ថ្ងៃ។

## ២.៤-កំដៅថ្ងៃ

ពន្លឺថ្ងៃជាផ្នែកមួយរបស់អាកាសធាតុ និងដើរតួនាទីយ៉ាងសំខាន់សម្រាប់ឲ្យដំណាំធ្វើរស្មីសំយោគក្លរ៉ូភីលដើម្បីបំពេញតួនាទីឲ្យរុក្ខជាតិមានពណ៌បៃតងនិងរឹងមាំ។តំបន់ដីសម្បទានដែលស្ថិតនៅក្នុងស្រុកកូនមុំ ខេត្តរតនគិរីអាចនឹងទទួលពន្លឺថ្ងៃជាមធ្យមប្រហែល៥,៤ម៉ោងក្នុង១ថ្ងៃនិងប្រមាណជាង ២០០០ម៉ោងក្នុង១ឆ្នាំ ដែលកំរិតនេះមានការកាន់តែកើនឡើងនៅចន្លោះខែឧសភា និងខែវិច្ឆិកា គឺពី ៥,៥ ទៅ ៧ម៉ោង ក្នុង១ថ្ងៃ និងជាមធ្យមគឺ៦,២ម៉ោងក្នុង១ថ្ងៃ។

# ៣-ស្ថានភាពដី និងប្រភេទដី

## ៣.១-ស្ថានភាពប្រភេទដី

ដោយយោងតាមលក្ខណៈដី និងឯកសារលេខា និងផែនទីចំណាត់ថ្នាក់ប្រភេទដីបង្ហាញឲ្យឃើញថាទំហំដីសម្បទានចំនួន ១៧ ០១៤ ហិកតា មានប្រភេទដីចំនួន ៤ ប្រភេទគឺ

**តារាង ១.១ បង្ហាញស្ថានភាពប្រភេទដី**

| លរ | ចំណាត់ថ្នាក់ប្រភេទដី | ទំហំ (ហិកតា) | ភាគរយ (%) |
|---|---|---|---|
| 1 | Acid Lithosols | ៦៧៩១ | ៣៩,៩១ |
| 2 | Grey hydromorphics | ៩០២២ | ៥៣,០៣ |
| 3 | Plinthite podxols | ១២០១ | ៧,០៦ |
| **សរុប** | | **១៧០១៤** | **១០០** |

## ៣.២-ស្ថានភាពប្រភេទដីជាតិដី

តាមការសង្កេតរបស់ក្រុមស្រាវជ្រាវបានបង្ហាញថា ជាទូទៅប្រភេទដីនៅតំបន់សម្បទាននេះជាប្រភេទដីមានថ្មបាយក្រៀមនៅស្រទាប់លើ (១-៥ស.ម) ជាពិសេសនៅតាមមាត់អូរ ឬ ផុសឡើងខ្លាំងដោយការហូរច្រោះ។ ជាប្រភេទដីល្បាយខ្សាច់លាយក្រួស ឬ និងដីល្បាប់ខ្មៅដោយកន្លែងដែលជាប្រដីមានដីជាតិសមសម្រួបសម្រាប់ដំណាំកសិ-ឧស្សាហកម្ម ដូចជាដំណាំកាកាវ ដូង អាកាស្យាសេណោហ្គាល់ សណ្តែកសៀង ស្រូវ កៅស៊ូ និងដំណាំកសិ-ឧស្សាហកម្មផ្សេងៗ។ ចំណាត់ថ្នាក់ប្រភេទដីជាតិដីក្នុងតំបន់សម្បទានទាំងមូលមានតែ ២ប្រភេទគឺ

**តារាង ១.២ បង្ហាញចំណាត់ថ្នាក់ប្រភេទដីជាតិដី**

| ល.រ | ចំណាត់ថ្នាក់ប្រភេទដី | ទំហំ (ហិកតា) | ភាគរយ (%) |
|---|---|---|---|
| 1 | High Productivity soil | ៩០៣៣ | ៥៣,០៩ |
| 2 | Low Productivity soil | ៧៩៨១ | ៤៦,៩១ |
| **សរុប** | | **១៧០១៤** | **១០០** |

# ៤-ស្ថានភាពសេដ្ឋកិច្ច

## ៤.១-វិស័យសេដ្ឋកិច្ច និងពាណិជ្ជកម្ម

ការអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ចក្នុងតំបន់នេះមានលក្ខណៈខុសៗ គ្នាទៅតាមទីប្រជុំជនខេត្ត ស្រុក និងជនបទ។ ប្រជាជនឃុំភ្នំកុក ឃុំហាត់ប៉ក់ ឃុំតឺន និងឃុំត្រពាំងក្រហម ស្ទើរតែទាំងអស់រស់នៅក្នុងតំបន់ស្នូល និងតំបន់រណប នៃដីសម្បទានសេដ្ឋកិច្ចដែលក្រុមហ៊ុនស្នើសុំនេះ ក្រៅពីការប្រកបរបរធ្វើស្រែនិងការរុករកផល-អនុផលព្រៃឈើក្រោយពីប្រមូលផលស្រូវរួចមានគ្រួសារខ្លះ ប្រកបរបរលក់ដូរបន្តិចបន្តួចតាមដងផ្លូវ៧៨អា ពីអូរពងមាន់-ខេត្តរតនគិរី-កូនមុំ-វ៉ឺនសៃ សម្រាប់បម្រើតម្រូវការក្នុងភូមិឃុំនិងអ្នកដំណើរ។ មានគ្រួសារខ្លះទៀតដាំដំណាំ និង បន្លែបង្ការបន្តិចបន្តួចក្បែរៗផ្ទះ (ក្បែរអណ្តូងខ្ទោះ និងតាមដងអូរ) សម្រាប់ផ្គត់ផ្គង់សេចក្តីត្រូវក្នុងគ្រួសារ និងដោះដូរជាមួយអ្នកភូមិផងរបងជាមួយ។

សេដ្ឋកិច្ចក្នុងតំបន់មានលក្ខណៈជាសេដ្ឋកិច្ចជនបទលើកលែងតែទីរួមខេត្តចេញ ដែលការប្រកបមុខរបរមានទ្រង់ទ្រាយពាណិជ្ជកម្ម។ ចំណូលប្រចាំឆ្នាំរបស់គ្រួសារក្នុងសហគមន៍មានលក្ខណៈផ្សេងៗគ្នាអាស្រ័យទៅនឹងការប្រកបមុខរបររបស់គ្រួសារនីមួយៗ។ ការវាយតម្លៃអំពីភាពក្រីក្របានបង្ហាញថាអត្រានៃភាពក្រីក្រនៅក្នុងខេត្តរតនគិរីមាន ៨.៨០ ភាគរយ (៨.១០ ពាន់) លើចំនួនប្រជាជនសរុប ១២៤.៤០៣ នាក់ ក្នុងនោះមាន ១១១.២៧៩នាក់ និងស្មើនឹង ៩០ ភាគរយ រស់នៅជនបទ (ផែនទីភាពក្រីក្ររបស់កម្មវិធីស្បៀង អង្គការសហប្រជាជាតិ ឆ្នាំ ២០០៥-២០០៦ និងប្រព័ន្ធទិន្នន័យសហគមន៍ឆ្នាំ២០០៨)។ ចំនួនអ្នកមិនចេះអក្សរនៅខេត្ត រតនគិរីទាំងមូលមានចំនួន៤៣.០១០នាក់ក្នុងនោះមាន (បុរស១៩.៤១៥នាក់ និងស្រី២៣.៥៩៥នាក់)។

## ៤.២-វិស័យកសិកម្ម

ក្នុងដំណើរការឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយនិរន្តភាព ឆ្លើយតបតម្រូវការទាំងបរិមាណនិងគុណភាពសម្រាប់សុខុមាលភាពសាធារណៈ ផលិតភាពកសិកម្មជាកត្តាអាទិភាពចំបង។ ការធ្វើផលិតកម្មដំណាំកសិ-ឧស្សាហកម្ម គឺជាសក្តានុពលចំបងផងដែរសម្រាប់ការផ្គត់ផ្គង់ដល់តម្រូវការក្នុងស្រុកនិងការកាត់បន្ថយភាពក្រីក្រ។ តាមប្រភពព័ត៌មានពីមន្ទីរកសិកម្មខេត្តរតនគិរីបានឲ្យដឹងថា ផលិតកម្មកសិកម្មមានការរីកចម្រើននិងមានភាពល្អូតលាស់គួរឲ្យកត់សម្គាល់។

- នៅក្នុងឆ្នាំ២០១៤-២០១៥ ផ្ទៃដីកសិកម្មដំណាំស្រូវមានប្រមាណ២៦.០៦៦ ហិកតា ហើយអាចប្រមូលផលបានលើផ្ទៃដី ២៥.៩១៨ ហិកតា។ ទិន្នផលមធ្យមត្រូវបានប៉ាន់ស្មានប្រហែល ២.៤៤៨ តោនក្នុងមួយហិកតា។ បរិមាណផលស្រូវដែលខេត្តផលិតបានមានចំនួន ៦៣.៤៥៣ តោន (របាយការណ៍ស្ថិតិកសិកម្មឆ្នាំ២០១៤-២០១៥)។ តម្រូវការស្បៀងគិតជាអង្ករសម្រាប់ការហូបចុករបស់ប្រជាពលរដ្ឋក្នុងខេត្តមានចំនួន ២៨.៤០៧តោន។ លទ្ធភាពផ្គត់ផ្គង់ស្បៀងរបស់ខេត្តមានរហូតដល់ ៣៥.៣៣១តោនអង្ករ ដែលធ្វើឲ្យខេត្តអាចធានាការហូបចុករបស់ប្រជាពលរដ្ឋ និងអាចសល់ស្បៀងប្រមាណ ៦.៩២៤ តោនអង្ករផងដែរ។
- ក្រៅពីផលិតកម្មស្រូវប្រជាពលរដ្ឋខេត្តរតនគិរីបានផលិតដំណាំរួមផ្សំ និងដំណាំកសិ-ឧស្សាហកម្មផ្សេងៗទៀតដូចជា ពោត ដំឡូងមី សណ្តែកដី បន្លែគ្រប់មុខ

Draft

សណ្តែកបាយ សណ្តែកសៀង ដំឡូងជ្វា ល្ង ថ្នាំជក់ អំពៅ .........។ល។ លើផ្ទៃដី ប្រមាណជាង ២៣.៣០៩ ហិកតា។

- ផលិតកម្មសត្វ ៖ គោសរុបចំនួន ៣០.៤៣២ក្បាល (កម្លាំងអូសទាញមានចំនួន ១.៣៦១ក្បាល) ក្របី ១៤.៦៧៦ក្បាល(កម្លាំងអូសទាញមានចំនួន ៣.០១៥ក្បាល) ការចិញ្ចឹមជ្រូកមានចំនួន ៣២.២៩២ក្បាល (មេជ្រូកចំនួន ៩.០៤៨ក្បាល) សេះមាន ចំនួន ៥ក្បាល ពពែមានចំនួន ១១៣ក្បាល (ញី ៧៦ក្បាល)។ ការចិញ្ចឹមសត្វមាន់-ទា បានចំនួន ១១៧.៦៥៧ ក្បាល ក្ងានមានចំនួន ១៤៣ក្បាល ព្រាបចំនួន៤២៤ក្បាល។

### ៤.៣-វិស័យសាធារណៈ និង ដឹកជញ្ជូន

*** ផ្លូវគោក**

ការធ្វើដំណើរនិងដឹកជញ្ជូននៅក្នុងតំបន់គម្រោងភាគច្រើន គឺប្រើប្រាស់ផ្លូវជាតិលេខ៦ (ភ្នំពេញ-ស្រុកជើងព្រៃ) លេខ៧ (ស្រុកជើងព្រៃ-ស្ទឹងត្រែង) និងលេខ៧៨ (អូរពងមាន់-រតនគិរី) ដែលជាផ្លូវយ៉ាងសំខាន់នៅតំបន់នេះ។ ផ្លូវដែលភ្ជាប់ផ្លូវជាតិទៅកាន់ទីរួមខេត្តរតនគិរី ជាផ្លូវដី ក្រាលគ្រួសក្រហមដោយអន្លើ ហើយផ្លូវមានសភាពទ្រុឌទ្រោម និងខូចខាតដោយកន្លែងជា ពិសេសនៅរដូវវស្សាមានសភាពបែកភក់ និងរដូវប្រាំងហុយទ្រលោម។ ចំណែកឯការធ្វើ ដំណើរពីផ្លូវជាតិទៅកាន់ឃុំនិងភូមិនានានៅក្នុងស្រុកកូនមុំ និងស្រុករ៉ុនសៃ ក៏រឹតតែមានការ លំបាកខ្លាំងថែមទៀត។ដោយសារតែការធ្វើដំណើរចេញចូលមានលក្ខណៈលំបាក ដូច្នេះហើយ ទើបធ្វើឲ្យការប្រាស្រ័យទាក់ទងរវាងសហគមន៍ទាំងនេះ ជាមួយនឹងតំបន់ខាងក្រៅពុំមានលក្ខណៈ ទូលំទូលាយដែលជាមូលហេតុទទួលបានការយកចិត្តទុកដាក់តិចតួចពីបណ្តាភ្នាក់ងារអភិវឌ្ឍន៍ ផ្សេងៗ។

***ផ្លូវទឹក**

ខេត្តរតនគិរី មានផ្លូវទឹកសំខាន់ៗ ចំនួនពីរគឺ ទន្លេសេសាន្ត ទន្លេស្រែពក ក្រៅពីនេះនៅមាន អូរ ស្ទឹង ព្រែកផ្សេងៗទៀត។ ព្រែក និងអូរទាំងនេះ មានប្រភពពីទន្លេមេគង្គ ដែលជាលក្ខណៈ អំណោយផលដល់ការផ្តល់ប្រភពទឹកសម្រាប់ធ្វើការស្រោចស្រពក្នុងការដាំដំណាំ។

***ផ្លូវអាកាស**

ខេត្តរតនគិរី មានព្រលានយន្តហោះថ្នាក់ជាតិមួយកន្លែង ដែលរដ្ឋលេខាធិការដ្ឋាន អាកាសចរណ៍ស៊ីវិលមានគម្រោងអភិវឌ្ឍន៍ព្រលាននោះ។ ព្រលាននោះមានខ្នាត MC និងអាច ឲ្យយន្តហោះប្រភេទ ATR72, AN 24, Y7, Y12 អាចចុះចតបាន។

***ថាមពល និងទឹកស្អាត**

ចំពោះថាមពលក្នុងការប្រើប្រាស់សម្រាប់ដុតបំភ្លឺសព្វថ្ងៃនេះ ប្រជាជននៅក្នុងឃុំភ្នំកុក ឃុំហាត់ប៉ក់ ឃុំតឺន និងឃុំត្រពាំងក្រហម ពុំបានទទួលការផ្គត់ផ្គង់អគ្គីសនីជាមូលដ្ឋានទេ នៅ ក្នុងឃុំទាំងមូលភាគច្រើនប្រើប្រាស់អាគុយប្រមាណ ៧៥ភាគរយ ប្រើម៉ាស៊ីនភ្លើង ៥ភាគរយ និងប្រើចង្កៀងប្រេងកាតប្រមាណ ២០-៣០ ភាគរយ ។ ចំណែកឯការចំអិនអាហារវិញគឺពួក គាត់ប្រើអុសដែលរកបានពីព្រៃនៅក្បែរភូមិ។

លទ្ធភាពនៃការប្រើប្រាស់ទឹកស្អាតរបស់ប្រជាជននៅតំបន់នេះ នៅមានកម្រិតទាបនៅ ឡើយបើយើងប្រៀបធៀបទៅនឹងលទ្ធភាពរបស់ប្រជាជនដែលរស់នៅតាមទីប្រជុំនានា។ មាន តែប្រជាពលរដ្ឋប្រមាណ ៣០ គ្រួសារ ប៉ុណ្ណោះប្រើប្រាស់ទឹកអណ្តូងស្នប់ចំនួន៥ ដែលជាការ



Draft

ឧបត្ថម្ភដោយអង្គការ CPA ក្រៅពីនោះពួកគាត់ប្រើប្រាស់ទឹកទន្លេស្រែពកទឹកអូរ ឬទឹកភ្លៀងនៅរដូវវស្សាដែលពុំទាន់មានអនាម័យត្រឹមត្រូវនៅឡើយ។

### ៤.៤-វិស័យទេសចរណ៍

វិស័យទេសចរណ៍នៅក្នុងខេត្តរតនគិរី មានសម្បត្តិវប្បធម៌ និងសម្បត្តិធម្មជាតិជាច្រើនកន្លែងដូចជា រមណីយដ្ឋានបឹងយក្សលោម បឹងកន្សែង បឹងលុមកត់ ទឹកធ្លាក់កញ្ចាញ ទឹកធ្លាក់កាទៀង ទឹកធ្លាក់ចាអុងវាលស្មៅ វ៉ឺនសៃ ភ្នំឥស្សី បាតាម៉ា ជ្រោះចាលយ និងសឹងទ្បេ បានទាក់ទាញភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិ មកទស្សនាកាន់តែច្រើនឡើងៗ។

## ៥-ស្ថានភាពសង្គមកិច្ច

### ៥.១-វិស័យអប់រំ

បច្ចុប្បន្ននេះខេត្តរតនគិរីមានសាលារៀនចំណេះទូទៅចាប់ពីកម្រិតមត្តេយ្យសិក្សារហូតដល់វិទ្យាល័យ។ ដោយឡែកឯការអប់រំសិក្សាវិញនៅក្នុងភូមិដែលពាក់ព័ន្ធនៃតំបន់គម្រោងស្នើសុំជាទូទៅនៅកម្រិតបឋមសិក្សា និងអនុវិទ្យាល័យមិនសូវជួបការលំបាកប៉ុន្មានទេ (ដោយឡែកនៅភូមិឡាំប៉ាត់ មិនទាន់មានសាលាបឋមសិក្សានៅឡើយធ្វើឲ្យក្មេងទាំងអស់នោះមិនបានរៀនសូត្រទេ)។ ចំពោះសិស្សាអនុសិស្សដែលត្រូវបន្តការសិក្សានៅកម្រិតវិទ្យាល័យមានការលំបាកសម្រាប់សិស្សដែលនៅឆ្ងាយគួបផ្សំនឹងកង្វះខាតមធ្យោបាយធ្វើដំណើរផងនោះ ជាមូលហេតុបណ្តាលឲ្យសិស្សមួយចំនួនបង្ខំចិត្តបោះបង់ការសិក្សាទាំងភាពសោកស្តាយ ព្រោះត្រូវបន្តទៅការសិក្សានៅទីរួមខេត្តដែលមានចម្ងាយប្រមាណជា ៤៥-៥៨គីឡូម៉ែត្រពីឃុំ។

### ៥.២-វិស័យសុខាភិបាល

នៅខេត្តរតនគិរី មានមណ្ឌលសុខភាពមានមន្ទីរពេទ្យបង្អែកនៅទីរួមខេត្ត និងនៅទីរួមស្រុក។ ហើយបច្ចុប្បន្នមន្ទីរសុខាភិបាលខេត្តកំពុងលើកផែនការកសាងមន្ទីរពេទ្យបង្អែកបន្ថែមទៀត។ លទ្ធភាពក្នុងការប្រើប្រាស់សេវាសុខភាពនៅតំបន់នោះមិនទាន់មានលក្ខណៈល្អប្រសើរ និងផ្តល់លទ្ធភាពដល់ប្រជាពលរដ្ឋទទួលសេវាទាំងនេះបានពេញលេញនៅឡើយទេ។ ជាក់ស្តែងនៅពេលមានសមាជិកគ្រួសារណាម្នាក់មានជំងឺនឹងត្រូវបញ្ជូនទៅពិនិត្យព្យាបាល នៅទីរួមស្រុកដែលមានចម្ងាយប្រមាណ ៨-៣២គីឡូម៉ែត្រ ពីឃុំភ្នំកុកនិងពីឃុំហាត់ប៉ក់ ឬមណ្ឌលសុខភាពស្រុកកូនមុំ។ បើអ្នកជំងឺមានសភាពធ្ងន់ធ្ងរត្រូវបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យខេត្ត ឬទៅភ្នំពេញតែម្តង។

## ៦-ស្ថានភាពព្រៃឈើក្នុងតំបន់ដីសម្បទាន

ដោយផ្អែកតាមរបាយការណ៍ចុះសិក្សា និងវាយតម្លៃ ដីសម្បទានដែលត្រូវផ្តល់ឲ្យក្រុមហ៊ុនអេស ខេ ផ្លេនថេសិន (ខេមបូឌា) ភីធីអ៊ី អិលធីឌី [SK PLANTATION (CAMBODIA) PTE.LTD] ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១១ របស់ក្រុមការងារលេខាធិការដ្ឋានបច្ចេកទេសសម្រាប់ដីសម្បទានសេដ្ឋកិច្ច និងតាមទិន្នន័យទទួលបានពីការបកស្រាយតាមរូបភាពផ្កាយរណបរបស់សហរដ្ឋអាមេរិក LANDSAT ETM ឆ្នាំ២០០៦ បានបង្ហាញថា ទីតាំងស្នើសុំនេះមានគម្របព្រៃឈើចំនួន ៦ ប្រភេទ ដូចក្នុងតារាងខាងក្រោម៖

| | | | |
|---|---|---|---|
| - ព្រៃស្រោង | ៣.២២៣ ហិកតា | ស្មើនឹង | ១៨,៩៤ ភាគរយ |
| - ព្រៃពាក់កណ្ដាលស្រោង | ១.៥៨៤ ហិកតា | ស្មើនឹង | ៩,៣១ ភាគរយ |
| - ព្រៃល្បោះ | ១០.១៣០ ហិកតា | ស្មើនឹង | ៥៩,៥៤ ភាគរយ |
| - ព្រៃគម្ពោតស្ងួត | ៣៥ ហិកតា | ស្មើនឹង | ០,២១ ភាគរយ |
| - ព្រៃគម្ពោតបៃតង | ៧៧ ហិកតា | ស្មើនឹង | ០,៤៥ ភាគរយ |
| - ព្រៃមិនមានគម្របព្រៃ | ១.៩៦៥ ហិកតា | ស្មើនឹង | ១១,៥៥ ភាគរយ |
| **សរុបរួម៖ ១៧.០១៤ ហិកតា** | | **ស្មើនឹង** | **១០០ ភាគរយ** |

ផ្អែកតាមលទ្ធផលដែលបានមកពីការសិក្សាធនធានព្រៃឈើ តាមរយៈការធ្វើសារពើភ័ណ្ឌវាស់វាប់ដើមឈើ នៅទីវាលជាក់ស្ដែង និងការវិភាគទិន្នន័យបានបង្ហាញឲ្យឃើញថា៖

**- ព្រៃស្រោង**

- ឈើដែលមានអង្កត់ផ្ចិតចាប់ពី ៥០ស.ម ឡើងមានចំនួន ១៤ ប្រភេទ ចំនួនដើមជាមធ្យមមាន៧ដើម/ហិកតា ស្មើនឹង ១២ម³០៦៥ ហើយគុណភាពឈើប្រភេទ A មានអត្រាស្មើ៣៤,៧៧% ប្រភេទ B មានអត្រាស្មើនឹង ៦១,៥៥% ប្រភេទ C មានអត្រាស្មើនឹង ០៣,៦៧%។
- ឈើដែលមានអង្កត់ផ្ចិតចាប់ពី ៣០-៤៩ស.ម មានចំនួន ២០ប្រភេទ ចំនួនដើមជាមធ្យមមាន ៤៧ ដើម/ហិកតា ស្មើនឹង ៣៤ម³៦៣៨ ហើយគុណភាពឈើប្រភេទ A មានអត្រា ស្មើ៣០,៤៦% ប្រភេទ B មានអត្រាស្មើនឹង ៦៥,៦៩% ប្រភេទ C មានអត្រាស្មើនឹង ០៣,៨៥%។
- ឈើដែលមានអង្កត់ផ្ចិតចាប់ពី ១០-២៩ ស.ម មានចំនួន ២៧ ប្រភេទ ចំនួនដើមជាមធ្យមមាន ២០០ ដើម/ហិកតា ស្មើនឹង ២៥ម³១៩៣ ហើយគុណភាពឈើប្រភេទA មានអត្រាស្មើ ២៨,៨៦% ប្រភេទ B មានអត្រាស្មើនឹង ៦៨,៣៤% ប្រភេទ C មានអត្រាស្មើនឹង ០២,៨០%។

**- ព្រៃពាក់កណ្ដាលស្រោង**

- ឈើដែលមានអង្កត់ផ្ចិតចាប់ពី ៥០ស.ម ឡើង មានចំនួន ០៧ ប្រភេទ ចំនួនដើមជាមធ្យមមាន ០៣ដើម/ហិកតា ស្មើនឹង ០៤ម³២៨៥ ហើយគុណភាពឈើប្រភេទ A មានអត្រាស្មើ ០៧,០៦% ប្រភេទ B មានអត្រាស្មើនឹង ៧៣,៩១% ប្រភេទ C មានអត្រាស្មើនឹង ១៩,០៣%។
- ឈើដែលមានអង្កត់ផ្ចិតចាប់ពី ៣០-៤៩ស.ម មានចំនួន ២០ប្រភេទ ចំនួនដើមជាមធ្យមមាន ៤៧ដើម/ហិកតា ស្មើនឹង ៣៤ម³៤១៥ ហើយគុណភាពឈើប្រភេទ A មានអត្រាស្មើ ២៧,២៦% ប្រភេទ B មានអត្រាស្មើនឹង ៦១,១៩% ប្រភេទ C មានអត្រា ស្មើនឹង ១១,៥៥%។
- ឈើដែលមានអង្កត់ផ្ចិតចាប់ពី ១០-២៩ស.ម មានចំនួន ២២ប្រភេទ ចំនួនដើមជាមធ្យមមាន ១៧១ដើម/ហិកតា ស្មើនឹង ៣៣ម³៧១៣ ហើយគុណភាពឈើប្រភេទ A មានអត្រាស្មើ ១៣,៣៧% ប្រភេទ B មានអត្រាស្មើនឹង ៧៣,២៧% ប្រភេទ C មានអត្រាស្មើនឹង ១៣,៣៧%។

Draft

- **ព្រៃល្បោះ**
  - ឈើដែលមានអង្កត់ផ្ចិតចាប់ពី ៥០ស.ម ឡើងមានចំនួន១៦ប្រភេទ ចំនួនដើមជាមធ្យម មាន ០២ដើម/ហិកតា ស្មើនឹង ០៤ម៉ែ៣១១៥ ហើយគុណភាពឈើប្រភេទ A មានអត្រាស្មើ ៣៤,៤៧% ប្រភេទ B មានអត្រាស្មើនឹង ៥៧,៥៥% ប្រភេទ C មានអត្រាស្មើនឹង ០៧,០៩៨%។
  - ឈើដែលមានអង្កត់ផ្ចិតចាប់ពី ៣០-៤៩ស.ម មានចំនួន ៣៣ប្រភេទ ចំនួនដើមជាមធ្យម មាន ៣៤ដើម/ហិកតា ស្មើនឹង ១៩ម៣៩៨១ ហើយគុណភាពឈើប្រភេទ A មានអត្រាស្មើ ២៦,០៤% ប្រភេទ B មានអត្រាស្មើនឹង ៧០,៦៤ % ប្រភេទ C មានអត្រាស្មើនឹង ០៣,៣២%។
  - ឈើដែលមានអង្កត់ផ្ចិតចាប់ពី ១០-២៩ស.ម មានចំនួន ៣៨ប្រភេទ ចំនួនដើមជាមធ្យមមាន ១៥៨ដើម/ហិកតា ស្មើនឹង ២២ម៣ ៧៨១ ហើយគុណភាពឈើប្រភេទ A មានអត្រាស្មើ ១១,៦៥% ប្រភេទ B មានអត្រាស្មើនឹង ៨០,០៨% ប្រភេទ C មានអត្រាស្មើនឹង ០៨,២៧%។

Draft

## ជំពូក II ផែនការរៀបចំ និងការគ្រប់គ្រងនៃសម្បទាន

ក្រុមហ៊ុន អេស ខេ ផ្លេនថេសិន (ខេមបូឌា) ភីធីអ៊ី អិលធីឌី [SK PLANTATION (CAMBODIA) PTE.LTD] ធ្វើវិនិយោគលើដីសម្បទាននេះ គឺដើម្បីពង្រីកអាជីវកម្មរបស់ខ្លួន និងគោលដៅចម្បងនៃការធ្វើវិនិយោគសំដៅចូលរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចកសិកម្មប្រកបដោយនិរន្តរភាព ការពារបរិស្ថានសង្គម និងជួយកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជាតាមរយៈការវិនិយោគស្តារ និងបង្កើនផលិតកម្មកសិ-ឧស្សាហកម្ម ដោយធ្វើការអភិវឌ្ឍចម្ការដូង កាកាវ ស្រូវ អាកាស្យាសេណោហ្គាល់ សណ្តែកសៀង កៅស៊ូ និងកសិ-ឧស្សាហកម្មផ្សេងៗ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពសេដ្ឋកិច្ចនៃព្រៃរិចរិល និងកែលម្អរិស្ថានធម្មជាតិដោយការបង្កើត ឡើងនូវចម្ការដូង កាកាវ អាកាស្យាសេណោហ្គាល់ សណ្តែកសៀង ស្រូវ កៅស៊ូ និងកសិ-ឧស្សាហកម្មផ្សេងៗ និងការសាងសង់រោងចក្រកែច្នៃផលិតផល។ ដោយសង្កេតឃើញបណ្តាប្រទេសមួយចំនួននៅសហគមន៍អាស៊ាន បានបង្វែរយុទ្ធសាស្ត្រមកធ្វើការដាំដំណាំដូង កាកាវ សណ្តែកសៀង ស្រូវ អាកាស្យាសេណោហ្គាល់ កៅស៊ូ និងកសិ-ឧស្សាហកម្មផ្សេងៗ ដោយមូលហេតុមានតម្រូវការលើផលិតកៅស៊ូក្នុងទីផ្សារអន្តរជាតិ ហើយដំណាំទាំងនោះក៏មានតួនាទីមកជំនួសជាគម្របព្រៃឈើដែលអាចបង្កើតឲ្យមានបរិស្ថានល្អផងដែរ។ គោលបំណងលម្អិតនៃសម្បទាននេះមានដូចខាងក្រោម៖

### ១-គោលបំណង នៃការធ្វើវិនិយោគ

- បង្កើនផលិតភាពកសិកម្ម លើផ្ទៃដីព្រៃដែលត្រូវបានកាប់បំផ្លាញរេចរិល ក្នុងតំបន់សម្បទានតាមរយៈការអភិវឌ្ឍន៍ដាំដុះដំណាំដូង កាកាវ អាកាស្យាសេណោហ្គាល់ ស្រូវ សណ្តែកសៀង និងកៅស៊ូ ជាលក្ខណៈកសិ-ឧស្សាហកម្ម។
- ពង្រីកគម្របព្រៃដែលបានបាត់បង់ដោយការកាប់បំផ្លាញអនាធិបតេយ្យកន្លងមកជំនួសដោយព្រៃដូង កាកាវ អាកាស្យាសេណោហ្គាល់ សណ្តែកសៀង ស្រូវ និងកៅស៊ូ សំដៅបង្កើនបរិមាណគម្របព្រៃឈើឡើងវិញ។
- រួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទបង្កើនប្រាក់ចំណូលដល់ប្រជាពលរដ្ឋ ពិសេសប្រជាកសិករដែលរស់នៅក្បែរតំបន់ដីសម្បទាន ក្នុងទិសដៅកាត់បន្ថយភាពក្រីក្រស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។
- ជំរុញការកែច្នៃផលិតផលដំណាំដូង កាកាវ អាកាស្យាសេណោហ្គាល់ សណ្តែកសៀង ស្រូវ និងកៅស៊ូ សម្រាប់ផ្គត់ផ្គង់តម្រូវការទីផ្សារក្នុងស្រុក និងធ្វើការនាំចេញទៅទីផ្សារ អន្តរជាតិ។ល។

Draft

## ២- កម្មវត្ថុ នៃការប្រើប្រាស់ដីសម្បទាន

កម្មវត្ថុនៃការរៀបចំប្រើប្រាស់ដីសម្បទានសម្រាប់ធ្វើវិនិយោគលើគម្រោងបង្កើតកសិដ្ឋានដើម្បីអភិវឌ្ឍន៍ចម្ការដូង កាកាវ អាកាស្យាសេណេហ្គាល់ សណ្តែកសៀង ស្រូវ កៅស៊ូ និងកសិ-ឧស្សាហកម្ម និងការសាងសង់រោងចក្រកែច្នៃ គឺផ្តោតលើវិនិយោគប្រភេទផលិតកម្ម-អាជីវកម្មដូចខាងក្រោម៖

- **ផលិតកម្មចំបង** ៖ *ដាំដំណាំដូង កាកាវ អាកាស្យាសេណេហ្គាល់ ស្រូវ សណ្តែកសៀង កៅស៊ូ និងដំណាំកសិ-ឧស្សាហកម្មផ្សេងៗទៀតមានលក្ខណៈជាចម្ការកសិ-ឧស្សាហកម្មទ្រង់ទ្រាយធំ។*
- **ផលិតកម្មបន្ទាប់បន្សំ** ៖ *ដាំដុះដំណាំផ្លូវបន្ទាប់បន្សំសម្រាប់ជាគម្របដី និងដំណាំកសិ-ឧស្សាហកម្មផ្សេងៗ*
- **ការសាងសង់** ៖ *សាងសង់រោងចក្រកែច្នៃផលិតផល ដំណាំកសិ-ឧស្សាហកម្មផ្សេងៗទៀត និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធដែលចាំបាច់បម្រើឲ្យគោលដៅផលិតកម្មជាចម្បងផងនិងដូចមានចែងក្នុងកិច្ចសន្យា។*

## ៣-ទស្សនទានការគ្រប់គ្រងដីសម្បទាន

ដោយមានការគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជា ក្រុមហ៊ុន អេស ខេ ផ្លេនថេសិន (ខេមបូឌា) ភីធីអ៊ី អិលធីឌី [SK PLANTATION (CAMBODIA) PTE.LTD] បានទទួលគោលការណ៍ឯកភាពអនុញ្ញាតឲ្យធ្វើការវិនិយោគលើផលិតកម្មដំណាំកៅស៊ូ នៅក្នុងតំបន់ដីសម្បទាននៃទីតាំងភូមិសាស្ត្រក្នុងឃុំភ្នំកុក ឃុំហាត់ប៉ក់ ស្រុកវ៉ឺនសៃ និងឃុំតឺន ឃុំត្រពាំងក្រហម ស្រុកកូនមុំ ខេត្តរតនគិរី លើផ្ទៃដីសរុបចំនួន ៨ ០០០ ហិកតា។ ប៉ុន្តែដោយតំបន់ដីសម្បទានភាគច្រើនមិនមានលក្ខណៈអំណោយផលដល់ដំណាំកៅស៊ូ ក្រុមហ៊ុនយើងខ្ញុំបានបន្ថែមមុខដំណាំដូង កាកាវ អាកាស្យាសេណេហ្គាល់ សណ្តែកសៀង ស្រូវ និងដំណាំកសិ-ឧស្សាហកម្មផ្សេងៗទៀត។ ដូច្នេះដើម្បីឲ្យដីសម្បទាននេះដំណើរការប្រកបដោយជោគជ័យ ក្រុមហ៊ុនបានសម្រេចរៀបចំគម្រោងផែនការមេដោយផ្អែកលើទំហំផ្ទៃដីដែលបានចុះបញ្ជីរួច តាមលក្ខណៈទីតាំងភូមិសាស្ត្រ និងស្ថានភាពដីនៃតំបន់សម្បទាន។

ទស្សនទានរបស់ក្រុមហ៊ុន **អេស ខេ ផ្លេនថេសិន (ខេមបូឌា) ភីធីអ៊ី អិលធីឌី** [SK PLANTATION (CAMBODIA) PTE.LTD] ដែលបានសម្រេចដាក់ទុនវិនិយោគនេះ គឺបណ្តាលមកពី ៖

- តំបន់ដីសម្បទានមានលក្ខណៈអំណោយផលល្អដល់ការដាំដុះដំណាំកាកាវ ដូង អាកាស្យាសេណេហ្គាល់ សណ្តែកសៀង ស្រូវ កៅស៊ូ និងប្រភេទដំណាំកសិ-ឧស្សាហកម្មផ្សេងៗទៀត
- រាជរដ្ឋាភិបាលកម្ពុជា មានការលើកទឹកចិត្តដល់ការវិនិយោគឯកជនវូបនីយកម្មពិសេសលើវិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម
- មានកិច្ចសហប្រតិបត្តិការល្អក្នុងសមាគមន៍អាស៊ាន និងព្រះរាជាណាចក្រកម្ពុជា

Draft

- កម្លាំងពលកម្មនិងការចំណាយលើថ្លៃផលិតកម្មមានកម្រិតទាបជាងប្រទេសដទៃក្នុងតំបន់
- ជួយធ្វើការអភិវឌ្ឍន៍តំបន់នេះតាមរយៈផ្តល់មុខរបរ និងបង្កើតការងារដល់ប្រជាពលរដ្ឋដែលរស់នៅក្បែរតំបន់ដីសម្បទាននោះផ្តល់បច្ចេកវិជ្ជា និងកសាងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗដូចជា៖ ផ្លូវថ្នល់ប្រព័ន្ធស្រោច ស្រព.....។ល។ ក្នុងគោលបំណងរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីសម្រេចនូវគោលដៅក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋកម្ពុជា និងជំរុញកំណើនសេដ្ឋកិច្ចជាតិ។
- ដើម្បីរកប្រាក់ចំណូលជូនក្រុមហ៊ុនដោយការធ្វើអាជីវកម្មមានលក្ខណៈបច្ចេកទេស និងគិតអំពីលំនឹងបរិស្ថានក៏ដូចជាផ្តល់ប្រាក់ចំណូលជូនដល់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈការបង់ពន្ធអាករផ្សេងៗ និងបង្កើនប្រាក់ចំណូលជូនប្រជាពលរដ្ឋកម្ពុជាផងដែរ។
- ក្រុមហ៊ុនមានទុនវិនិយោគ និងបទពិសោធន៍គ្រប់គ្រាន់លើដំណាំដូង កាកាវ អាកាស្យាសេណេហ្គាល់ សណ្តែកសៀង ស្រូវ និងកៅស៊ូ។ ម្យ៉ាងវិញទៀតដើម្បីឈានដល់ការផ្លាស់ប្តូរបទពិសោធន៍បច្ចេកទេសលើវិស័យកសិកម្មរវាងក្រុមអ្នកបច្ចេកទេសក្រុមហ៊ុនជាមួយអ្នកបច្ចេកទេសរដ្ឋ។ល។

ក្រុមហ៊ុន **អេស ខេ ផ្លេនថេសិន (ខេមបូឌា) ភីធីអ៊ី អិលធីឌី** [SK PLANTATION (CAMBODIA) PTE.LTD] បានអនុវត្តនូវគោលការណ៍ក្នុងការប្រតិបត្តិប្រចាំថ្ងៃរបស់ក្រុមហ៊ុនតាមរយៈប្រព័ន្ធនៃការគ្រប់គ្រងដែលក្នុងនោះមានដូចជា ៖

- **គោលនយោបាយនៃការគ្រប់គ្រង** គឺជាការរៀបចំយុទ្ធសាស្ត្រក្នុងការគ្រប់គ្រងតំបន់សម្បទាន ដើម្បីធានាឲ្យការប្រតិបត្តិ ប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព និងមានដំណើរឆ្ពោះទៅរកការអនុវត្តល្អបំផុតតាមលក្ខណៈស្តង់ដាអន្តរជាតិ នូវរាល់សកម្មភាពរបស់ក្រុមហ៊ុនទាំងផ្នែកការងាររដ្ឋបាល ការគ្រប់គ្រងបុគ្គលិក ផ្នែកបច្ចេកទេស ផ្នែកទីផ្សារ។ល។ គោលនយោបាយទាំងនោះត្រូវបានរៀបចំដោយថ្នាក់គ្រប់គ្រង និងក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនដើម្បីសម្រេចជាផ្លូវការ។

- **នីតិវិធីនៃការគ្រប់គ្រង** គឺបានកំណត់ចេញនូវកម្មវត្ថុ វិសាលភាពការងារ តម្រូវការបរិក្ខារបញ្ហាសុវត្ថិភាព បុគ្គលិកពាក់ព័ន្ធ និងបទដ្ឋានអនុវត្តសម្រាប់ការងារដែលត្រូវចាប់ផ្តើមពីដំបូង។ ត្រូវរៀបចំកសាងឯកសារពាក់ព័ន្ធជាច្រើន នៃស្ថានភាពក្នុងតំបន់សម្បទានមុន នឹងចាប់ផ្តើមការអនុវត្តន៍ដំណើរការ។

- **នីតិវិធីនៃការប្រតិបត្តិ** គឺឧបករណ៍គ្រប់គ្រង និងគោលការណែនាំសម្រាប់ក្រុមប្រតិបត្តិការ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ប្រធានប្រតិបត្តិ ពោលគឺសំដៅទៅលើការងារប្រតិបត្ត ជាងការងាររៀបចំឯកសារ ការប្រមូលព័ត៌មាន។ នីតិវិធីនៃការប្រតិបត្តិមានដូចជា: ការងារដាំដុះ, ការរៀបចំថ្នាល, ការបង្កើតឡូត៍ចម្ការកៅស៊ូ ដូង កាកាវ អាកាស្យាសេណេហ្គាល់ សណ្តែកសៀង ស្រូវ ជាដើម។

Draft

## ៤-ប្រព័ន្ធ នៃការគ្រប់គ្រងដីសម្បទាន

### ៤.១-រចនាសម្ព័ន្ធ នៃការគ្រប់គ្រងដីសម្បទាន

គម្រោងបង្កើតកសិដ្ឋានដាំដុះដំណាំដូង កាកាវ អាកាស្យាសេណោហ្គាល់ សណ្តែកសៀង ស្រូវ កៅស៊ូ និងដំណាំកសិ-ឧស្សាហកម្មផ្សេងៗទៀត របស់ក្រុមហ៊ុនមានមូលដ្ឋានស្ថិតនៅស្រុកកូនមុំ ខេត្តរតនគិរី (មានផែនទីបង្ហាញទីតាំងជូនភ្ជាប់) ដែលមានទំហំ ៦.៥០៩,២៧ ហិកតា ដែលបានចុះបញ្ជីដីរដ្ឋត្រូវបានគ្រប់គ្រងដោយក្រុមហ៊ុន។ ក្នុងការគ្រប់គ្រងដីសម្បទាននេះក្រុមហ៊ុននឹងត្រូវធ្វើការបែងចែកដើម្បីគ្រប់គ្រងប្រពន្ធ័ការងារជា០៤ ការិយាល័យធំៗគឺៈ

១-ការិយាល័យកិច្ចការរដ្ឋបាលដែលរួមមានផ្នែកគ្រប់គ្រងរដ្ឋបាល-បុគ្គលិកផ្នែកគ្រប់គ្រងអចលនវត្ថុ និងផ្នែកការពារសន្តិសុខ។

២-ការិយាល័យបច្ចេកទេស និងពិនិត្យគុណភាពដែលរួមមានផ្នែកបច្ចេកទេស និងកិច្ចការពិនិត្យគុណភាព។

៣-ការិយាល័យផែនការគណនេយ្យ-ហិរញ្ញវត្ថុ និងគ្រប់គ្រងពលកម្មដែលរួមមានផ្នែកធ្វើផែនការគណនេយ្យ-ហិរញ្ញវត្ថុ និងចាត់តាំងគ្រប់គ្រងកម្លាំងពលកម្ម។

៤-ការិយាល័យគ្រប់គ្រងការលក់ផលិតផល និងការនាំចេញដែលរួមមានផ្នែកគ្រប់គ្រងការលក់ផលិតផល ផ្នែកទីផ្សារ-ទំនាក់ទំនងទីផ្សារ និងផ្នែកគ្រប់គ្រងការនាំចេញ-នាំចូល។

រចនាសម្ពន្ធ័គ្រប់គ្រងនៃសម្បទាននេះត្រូវបានរៀបចំដូចខាងក្រោមៈ

### រចនាសម្ព័ន្ធគ្រប់គ្រងការងារ




Draft

### ៤.២-ផែនការបែងចែកផ្ទៃដីសម្រាប់ផលិតកម្ម

ក្រោយពីបានសិក្សាតំបន់សម្បទានបឋមមួយ និងលទ្ធផលនៃការធ្វើអង្កេតសារពើភ័ណ្ឌព្រៃឈើធម្មជាតិដែលមាននៅក្នុងតំបន់ដីសម្បទាន ដោយនឹងផ្តល់ទិន្នន័យផ្ទៃដីដែលក្រុមហ៊ុនអាចឈូសឆាយព្រៃធម្មជាតិដែលមិនមានតម្លៃសេដ្ឋកិច្ច ដើម្បីដាំដំណាំដូង កាកាវ អាកាស្យា សេណោហ្គាល់ សណ្តែកសៀង ស្រូវ និងកៅស៊ូ ទៅតាមផែនការនៃការដាំដុះ។ ចំណែកឯផ្ទៃដីដែលនៅមានគម្របព្រៃធម្មជាតិ និងមានប្រសិទ្ធភាពសេដ្ឋកិច្ច ក្រុមហ៊ុនមានភារៈកិច្ចថែរក្សាការពារ មិនធ្វើការឈូសឆាយតំបន់នោះឡើយ។

ក្រុមហ៊ុនសូមបង្ហាញពីជំហរច្បាស់លាស់ និងរឹងមាំរបស់ក្រុមហ៊ុនលើការគ្រប់គ្រងធ្វើអាជីវកម្ម-ផលិតកម្មក្នុងតំបន់ដីនៃសម្បទានឲ្យប្រកបដោយនិរន្តរភាពនិងរក្សាបរិស្ថានល្អ។

-យោងលិខិតចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១១ របស់ក្រុមហ៊ុនយើងខ្ញុំ ដែលបានស្នើសុំផ្ទៃដីចំនួន ១៧.០១៤ ហិកតា។ បន្ទាប់ពីទទួលបានលិខិតស្នើសុំរបស់ក្រុមហ៊ុនរួចមកក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ បានចាត់ក្រុមលេខាធិការដ្ឋានបច្ចេកទេសសម្រាប់ដីសម្បទានសេដ្ឋកិច្ច សហការជាមួយក្រុមការងារខេត្តរតនគិរី ចុះធ្វើការសិក្សាវាយតម្លៃលើសំណើសុំរបស់ក្រុមហ៊ុន។

-តាមលទ្ធផលនៃការចុះសិក្សាវាយតម្លៃលើសំណើសុំដីសម្បទានរបស់ក្រុមហ៊ុន ដោយការក្រុមការងារលេខាធិការដ្ឋានបច្ចេកទេសសម្រាប់ដីសម្បទានសេដ្ឋកិច្ច ក្រុមការងារក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រុមការងារខេត្តរតនគិរី ឃើញថា តាមការគណនាតាមប្រព័ន្ធ GIS ផ្ទៃដីស្នើសុំមានទំហំ សរុបចំនួន ១៧.០១៤ ហិកតា។ ក្រុមការងារបានវាយតម្លៃ និងសន្និដ្ឋានថា ក្នុងផ្ទៃដី១៧.០១៤ ហិកតា មានផ្ទៃដីដែលពាក់ព័ន្ធសរុបមានចំនួន ៩០១៤ ហិកតា ដែលត្រូវរក្សាទុក និងកាត់ចេញពីដីសម្បទានក្នុងនោះមានៈ

- ផ្ទៃដីតំបន់ទ្រនាប់ជងអូរ (៥០០ម និង១០០ម) ចំនួន ២២៤៨ ហិកតា
- ផ្ទៃដីតំបន់សហគមន៍ព្រៃឈើចំនួន ១៧៣ ហិកតា
- តំបន់រក្សាទុកចំនួន ២២២៤ ហិកតា
- ផ្ទៃដីជាន់ព្រៃគុបក្នុងស្រុកចំនួន ២៨៧ ហិកតា
- ផ្ទៃដីត្រៀមបម្រុងទុកសម្រាប់កំណើនប្រជាពលរដ្ឋនៅពេលអនាគត ១០% ចំនួន ៨៥៧ហិកតា
- ផ្ទៃដីត្រៀមបម្រុងទុកសម្រាប់សម្បទានដីសង្គមកិច្ចចំនួន ៥៩៨ ហិកតា
- ផ្ទៃដីស្រែចម្ការរបស់ប្រជាពលរដ្ឋ និងដីផ្សេងៗចំនួន ២៦២៧ ហិកតា

របាយការណ៍ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១១ របស់ក្រុមការងារលេខាធិការដ្ឋានបច្ចេកទេសសម្រាប់ដីសម្បទានសេដ្ឋកិច្ច ក្រុមការងារក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រុមការងារខេត្តរតនគិរី ជូនភ្ជាប់ក្នុងឧបសម្ព័ន្ធ។

-យោងតាមលទ្ធផលចុះសិក្សាវាយតម្លៃរបស់ក្រុមការងារ និងតាមការសម្រេចរបស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានស្នើសុំគោលការណ៍ទៅទីស្តីការគណៈរដ្ឋមន្ត្រីតាមលិខិតលេខ ៩៤៦៤/១០៧៣កសក.នផ.ផក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១១

ដើម្បីស្នើសុំគោលការណ៍ផ្តល់ដីសម្បទានចំនួន ៨.០០០ ហិកតា សម្រាប់ធ្វើការវិនិយោគដាំដំណាំកៅស៊ូ។

-ទីស្តីការគណៈរដ្ឋមន្ត្រីបានឯកភាពជាគោលការណ៍ អនុញ្ញាតផ្តល់ជូនក្រុមហ៊ុនធ្វើវិនិយោគតាមលិខិតលេខ ១៦០១សជណ ចុះថ្ងៃទី២៩ខែធ្នូឆ្នាំ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីការសម្រេចយល់ព្រមឲ្យក្រុមហ៊ុនធ្វើវិនិយោគដំដំណាំកៅស៊ូ លើផ្ទៃដីសរុបចំនួន ៨.០០០ ហិកតា។

-យោងតាមលិខិតលេខ ១៦០១សជណ ចុះថ្ងៃទី២៩ខែធ្នូឆ្នាំ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចាត់ក្រុមការងារចុះសិក្សាកំណត់ចំនុចគោលព្រំដីសម្បទាន និងធ្វើសម្រង់ស្ថិតិផ្ទៃដីពាក់ព័ន្ធក្នុងតំបន់ដីសម្បទានលទ្ធផលទទួលបានដូចកាលពីចុះសិក្សាវាយតម្លៃ គឺលើផ្ទៃដីស្នើសុំចំនួន ១៧.០១៤ហិកតា ត្រូវកាត់ចេញផ្ទៃដីពាក់ព័ន្ធសរុបចំនួន ៩.០១៤ហិកតា (កំណត់ហេតុចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១២ និងរបាយការណ៍ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១២ របស់ក្រុមការងារជូនភ្ជាប់ក្នុងឧបសម្ព័ន្ធ) ពុំមានការប្រែប្រួលទំហំផ្ទៃដីខុសពីមុនឡើយ។

-យោងតាមលិខិតលេខ ៥០២៥/៤៨២កសក.នផ.ជក ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១២ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លើសំណើសុំធ្វើការចុះបញ្ជីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន អេស ខេ ផ្លេនថេសិន (ខេមបូឌា) ភីធីអ៊ី អិលធីឌី [SK PLANTATION (CAMBODIA) PTE.LTD] គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តរតនគិរីបានចុះធ្វើការអង្កេតវាស់វែង និងធ្វើអត្តសញ្ញាណកម្មដីរួមហើយជាលទ្ធផលទទួលបាន ៖ លើផ្ទៃដីតាមផែនទី (ផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធនៃកិច្ចសន្យា) របស់មន្ទីររៀបចំដែនដី នគរូបនីយកម្មនិងសុរិយោដីខេត្តរតនគិរី មានផ្ទៃដីសរុបចំនួន **<u>១៦៩៩០ហិកតា</u>**(ផ្ទៃដីតាមការស្នើសុំសរុបចំនួន ១៧.០១៤ហិកតា) ដោយកាត់ចេញផ្ទៃដីពាក់ព័ន្ធសរុបចំនួន **<u>១០៤៨១ហិកតា</u>** ក្នុងនោះមាន៖ ផ្ទៃដីតំបន់ទ្រនាប់ដងអូរ (៥០០ម និង១០០ម) មានចំនួន ២១៤៣ហិកតា (ផ្ទៃដីទ្រនាប់ដងអូរ កាលពីចុះសិក្សាវាយតម្លៃមានចំនួន ២២៤៨ហិកតា ពេលចុះបញ្ជីដីមានការថយចុះចំនួន១០៥ហិកតា) ផ្ទៃដីតំបន់សហគមន៍ព្រៃឈើចំនួន ១៧៣ ហិកតា ផ្ទៃដីតំបន់រក្សាទុកចំនួន ២២២៤ហិកតា ផ្ទៃដីជាន់ព្រៃគុបក្នុងស្រុកចំនួន ២៨៧ ហិកតា ផ្ទៃដីត្រៀមបម្រុងទុកសម្រាប់កំណើនប្រជាពលរដ្ឋនៅពេលអនាគត ១០% ចំនួន ៨៥៧ ហិកតា ផ្ទៃដីត្រៀមបម្រុងទុកសម្រាប់សម្បទានដីសង្គមកិច្ចចំនួន ៥៩៨ហិកតា ផ្ទៃដីពាក់ព័ន្ធផ្សេងៗចំនួន ៨៥ ហិកតា (ដីព្រៃកប់ខ្មោច ដីព្រៃអ្នកតា ដីទួលសុវត្ថិភាព និងដីទ្រនាប់ផ្លូវ) និងផ្ទៃដីស្រែចម្ការរបស់ប្រជាពលរដ្ឋចំនួន ៤១១៤ហិកតា (ផ្ទៃដីពាក់ព័ន្ធជាមួយប្រជាពលរដ្ឋ កាលពីចុះសិក្សាវាយតម្លៃមានចំនួន ២៦២៧ ហិកតា ពេលចុះបញ្ជីដីមានការកើនលើសចំនួន ១៤៨៧ហិកតា) ដូច្នេះផ្ទៃដីជាកម្មវត្ថុនៃការចុះបញ្ជីដីសម្បទានសេដ្ឋកិច្ចមានចំនួន **<u>៦៥០៩ហិកតា</u>** ផ្ទៃដីនេះជាផ្ទៃដីសម្រាប់ក្រុមហ៊ុនធ្វើអាជីវកម្ម-ផលិតកម្ម (លិខិតលេខ ១០៣៥/១៤ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៤ និងផែនទីបង្ហាញទីតាំងក្បាលដីជូនភ្ជាប់ក្នុងឧបសម្ព័ន្ធ)។

-ដោយប្រភេទដីក្នុងតំបន់ដីសម្បទានមានលក្ខណៈមិនសូវអំណោយផលដល់ការដាំដុះដំណាំកៅស៊ូ ទើបក្រុមហ៊ុនយើងខ្ញុំស្នើសុំមកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីបន្ថែមមុខដំណាំ នឹងបានទទួលការឯកភាពតាមលិខិតលេខ ៥៩៨៩កសក ចុះថ្ងៃទី០៨ ខែកញ្ញា

Draft

ឆ្នាំ២០១៥ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងលិខិតលេខ ១០៣១ សជណ ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី សម្រេចឲ្យក្រុមហ៊ុនបន្ថែមដំណាំដូងកាកាវ អាកាស្យាសេណេហ្គាល់ សណ្តែកសៀង ស្រូវ និងដំណាំកសិ-ឧស្សាហកម្មផ្សេងៗទៀត។

-ក្រុមហ៊ុនយើងខ្ញុំបានរៀបចំផែនការមេលើផ្ទៃដីជាកម្មវត្ថុ នៃការចុះបញ្ជីដីសម្បទានសេដ្ឋកិច្ចមានចំនួន ៦៥០៩,២៧ហិកតា ផ្ទៃដីនេះជាផ្ទៃដីសម្រាប់ក្រុមហ៊ុនធ្វើអាជីវកម្ម-ផលិតកម្ម។ ផែនការមេនេះនឹងបង្ហាញអំពីការគ្រោងនឹងធ្វើការបែងចែកដីសម្រាប់ការដាំដុះ និងការសាងសង់ហេដ្ឋារចនាសម្ពន្ធ័ដូចខាងក្រោម៖

| | |
|---|---|
| -ផ្ទៃដីដាំដូង/កាកាវ និងអាកាស្យាសេណេហ្គាល់ | = ៣៥៥៦ ហិកតា |
| -ផ្ទៃដីដាំស្រូវ/កសិ-ឧស្សាហកម្ម | = ១៨៥៧ ហិកតា |
| -ផ្ទៃដីដាំកៅស៊ូ | = ៤០០ ហិកតា |
| -ផ្ទៃដីដាំសណ្តែកសៀង/កសិ-ឧស្សាហកម្ម | = ៧១៣ ហិកតា |
| -ផ្ទៃដីសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ | = ៣៨៣,២៧ ហិកតា |
| *<u>សរុបផ្ទៃដីអាជីវកម្ម-ផលិតកម្ម</u>* | *<u>= ៦៥០៩,២៧ ហិកតា</u>* |

<u>សម្គាល់៖</u> ក្នុងផ្ទៃដីអាជីវកម្ម-ផលិតកម្មសរុបចំនួន ៦៥០៩,២៧ហិកតា មានផ្ទៃដីដែលអាចធ្វើការដាំដុះបានមានចំនួន ៦១២៦ ហិកតា ផ្ទៃដីដែលនៅសល់ជាផ្ទៃដីសម្រាប់សាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ។

Draft

### ៤.៣-ការបែងចែកតំបន់ដាំដុះក្នុងតំបន់ដីសម្បទាន

ការរៀបចំផែនការមេនេះ គឺក្រុមហ៊ុនរៀបចំលើទំហំផ្ទៃដីសរុបតាមផែនទីដែលបានចុះបញ្ជីដីសរុបចំនួន **<u>១៦៩៩០ ហិកតា</u>** ដោយកាត់ផ្ទៃដីពាក់ព័ន្ធសរុបចំនួន **<u>១០៤៨១ហិកតា</u>** ដូច្នេះផ្ទៃដីនៅសល់សម្រាប់ក្រុមហ៊ុនធ្វើអាជីវកម្ម-ផលិតកម្មចំនួន **<u>៦៥០៩ ហិកតា</u>**។

លើផ្ទៃដីគម្រោងវិនិយោគចំនួន **៦៥០៩ ហិកតា** ក្រុមហ៊ុនយើងខ្ញុំធ្វើការបែងចែកជា **០៤ អនុតំបន់** សម្រាប់ធ្វើការដាំដុះតាមឆ្នាំនីមួយៗ ដូចមានផែនទីជូនភ្ជាប់ក្នុងគម្រោងផែនការមេ។ ការបែងចែកទំហំផ្ទៃដីសម្រាប់ដាំដុះតាមអនុតំបន់នីមួយៗមានដូចខាងក្រោម ៖

**<u>អនុតំបន់ទីI៖</u>**

អនុតំបន់ទីI មានផ្ទៃដីសរុបចំនួន **២៩៨៥** ហិកតា អនុតំបន់នេះមានផ្ទៃដីព្រៃដែលត្រូវរក្សាទុកតាមដងអូរចំនួន ៧៧ ហិកតា ផ្ទៃដីតំបន់រក្សាទុកចំនួន ៧៩៩ ហិកតា និងផ្ទៃដីពាក់ព័ន្ធជាមួយប្រជាពលរដ្ឋចំនួន ៦៧ ហិកតា ដូច្នេះផ្ទៃដីនៅសល់សម្រាប់ធ្វើអាជីវកម្ម-ផលិតកម្មមានចំនួន **២០៤២** ហិកតា។

អនុតំបន់ទីI មានព្រំប្រទល់ចាប់ផ្តើម ៖

ពីចំនុច **A** រត់តាមផ្លូវមេពទ្ធ័តំបន់ដីសម្បទាន ឬរត់តាមព្រំប្រទល់ដីសម្បទានទៅទិសខាងជើងត្រង់ដល់ចំនុច **B**។ ពីចំនុច **B** រត់តាមផ្លូវមេពទ្ធ័តំបន់ដីសម្បទាន ឬរត់តាមព្រំប្រទល់ដីសម្បទានទៅទិសខាងជើងចំនុច**P1**។ ពីចំនុច **P1** រត់តាមផ្លូវមេបែងចែកអនុតំបន់ដីសម្បទានទៅទិសខាងកើតត្រង់ដល់ចំនុច**O1**។ ពីចំនុច**O1** រត់តាមតាមព្រំប្រទល់ដីសម្បទានទៅទិសខាងត្បូងឈាងខាងលិចចំនុច**D1**។ពីចំនុច**D1**រត់តាមព្រំប្រទល់ដីសម្បទានទៅទិសខាងកើត**E1**។ ពីចំនុច**E1** រត់ត្រង់តាមព្រំប្រទល់ដីសម្បទានទៅទិសខាងត្បូង**F1**។ ពីចំនុច**F1** រត់តាមព្រំប្រទល់ដីសម្បទាន

ទៅទិសខាងត្បូងឈាងខាងលិចG1។ ពីចំនុច G1 រត់តាមព្រំប្រទល់ដីសម្បទានដល់ចំនុចH1 ។ ពីចំនុច H1 រត់តាមព្រំប្រទល់ដីសម្បទានដល់ចំនុច I1។ ពីចំនុច I1 រត់តាមព្រំប្រទល់ដីសម្បទានដល់ចំនុច J1។ ពីចំនុច J1 រត់តាមព្រំប្រទល់ដីសម្បទានទៅទិសខាងលិចដល់ចំនុច A ដែលជាចំនុចដើមវិញ។ ចំនុចនិយាមកាចំនុចគោលនីមួយៗមានបញ្ជាក់ក្នុងតារាងខាងក្រោម៖

**តារាងបញ្ជាក់ពីចំនុចនិយាមកានៃអនុតំបន់ទីI**

| ឈ្មោះចំនុច | ចំនុចនិយាមកា | |
|---|---|---|
| | X | Y |
| A | 673835 | 1513958 |
| B | 676845 | 1517016 |
| P1 | 677544 | 1519588 |
| O1 | 680962 | 1519001 |
| D1 | 678496 | 1514828 |
| E1 | 681204 | 1514836 |
| F1 | 681189 | 1512525 |
| G1 | 680246 | 1511801 |
| H1 | 679667 | 1511606 |
| I1 | 679549 | 1510676 |
| J1 | 679010 | 1509975 |
| K1 | 677995 | 1509979 |
| L1 | 677994 | 1513914 |

**អនុតំបន់ទីII៖**

អនុតំបន់ទីII មានផ្ទៃដីសរុបចំនួន ២៣១៤ ហិកតា អនុតំបន់នេះមានផ្ទៃដីព្រៃដែលត្រូវរក្សាទុកតាមដងអូរចំនួន ៣៦៨ហិកតា ផ្ទៃដីតំបន់រក្សាទុកចំនួន ៤០៥ហិកតា ផ្ទៃដីជាន់ព្រៃគុបក្នុងស្រុកចំនួន ៣៧ ហិកតា ផ្ទៃដីពាក់ព័ន្ធផ្សេងៗចំនួន ១៦ ហិកតា និងផ្ទៃដីពាក់ព័ន្ធជាមួយប្រជាពលរដ្ឋចំនួន ១៥៣ ហិកតា ដូច្នេះផ្ទៃដីនៅសល់សម្រាប់ធ្វើអាជីវកម្ម-ផលិតកម្មមានចំនួន ១៣៣៥ ហិកតា។

អនុតំបន់ទីII មានព្រំប្រទល់ចាប់ផ្តើម ៖

ពីចំនុច P1 រត់តាមផ្លូវមេពទ្ធ័តំបន់ដីសម្បទាន ឬរត់តាមព្រំប្រទល់ដីសម្បទានទៅទិសខាងជើងឈាងខាងកើតដល់ចំនុចC ។ ពីចំនុច C រត់តាមព្រំប្រទល់ដីសម្បទានទៅទិសខាងជើងឈាងខាងកើតដល់ចំនុចD ។ ពីចំនុច D រត់តាព្រំប្រទល់ដីសម្បទានទៅទិសខាងជើងដល់ចំនុច Q1។ ពីចំនុច Q1 រត់តាមព្រំប្រទល់អូរទៅទិសខាងកើតឈាងខាងត្បូងដល់ចំនុច R1។ ពីចំនុច R1 រត់តាមផ្លូវមេក្នុងតំបន់ដីសម្បទានទៅទិសខាងត្បូងត្រង់ដល់ចំនុច S1 ។ ពីចំនុច S1 រត់តាមព្រំអនុតំបន់ដីសម្បទានទៅទិសខាងកើតឈាងខាងត្បូងដល់ចំនុច T1។ ពីចំនុច T1 រត់តាម

ផ្លូវមេបែងចែកអនុតំបន់ដីគម្រោងវិនិយោគទៅទិសខាងត្បូងត្រង់ដល់ចំនុច **U1** ។ ពីចំនុច **U1** វត់តាមព្រំប្រទល់ដីសម្បទានទៅទិសខាងកើតឈាងខាងត្បូងដល់ចំនុច **N1** ។ ពីចំនុច **N1** វត់តាមព្រំប្រទល់ដីសម្បទានទៅទិសខាងត្បូងឈាងខាងលិចដល់ចំនុច **B1** ។ ពីចំនុច **B1** វត់តាមព្រំប្រទល់ដីសម្បទានទៅទិសខាងកើតឈាងខាងត្បូង **C1**។ ពីចំនុច **C1** វត់តាមព្រំប្រទល់ដីសម្បទានទៅទិសខាងលិចឈាងខាងត្បូងដល់ចំនុច **O1**។ ពីចំនុច **O1** វត់តាមព្រំអនុតំបន់ដីសម្បទានទៅទិសខាងលិចឈាងខាងជើងដល់ចំនុច**P1** ដែលជាចំនុចដើមវិញ។

ចំនុចនិយាមកាចំនុចគោលនីមួយៗមានបញ្ជាក់ក្នុងតារាងខាងក្រោម៖

**តារាងបញ្ជាក់ពីចំនុចនិយាមកានៃអនុតំបន់ទីII**

| ឈ្មោះចំនុច | ចំនុចនិយាមកា | |
|---|---|---|
| | X | Y |
| P1 | 677544 | 1519588 |
| C | 678544 | 1520560 |
| D | 680243 | 1523667 |
| E | 679661 | 1527890 |
| Q | 696433 | 1541628 |
| R1 | 681999 | 1527634 |
| S1 | 682000 | 1526544 |
| T1 | 682503 | 1526309 |
| U1 | 682485 | 1525054 |
| N1 | 683273 | 1524418 |
| B1 | 681494 | 1523675 |
| C1 | 682935 | 1522338 |
| O1 | 680962 | 1519001 |

Draft

**អនុតំបន់ទីIII ៖**

អនុតំបន់ទីIII មានផ្ទៃដីសរុបចំនួន ៦៧៨៦ ហិកតា អនុតំបន់នេះមានផ្ទៃដីព្រៃដែលត្រូវរក្សាទុកតាមជងអូរចំនួន ៨៩០ ហិកតា ផ្ទៃដីតំបន់រក្សាទុកចំនួន ១០២០ហិកតា ផ្ទៃដីជាន់ព្រៃគុបក្នុងស្រុកចំនួន ២៥០ ហិកតា ផ្ទៃដីពាក់ព័ន្ធផ្សេងៗចំនួន ៦៣ ហិកតា ផ្ទៃដីត្រៀមបម្រុងទុកសម្រាប់កំណើនប្រជាពលរដ្ឋនៅពេលអនាគត ១០% ចំនួន ៨៥៧ ហិកតា ផ្ទៃដីត្រៀមបម្រុងទុកសម្រាប់សម្បទានដីសង្គមកិច្ចចំនួន ១៩២ ហិកតា និងផ្ទៃដីពាក់ព័ន្ធជាមួយប្រជាពលរដ្ឋចំនួន ១០០៤ ហិកតា ដូច្នេះផ្ទៃដីនៅសល់សម្រាប់ធ្វើអាជីវកម្ម-ផលិតកម្មមានចំនួន ២៤៧០ ហិកតា។

អនុតំបន់ទីIII មានព្រំប្រទល់ចាប់ផ្តើម ៖

ពីចំនុច **Q1** វត់តាមព្រំប្រទល់អូរទៅទិសខាងកើតឈាងខាងត្បូងដល់ចំនុច **R1**។ពីចំនុច **R1** វត់តាមផ្លូវមេក្នុងតំបន់ដីសម្បទានទៅទិសខាងត្បូងត្រង់ដល់ចំនុច **S1** ។ ពីចំនុច **S1** វត់តាម

ព្រំអនុតំបន់ដីសម្បទានទៅទិសខាងកើតឈាងខាងត្បូងដល់ចំនុច **T1**។ ពីចំនុច **T1** រត់តាមផ្លូវមេបែងចែកអនុតំបន់ដីគម្រោងវិនិយោគទៅទិសខាងត្បូងត្រង់ដល់ចំនុច **U1** ។ ពីចំនុច **U1** រត់តាមព្រំប្រទល់ដីសម្បទានទៅទិសខាងកើតឈាងខាងត្បូងដល់ចំនុច **N1** ។ ពីចំនុច **N1** រត់តាមព្រំប្រទល់ដីសម្បទានទៅទិសខាងជើងឈាងខាងកើតដល់ចំនុច **A1**។ ពីចំនុច **A1** រត់តាមផ្លូវព្រំប្រទល់ដីសម្បទានទៅទិសខាងជើងចំនុច **Z**។ ពីចំនុច**Z** រត់តាមផ្លូវព្រំប្រទល់តំបន់ដីសម្បទានទៅទិសខាងជើងឈាងខាងកើតដល់ចំនុច **Y**។ ពីចំនុច **Y** រត់តាមព្រំប្រទល់ដីសម្បទានទៅទិសខាងជើងឈាងខាងកើតដល់ចំនុច**X** ។ពីចំនុច**X** រត់តាមព្រំប្រទល់ដីសម្បទានទៅទិសខាងកើតឈាងខាងត្បូងដល់ចំនុច**W**។ ពីចំនុច**W** រត់តាមព្រំប្រទល់ដីសម្បទានទៅទិសខាងលិចឈាងខាងជើងដល់ចំនុច**V**។ ពីចំនុច**V** រត់តាមព្រំប្រទល់ដីសម្បទានទៅទិសខាងកើតត្រង់ដល់ចំនុច **M1** ។ ពីចំនុច **M1**រត់តាមផ្លូវព្រំអនុតំបន់ដីសម្បទានទៅទិសខាងជើងឈាងខាងលិចដល់ចំនុច **V1**។ ពីចំនុច **V1** រត់តាមព្រំប្រទល់ដីសម្បទានទៅទិសខាងត្បូងដល់ចំនុច **K** ។ ពីចំនុច **K** រត់តាមព្រំប្រទល់ដីសម្បទានខាងត្បូងឈាងខាងលិចដល់ចំនុច**J**។ ពីចំនុច**J** រត់តាមព្រំប្រទល់ដីសម្បទានទៅទិសខាងត្បូងដល់ចំនុច**I**។ពីចំនុច**I** រត់តាមព្រំប្រទល់ដីសម្បទានទៅទិសខាងលិចឈាងខាងត្បូងដល់ចំនុច**H**។ ពីចំនុច**H** រត់តាមព្រំប្រទល់ដីសម្បទានទៅទិសខាងលិចឈាងខាងជើងត្រង់ដល់ចំនុច**G** ។ ពីចំនុច**G** រត់តាមព្រំប្រទល់ដីសម្បទានទៅទិសខាងត្បូងត្រង់ដល់ចំនុច**F**។ ពីចំនុច **F** រត់តាមព្រំប្រទល់ដីសម្បទានទៅទិសខាងត្បូងឈាងខាងលិចដល់ចំនុច **Q1** ដែលជាចំនុចដើមវិញ។

**<u>តារាងបញ្ជាក់ពីចំនុចនិយាមកានៃអនុតំបន់ទីIII</u>**

| ឈ្មោះចំនុច | ចំនុចនិយាមកា | |
|---|---|---|
| | X | Y |
| Q1 | 679981 | 1528254 |
| F | 682039 | 1530075 |
| G | 682088 | 1532235 |
| H | 685680 | 1530196 |
| I | 687937 | 1531191 |
| J | 689515 | 1534638 |
| K | 690996 | 1535706 |
| V1 | 690613 | 1537243 |
| M1 | 695828 | 1535190 |
| V | 694951 | 1535095 |
| W | 696027 | 1533395 |
| X | 693342 | 1534085 |
| Y | 691619 | 1533004 |

| | | |
|---|---|---|
| Z | 690613 | 1530965 |
| A1 | 689923 | 1527195 |
| N1 | 683273 | 1524418 |
| U1 | 682485 | 1525054 |
| T1 | 682503 | 1526309 |
| S1 | 682000 | 1526544 |
| R1 | 681999 | 1527634 |

**អនុតំបន់ទីIV៖**

អនុតំបន់ទីIV មានផ្ទៃដីសរុបចំនួន ៩៩៥ ហិកតា អនុតំបន់នេះមានផ្ទៃដីព្រៃដែលត្រូវរក្សាទុកតាមដងអូរចំនួន ៨០៨ហិកតា ផ្ទៃដីព្រៃសហគមន៍ចំនួន ១៧៣ហិកតា ផ្ទៃដីត្រៀមបម្រុងទុកសម្រាប់សម្បទានដីសង្គមកិច្ចចំនួន ៨០៦ ហិកតា ផ្ទៃដីពាក់ព័ន្ធផ្សេងៗចំនួន ៦ហិកតា និងផ្ទៃដីពាក់ព័ន្ធជាមួយប្រជាពលរដ្ឋចំនួន ២៨៩០ហិកតា ដូច្នេះផ្ទៃដីនៅសល់សម្រាប់ធ្វើអាជីវកម្ម-ផលិតកម្មមានចំនួន ៦៦២ ហិកតា។

អនុតំបន់ទីIV មានព្រំប្រទល់ចាប់ផ្តើម ៖

ពីចំនុចV1 វត់តាមផ្លូវព្រំប្រទល់ដីគម្រោងវិនិយោគទៅទិសខាងជើងដល់ចំនុច L ។ ពីចំនុច L វត់តាមព្រំប្រទល់ដីគម្រោងវិនិយោគទៅទិសខាងជើងឈាងខាងកើតដល់ចំនុចM។ ពីចំនុច M វត់តាមព្រំប្រទល់ដីសម្បទានទៅទិសខាងកើតឈាងខាងត្បូងដល់ចំនុចN។ ពីចំនុច N វត់តាមព្រំប្រទល់ដីសម្បទានទៅទិសខាងជើងឈាងខាងកើតដល់ចំនុចP។ ពីចំនុចP វត់តាមព្រំប្រទល់តំបន់ដីសម្បទានទៅទិសខាងត្បូងដល់ចំនុចQ។ ពីចំនុច Q វត់តាមព្រំប្រទល់ដីសម្បទានទៅទិសខាងកើតឈាងខាងជើងដល់ចំនុច R។ ពីចំនុចR វត់តាមផ្លូវព្រំប្រទល់តំបន់ដីសម្បទានខាងកើតឈាងខាងត្បូងដល់ចំនុច S ។ ពីចំនុច S វត់តាមព្រំប្រទល់ដីសម្បទានទៅទិសខាងត្បូងឈាងខាងកើតដល់ចំនុចT។ ពីចំនុច T វត់តាមព្រំប្រទល់ដីសម្បទានទៅទិសលិចដល់ចំនុចU ។ ពីចំនុចU វត់តាមព្រំប្រទល់ដីសម្បទានត្រង់ទៅទិសខាងលិចដល់ចំនុចM1។ ពីចំនុចM1 វត់តាមព្រំអនុតំបន់ដីសម្បទានទៅទិសខាងលិចឈាងខាងត្បូងដល់ចំនុចV1 ដែលជាចំនុចដើមវិញ។

Draft

**តារាងបញ្ជាក់ពីចំនុចនិយាមកានៃអនុតំបន់ទីIV**

| ឈ្មោះចំនុច | ចំនុចនិយាមកា | |
|---|---|---|
| | X | Y |
| V1 | 690613 | 1537243 |
| L | 690437 | 1538084 |
| M | 691238 | 1542186 |

| | | |
|---|---|---|
| N | 695146 | 1539638 |
| O | 694515 | 1542769 |
| P | 695389 | 1543885 |
| Q | 696433 | 1541628 |
| R | 698277 | 1542793 |
| S | 700804 | 1540114 |
| T | 697710 | 1535411 |
| U | 697010 | 1535194 |
| M1 | 695828 | 1535190 |

## ៤.៤-កម្មវិធីប្រើប្រាស់ដីតាមបណ្តាអនុតំបន់

គម្រោងនៃការប្រើប្រាស់ផ្ទៃដីក្នុងតំបន់ដីសម្បទានត្រូវធ្វើតាមឆ្នាំនីមួយៗដោយគ្រោងឲ្យហើយក្នុងកំឡុងពេល ០៦ ឆ្នាំ តាមកម្មវិធីការងារប្រើប្រាស់ដីតាមអនុតំបន់ដូចខាងក្រោម៖

**តារាងប្រើប្រាស់ដីរបស់ក្រុមហ៊ុន អេស ខេ ផ្លេនថេសិន (ខេមបូឌា) ភីធីអ៊ី អិលធីឌី**

ខ្នាតគិតជាហិកតា

| លេខ អនុតំបន់ | ផ្ទៃដីសរុប តាម ផែនទី | ផ្ទៃដីដែលត្រូវកាត់ចេញ និងរក្សាទុក | | | | | | | | ផ្ទៃដី អាជីវកម្ម-ផលិតកម្មសរុប |
|---|---|---|---|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | |
| I | ២៩៨៥ | ៧៧ | ៧៩៩ | ៦៧ | ០ | ០ | ០ | ០ | ០ | ២០៤២ |
| II | ២៣១៤ | ៣៦៨ | ៤០៥ | ១៥៣ | ៣៧ | ០ | ០ | ០ | ១៦ | ១៣៣៥ |
| III | ៦៧៤៦ | ៨៩០ | ១០២០ | ១០០៤ | ២៥០ | ៨៥៧ | ១៩២ | ០ | ៦៣ | ២៤៧០ |
| IV | ៤៩៤៥ | ៨០៨ | ០ | ២៨៩០ | ០ | ០ | ៤០៦ | ១៧៣ | ៦ | ៦៦២ |
| ផ្ទៃដីសរុបរួម | ១៦៩៩០ | ២១៤៣ | ២២២៤ | ៤១១៤ | ២៨៧ | ៨៥៧ | ៥៩៨ | ១៧៣ | ៨៥ | ៦៥០៩ |

Draft

បញ្ជាក់៖

- ផ្ទៃដីសរុបចំនួន **១៦៩៩០ ហិកតា** ជាផ្ទៃដីតាមផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធនៃកិច្ចសន្យា ដែលជាមូលដ្ឋានក្នុងការចុះបញ្ជីដីដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសុរិយោដីខេត្តរតនគិរី (ផ្ទៃដីតាមការស្នើសុំសរុបទំហំ ១៧០១៤ ហិកតា)
- លេខ ១ ជាផ្ទៃដីរក្សាទុកតាមដងអូរ

- លេខ ២ ជាផ្ទៃដីតំបន់រក្សាទុក
- លេខ ៣ ជាផ្ទៃដីពាក់ព័ន្ធជាមួយប្រជាពលរដ្ឋ
- លេខ ៤ ជាផ្ទៃដីជាន់ព្រៃគុបក្នុងស្រុក
- លេខ ៥ ជាផ្ទៃដីត្រៀមបម្រុងទុកសម្រាប់កំណើនប្រជាពលរដ្ឋនៅពេលអនាគត១០%
- លេខ ៦ ជាផ្ទៃដីត្រៀមបម្រុងទុកសម្រាប់សម្បទានដីសង្គមកិច្ច
- លេខ ៧ ជាផ្ទៃដីព្រៃសហាគមន៍
- លេខ ៨ ជាផ្ទៃដីពាក់ព័ន្ធផ្សេងៗ(ដីព្រៃកប់ខ្មោច ដីព្រៃអ្នកតា ដីទូលសុវត្ថិភាព និងដីទ្រនាប់ផ្លូវ)
- ក្រុមហ៊ុនដាំកៅស៊ូក្នុងអនុតំបន់IV
- ចំពោះអនុតំបន់I និងអនុតំបន់III គឺក្រុមហ៊ុនគ្រោងអនុវត្តគម្រោងក្នុងមួយអនុតំបន់រយៈពេលពីរឆ្នាំ
- ទំហំផ្ទៃដីដែលកំណត់តាមអនុតំបន់នីមួយៗគឺជាទំហំផ្ទៃដីធ្វើអាជីវកម្ម-ផលិតកម្ម និងផ្ទៃដីសម្រាប់ធ្វើការដាំដុះ (តារាងឧបសម្ព័ន្ធទី១ជូនភ្ជាប់)។
- ក្រុមហ៊ុនគ្រោងផ្ទៃដីចំនួន ៣៨៣,២៧ ហិកតា សម្រាប់សំណង់ផ្សេងៗដូចជារោងចក្រ ទីស្នាក់ការលំនៅដ្ឋានឃ្លាំងប្រពន្ធ័ផ្លូវប្រពន្ធ័ស្រោចស្រព.....។ល។

## ៤.៥-ការដាំដុះកៅស៊ូ

### ៤.៥.១-ការងារដាំដុះ

បច្ចុប្បន្ននេះការដាំដុះកៅស៊ូដោយគ្រាប់ផ្ទាល់នៅឡូត៍ចម្ការ គឺត្រូវបានឈប់អនុវត្តដាំបែបនេះទៀត ហើយគេដាំដោយបានថែទាំក្នុងថ្នាលបណ្តុះកូនបំបៅរួចហើយយកទៅដាំក្នុងចម្ការអាជីវកម្ម។

#### ៤.៥.១.១-ការរៀបចំច្បារពូជ

ច្បារពូជជាកន្លែងផលិតមែកពូជ សម្រាប់យកទៅបំបៅលើកូនកៅស៊ូនៅថ្នាលបណ្តុះកូន។ ដូចនេះដើម្បីទទួលបានមែកពូជចាំបាច់ត្រូវរៀបចំច្បារពូជនៅលើផ្ទៃដីមួយដែលមានបរិមាណសមស្របគ្រប់គ្រាន់ដែលត្រូវផ្តល់ឲ្យដល់រដូវបំបៅ។ ដូច្នេះច្បារពូជត្រូវបង្កើតឲ្យបានមុន០១ឆ្នាំ មុននឹងមានផែនការដាំកៅស៊ូ។

#### ៤.៥.១.២-ការបង្កើតច្បារពូជ

ចន្លោះពីគុម្ពមួយទៅគុម្ពមួយមានប្រវែង១មx១ម និងមានចំនួន ១០.០០០គុម្ព/ហិកតា។ ច្បារពូជទំហំ ០១ ហិកតា អាចផ្តល់ភ្នែកបំបៅបាន ២០០ ហិកតា នៃផ្ទៃដីដាំនៅឡូត៍ចម្ការ។

#### ៤.៥.១.៣-ការជ្រើសរើសទីតាំង

ការជ្រើសរើសទីតាំងគឺមានការសំខាន់សម្រាប់ការរៀបចំច្បារពូជ។ ទីតាំងត្រូវស្ថិតឲ្យឆ្ងាយពីឡូត៍ចម្ការចាស់ឬឡូត៍ចម្ការកាប់ចាស់ៗ។ ទិសនៃរងនិងជួរដើមនៃច្បារពូជតាម

Draft

ធម្មតាត្រូវរៀបចំឡើងពីទិសខាងកើត-លិច ឬជើង-ត្បូងតាមទិសខ្យល់ភ្លៀងមូសុងរៀងរាល់ឆ្នាំ។

**៤.៥.១.៤-ប្រភេទភ្នែកបំបៅ**

<u>ភ្នែកបំបៅពណ៌ត្នោត</u>

សំបកបំបៅនិងគល់បំបៅសុទ្ធតែមានពណ៌ត្នោតដោយសារតែមែកបំបៅ និងគល់បំបៅសុទ្ធតែសាច់ ឈើហើយអាយុរបស់វាចន្លោះពី ១០-២០ខែ។ បំបៅរបៀបនេះត្រូវបានគេនិយមប្រើប្រាស់យ៉ាងទូលំទូលាយតាំងពីយូរយារណាស់មកហើយ។

<u>ភ្នែកបំបៅពណ៌បៃតងខ្ចី</u>

សំបកភ្នែកបំបៅ និងសំបកដើមបំបៅសុទ្ធតែនៅពណ៌បៃតងខ្ចីជាងនេះទៅទៀត មែកបំបៅនិងដើមបំបៅមិនទាន់ក្លាយជាសាច់ឈើនៅឡើយហើយវាទើបតែមានអាយុប្រហែល ៣-៤ខែប៉ុណ្ណោះ។

**៤.៥.១.៥-ការគ្រប់គ្រងច្បារពូជ**

ទិដ្ឋភាពសំខាន់នៃការគ្រប់គ្រងច្បារពូជ គឺរក្សាទុកនូវភាពសុទ្ធនៃរុក្ខសម្ភារៈនិងធានាផ្គត់ផ្គង់ឲ្យបានទាំងគុណភាព និងភាពក្មេងខ្ចីនៃមែកពូជបម្រើដល់ការបំបៅ។

**៤.៥.១.៦-ប្រភេទពូជ(ក្លូន)ត្រៀមដាំ**

ពូជត្រៀមដាំ(ក្លូន)៖GT11, PB260, RRIM600, IRCA230, PB217 IRCA18, RRIC100, PB235, IRCA130 KV4 VM 515)...

**៤.៥.២-ការរៀបចំថ្នាលបណ្តុះកូន**

គេធ្វើថ្នាលបណ្តុះកូនដើម្បីប្រមូលផ្តុំងាយស្រួល ក្នុងការថែទាំនិងការពារសត្វល្អិតចង្រៃ-ជំងឺឲ្យដល់កូនកៅស៊ូដាំថ្មីក្នុងគោលបំណង ទទួលបាននូវដើមមាំមួនល្អធន់នឹងកត្តាខាងក្រៅឆាប់ដុះឫសនិងលូតលាស់លឿនពេលគាស់យកទៅដាំនៅតាមឡូត៍ចម្ការក្នុងអនុតំបន់។ ត្រូវបំបៅឲ្យរស់សិនទើបយកទៅដាំក្នុងឡូត៍ចម្ការ។ ០១ ហិកតា ថ្នាលបណ្តុះកូនផលិតកូនបំបៅសម្រាប់ដាំនៅឡូត៍ចម្ការចំនួន ១០០ ហិកតា។

**៤.៥.២.១-ការជ្រើសរើសទីតាំង**

ការជ្រើសរើសទីតាំងសម្រាប់រៀបចំថ្នាលកូនត្រូវនៅជិតប្រភពទឹកសម្រាប់ស្រោចស្រពសណ្ឋានដីរាបស្មើមិនដក់ទឹក និងមានជម្រៅប្រហែល០១ម៉ែត្រគឺសមស្របចល្អសម្រាប់ថ្នាលបណ្តុះកូន។

**៤.៥.២.២-ការរៀបចំថ្នាលបណ្តុះកូន**

ត្រូវធ្វើដីឲ្យរាបស្មើរង្វះទឹក ឬប្រឡាយស្នាមភ្លោះ ៣០ស.ម គុណ ៣០ស.ម មិនដក់ទឹកងាយ និងត្រូវមានផ្លូវសម្រាប់ការងារថែទាំដូចជាការដាក់ជីបោចស្មៅបង្ការជំងឺ ស្រោចទឹកការបំបៅ និងត្រួតពិនិត្យការលូតលាស់ក៏ដូចជាសម្រួលដល់ចលនាខ្យល់និងពន្លឺដល់កូនកៅស៊ូផង។

**៤.៥.២.៣-ការរៀបចំដី**

ការរៀបចំដីឲ្យបានត្រឹមត្រូវ គឺជាប្រការសំខាន់ណាស់សម្រាប់ការលូតលាស់នៃកូនកៅស៊ូក៏ដូចជាចៀសវាងការខូចខាតប្រព័ន្ធឫសកូនកៅស៊ូពេលគាស់យកទៅដាំ។ ដីគួរជីកឲ្យបានជម្រៅយ៉ាងតិច៦០ស.ម។

Draft

## ៤.៥.៣-ការបង្កើតឡូត៍ចម្ការកៅស៊ូ

ធ្វើការត្រួតពិនិត្យកសាងគម្រោងការគ្រប់ផ្នែក និងត្រូវធ្វើឲ្យបានហ្មត់ចត់នូវបណ្តាលក្ខខណ្ឌធានាដល់កសិដ្ឋាននិងមានប្រសិទ្ធិភាពសេដ្ឋកិច្ចខ្ពស់។ ត្រូវបែងចែកឲ្យបានច្បាស់នូវប្រភេទដីដែលមិនអាចដាំកៅស៊ូបាន (ដីចំណោទខ្លាំងនិងដីមានគ្រួសថ្មច្រើន...) ដើម្បីទុកក្នុងពេលបែងចែកឡូត៍។ ការគាស់រានរៀបចំដីចែកជាក្បាលដីរាងជាការ៉េមានទំហំ ១០០ ហិកតា ដោយរៀបចំផ្លូវបែងចែកក្បាលដីឲ្យបានត្រង់ប្រសិនដីរាបស្មើ។ ក្នុងមួយក្បាលដីនីមួយៗ ត្រូវបែងចែកជា៤ឡូត៍ដែលក្នុងមួយឡូត៍មាន ២៥ហិកតា។ ការកាប់ឆ្ការត្រូវធ្វើនៅរដូវប្រាំងដើម្បីដាំឲ្យទាន់ពេលវេលានៅរដូវភ្លៀងដែលស៊ីសង្វាក់ជាមួយនឹងការងារផលិតកូនកៅស៊ូ(បំបៅ) ចៀសវាងទុកដីឲ្យនៅទំនេរងាយរងនូវសំនឹក និងការហូរច្រោះ។

### ៤.៥.៣.១-ការរានរៀបចំដី

ការរៀបចំដីត្រូវធ្វើឲ្យបានត្រឹមត្រូវដើម្បីចៀសវាងនូវជំងឺឫស និងការហូរច្រោះដីនិងដើម្បីសម្រេចឲ្យបាននូវជួរត្រឹមត្រូវដែលនេះ គឺជាទិដ្ឋភាពសំខាន់បំផុតក្នុងការដាំដុះកៅស៊ូ។ ការគាស់គល់ចាំបាច់ត្រូវគាស់ឫសឲ្យអស់ បំណែកនៃគល់ត្រូវប្រមូលដុតនៅនឹងកន្លែង។ ការងារនេះត្រូវអនុវត្តក្នុងកំឡុងពេលខ្យល់មូសុងពេលដីសើមបង្កការងាយស្រួល ដល់ការគាស់ឫសហើយជួយលុបបំបាត់ប្រព័ន្ធឫសបានទាំងស្រុង។

### ៤.៥.៣.២-ចន្លោះរងនិងដង់ស៊ីតេដើម

ចន្លោះនៃការដាំកំណត់បាននូវចំនួនដើមកៅស៊ូក្នុង ១ ហិកតា។ ជាទូទៅការដាំកៅស៊ូប្រើប្រាស់ ចន្លោះរងផ្សេងៗគ្នាប៉ុន្តែដង់ស៊ីតេដើមជានិច្ចកាលចន្លោះពី ៥០០-៥៥៥ ដើម/ហិកតា។ តាមធម្មតាគេតែងរៀបចំតាមចន្លោះរងដូចខាងក្រោម ៖

| ល.រ | ចន្លោះរង | ដង់ស៊ីតេដើម/ហិកតា |
|---|---|---|
| ១. | ៦មx៣ម | ៥៥៥ដើម |
| ២. | ៦,៥មx៣ម | ៥១៣ដើម |

ដោយឡែកនៅប្រទេសកម្ពុជាជាការល្អយើងត្រូវដាំចន្លោះរង ៦,៥ម គុណ ៣ម (៥៥៥ដើម) ព្រោះចន្លោះនេះមានលក្ខខណ្ឌល្អប្រសើរដល់ការលូតលាស់របស់កូនកៅស៊ូមិនចង្អៀតមានពន្លឺថ្ងៃគ្រប់គ្រាន់ និងចលនាខ្យល់ល្អ។ ទិសនៃរង និងជួរដើមកៅស៊ូកើត-លិចនិងជើង-ត្បូងគម្បីស្របទៅតាមទិសសំខាន់នៃខ្យល់ និងត្រូវដាំឃ្លាតពីគ្នាប្រវែង ៦ម៉ែត្រ។

### ៤.៥.៣.៣-ការបោះបង្គោល និងជីករណ្តៅដាំ

គេត្រូវបោះបង្គោលប្រវែង ១.២០ម ដោយឫស្សីឬកូនឈើដើម្បីដៅសញ្ញាចំនុចត្រូវដាំ។ ចុងម្ខាងនៃបង្គោលត្រូវសម្រួចដើម្បីងាយស្រួលបោះ។ រណ្តៅដាំទំហំ ៦០ស.ម គុណ ៦០ស.ម គុណ៦០ស.ម ឬធំជាងនេះគឺ ៧០ស.ម គុណ ៧០ស.ម គុណ ៧០ស.ម។ តាមធម្មតាត្រូវជីករណ្តៅយ៉ាងតិចឲ្យបានមុនពេលដាំ ០១ខែ ឬ០២ខែ។ ស្រទាប់ដីលើពី ០-២៥ ស.ម ជាការល្អដីមានជីជាតិច្រើនទុកដោយឡែកនៅម្ខាង និងស្រទាប់ក្រោមទុកនៅម្ខាង។ លប់រណ្តៅពី ១៥-២០ថ្ងៃ ក្រោយ។ ដីស្រទាប់លើដាក់ខាងក្រោមដីស្រទាប់ក្រោមដាក់ខាងលើវិញដើម្បីផ្តល់

Draft

មមោកដល់កូនកៅស៊ូតូចៗ។ គម្បីដាក់ជីក្នុងរណ្តៅពី ៥-១០គ.ក្រ នៃជីលាមកសត្វឬជីសំរាមផុយល្អលាយច្របល់ជាមួយផេះនិងជីស៊ុបពែផូស្វាតចំនួន២០ក្រាម។

**៤.៥.៣.៤-ការដាំកូនក្នុងថង់នៅឡូត៍ចម្ការ**

របៀបដាំកូនក្នុងថង់ធានាការរស់រានបានល្អប្រសើរបំផុត ដែលបច្ចុប្បន្ននេះគេកំពុងអនុវត្តនៅតាមបណ្តាក្រុមហ៊ុនចម្ការកៅស៊ូខេត្តត្បូងឃ្មុំ។ដាក់គ្រាប់កៅស៊ូ ០២ គ្រាប់ ដែលបានដុះពន្លកក្នុងថង់ប៉ូលីអេទីឡែនទំហំ ៣០ស.ម គុណ៤០ស.ម ទម្ងន់ ១០-១៥គ.ក្រ គិតទាំងថង់ដី និងដើមកៅស៊ូ។ ត្រូវចោះប្រហោងនៅតាមបាតថង់ដើម្បីឲ្យឬសចាក់ទម្លុះចេញស្រួល និងមានប្រហោងតូចៗនៅផ្នែកចំហៀងដើម្បីរំដោះទឹកចេញ។

ពេលដាំត្រូវកាត់បាតថង់ចេញដាក់ថង់ ក្នុងរណ្តៅដោយហែកតាមបណ្តោយថង់ប៉ូឡីអេទីឡែនដាច់ខាតកុំឲ្យប៉ះពាល់ដល់ឬសរយាង និងកុំឲ្យបែករបុំដីកំណើតដែលបង្កឲ្យមានរបួសដល់កន្ទ្រាមឬស។

**៤.៥.៣.៥-ការថែទាំក្រោយពេលដាំក្នុងឡូត៍ចម្ការ**

កូនកៅស៊ូត្រូវត្រួតពិនិត្យជារៀងរាល់សប្តាហ៍ក្រោយពីការដាំរួច។ បើពិនិត្យឃើញមានពន្លកខ្ចីចេញច្រើនត្រូវកាត់ចេញទុកតែពន្លកខ្ចីណាដែលដុះចេញ ពីភ្នែកបំប៉ៅតែមួយប៉ុណ្ណោះ។១០%នៃចំនួនកូនកៅស៊ូសរុបដែលបានដាំក្នុងថង់ប៉ូលីអេទីឡេនទុកសម្រាប់ដាំជួសកូនអន់ និងងាប់។

**៤.៥.៣.៦-ដាំរុក្ខជាតិគ្របដី និងបំផ្លាញស្មៅចង្រៃ**

គេតែងតែប្រើប្រាស់ពួករុក្ខជាតិនៅក្នុងអំបូរ សណ្តែកដែលមានលទ្ធភាពកំណត់អាសូតរបស់ខ្យល់អាកាស និងការរស់រានមានជីវិតអាស្រ័យដោយអន្តរកម្មនៃពពួកបាក់តេរីមួយចំនួនដូចជា: Rhizobium ដែលរស់នៅក្នុងបណ្តាញឬសដែលស្ថិតនៅលើឬស។ រុក្ខជាតិគ្របដណ្តប់លើដីបានរហ័សផ្តល់ឲ្យជាតិបៃតងច្រើន និងបំប៉នជីជាតិបន្ថែមដល់ដី។

**៤.៥.៣.៧-ការដាក់ជី**

ចំពោះកូនកៅស៊ូត្រូវបំប៉នដាក់ជីឲ្យបានច្រើន។ ប្រភេទជីគីមីប្រើប្រាស់គឺNPK ជី ១៥.១៥.១៥។ ត្រូវដាក់ជីនៅពេលដែលមានសំណើមដីគ្រប់គ្រាន់ដើម្បីឲ្យកូនកៅស៊ូលាស់ស្លឹកថ្មីឡើងវិញ។

**៤.៦-ការដាំដំណាំកាកាវ**

**៤.៦.១-ការបង្កើនថ្នាលបណ្តុះកូន**

ការបង្កើតថ្នាលបណ្តុះកូន គឺតម្រូវឲ្យមានប្រភពដាក់លាក់ដែលអាចទុកចិត្តបានក្នុងការដាំដុះ (ប្រភពគ្រាប់ពូជ) និងត្រូវរកប្រភពទឹកនៅជិតកន្លែងថ្នាលបណ្តុះកូន។ ប្រភពគ្រាប់ពូជនេះអាចជា សួនច្បារគ្រាប់ពូជមួយដែលជាកន្លែងដែលមានភាពល្អប្រសើរលើការដាំដុះត្រូវបានផលិត។ កូនឈើគួរដុះឡើងនៅក្នុងថ្នាលបណ្តុះក្នុងរយៈពេលបីទៅប្រាំមួយខែ។ ថ្នាលបណ្តុះកូនអចិន្ត្រៃយ៍មួយគឺ ត្រូវលៃទុកកន្លែងសម្រាប់ការកើនឡើងនូវបរិមាណកូនឈើដែលធំសម្រាប់ប្រើប្រាស់ជាលក្ខណៈពាណិជ្ជកម្ម។ ដូច្នេះគោលបំណងបម្រុងទុកកូនឈើ និងកំណត់ប្រភេទនៃថ្នាលបណ្តុះកូនដើម្បីបង្កើតការដាំដុះ។ ខាងក្រោមនេះគឺជាកត្តាដែលគួរតែត្រូវបាន

Draft

យកមកពិចារណានៅពេលដែលបង្កើនថ្នាលបណ្តុះកូនសម្រាប់កាកាវ និងពូជដើមឈើផ្សេងទៀត៖

**៤.៦.១.១-ការជ្រើសរើសទីតាំង**

- ជ្រើសរើសតំបន់រាបស្មើ
- រកមើលកន្លែងដែលនៅជិតទៅនឹងប្រភពទឹក និងវត្ថុធាតុដើមសម្រាប់ដាំដុះ និងមានប្រព័ន្ធបង្ហូរទឹកដ៏ល្អ
- ត្រូវមានការបង្កើតឲ្យដីមានជីជាតិ ឬគួរប្រើជីបំប៉នឬជីធម្មជាតិ
- ត្រូវតែមានការងាយស្រួលអាចចូលទៅប្រតិបត្តិការនៅក្នុងថ្នាលបណ្តុះកូន។

**៤.៦.១.២-ការគ្រប់គ្រង**

- ថ្នាលបណ្តុះកូនត្រូវការធ្វើរបងដើម្បីទប់ស្កាត់អ្នកដទៃ ឬសត្វពាហនៈចូលរុករាន
- ត្រូវការឲ្យមានម្លប់និងថែទាំបានល្អ។

**៤.៦.១.៣-លក្ខណៈសម្បត្តិថ្នាលបណ្តុះកូន**

- ដីត្រូវតែធូររលុងនិងមានរចនាសម្ព័ន្ធល្អ៖ កត្តាទាំងអស់នេះនឹងប្រាកដជានាបាននូវការទំនាក់ទំនងល្អរវាងគ្រាប់ពូជនិងដី។ ត្រូវផ្គត់ផ្គង់ទឹកបន្តបន្ទាប់ និងផ្តល់នូវខ្យល់គ្រប់គ្រាន់សម្រាប់ការដកដង្ហើមរបស់ឫស។ ភាគច្រើនដាំកូនពន្លកល្អនៅលើដីល្បាយដែលមានជីវជាតិល្អពោលគឺ ដីមានភាគល្អិតៗដែលមិនជាដីខ្សាច់ពេកនិងមិនជាដីឥដ្ឋពេក ។
- ដីល្បាយខ្សាច់ (ខ្សាច់ទន្លេ) និងរុក្ខជាតិពុករលួយ (វត្ថុធាតុដើមដែលមានសារធាតុសរីរាង្គខ្ពស់) អាចត្រូវបានលាយជាមួយដីដែលអាចប្រើបានដើម្បីផ្តល់នូវដីដែលអ្នកចង់បានសម្រាប់ថ្នាលគ្រាប់ពូជឬpoly bags។ នេះគឺដោយសារខ្សាច់អាចធ្វើឲ្យទឹកជ្រាបចូលបានល្អ និងធ្វើឲ្យមានដង្ហើមខ្យល់ផងដែរ ចំណែកឯរុក្ខជាតិពុករលួយអាចធ្វើឲ្យប្រសើរឡើងនូវសមត្ថភាពកាន់ទឹក។
- ក្នុងថ្នាលបណ្តុះកូនខ្នាតធំ, ដីថ្នាលគ្រាប់ពូជពីឆ្នាំមុនអាចចម្លងមេរោគដោយសារសារធាតុបង្កជំងឺ ដូច្នេះគួរតែត្រូវរំងាប់មេរោគឲ្យហើយមុនពេលដែលប្រើប្រាស់ថ្នាលនោះ គឺអាចត្រូវធ្វើដោយកំដៅដី ឬការផ្អាប់ដី និងតម្រូវឲ្យយកដីនេះចេញហើយដាក់ត្រឡប់មកវិញបន្ទាប់ពីវាត្រូវបានរំងាប់មេរោគ
- លើផ្ទៃដីប្រហែល ៩ ម៉ែត្រx ៩ម៉ែត្រ អាចផ្ទុកបានចំនួនប្រមាណ ២៥០០ កូនឈើអាស្រ័យលើទំហំនៃpoly bagនេះ
- កូនឈើ ២៥០០ដើម អាចប្រើទឹកជាមធ្យម ៤៥០ លីត្រ (០,១៨ លីត្រក្នុងកូនឈើមួយដើម)
- កម្រាស់នៃម្លប់ឬរោងនេះត្រូវតែលៃតម្រូវទៅតាមប្រភេទនៃកូន ឧទាហរណ៍៖ ប្រសិនបើម្លប់ក្រាស់ គឺត្រូវបានប្រើសម្រាប់ពន្លឺដែលរុក្ខជាតិត្រូវការ កូនឈើអាចនឹងស្តើង

Draft

ហើយខ្សោយ។ ម្យ៉ាងវិញទៀតម្លប់តិចពេកអាចផ្តល់នូវការការពារមិនបានគ្រប់គ្រាន់ទៅនឹងពន្លឺព្រះអាទិត្យផ្ទាល់ ការផ្លាស់ប្តូរសីតុណ្ហភាពខ្លាំង ស្ងួតខ្លាំងពេកនិងភ្លៀងខ្លាំង។

**៤.៦.១.៤-របៀបបង្កើតថ្នាលបណ្តុះកូន**

ជំហានដំបូងនៅក្នុងការបង្កើតថ្នាលបណ្តុះកូន គឺត្រូវកម្ចាត់ចោលនៅរុក្ខជាតិតូចៗឥតប្រយោជន៍ និងយកកំទេចកំទីរុក្ខជាតិចាស់ៗចេញទាំងអស់ និងធ្វើដីនេះយ៉ាងហ្មត់ចត់ដល់ជម្រៅឫស នេះគឺជាការងាយស្រួលបំផុតនៅពេលដែលដីមានសំណើមបន្តិចៗប៉ុន្តែមិនត្រូវសើមខ្លាំងទេ។ នៅពេលដែលរៀបថ្នាលពូជរួចត្រូវជៀសវៀងការធ្វើអ្វីផ្សេងៗដែលធ្វើឲ្យដីហាប់ដូចជាការដើរជាន់នៅលើដីដែលធ្វើរួចជាដើម។

- ជីកជ្រោយ និងត្រលប់ដីប្រហែលទទឹងកន្លះម៉ែត្រ ដីសម្រាប់សាបព្រួសគ្រាប់ពូជតូចគួរតែមានភាគល្អិតៗតូចស្តើងច្រើនជាងដីសម្រាប់សាបព្រួសគ្រាប់ពូជធំៗ
- ចាប់ផ្តើមធ្វើថ្នាលជាមួយនឹងក្រួសសិនមុនពេលធ្វើការបន្ថែមដីទៀត ព្រោះវានឹងអនុញ្ញាតឲ្យទឹកហូរច្រោះចូលទៅក្នុងដី ហើយកូនឈើនឹងធ្វើការស្រូបយកបានយ៉ាងងាយស្រួល
- លើកថ្នាលដល់កម្ពស់ប្រហែល ១០ សង់ទីម៉ែត្រទៅ ២០ សង់ទីម៉ែត្រ, ទទឹង ១២០ សង់ទីម៉ែត្រ និងបណ្តោយប្រហែល ២ ម៉ែត្រផ្សេងៗគ្នាដើម្បីអនុញ្ញាតឲ្យទឹកហូរច្រោះចូលទៅថ្នាលបាន
- ចម្ងាយរវាងពីថ្នាលមួយទៅថ្នាល់មួយគួរតែ ៦០cm និងផ្តល់ម្លប់ប្រហែល ៣០-៦០ សង់ទីម៉ែត្រនៅខាងលើថ្នាលគ្រាប់ពូជ។

**៤.៦.១.៥-ការសាបព្រួសគ្រាប់ពូជនៅលើថ្នាលបណ្តុះកូន**

- មុនពេលសាបព្រួសត្រូវស្រោចទឹកនៅថ្នាលបណ្តុះកូនជាមុនសិន និងប្រើខ្សែដើម្បីធ្វើឲ្យរត់ជាជួរ ៦០ សង់ទីម៉ែត្រពីគ្នា តាមប្រវែងបណ្តោយទាំងអស់នៃថ្នាលនិមួយៗ
- នៅលើជួរនិមួយៗត្រូវចោះរន្ធទំហំពីរដងនៃគ្រាប់ពូជ (គ្រាប់ស្រស់សំរាប់កាការ) នៅ ៥ សង់ទីម៉ែត្រពីគ្នា។

**៤.៦.១.៦-ការសាបព្រួសគ្រាប់ពូជនៅក្នុង poly bag**

- លាយដីជាមួយខ្សាច់និងជីកំប៉ុសរួចចោះរន្ធនៅក្នុងpoly bag និមួយៗដោយបំពេញជាមួយនឹងដី/ខ្សាច់/ ការលាយជីកំប៉ុសហើយសង្កត់ល្បាយនេះដូច្នេះធ្វើឲ្យ poly bag បញ្ឈរបានរឹងមាំ និងត្រូវប្រាកដថា poly bag ត្រូវបានបញ្ឈរដោយត្រឹមត្រូវ
- រៀបចង់នៅក្នុងជួរទទឹង ៥ ឬ១០ ចង់និង បណ្តោយ ១០០ ចង់នៅក្រោមម្លប់ ទុកឲ្យមានចន្លោះប្រហែល ៥០សង់ទីម៉ែត្រ រវាងជួរទាំងពីរ។ ធ្វើដូចនេះ គឺដើម្បីទុកផ្លូវពេលធ្វើប្រតិបត្តិការក្នុងថ្នាលបណ្តុះកូន ដូចជាការស្រោចទឹកនិងការធ្វើស្មៅ
- ចំពោះកាការ, សាបព្រួសគ្រាប់កាការស្រស់ដោយរុញគ្រាប់អោយចូលទៅក្នុងដីនោះជាមួយនឹងចុងគ្រាប់ចុះទៅជម្រៅ 2 សង់ទីម៉ែត្រមួយ។



Draft

### ៤.៦.២-ការរៀបចំដី

កាកាវអាចត្រូវបានដាំនៅលើដីទំនេរ ឬដីជាប់រវល់ដាំដោយដំណាំម្ហូបអាហារនិងដើមឈើដទៃទៀត។ នៅកន្លែងដែលអ្នកដាំប្រើប្រាស់ផ្ទៃដីទំនេរ, បន្លែដែលនៅក្រោមគួរតែត្រូវបានជម្រះនៅចុងនៃរដូវវស្សាឬនៅពេលឆាប់ៗនៅរដូវប្រាំងចាប់ផ្ដើម។ ធ្វើដូចនេះការឈូសឆាយដំបូងធ្វើឲ្យវាងាយស្រួលក្នុងការផ្ដួលរំលំដើមឈើដែលមិនចង់បាននៅមុនពេលកាកាវត្រូវបានដាំដុះ។ កំទេចដែលមាន (biomass) អាចដុតបានឬក៏អាចទុកឲ្យរលួយ។ អ្នកដាំដុះអាចធ្វើការជ្រើសរើសការដុត (ពោលគឺដុតជាពំនូកតូចៗ) ឬជៀសវាងការដុតបំផ្លាញទាំងស្រុង និងគ្រប់គ្រងកំទេចកំទី (biomass), បន្ទាប់មកដើមឈើធំៗភាគច្រើនត្រូវបានកាត់ទៅជាបំណែក និងយកទៅឆ្ងាយពីកន្លែងភ្លើងឆេះ, ដោយការទុកវាទៅជារលួយនៅក្នុងដី ដោយហេតុនេះយើងក៏បានបន្ថែមសារធាតុសរីរាង្គដើម្បីកែលម្អដីផងដែរ។

### ៤.៦.៣-ការដាំកាកាវក្នុងដីកសិដ្ឋាន

គ្រាប់ពូជកាកាវត្រូវដាំចាប់ពីខែមេសា និងកក្កដា ក្នុងរដូវភ្លៀងធ្លាក់។ ទោះជាយ៉ាងណាគ្រាប់ពូជ គឺជាសម្ភារៈជួយក្នុងការដាំដុះមានភាពប្រសើរឡើង គ្រាប់ពូជភាគច្រើន ទទួលបានពីកន្លែងដាំចាប់ពីខែកញ្ញា ដល់ខែមករា។ ការដាំមានភាពប្រសើរឡើង ប្រសិនសម្ភារៈដាំមានតាមតម្រូវការដូចជា ពូជបណ្ដុះ ដែលត្រូវលើកមកដាំត្រូវមានអាយុចាប់ពី ៣ទៅ ៦ ខែមុនពេលធ្វើការដាំទៅវាលចម្ការ។ កសិដ្ឋានកាកាវ ត្រូវបានបង្កើតឡើងដូចជាៈ

- ត្រូវលើកពូជបណ្ដុះរួមទាំងថង់ចេញពីថ្នាល
- ពូជបណ្ដុះដែលបានយកពីថ្នាលត្រូវដាំជាមួយឫស
- ត្រូវយកពូជបណ្ដុះរួចដាក់តាមបង្គោលតម្រុយទុកសម្រាប់ដាំនៅកន្លែងចម្ការ។

### ៤.៦.៤-ការលើកយកពូជសម្រាប់ដាំចេញពីថង់

ការដាំត្រូវយកពូជចេញពីថង់ ជាការងារលំបាក ដូច្នេះត្រូវរកកម្លាំងកម្មករជាច្រើនសម្រាប់ធ្វើការងារនេះ ជាពិសេស ដឹកជញ្ជូនពូជឆ្ងាយពីកន្លែងបណ្ដុះកូន ទៅកន្លែងដាំផងដែរ ប្រមូលថង់គ្រាប់ពូជទុកមួយកន្លែង។ នៅពេលដាំកូនកាកាវខុសពីកន្លែងថ្នាល ត្រូវទុកនៅទីណាដែលមានម្លប់គ្រប់គ្រាន់យ៉ាងហោចណាស់ធ្វើឲ្យបានដូចកន្លែងថ្នាល ដូចនេះត្រូវធ្វើដូចគ្នានៅគ្រប់ទីកន្លែងដែលបានដាំរួច។ ប្រសិនជាម្លប់មានតិចនៅកន្លែងចម្ការ ប្រៀបធៀបទៅនិងកន្លែងថ្នាល ត្រូវបន្ថយម្លប់នៅកន្លែងថ្នាលឲ្យបាន ២ សប្ដាហ៍មុនធ្វើការលើកពូជទៅដាំដុះ។ វិធីនៃការដាំដុះមានដូចខាងក្រោមៈ

- ត្រូវស្រោចទឹកពូជបណ្ដុះឲ្យបានជោគជាំមុនពេលយកទៅដាំ
- នៅកន្លែងដាំ និងចន្លោះ ៣ x ៣ ម, ត្រូវជីករណ្ដៅ តាមទំហំ និង ជម្រៅឲ្យបានសមល្មមនិងកន្ទោងបណ្ដុះកូន និងត្រូវជីករណ្ដៅទុកមុនយ៉ាងហោចណាស់ ២ សប្ដាហ៍មុនពេលដាំ។

- ត្រូវបកកន្ទោងដោយប្រុងប្រយ័ត្នតាមលំដាប់លំដោយ មិនឲ្យជ្រុះដីចេញពីឫស ហើយដាក់កូនបណ្តុះចូលទៅក្នុងរណ្តៅឲ្យបានសមស្រប។
- ត្រូវលុបរណ្តៅនីមួយៗដោយប្រើដីបានពីការជីក ហើយឲ្យមានកម្រិតការលុបដីដូចគ្នានៅកន្លែងបណ្តុះកូន។
- កុំពូនដីនៅជុំវិញកូនបណ្តុះដែលបានដាំរួចព្រោះវាមិនអាចទទួលសំណើម ផ្តល់ឲ្យដើមបាន និងបណ្តាលឲ្យរលួយកូនបណ្តុះបានទូទាំងកសិដ្ឋាន។

### ៤.៦.៥-ការគ្រប់គ្រងដើមកាការទើបតែដាំថ្មី

ការគ្រប់គ្រងដើមកាការនៅតូច ត្រូវធ្វើការដកវុក្ខជាតិតូចៗចេញដូចជាស្មៅ ត្រូវគ្រប់គ្រងឲ្យមានម្លប់ ការបង្កើតឲ្យមានរចនាសម្ព័ន្ធ ការគ្រប់គ្រងសត្វល្អិត និងដាក់ជីឲ្យបានត្រឹមត្រូវ។

#### ៤.៦.៥.១-ការគ្រប់គ្រងម្លប់ និង រុក្ខជាតិឥតប្រយោជន៍

- ត្រូវផ្តល់ម្លប់ឲ្យបានគ្រប់គ្រាន់យ៉ាងហោចណាស់ ៧០%
- ត្រូវជំរះដីឲ្យបានញឹកញាប់ដែលអាចធ្វើទៅបាន(៤-៦ ដងក្នុងមួយឆ្នាំ) ដើម្បីការពារដើមឈើរុក្ខជាតិតូចៗទើបដុះ មានស្មៅ និង សត្វល្អិតបំផ្លាញ
- ត្រូវដកចេញកូនបណ្តុះដែលងាប់ទាំងអស់ក្នុងចន្លោះពេលដាំឆ្នាំដំបូង។

#### ៤.៦.៥.២-ការកាត់មែកចេញ

ដើមកាការដែលនៅតូច ត្រូវពិនិត្យមើលមុនធ្វើការកាត់មែកតូចៗចេញ ហើយមើលទ្រង់ទ្រាយដើម និងកម្ពស់ មុនពេលធ្វើប្រតិបត្តិការ (ដូចជាការប្រមូលផលនិងការបាញ់ថ្នាំ) អាចត្រូវបានអនុវត្តយ៉ាងងាយស្រួល។ ដើមកាការបានចេញលម្អងផ្កាផ្លែបន្ទាប់ពី ២ ឆ្នាំ នៅកម្ពស់ប្រហែល ១.២ ម។ វាត្រូវបានដកចេញលម្អងផ្កាស្រោបផ្លែនៅដំណាក់កាលទី ២ បង្កើតជារូបរាង នេះហៅថាការហើបចេញសំបកលម្អងស្រោបខាងក្រៅ។ លទ្ធផលនេះដើមមានសភាពរលោង និង ដំណើរការយ៉ាងស្រួលរបស់ផ្លែដែលមានចលនាយ៉ាងសេរីនៅក្នុងកសិដ្ឋានកាការ លើពីនេះទៀតត្រូវកាត់ពន្លកដុះចេញថ្មីៗ ដែលបានដុះនៅលើដើមមុនពេលចេញផ្លែ។ ការធ្វើយ៉ាងនេះនឹងនាំឲ្យមានកំណើននៃដើមមានសភាពរឹងមាំ។

### ៤.៦.៦-ការគ្រប់គ្រងសត្វល្អិត

Mirids គឺជាសត្វល្អិតដែលបំផ្លាញពន្លកទើបដុះថ្មី និងផ្លែកាការធ្វើឲ្យកាត់បន្ថយទិន្នផលផ្លែកាការ។ ដើមកាការដែលនៅតូចងាយរងគ្រោះដោយការបំផ្លាញពីពួក Mirid។ ដើម្បីកាត់បន្ថយការខូចខាតពីពពួកMirid ធានាបានថា មានម្លប់គ្រប់គ្រាន់នៅលើដើមកាការដែលនៅតូច (សូមមើលការរៀបរាប់អំពីការធ្វើម្លប់ខាងលើ)។ ហើយដើមកាការដែលនៅតូចក៏ងាយនឹងបំផ្លាញដោយពពួកសត្វកណ្តៀរដែរក្នុងចន្លោះ៦-៣៦ខែក្នុងរដូវប្រាំង (ចាប់ពីខែធ្នូ ដល់មីនា)។ ក្នុងរយៈពេលនោះត្រូវពិនិត្យដើមកាការនៅពេលមានសញ្ញារកឃើញដូចខាងក្រោម៖

- ឃើញមានផ្លូវសត្វកណ្តៀរឡើងដើមឈើដែលគ្រប់ដណ្តប់ទៅលើដើម មែកទងជាដើម

- ប្រសិនជាមានការខាំ ឬខួលជ្រៅទៅលើដើមស្រស់ជាញឹកញាប់អាចឈានទៅដល់បែកមែកឬដើមជាច្រើន
- ដើមមានពូនដោយដីបន្ទាប់ពីសត្វកណ្ដៀរស៊ីនឹងស៊ីនៅពេលក្រោយទៀត
- ស្លឹកស្វិតគឺមានការខានដោយរុករានពីសត្វល្អិតលើរុក្ខជាតិ
- ប្រសិនមានសត្វកណ្ដៀរ រួមទាំងមានឬសត្វចមួយ
- កូនកាការធ្លាក់ចុះគុណភាពលូតលាស់ នៃដើមសង្ស័យថា ទទួលរងការកាត់បំផ្លាញដោយសត្វកណ្ដៀរ។

**៤.៦.៧-របៀបនៃការកាត់មែក**

- ហាមមិនឲ្យកាត់គម្របព្រៃឈើច្រើនជាង ២៥% គឺដើម្បីជួយឲ្យវាមានការរីកលូតលាស់បានលឿន ហើយធ្វើឲ្យរុក្ខជាតិតូចៗដុះជាប់គល់លូតលាស់ចុះទន់ខ្សោយ ហើយបង្កើនការបាំងខ្យល់យ៉ាងងាយស្រួលនៅក្នុងរដូវកាលខ្យល់ខ្លាំង។
- ការកាត់ផ្ដាច់មែកខាងក្រៅភ្ជាប់នឹងដើម ដូចដែលបានបង្ហាញនៅក្នុងរូបក្រោមខាងក្រោម។ មែកភ្ជាប់នឹងដើមបន្ទាប់ពីកាត់វាមានស្ថានភាពហើមនៅចំណុចមួយនៅកន្លែងមែកជាប់នឹងដើមហើយហ៊ុមបិទបន្ទះលើការកាត់នោះបន្តិចម្ដងៗ។ ប្រសិនមានថ្នាំគីមីលាបជួយរារាំងការរីករាលដាលឬពុកផុយនៅលើដើម។ នៅពេលមានដើមស្អុយឬពុកកើតឡើងលើមែក វានឹងរាលដាលឆ្ពោះទៅកន្លែងសារធាតុគីមីដែលបានលាបនៅកន្លែងមែកដែលបានកាត់រួច។ នៅពេលដែលវាបង្កើតបានជាសារធាតុការពារ មែកក៏មានស្ថានភាពល្អច្រើន។
- នៅពេលកាត់មែកធំ (ត្រូវវិភាគដូចខាងក្រោម) ត្រូវកាត់ជា ៣ ទៅ ៤ កំណាត់។ ត្រូវកាត់មែកដំបូង មែកនៅខាងក្រោមប្រហែល ១៨ ស.ម ពីដើមឈើ។ ត្រូវកាត់មួយភាគបីចំពាក់កណ្ដាលមែក។ ទីពីនៅផ្នែកខាងចុងអាចកាត់ចាប់ពី ២០ ទៅ ៣៦ ស.ម ពីដើមឈើ។ ការកាត់នេះបានកាត់តាមវិធីទាំងអស់តាមស្ថានភាពមែក។

Branch bark ridge and branch collar



នេះជាប់ទាក់ទងនឹងការកាត់ដើមឈើប្រហែល ៥០សម ពីដីដើម្បីជួយឲ្យដុះពន្លកថ្មីចេញពីដី។ វិធីនេះអាចជួយជាប្រយោជន៍សម្រាប់ដើមឈើចាស់ និងជាវិធីសាស្ត្រដ៏មានសារៈប្រយោជន៍នៃការបង្កើតឡើងវិញពីធម្មជាតិផងដែរ។ ការកាត់ដើមត្រូវបានដុះសារឡើងវិញ អាចរស់នៅបានយូរប្រសិនបើដើមឈើមិនត្រូវបានកាត់ទាំងស្រុង។

## ៤.៧-ការដាំដំណាំអាកាស្យាសេណោហ្គាល់

### ៤.៧.១-ថ្នាលបណ្ដុះកូន

ចំពោះការដាំដើមអាកាស្យាសេណោហ្គាល់ មិនចាំបាច់តម្រូវឲ្យមានថ្នាលបណ្ដុះកូនទេ។ បន្ទាប់ពីការរៀបចំដីរួចរាល់គេត្រូវបានដាំដោយសាបព្រួសគ្រាប់ពូជដោយផ្ទាល់។ គម្លាតនៃការដាំគឺ ៥ ម៉ែត្រ x ៥ ម៉ែត្រ ឬ ៤០០ដើមក្នុងមួយហិកតា។ រណ្ដៅដាំត្រូវបានជីកដោយប្រើម៉ាស៊ីនខួងឬប្រើចបជីក ជីកដោយដៃ។ ទំហំអង្កត់ផ្ចិត ៣០CM និងជម្រៅ ៣០CM ហើយយើងធ្វើការដាំចំនួនបួនគ្រាប់ក្នុងមួយរណ្ដៅ។

### ៤.៧.២-ការថែទាំចម្ការ

ត្រូវធ្វើការដាំបំពេញបន្ថែមនៅពេលដែលកូនឈើងាប់ ហើយការងារនេះគឺត្រូវធ្វើឲ្យចប់ក្នុងរយៈពេលពីរខែនៃការបង្កើតចម្ការដំណាំ។ ស្មៅគឺជាកត្តាចាំបាច់ដែលត្រូវសម្អាតដើម្បីឲ្យកូនអាកាស្យាសេណោហ្គាល់លូតលាស់បានល្អ។ នៅពេលកូនអាកាស្យាសេណោហ្គាល់នៅតូចត្រូវតែការពារ និងទប់ស្កាត់នៃគ្រោះថ្នាក់ភ្លើងឆេះ ដោយធ្វើការឈូសផ្លូវភ្លើងព័ទ្ធជុំវិញចម្ការ។ ធ្វើរបងលួសបន្លាព័ទ្ធជុំវិញកូនអាកាស្យាសេណោហ្គាល់ ដើម្បីការពារហ្វូងសត្វដែលចូលមកក្នុងចម្ការ រហូតដល់អាកាស្យាសេណោហ្គាល់អាយុបាន៣ឆ្នាំ។ ក្នុងអំឡុងពេលពីរឆ្នាំដំបូងដើមអាកាស្យាសេណោហ្គាល់ធ្វើការលូតលាស់មែកជាងច្រើន ដូច្នេះត្រូវធ្វើការកាត់មែកចេញចាប់ពីដីរហូតដល់កម្ពស់១ម៉ែត្រនៃដើម។

### ៤.៧.៣-ការការពារបញ្ហាសត្វល្អិត

ការដាំអាកាស្យាសេណោហ្គាល់ គឺត្រូវធ្វើការការពារសត្វល្អិត និងជំងឺគ្មានពេលទំនេរនោះទេ ងាយរងគ្រោះទៅនឹងការវាយប្រហាររបស់កណ្ដៀរ ទាំងដើមនៅតូចនិងដើមធំ។ ពួកកណ្ដៀរអាចវាយប្រហារតាមរយៈគល់និងមែកជាង ដោយពូនដីធ្វើជាសំបុកនៅជុំវិញផ្ទៃកនៃសំបកឈើកត្តាទាំងនោះ ហើយដែលហេតុធ្វើឲ្យរំខានដល់មុខងារសរីរាង្គនៃរុក្ខជាតិ។ នៅប្រហែលបីឆ្នាំបន្ទាប់ពីការដាំរួចវាត្រូវបានវាយប្រហារដោយសត្វល្អិតជាច្រើននិងទីបំផុតបញ្ចប់ដោយការវាយប្រហាររបស់កណ្ដៀរ។ អាកាស្យាសេណោហ្គាល់ត្រូវបានបំផ្លិចបំផ្លាញធ្វើឲ្យខូចខាតដោយសត្វកញ្ជែរនិងសត្វមួយប្រភេទទៀតដែលស៊ីដើមជាចំណីអាហារ។ កណ្ដុបគឺជាភ្នាក់ងារបំផ្លេចបំផ្លាញស្លឹករុក្ខជាតិជាលក្ខណៈទ្រង់ទ្រាយធំនៅពេលដែលអាកាស្យាសេណោហ្គាល់កំពុងលូតលាស់បានល្អ ហើយវានឹងមកបំផ្លាញជាថ្មីម្ដងទៀតផងដែរ។ ពពែនិងគោគឺជាខ្មាំងដ៏ធំមួយរបស់អាកាស្យាសេណោហ្គាល់ខណៈពេលដែលស្លឹកមានរស់ជាតិឆ្ងាញ់ និងមានអាហារូបត្ថម្ភដល់ពួកវា ភ្លើងឆេះក៏ជាកត្តាដែលអាចសម្លាប់កូនឈើនិងបំផ្លាញដើមឈើយ៉ាងធំសំបើមដែរ។

Draft

### ៤.៧.៤-វិធានការការពារ

ការការពារសត្វកណ្ដៀរអាចត្រូវបានធ្វើឡើងដោយផ្សើមថងដី ហើយប្រើថ្នាំ Chloropyriphos ត្រូវលាយបញ្ចូលគ្នានៅក្នុងអត្រាកម្រិត៥mls នៃChloropyripos ក្នុងទឹកមួយលីត្រ។ ចំពោះសត្វកណ្ដុបប្រើថ្នាំបាញ់ Selvin / Vetox 85 លាយនៅក្នុងកម្រិត ១២g ក្នុងទឹកមួយលីត្រ។ ពពែនិងគោអាចរក្សាទុកនៅក្រៅពីថ្នាលបណ្ដុះកូនឬចម្ការដំណាំដោយហ៊ុំព័ទ្ធរបងជាមួយនឹងបន្លាលួស តែប្រសិនបើចង់ចំណាយអស់តិច គឺធ្វើរបងដោយកាត់ប្រភេទដើមអាកាស្យាសេណោហ្គាល់ផ្សេងៗមកហ៊ុំព័ទ្ធក៏វាល្អគ្រប់គ្រាន់ផងដែរ។

### ៤.៧.៥-ការជាជ័រ

បន្ទាប់ពីបួនទៅប្រាំឆ្នាំក្រោយមក ដើមឈើគ្រប់អាយុក្នុងការជាសម្រាប់យកជ័រ។ ការជាជ័រត្រូវបានធ្វើជាធម្មតាក្នុងអំឡុងពេលរដូវត្រជាក់នៃឆ្នាំ ចាប់ផ្ដើមនៅខែតុលា ឬវិច្ឆិកា។ ឧបករណ៍ពិសេសឬកាំបិតត្រូវបានប្រើដើម្បីជាដើមសម្រាប់យកជ័រ ហើយកាំបិតនេះមានរាងជាអក្សរ "r"។ វាមានមុខមុតស្រួចមួយនៅខាងចុងដើម្បីកាត់សំបក បន្ទាប់មកប្រើទំពក់មុតដើម្បីគាស់សំបកឈើ។ ជាធម្មតាក្បាលកាំបិតត្រូវបានតភ្ជាប់ទៅនឹងដងឈើវែង ដូច្នេះសូម្បីតែមែកខ្ពស់បំផុតនៃដើមឈើក៏អាចជាដល់ដែរ។

មុនពេលចូលទៅធ្វើការ អ្នកជាជ័រត្រូវកាត់សម្អាតមែកសាខាដែលរាំងស្ទះជាមុនសិន ទើបអនុញ្ញាតឲ្យចូលទៅជិតគល់និងមែកចាស់នៃដើមបាន។ ចំពោះមែកណាមួយដែលមានទំហំអង្កត់ផ្ចិតជាមធ្យម ៣cm គឺអាចជាជ័របាន។ ការជាត្រូវធ្វើតាមការណែនាំជាមួយនឹងនីតិវិធីដូចខាងក្រោម៖

1. ដាក់ចុងគែមកាំបិតកាត់ទៅនឹងសំបកនៃមែក
2. រុញមុខកាំបិតកាត់សំបកបំបែកចេញពីឈើ
3. ជាមួយទំពួកក៏ដូចជាផ្នែកមួយនៃកាំបិត។ បត់កាំបិតចេញឲ្យឆ្ងាយពីមែក ដូច្នេះទំពក់អាចគាស់សំបកឈើបាន
4. ទាញឆ្ពូតបញ្ឈរឡើងរួចផ្ដក់សំបកឈើ ដូច្នេះសំបកនឹងរហែកពី ១ ទៅ ៣cm (អាស្រ័យលើកម្រាស់នៃមែកឈើ)ត្រូវទាញចម្ងាយពី៤០ ទៅ៥០cm។ ការងារនេះគឺមិនបណ្ដាលឲ្យមានការខូចខាតទៅនឹងសាច់ដើមឈើឡើយ
5. ធ្វើឡើងម្ដងទៀតនៅដំណើរការខាងលើនេះ ទៅលើមែកដូចគ្នាចំនួនបីបួនកន្លែងទៀត ហើយធ្វើទៅលើមែកជាច្រើនទៀតប្រសិនបើអាចធ្វើទៅបានដើម្បីទទួលបាននូវទិន្នផលជ័រជាអតិបរិមាពីដើមឈើ
6. ត្រូវផ្អាកជាដើមឈើរយៈពេលចាប់ពី ៣០ ទៅ ៤០ថ្ងៃ។ ក្នុងអំឡុងពេលនោះរាល់ដើមដែលជាជ័រហើយវានឹងជ្រាបចេញជ័រមកក្រៅ ហើយកកទៅជាដុំធំៗរាងមូលដូចបាល់ភ្លីថ្លា

Draft

7. តាមការណែនាំ គឺតម្រូវឲ្យជានៅលើមែកម្ខាងតាមឆ្នាំនិមួយៗ ហើយជាឆ្លាស់នៅមែកម្ខាងទៀតនៅឆ្នាំបន្ទាប់ ដើម្បីបង្កើននូវទិន្នផលប្រកបដោយនិរន្តរភាពពីដើមឈើនោះ។

**ចំណាំ**៖ ពេលវេលាល្អបំផុតក្នុងការជាដើមអាកាស្យាសេណេហ្គាល់ដើម្បីទទួលបានទិន្នផលខ្ពស់គឺនៅប្រហែលម៉ោង៩ព្រឹក និងម៉ោង៥ល្ងាច។ ជ័រអាកាស្យាដែលបានបញ្ចេញមកពីស្នាមប្រេះពីធម្មជាតិនៅលើដើមឬស្នាមប្រេះផ្សេងៗដែលបានបង្កើតដោយការចោះរន្ធ គួរតែត្រូវប្រមូលទាំងអស់។ ជ័រវែបនេះគឺងាយស្រួលក្នុងការកត់សម្គាល់ពីជ័រផ្សេងៗទៀត ហើយពួកវាមានគុណភាពល្អបំផុត។

### ៤.៧.៦-ការប្រមូលមូលផលនិងទិន្នផល

ការប្រមូលផលដំបូងនៃជ័រគឺប្រព្រឹត្តិទៅ ៣០ ទៅ ៤០ ថ្ងៃបន្ទាប់ពីជាឬឆូតសំបកហើយ។ ជ័រដែលមានរាងមូលដូចបាល់អាចបេះបានច្រើនដងក្នុងអំឡុងពេលអាកាសធាតុក្តៅល្មម។ ការប្រមូលត្រូវបានបន្តជារៀងរាល់មួយឬពីរសប្តាហ៍អាស្រ័យលើភាពកករឹងនៃជ័រនោះរហូតដល់ពេលចាប់ផ្តើមភ្លៀង។ ជ័រគួរតែបេះរួចនៅពេលព្រឹកព្រោះជ័រអាចរលាយនៅពេលដែលសីតុណ្ហភាពកើនឡើងកំដៅ។ អំឡុងពេលនៃការបេះត្រូវពិនិត្យឲ្យបានច្បាស់លាស់ថារាល់ជ័រល្អិតៗត្រូវបានប្រមូលអស់ពីមែកធាង។ ដើមអាកាស្យាសេណេហ្គាល់មួយដើមមានសមត្ថភាពផលិតជ័របានពី ៤០០ ទៅ ៦០០gm ក្នុងរដូវកាលជាជ័រ។ ដូច្នេះនៅក្នុងចម្ការមួយដែលមានគម្លាត ៥m x ៥m គឺទទួលបានទិន្នផលជាមធ្យមចំនួន ២០០kg ក្នុងមួយហិកតាក្នុងការរំពឹងទុក។

### ៤.៧.៧-ថង់វេចខ្ចប់

ជ័រទាំងអស់សម្រាប់នាំចេញត្រូវតែវេចខ្ចប់ដាក់ក្នុងបាវក្រចៅ។ ថង់ខាងក្រៅគួរតែថ្មីនិងមានគុណភាពល្អ។ ប្រើថង់ណាដែលអាចប្រើជាថង់ខាងក្នុងបាន ប៉ុន្តែវាត្រូវតែស្អាតស្ងួតនិងរឹងមាំ។

### ៤.៧.៨-កន្លែងស្តុកទុក

ជ័រគួរតែទុកនៅក្នុងកន្លែងស្អាតហើយស្ងួតនិងត្រជាក់។ វាមិនធ្វើឲ្យអាក្រក់ដោយសារតែការផ្ទុករយៈពេលវែងនៅក្រោមស្ថានភាពអំណោយផលឡើយ។ ទោះជាយ៉ាងណាក្តីប្រសិនបើកន្លែងស្តុកទុកនោះភ្លៀងអាចសាចចូលទៅប៉ះបាន នឹងធ្វើឲ្យជ័រនោះក្លាយជារឹងហើយឡើងពណ៌ខ្មៅ ហើយក៏អាចធ្វើឲ្យប៉ះពាល់ដល់គុណភាពរបស់វាផងដែរ។

## ៤.៨-ផែនការបែងចែក និងរៀបចំដីដាំដុះ

ផែនការបែងចែកផ្ទៃដីដាំដុះ និងការរៀបចំដីសម្រាប់សម្បទានដាំដុះដំណាំដូង កាកាវ អាកាស្យាសេណេហ្គាល់ សណ្តែកសៀង ស្រូវ កៅស៊ូ និងដំណាំកសិ-ឧស្សាហកម្ម របស់ក្រុមហ៊ុនយើងខ្ញុំត្រូវបានគ្រោងអនុវត្តសម្រាប់ការដាំដុះក្នុងរយៈពេល ០៦ឆ្នាំ (២០១៦-២០២១) ដែលមានផ្ទៃដីដាំដុះសរុបចំនួន ៦១២៦ ហិកតា។ ក្នុងនោះផ្ទៃដីសម្រាប់ដាំដូង កាកាវ និងអាកាស្យា



Draft

សេណោហ្គាល់គ្រោងដាំដុះលើផ្ទៃដីប្រមាណ ៣៥៥៦ ហិកតា ផ្ទៃដីដាំស្រូវចំនួន ១៤៥៧ ហិកតា ផ្ទៃដីដាំកៅស៊ូចំនួន ៤០០ ហិកតា និងផ្ទៃដីដាំសណ្តែកសៀងចំនួន៧១៣ ហិកតា។ ក្រុមហ៊ុនយើងខ្ញុំក៏បានត្រៀមនូវផ្ទៃដីប្រហែល ៣៨៣,២៧ ហិកតាទៀត សម្រាប់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ដែលរួមមានប្រព័ន្ធផ្លូវគមនាគមន៍ក្នុងតំបន់ដីសម្បទាន ការសាងសង់ប្រព័ន្ធស្រោចស្រពសំណង់អាគារការដ្ឋានរោងចក្រកែច្នៃ និងសំណង់ផ្សេងៗទៀត។

ក្រុមហ៊ុនគ្រោងចាប់ផ្តើមអនុវត្តការដាំដុះដំណាំដូង កាកាវ អាកាស្យាសេណាហ្គាល់ សណ្តែកសៀង ស្រូវ កៅស៊ូ និងដំណាំកសិ-ឧស្សាហកម្ម នៅឆ្នាំ២០១៦ និងគ្រោងដាំឲ្យអស់ចប់សព្វគ្រប់នៅឆ្នាំ២០២១ លើផ្ទៃដីដែលអាចធ្វើអាជីវកម្មបានចំនួន ៦៥០៩ ហិកតា (លម្អិតក្នុងឧបសម្ព័ន្ធ-១)។

ក្នុងផ្ទៃដីដែលអាចធ្វើអាជីវកម្មបានចំនួន ៦៥០៩ ហិកតា នេះ ក្រុមហ៊ុនត្រូវកាត់ចេញផ្ទៃដីសាងសង់ សំណង់នានាចំនួន ៣៨៣ ហិកតា ដែលធ្វើឲ្យផ្ទៃដីអាចដាំដុះបានមានចំនួន ៦១២៦ ហិកតា សម្រាប់ដាំដំណាំកៅស៊ូ ដូង កាកាវ អាកាស្យាសេណាហ្គាល់ សណ្តែកសៀង និងស្រូវ។

Draft

**<u>ផែនការបែងចែកផ្ទៃដីដាំដុះតាមបណ្តាឆ្នាំ២០១២ ដល់ឆ្នាំ២០១៦</u>**

| មុខដំណាំ | **ឆ្នាំទី-១ និងឆ្នាំទី-២** | **ឆ្នាំទី-៣** | **ឆ្នាំទី-៤ និងឆ្នាំទី-៥** | **ឆ្នាំទី-៦** | **សរុប (ហ.ត)** |
|---|---|---|---|---|---|
| ឆ្នាំ | ២០១៦-២០១៧ | ២០១៨ | ២០១៩-២០២០ | ២០២១ | |
| ផ្ទៃដីដាំដុះដូង/កាកាវ/អាកាស្យាសេណោហ្គាល់ | ១៥១២ | ៩៤០ | ១១០៤ | ០ | ៣៥៥៦ |
| ផ្ទៃដីដាំស្រូវ/កសិ-ឧស្សាហកម្ម | ៨១ | ២៩៨ | ៨៦៤ | ២១៤ | ១៤៥៧ |
| ផ្ទៃដីដាំសណ្តែកសៀង/កសិ-ឧស្សាហកម្ម | ៣៥០ | ២៤ | ៣៣៩ | ០ | ៧១៣ |
| ផ្ទៃដីដាំដុះកៅស៊ូ | ០ | ០ | ០ | ៤០០ | ៤០០ |
| **សរុបផ្ទៃដីសម្រាប់ដាំដុះ** | **១៩៤៣** | **១២៦២** | **២៣០៧** | **៦១៤** | **៦១២៦** |
| ផ្ទៃដីប៉ាន់ស្មានហេដ្ឋារចនាសម្ព័ន្ធនានា | ៩៩ | ៧៣ | ១៦៣ | ៤៨ | ៣៨៣ |
| **<u>សរុបផ្ទៃដីអាជីវកម្ម</u>** | **<u>២០៤២</u>** | **<u>១៣៣៥</u>** | **<u>២៤៧០</u>** | **<u>៦៦២</u>** | **<u>៦៥០៩</u>** |
| ផ្ទៃដីរក្សាតាមដងអូរ | ៧៧ | ៣៦៨ | ៨៩០ | ៨០៨ | ២១៤៣ |
| ផ្ទៃដីតំបន់រក្សាទុក | ៧៩៩ | ៤០៥ | ១០២០ | ០ | ២២២៤ |
| ផ្ទៃដីពាក់ព័ន្ធ ប្រជាពលរដ្ឋ | ៦៧ | ១៥៣ | ១០០៤ | ២៨៩០ | ៤១១៤ |
| ផ្ទៃដីជាន់ព្រៃគុបក្នុងស្រុក | ០ | ៣៧ | ២៥០ | ០ | ២៨៧ |
| ផ្ទៃដីសម្រាប់កំណើនប្រជាពលរដ្ឋនៅពេលអនាគត១០% | ០ | ០ | ៨៥៧ | ០ | ៨៥៧ |

| | | | | | |
|---|---|---|---|---|---|
| ផ្ទៃដីត្រៀមបម្រុងទុកសម្រាប់សម្បទានដីសង្គមកិច្ច | ០ | ០ | ១៩២ | ៤០៦ | ៥៩៨ |
| ផ្ទៃដីព្រៃសហគមន៍ | ០ | ០ | ០ | ១៧៣ | ១៧៣ |
| ផ្ទៃដីពាក់ព័ន្ធផ្សេងៗ | ០ | ១៦ | ៦៣ | ៦ | ៨៥ |
| **សរុបផ្ទៃដី (Ha)** | **២៩៨៥** | **២៣១៤** | **៦៧៤៦** | **៤៩៩៥** | **១៦៩៤០** |

<u>បញ្ជាក់</u>៖ ផ្ទៃដីពាក់ព័ន្ធផ្សេងៗមាន៖ ផ្ទៃដីព្រៃកប់ខ្មោចចំនួន ១៦,៧៨ហិកតា ដីព្រៃអ្នកតាចំនួន ៨,៤១ហិកតា ដីទូលសុវត្ថិភាពចំនួន ៤៣,៨១ហិកតា និងដីទ្រនាប់ផ្លូវចំនួន ១៦ហិកតា)

នៅក្នុងផ្ទៃដីអាចដាំដុះចំនួន ៦១២៦ហិកតា នេះក្រុមហ៊ុនយើងខ្ញុំនឹងគ្រោងធ្វើការដាំដុះ និងបែងចែកផ្ទៃដីដាំដុះតាមឆ្នាំនីមួយៗដូចខាងក្រោម ៖

ឆ្នាំទី១-ទី២ (២០១៦-២០១៧) ក្រុមហ៊ុនគ្រោងដាំដុះដំណាំកសិ-ឧស្សាហាកម្មលើផ្ទៃដីចំនួន ១៩៤៣ ហិកតា នៅក្នុងអនុតំបន់I ។

ឆ្នាំទី២ (២០១៨) ក្រុមហ៊ុនគ្រោងដាំដុះដំណាំកសិ-ឧស្សាហាកម្ម លើផ្ទៃដីចំនួន ១២៦២ ហិកតា នៅក្នុងអនុតំបន់II។

ឆ្នាំទី៣ (២០១៩-២០២០) ក្រុមហ៊ុនគ្រោងដាំដុះដំណាំកសិ-ឧស្សាហាកម្ម លើផ្ទៃដីចំនួន ២៣០៧ ហិកតា នៅក្នុងអនុតំបន់III។

ឆ្នាំទី៤ (២០២១) ក្រុមហ៊ុនគ្រោងដាំដុះដំណាំកសិ-ឧស្សាហាកម្ម លើផ្ទៃដីចំនួន ៦១៤ ហិកតា នៅក្នុងអនុតំបន់IV។

តារាងបង្ហាញពីផែនការដាំដុះដំណាំដូង កាកាវ អាកាស្យាសេណោហ្គាល់ សណ្តែកសៀង ស្រូវ កៅស៊ូ និងកសិ-ឧស្សាហាកម្ម រយៈពេល៦ឆ្នាំ (២០១៦-២០២១) ដូចខាងក្រោម៖

**<u>ផែនការរៀបចំដីវិនិយោគដាំដំណាំដូង កាកាវ អាកាស្យាសេណោហ្គាល់ សណ្តែកសៀង ស្រូវ កៅស៊ូ និងដំណាំកសិ-ឧស្សាហាកម្មពីឆ្នាំទី១ ដល់ឆ្នាំទី៦</u>**

<u>ឯកតា:ហិកតា</u>

| មុខដំណាំ | ឆ្នាំទី១-ឆ្នាំទី២ | ឆ្នាំទី៣ | ឆ្នាំទី៤-ឆ្នាំទី៥ | ឆ្នាំទី៦ |
|---|---|---|---|---|
| ផ្ទៃដីដាំដុះដូង/កាកាវ/អាកាស្យាសេណោហ្គាល់ | ១៥១២ | ៩៤០ | ១១០៤ | ០ |
| ផ្ទៃដីដាំស្រូវ/កសិ-ឧស្សាហាកម្ម | ៨១ | ២៩៨ | ៨៦៤ | ២១៤ |
| ផ្ទៃដីដាំសណ្តែកសៀង/កសិ-ឧស្សាហាកម្ម | ៣៥០ | ២៤ | ៣៣៩ | ០ |
| ផ្ទៃដីដំណាំកៅស៊ូ | ០ | ០ | ០ | ៤០០ |
| **សរុបផ្ទៃដីដាំដុះ(ហ.ត)** | **១៩៤៣** | **១២៦២** | **២៣០៧** | **៦១៤** |

Draft

បញ្ជាក់៖

- ផ្ទៃដីដែលអាចដាំដុះបានមានចំនួន **៦១២៦** ហិកតា
- ក្រោយពីដាំដើមដូងបានរយៈពេល ៣ឆ្នាំ ក្រុមហ៊ុននឹងចាប់ផ្តើមចាប់ធ្វើការដាំដុះដំណាំកាការនៅតាមចន្លោះរងដាំដើមដូង។

## ៥-ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ (Infrastructure Development)

### ៥.១-ប្រពន្ធ័ផ្លូវ (Road Network)

គម្រោងផែនការសម្រាប់ការរៀបចំប្រពន្ធ័ផ្លូវក្នុងតំបន់ដីសម្បទាន ក្រុមហ៊ុនមានផែនការសាងសង់ប្រពន្ធ័ផ្លូវដោយមិនគិតពីផ្លូវចាស់។ ដោយឡែកក្នុងតំបន់ផ្ទៃដីដែលត្រូវរក្សាទុកដូចជាដីព្រៃដែលត្រូវរក្សាទុក តំបន់ការពារទីជម្រាល ដីពាក់ព័ន្ធផ្សេងៗ និងដីប្រជាពលរដ្ឋគឺក្រុមហ៊ុនយើងខ្ញុំមិនសាងសង់ផ្លូវកាត់ទេ។ ក្នុងករណីចាំបាច់ ឬមានកិច្ចសហការពីប្រជាពលរដ្ឋអាជ្ញាធរមូលដ្ឋានក្រុមហ៊ុនយើងខ្ញុំនឹងសាងសង់ជួសជុលផ្លូវចាស់ដែលមានស្រាប់ដើម្បីប្រើប្រាស់រួមជាសាធារណៈ។

ដើម្បីជំរុញឲ្យការធ្វើអាជីវកម្ម-ផលិតកម្ម ក្នុងតំបន់ដីវិនិយោគដំណើរការទទួលបានជោគជ័យក្រុមហ៊ុនមានផែនការសាងសង់ប្រពន្ធ័ផ្លូវ ០៥ ប្រភេទ សម្រាប់ជាខ្សែខ័ណ្ឌព្រំប្រទល់ជុំវិញតំបន់ដីគម្រោងវិនិយោគជាព្រំ ប្រទល់សម្រាប់ការបែងចែកអនុតំបន់ដីសម្បទាននិងជាការបែងចែកឡូត៍សម្រាប់ការដាំដុះ និងការគ្រប់គ្រង។ ប្រពន្ធ័ផ្លូវទាំង០៥ប្រភេទមាន៖

១- ផ្លូវពទ្ធ័ជុំវិញដីអាជីវកម្មប្រវែង ២៣៤,២៩ គីឡូម៉ែត្រ និងទទឹង ៦ម៉ែត្រ

២- ផ្លូវមេក្នុងតំបន់ដីសម្បទានចំនួន ០៣ខ្សែ ប្រវែង ៣១,២៦ គីឡូម៉ែត្រ និងទទឹង ៨ ម៉ែត្រ

៣- ផ្លូវមេបែងចែងអនុតំបន់ចំនួន ០៣ខ្សែ ប្រវែង ៣,៨០ គីឡូម៉ែត្រ និងទទឹង ៨ ម៉ែត្រ

៤- ផ្លូវមេក្នុងអនុតំបន់ដីសម្បទានសរុបចំនួន ៧៩ខ្សែ ស្មើនឹង ១២២,៥២ គីឡូម៉ែត្រ និងមានប្រវែងទទឹងផ្លូវ ០៦ ម៉ែត្រ

៥- ផ្លូវបែងចែកឡូត៍សរុបចំនួន ៧៨ខ្សែ ប្រវែង ១២០,២៤ គីឡូម៉ែត្រ នឹងទទឹងផ្លូវចំនួន ៤ ម៉ែត្រ

ផ្លូវទាំង ០៥ ប្រភេទ នេះមានបញ្ជាក់សង្ខេបក្នុងតារាងខាងក្រោមបន្ទាប់ពីការអត្ថាធិប្បាយពីផ្លូវនីមួយៗ។ ប្រភេទផ្លូវនីមួយៗមានទំហំប្រវែងខុសៗគ្នា និងមានអត្ថប្រយោជន៍សម្រាប់ម្រើឲ្យការធ្វើអាជីវកម្ម-ផលិតកម្មផ្សេងៗពីគ្នាតាមប្រភេទផ្លូវ។ តាមការសិក្សារបស់ក្រុមហ៊ុន និងការរៀបចំគំនូសប្លង់ (ផែនទីជូនភ្ជាប់) សម្រាប់ការសាងសង់ប្រពន្ធ័ផ្លូវទាំងនោះដូចខាងក្រោម៖

#### ៥.១.១-ផ្លូវព័ទ្ធជុំវិញដីអាជីវកម្មតំបន់ដីសម្បទាន

ផ្លូវពទ្ធ័ជុំវិញដីអាជីវកម្មក្នុងតំបន់ដីសម្បទាន គឺជាផ្លូវដែលត្រូវសាងសង់ពទ្ធ័ជុំវិញដីអាជីវកម្មក្នុងតំបន់ដីសម្បទានដែលមានប្រវែងសរុប ២៣៤,២៩គីឡូម៉ែត្រ និងទទឹងផ្លូវមានប្រវែង៦ម៉ែត្រ សរុបផ្ទៃដីសម្រាប់កសាងផ្លូវពទ្ធ័ជុំវិញដីអាជីវកម្មក្នុងតំបន់ដីសម្បទានមានចំនួន ១៤០,៥១ ហិកតា។ ផ្លូវនេះធ្វើការសាងសង់ចាប់ផ្តើមពីចំនុច K1 វត់តាមព្រំប្រទល់ដីសម្បទាន

Draft

ទៅទិសខាងជើងត្រង់ឆ្លងកាត់ចំនុចL1។ ពីចំនុច L1 វត់តាមព្រំប្រទល់ដីសម្បទានទៅទិសខាងលិចដល់ចំនុច A ។ ពីចំនុច A វត់តាមព្រំប្រទល់ដីសម្បទានទៅទិសខាងកើតឈាងខាងលិចដល់ចំនុចB។ ពីចំនុច B វត់តាមព្រំប្រទល់ដីសម្បទានដល់ចំនុចP1។ ពីចំនុចP1 វត់តាមព្រំប្រទល់ដីសម្បទានដល់ចំនុចC។ ពីចំនុចC វត់ទៅទិសខាងជើងឈាងខាងកើតតាមព្រំប្រទល់ដីគម្រោងវិនិយោគកាត់ក្នុងអនុតំបន់II បន្តឆ្លងកាត់ក្នុងអនុតំបន់III ដែលជាចំនុចបញ្ចប់នៃផ្លូវនេះ។

សារៈប្រយោជន៍របស់ផ្លូវនេះ គឺដើម្បីជារបងកំណត់ព្រំប្រទល់ដីអាជីវកម្មក្នុងតំបន់ដីសម្បទានជាផ្លូវសម្រាប់ធ្វើចរាចរក្នុងការធ្វើអាជីវកម្ម-ផលិតកម្មការដឹកជញ្ជូន ជាផ្លូវយុទ្ធសាស្ត្រសម្រាប់ការពារសន្តិសុខ និងសុវត្ថិភាពដូចជា ៖ ការពារភ្លើងឆេះព្រៃ និងចល័តកម្លាំងសន្តិសុខនៅពេលមានបញ្ហា......។ល។

**៥.១.២-ប្រភេទផ្លូវមេក្នុងតំបន់ដីសម្បទាន**

គម្រោងផែនការក្នុងការរៀបចំកសាងផ្លូវមេក្នុងតំបន់ដីសម្បទានគឺមានចំនួន ០៣ខ្សែ។ ប្រវែងសាងសង់ប៉ាន់ស្មានសរុបចំនួន ៣១,២៦គីឡូម៉ែត្រ និងមានទទឹង៨ម៉ែត្រសរុបផ្ទៃដីសម្រាប់កសាងផ្លូវមេក្នុងតំបន់ដីសម្បទានមានចំនួន ២៥,០១ ហិកតា (ដូចមានផែនទីជូនភ្ជាប់)។

សារៈប្រយោជន៍របស់ផ្លូវមេក្នុងតំបន់ដីសម្បទានគឺៈ

- ជាផ្លូវសម្រាប់ធ្វើចរាចរគ្រឿងចក្រដឹកនាំផលដែលទទួលបានពីការដាំដុះ និងផលិតផលផ្សេងៗសម្រាប់បម្រើឲ្យការធ្វើអាជីវកម្ម-ផលិតកម្ម
- ជាផ្លូវយុទ្ធសាស្ត្រសម្រាប់ការពារសន្តិសុខ និងសុវត្ថិភាព ដូចជាការពារភ្លើងឆេះព្រៃ និងកម្លាំងនៅពេលមានឧប្បទ្ទហេតុកើតមានឡើងក្នុងតំបន់ដីសម្បទាន..។ល។
- ចរាចរត្រួតពិនិត្យក្នុងតំបន់ដីសម្បទាន។

**៥.១.៣-ប្រភេទផ្លូវមេចែកអនុតំបន់**

ផ្លូវមេចែកអនុតំបន់ គឺជាប្រភេទផ្លូវកសាងឡើងដើម្បីកំណត់អនុតំបន់សម្រាប់ធ្វើការដាំដុះតាមឆ្នាំនីមួយៗ និងសម្រាប់បំរើឲ្យការធ្វើអាជីវកម្ម-ផលិតកម្ម។ ផ្លូវនេះក្រុមហ៊ុនមានផែនការកសាងចំនួន ០៣ខ្សែ ប្រវែងប៉ាន់ស្មានសរុបចំនួន ៣,៨០ គីឡូម៉ែត្រ និងទទឹងផ្លូវ ៨ម៉ែត្រ ផ្ទៃដីប៉ាន់ស្មានសម្រាប់ការសាងសង់សរុបមានចំនួន ៣.០៤ ហិកតា (ដូចមានផែនទីជូនភ្ជាប់)។

សារៈប្រយោជន៍របស់ផ្លូវមេក្នុងអនុតំបន់ដីសម្បទានគឺៈ

- ជាផ្លូវសម្រាប់កំណត់ព្រំប្រទល់ឡូត៍ក្នុងអនុតំបន់នីមួយៗ
- ជាផ្លូវសម្រាប់អ្នកបច្ចេកទេសងាយស្រួលក្នុងត្រួតពិនិត្យ និងគ្រប់គ្រង
- ជាផ្លូវសម្រាប់កម្មករប្រមូលផលតាមឡូត៍នីមួយៗ
- ជាផ្លូវសម្រាប់ធ្វើចរាចរគ្រឿងចក្រដឹកនាំផលដែលទទួលបានពីការដាំដុះ និងផលិតផលផ្សេងៗសម្រាប់បម្រើឲ្យការធ្វើអាជីវកម្ម-ផលិតកម្ម។
- ជាផ្លូវយុទ្ធសាស្ត្រសម្រាប់ការពារសន្តិសុខ និងសុវត្ថិភាពដូចជាការពារភ្លើងឆេះព្រៃ និងចល័តកម្លាំងនៅពេលមានឧប្បត្តិហេតុកើតមានឡើងក្នុងតំបន់ដីសម្បទាន......។ល។

- ចរាចរត្រួតពិនិត្យក្នុងតំបន់ដីសម្បទាន និងការពារការហូរច្រោះដី...។ល។

### ៥.១.៤-ប្រភេទផ្លូវមេក្នុងអនុតំបន់

ផ្លូវមេក្នុងអនុតំបន់ដីសម្បទានគ្រោងធ្វើការសាងសង់មានចំនួន ៧៩ខ្សែប្រវែងផ្លូវប៉ាន់ស្មានសម្រាប់ការសាងសង់នេះប្រមាណ ១២២,៥២គីឡូម៉ែត្រ និងមានប្រវែងទទឹងផ្លូវ ៦ម៉ែត្រ ផ្ទៃដីប៉ាន់ស្មានសម្រាប់សាងសង់មានចំនួន ៧៣,៥៣ហិកតា។ ផ្លូវមេក្នុងអនុតំបន់ដីសម្បទានមានគម្លាតពីផ្លូវមួយទៅផ្លូវមួយចំងាយ ១ គីឡូម៉ែត្រ (ផែនទីជូនភ្ជាប់)។ សារៈប្រយោជន៍របស់ផ្លូវមេក្នុងអនុតំបន់ដីសម្បទានគឺៈ

- ជាផ្លូវសម្រាប់កំណត់ព្រំប្រទល់ឡូត៍ក្នុងអនុតំបន់នីមួយៗ
- ជាផ្លូវសម្រាប់អ្នកបច្ចេកទេសងាយស្រួលក្នុងត្រួតពិនិត្យ និងគ្រប់គ្រង
- ជាផ្លូវសម្រាប់កម្មករប្រមូលផលតាមឡូត៍នីមួយៗ
- ជាផ្លូវសម្រាប់ធ្វើចរាចរគ្រឿងចក្រការដឹកនាំផលដែលទទួលបានពីការដាំដុះនិងផលិតផលផ្សេងៗសម្រាប់បម្រើឲ្យការធ្វើអាជីវកម្ម-ផលិតកម្ម
- ជាផ្លូវយុទ្ធសាស្ត្រសម្រាប់ការពារសន្តិសុខ និងសុវត្ថិភាពដូចជាការពារភ្លើងឆេះព្រៃ និងចល័តកម្លាំងនៅពេលមានឧប្បត្តិហេតុកើតមានឡើងក្នុងតំបន់ដីគម្រោងវិនិយោគ..។ល។
- ចរាចរត្រួតពិនិត្យក្នុងតំបន់ដីសម្បទាន និងការពារការហូរច្រោះដី............។ល។

### ៥.១.៥-ផ្លូវឡូត៍

ផ្លូវឡូត៍គ្រោងធ្វើការសាងសង់សរុបចំនួន ៧៨ខ្សែ មានប្រវែង ១២០,២៥គីឡូម៉ែត្រ ផ្ទៃដីប៉ាន់ស្មានសម្រាប់សាងសង់មានចំនួន៥៨,១១ហិកតា និងមានទទឹង៥ម៉ែត្រ។

ផ្លូវឡូត៍គ្រោងធ្វើការសាងសង់គំលាតពីផ្លូវមួយទៅផ្លូវមួយចំងាយ ៥០០ ម៉ែត្រ ឬ គម្លាត ៥០០ម៉ែត្រ ពីផ្លូវផ្សេងៗទៀត (ផែនទីជូនភ្ជាប់)។

សារៈប្រយោជន៍របស់ផ្លូវឡូត៍ក្នុងតំបន់ដីសម្បទានគឺៈ

- ជាផ្លូវសម្រាប់កំណត់ព្រំប្រទល់ឡូត៍ក្នុងអនុតំបន់នីមួយៗ
- ជាផ្លូវសម្រាប់អ្នកបច្ចេកទេសងាយស្រួលក្នុងត្រួតពិនិត្យ និងគ្រប់គ្រង
- ជាផ្លូវសម្រាប់កម្មករប្រមូលផលតាមឡូត៍នីមួយៗ
- ជាផ្លូវសម្រាប់ធ្វើចរាចរគ្រឿងចក្រដឹកនាំផលដែលទទួលបានពីការដាំដុះ និងផលិតផលផ្សេងៗសម្រាប់បម្រើឲ្យការធ្វើអាជីវកម្ម-ផលិតកម្ម
- ជាផ្លូវយុទ្ធសាស្ត្រសម្រាប់ការពារសន្តិសុខ និងសុវត្ថិភាពដូចជាការពារភ្លើងឆេះព្រៃ និងចល័តកម្លាំងនៅពេលមានឧប្បទ្ទវហេតុកើតមានឡើងក្នុងតំបន់ដីសម្បទាន...។ល។
- ជាផ្លូវសម្រាប់ឲ្យកម្មករងាយស្រួលក្នុងការជញ្ជូនផលិតផលដោយកម្លាំងពលកម្ម ការថែទាំការពារភ្លើងនិងសម្រាប់ប្រមូលផ្តុំផលរួចដឹកចេញមកកន្លែងប្រមូលផ្តុំផលតាមឡូត៍ និងបន្តមកកាន់រោងចក្រ

Draft

- ចរាចរត្រួតពិនិត្យក្នុងតំបន់ដីសម្បទាន និងការពារការហូរច្រោះដី...។ល។

**បញ្ជាក់**

-គម្រោងការសាងសង់ផ្លូវទាំង ៥ប្រភេទ ខាងលើនៅពេលអនុវត្តក្រុមហ៊ុនយើងខ្ញុំនឹងដំណើរការតាមសណ្ឋានដីជាក់ស្តែង។ គម្រោងផែនការសម្រាប់ការរៀបចំប្រព័ន្ធផ្លូវក្នុងតំបន់ដីសម្បទានក្រុមហ៊ុនមានផែនការសាងសង់ប្រព័ន្ធផ្លូវដោយមិនគិតពីផ្លូវចាស់។ ដោយឡែកក្នុងតំបន់ដីរក្សាទុកក្រុមហ៊ុនយើងខ្ញុំមិនសាងសង់ផ្លូវកាត់ទេ។

-ចំពោះផ្លូវចាស់ដែលមានស្រាប់ក្នុងករណីចាំបាច់ និងមានកិច្ចសហការល្អពីប្រជាពលរដ្ឋអាជ្ញាធរមូលដ្ឋានក្រុមហ៊ុនយើងខ្ញុំនឹងធ្វើការសាងសង់ ឬជួសជុលផ្លូវចាស់ដែលមានស្រាប់នោះសម្រាប់ប្រើប្រាស់រួមជាសាធារណៈ។

**តារាងសង្ខេបអំពីប្រព័ន្ធផ្លូវសម្រាប់ដំណើរការអភិវឌ្ឍន៍ក្នុងតំបន់ដីសម្បទាន**

| ល.រ | ប្រភេទផ្លូវ | ចំនួន ខ្សែ | ប្រវែង គ.ម | ទទឹងផ្លូវ ម៉ែត្រ | ផ្ទៃដី ហ.ត |
|---|---|---|---|---|---|
| ១ | ផ្លូវមេព័ទ្ធជុំវិញដីអាជីវកម្ម | | 234.29 | 6 | 140.51 |
| ២ | ផ្លូវមេនៅក្នុងដីសម្បទាន | 3 | 31.26 | 8 | 25.01 |
| ៣ | ផ្លូវមេបែងចែកអនុតំបនដីសម្បទាន | 3 | 3.8 | 8 | 3.04 |
| ៤ | ផ្លូវមេក្នុងអនុតំបន់ដីសម្បទាន | 79 | 122.52 | 6 | 73.53 |
| ៥ | ផ្លូវបែងចែកឡូត៍ | 78 | 120.24 | 4 | 48.11 |
| សរុប | | **163** | **512.11** | | **290.2** |

### ៥.២-ប្រព័ន្ធស្រោចស្រព (Irrigation System)

ប្រភពទឹកសម្រាប់បម្រើឲ្យការស្រោចស្រពក្នុងតំបន់ដីសម្បទាន មានលក្ខណៈអំណោយផលល្អព្រោះ ក្នុងតំបន់ដីសម្បទានមានប្រភពទឹកជាប់ទន្លេសេសាន និងមានទឹកអូរព្រែកធម្មជាតិមួយចំនួនហូរកាត់ ជាពិសេសនៅតំបន់ដីសម្បទានផ្នែក មានព្រែកដែលជាប្រភពដ៏សំខាន់ហូរកាត់ស្ទើរតែកណ្តាលដីដែលអាចឲ្យយើងងាយស្រួលក្នុងការទាញយកទឹក មកស្រោចស្រព និងប្រើប្រាស់ផ្សេងៗ។

វិធីសាស្ត្រទាញទឹកយកមកប្រើប្រាស់គឺក្រុមហ៊ុនមានផែនការស្ថាបនាប្រព័ន្ធប្រឡាយកសាង ប្រឡាយបណ្តែត និងប្រើប្រាស់ទុយោសម្រាប់ការស្រោចស្រពទៅតាមស្ថានភាពដីជាក់ស្តែងក្នុងតំបន់ដីគម្រោងវិនិយោគ។

ម្យ៉ាងវិញទៀតក្នុងករណីជួបការលំបាកលើការទាញទឹកពីប្រភពទឹក ដែលបានរៀបរាប់ខាងលើ ក្រុមហ៊ុនក៏មានផែនការកសាងប្រពន្ធ័ធារាសាស្រ្តស្ទាក់ទឹកភ្លៀង និងប្រើប្រាស់ប្រពន្ធ័ទឹកក្រោមផងដែរ។

## ៥.៣-រោងចក្រកែច្នៃផលិតផល (Processing Factory)

ក្រុមហ៊ុនមានគម្រោងសាងសង់ចក្រកែច្នៃផលិតផល ០១ កន្លែង ដោយគ្រោងផ្ទៃដីប្រហែល ១២ ហិកតា សម្រាប់ការសាងសង់។ រោងចក្រកែច្នៃនេះគ្រោងចំណាយថវិកា នៃទុនវិនិយោគប្រហែល ៩០០.០០០ ដុល្លារអាមេរិក។ ការសាងសង់រោងចក្រកែច្នៃនឹងត្រូវចាប់ផ្តើមនៅឆ្នាំទី៦។ ទីតាំងនៃសំណង់រោងចក្រកែច្នៃស្ថិតនៅក្នុងតំបន់សម្បទានដែលមាននិយាមកានៅត្រង់ចំនុចកូអដោនេ X ៖ ៦៧៩២៥០ និងY៖១៥១៣៥០០។ លម្អិតការចំណាយ នៃការសាងសង់រោងចក្រនឹងបង្ហាញជូនក្នុងជំពូកទី៣។

## ៥.៤ –ទីតាំងទំហំផ្ទៃដីសម្រាប់ហេដ្ឋារចនាសម្ព័ន្ធ (Infrastructure Development)

Draft

ក្រុមហ៊ុនយើងខ្ញុំមានផែនការសាងសង់សំណង់មួយចំនួន សម្រាប់ដំណើរការក្នុងការធ្វើអាជីវកម្ម-ផលិតកម្មក្នុងតំបន់ដីសម្បទានសំណង់ទាំងនោះមានដូចតទៅ៖

-ផ្លូវមេពទ្ធ័ជុំវិញដីអាជីវកម្មក្នុងតំបន់ដីសម្បទាន គឺជាផ្លូវដែលត្រូវសាងសង់ពទ្ធ័ជុំវិញដីអាជីវកម្មក្នុងតំបន់ដីសម្បទានដែលសាងសង់មានប្រវែងសរុប ២៣៤,២៩គីឡូម៉ែត្រ និងទទឹងផ្លូវមានប្រវែង ៦ម៉ែត្រ សរុបផ្ទៃដីសម្រាប់កសាងផ្លូវមេពទ្ធ័តំបន់ដីសម្បទានមានចំនួន ១៤០,៥១ ហិកតា។

-ផ្លូវមេក្នុងតំបន់ដីសម្បទានមានចំនួន ០៣ ខ្សែ ប្រវែងសាងសង់ប៉ាន់ស្មានសរុបចំនួន ៣១,២៦ គីឡូម៉ែត្រ និងមានទទឹង ៨ម៉ែត្រ សរុបផ្ទៃដីសម្រាប់កសាងផ្លូវមេក្នុងតំបន់ដីសម្បទានមានចំនួន ២៥.០១ ហិកតា។

-ផ្លូវមេចែកអនុតំបន់មានចំនួន ០៣ ខ្សែ ប្រវែងប៉ាន់ស្មានសរុបចំនួន ៣.៨០ គីឡូម៉ែត្រ និងទទឹងផ្លូវ ៨ ម៉ែត្រ ផ្ទៃដីប៉ាន់ស្មានសម្រាប់ការសាងសង់សរុបមានចំនួន ៣.០៤ ហិកតា។

-ផ្លូវមេក្នុងអនុតំបន់ដីសម្បទានគ្រោងធ្វើការសាងសង់មានចំនួន ៧៩ ខ្សែ ប្រវែងផ្លូវប៉ាន់ស្មានសម្រាប់ការសាងសង់នេះប្រមាណ ១២២,៥២គីឡូម៉ែត្រ និងមានប្រវែងទទឹងផ្លូវ ៦ម៉ែត្រ ផ្ទៃដីប៉ាន់ស្មានសម្រាប់សាងសង់មានចំនួន ៧៣,៥៣ ហិកតា។

-ផ្លូវឡូត៍គ្រោងធ្វើការសាងសង់សរុបចំនួន ៧៨ខ្សែ មានប្រវែង ១២០,២៤ គីឡូម៉ែត្រ ផ្ទៃដីប៉ាន់ស្មានសម្រាប់សាងសង់មានចំនួន ៤៨,១១ ហិកតា និងមានទទឹង ៤ម៉ែត្រ។

**សរុបផ្ទៃដីប៉ាន់ស្មានសម្រាប់ប្រពន្ធ័ផ្លូវទាំង៥ប្រភេទសរុប ១៦៣ ខ្សែខាងលើមានចំនួន ២៩០,២ ហិកតា។**

- រោងចក្រកែច្នៃចំនួន ០១ កន្លែង ផ្ទៃដីប៉ាន់ស្មានសរុបចំនួន ១២ ហិកតា ស្ថិតនៅក្នុងអនុតំបន់|

- ទីស្នាក់ការធំនិងផ្ទះស្នាក់នៅរបស់ថ្នាក់ដឹកនាំក្រុមហ៊ុនមានចំនួន ០១កន្លែងស្ថិតនៅក្នុងអនុតំបន់I ផ្ទៃដីប៉ាន់ស្មានសរុបចំនួន ១៣ ហិកតា
- ទីស្នាក់ការរង និងជំរុំកម្មករមានចំនួន ០៦ កន្លែង ដែលទីស្នាក់ការរង និងជំរុំកម្មករស្ថិតនៅរាយតាមអនុតំបន់នីមួយៗផ្ទៃដីប៉ាន់ស្មាន់សរុបចំនួន ២០ ហិកតា
- ប៉ុស្តិយាមចំនួន ២៨ ស្ថិតនៅគ្រប់អនុតំបន់
- ផ្ទៃដីគ្រោងសម្រាប់សំណង់ផ្សេងៗសរុបចំនួន ៤៨,០៧ ហិកតា។

សំណង់ដែលរៀបរាប់ខាងលើបញ្ជាក់ទីតាំងកាន់តែច្បាស់នៅក្នុងលើផែនទីដីសម្បទាន និងតារាងចំនុចនិយាមកាដូចខាងក្រោមៈ

**<u>តារាងបញ្ជាក់ពីចំនួនប្រភេទទីតាំងផ្ទៃដីសំណង់</u>**

| ល.រ | ប្រភេទសំណង់ | ចំនួនសរុប | ឆ្នាំសាងសង់ | ផ្ទៃដី (ហ.ត) | ចំនុចទីតាំងសំណង់ |
|---|---|---|---|---|---|
| ១ | ប្រពន្ធ័ផ្លូវ | ១៦៣ខ្សែ | ឆ្នាំទី១-៦ | ២៩០,២ | ផែនទីជូនភ្ជាប់ |
| ២ | រោងចក្រកែច្នៃ | ០១ | ឆ្នាំទី៥ | ១២ | X ៖៦៧៩២៥០ និងY ៖១៥១៣៥០០ |
| ៣ | ស្នាក់ការធំនិងផ្ទះស្នាក់នៅរបស់ថ្នាក់ដឹកនាំក្រុមហ៊ុន | ០២ | ឆ្នាំទី១ | ១៣ | X ៖៦៧៩០០០ និងY ៖១៥១៤០០០ |
| ៤ | ស្នាក់ការរងនិងផ្ទះកម្មករ | ០៦ | ឆ្នាំទី១ | ២០ | X ៖៦៨៦៥០០ និងY ៖១៥២៨៥០០<br>X ៖៦៨១៣០០ និងY ៖១៥២២៥០០<br>X ៖៧០០២៥០ និងY ៖១៥៤០៥០០ |
| ៥ | ប៉មយាមភ្លើងឆេះព្រៃនិងសន្តិសុខ | ២៨ | ឆ្នាំទី១ | | ចំនុចនិយាមកាមានក្នុងឧបសម្ព័ន្ធជូនភ្ជាប់ |
| ៦ | ផ្ទៃដីគ្រោងសម្រាប់សំណង់ផ្សេង | | ឆ្នាំទី១ | ៤៨,០៧ | |
| ៧ | សរុបផ្ទៃដីសំណង់ហេដ្ឋារចនាសម្ព័ន្ធ | | | ៣៨៣,២៧ | |

Draft

# ជំពូក V ការវាយតម្លៃផលប៉ះពាល់បរិស្ថាន-សង្គម

## ១-ការវាយតម្លៃផលប៉ះពាល់បរិស្ថាន-សង្គម និងវិធានការកាត់បន្ថយ

### ១.១-ទិដ្ឋភាពទូទៅ នៃផលប៉ះពាល់

ការវាយតម្លៃផលប៉ះពាល់បរិស្ថាន-សង្គម គឺជាឧបករណ៍បច្ចេកទេសយ៉ាងសំខាន់សម្រាប់ជាយន្តការគ្រប់គ្រងតំបន់អភិវឌ្ឍន៍ដីសម្បទានរបស់ក្រុមហ៊ុនប្រកបដោយចិរភាព និងរក្សាបានបរិស្ថានល្អប្រសើរ។ ផលប៉ះពាល់ជាអវិជ្ជមានទៅលើបញ្ហាបរិស្ថាន និងសង្គមនឹងត្រូវបានទទួលការចាប់អារម្មណ៍យ៉ាងខ្លាំង និង ត្រូវតែរិះរកវិធានការដើម្បីកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមាន នៃបរិស្ថាន-សង្គម ដែលនឹងត្រូវបានដាក់ចេញ ដើម្បីឱ្យការអនុវត្តន៍សម្បទានអាចជៀសវាងបាន និងធានាបាននូវផលប្រយោជន៍ដ៏យូរអង្វែងសម្រាប់ សង្គមជាតិ។ ក្រុមហ៊ុននឹងត្រូវរៀបចំផែនការដើម្បីពិនិត្យ និងព្យាករណ៍អំពីផលប៉ះពាល់សង្គម-បរិស្ថាន រកវិធានការក្នុងការកាត់បន្ថយផលប៉ះពាល់អវិជ្ជមានទាំងនោះ និងជំរុញដំណើរការអនុវត្តន៍នៃការដាំដុះដំណាំកសិ-ឧស្សាហកម្មប្រកបដោយនិរន្តរភាព។

ការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គមគឺជាដំណើរការវិភាគនូវអត្តសញ្ញាណ និងនិទស្សន៍ ផលប៉ះពាល់ដែលបណ្តាលមកពី សកម្មភាពណាមួយរបស់គម្រោងទៅលើប្រព័ន្ធមជ្ឈដ្ឋានព្រៃឈើ ដី ទឹក សត្វមានជីវិត និងសុខមាលភាពសង្គមដោយផ្តល់នូវបណ្តាទិន្នន័យពិតមាន និងបកស្រាយអំពីអត្ថន័យ នៃផលប៉ះពាល់ទៅអនាគត រួមទាំងមធ្យោបាយកាត់បន្ថយសម្រាលដល់ផលប៉ះពាល់ ឬលុបបំបាត់ភាពមហន្តរាយនានា។ល។ ការវាយតម្លៃក៏នឹងផ្អែកផងដែរលើមូលដ្ឋានទិន្នន័យដែលក្រុមហ៊ុនប្រមូលបាន និងឯកសារបច្ចេកទេសទាក់ទងសំខាន់ផ្សេងៗទៀត។

នៅពេលក្រុមហ៊ុនធ្វើអាជីវកម្មដាំដុះលើតំបន់ដីសម្បទាននេះ ក្រុមហ៊ុននឹងផ្អែកផងដែរលើលក្ខ័ខណ្ឌ នានាដែលមានចែងក្នុងកិច្ចសន្យារវាងក្រុមហ៊ុន និងក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទដើម្បីធានាថា រាល់ការអនុវត្តន៍សកម្មភាពដាំដុះ និងការអភិវឌ្ឍន៍ចម្ការដំណាំកសិ-ឧស្សាហកម្មនេះមិនមានផលប៉ះពាល់ ធ្ងន់ធ្ងរដល់បរិស្ថាន-សង្គមឡើយ។

ច្បាប់បរិស្ថានត្រូវបានកំណត់ដោយឈរលើគោលការណ៍ និងស្តង់ដាជាមូលដ្ឋានតម្រូវឲ្យមានការរៀបចំដើម្បីការពារដល់ការបំពុលបរិស្ថានចំពោះរាល់គ្រប់សម្បទានទាំងអស់។ ដូចនេះចំនុចចំបងលើផលប៉ះពាល់បរិស្ថានក្នុងការរៀបចំបង្កើតកសិដ្ឋាននេះ ក្រុមហ៊ុនបានធ្វើការសិក្សា និងត្រៀមលក្ខណៈគ្រប់យ៉ាង និងរៀបចំអនុវត្តសកម្មភាពការពារបរិស្ថានដោយគោរព និងអនុវត្តទៅតាមមាត្រា និងបទបញ្ញាតិដែលមានចែងក្នុងច្បាប់ សំដៅជាប្រយោជន៍ដល់ការការពារបរិស្ថានក៏ដូចជាស្ថានភាពសង្គមទាំងក្នុង និងជុំវិញតំបន់វិនិយោគ។

ជាទូទៅដំណើរប្រតិបត្តិការឈូសឆាយដាំដុះដំណាំកៅស៊ូ និងដំណាំផ្សេងៗ តែងតែប៉ះពាល់ដល់បរិស្ថានខ្លះៗចៀសមិនរួចហើយហេតុសំខាន់ៗ ទាំងនោះរួមមានៈ ការហូរច្រោះដី និងសំណឹកដែលបណ្តាលឲ្យមានកំណកដីនៅតាមទំនាបអូរបឹង និងស្ទឹងការធ្វើឲ្យខូចគុណភាពទឹកនិងប្រែប្រួលរបបទឹកការបាត់បង់ទីជម្រកសត្វព្រៃ និងជីវៈចំរុះការប្រែប្រួលប្រព័ន្ធអេកូឡូស៊ីក្នុងតំបន់វិនិយោគការរំខានដោយសំឡេង និងរំញ័រ ពីការធ្វើអាជីវកម្មដោយគ្រឿងយន្ត

ការបំពុលខ្យល់ដោយធូលី និងកំណើនឧស្ម័នកាបូនិកដោយសារការដឹកជញ្ជូនដែលអាចបណ្តាលឱ្យប៉ះពាល់ខូចខាតដល់ផ្លូវគមនាគមន៍និងប៉ះពាល់សុខភាពសាធារណៈជាដើម។

**១.២-ផលប៉ះពាល់បរិស្ថាន-សង្គម និងវិធានការកាត់បន្ថយ**

ក្នុងការរៀបចំផែនការវាយតម្លៃផលប៉ះពាល់បរិស្ថាន-សង្គម ក្រុមហ៊ុនបានប្រមូលឯកសារពាក់ព័ន្ធដូចជា ៖ ឋានលេខាភូមិសាស្ត្រលក្ខណៈអេកូឡូស៊ីទិន្នន័យអាកាសធាតុប្រភេទសារព័ន្ធរុក្ខជាតិសត្វព្រៃ និងស្ថានភាពប្រជាសាស្ត្រក្នុងផ្នែកសេដ្ឋកិច្ច-សង្គមដែលរស់នៅក្នុង និងក្បែរតំបន់អភិវឌ្ឍន៍របស់ក្រុមហ៊ុន។

ចំពោះការវាយតម្លៃផលប៉ះពាល់សេដ្ឋកិច្ច-សង្គមទិន្នន័យ ដែលប្រមូលបានត្រូវបានចងក្រងរៀបចំ ដើម្បីជាមូលដ្ឋានក្នុងការវិភាគ និងបង្ហាញនូវលទ្ធផលច្បាស់លាស់ដោយក្រុមអ្នកជំនាញការរបស់ក្រុមហ៊ុន។ សកម្មភាពប្រតិបត្តិការឈូសឆាយដាំដំណាំកសិ-ឧស្សាហកម្ម និងសកម្មភាពពាក់ព័ន្ធទាំងឡាយ ដែលនឹងជះឥទ្ធិពលទៅវិញទៅមកក្នុងទិដ្ឋភាពអេកូឡូស៊ី និងសេដ្ឋកិច្ច-សង្គមត្រូវវិភាគ ផ្អែកលើកម្រិតប៉ះពាល់ការប៉ាន់ស្មានឬព្យាករណ៍តាមសន្ទស្សន៍បទពិសោធន៍។

ការពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋានដែលរស់នៅក្នុង និងក្បែរតំបន់អភិវឌ្ឍន៍ជាការចាំបាច់ណាស់ព្រោះឱកាសនេះ ក្រុមហ៊ុនអាចពិភាក្សាវែកញែកយ៉ាងល្អិតល្អន់សំដៅរកដំណោះស្រាយបញ្ហាទំនាស់ផលប្រយោជន៍រវាងវិនិយោគិន និងសហគមន៍មូលដ្ឋាន និងប្រសិទ្ធភាពអនុវត្តគម្រោងឈានទៅរកចីរភាព។

ជំហានបន្ទាប់ពីការចុះយកព័ត៌មានពីទីវាល គឺក្រុមអ្នកជំនាញនឹងធ្វើការសិក្សាវាយតម្លៃលម្អិតពីផលប៉ះពាល់ដោយធ្វើអញ្ញាណប៉ាន់ស្មានផលប៉ះពាល់ដែល នឹងអាចកើតមានឡើងដោយថាហេតុណាមួយក្នុង ពេលប្រតិបត្តិគម្រោងទៅលើផលប៉ះពាល់បរិស្ថាន-សង្គម និងសិក្សាលម្អិតដើម្បីលើកឡើងនូវវិធានការទាំងឡាយ សំដៅកាត់បន្ថយផលប៉ះពាល់មុនពេលគម្រោងត្រូវបានអនុវត្ត។

ដើម្បីងាយស្រួលក្នុងការវិភាគ និងការសិក្សារិះរកនូវបណ្តាវិធានការកាត់បន្ថយផលប៉ះពាល់បរិស្ថាន-សង្គមក្រុមហ៊ុនសូមធ្វើការលម្អិតតាម៣ដំណាក់កាលៈ ១-ដំណាក់កាលកសាងគម្រោងវិនិយោគ,២-ដំណាក់កាលអនុវត្តសម្បទាន និង៣-ដំណាក់កាលបញ្ចប់សម្បទាន។

**ក-ផលប៉ះពាល់បរិស្ថាន-សង្គម**ក្នុងដំណាក់កាលកសាងសម្បទាន

| ធនធានបរិស្ថាននិងផលប៉ះពាល់ | វិធានការកាត់បន្ថយ |
|---|---|
| **បរិស្ថានសង្គមៈ**<br>ការរស់នៅរបស់សហគមន៍មូលដ្ឋាន និងការប្រើប្រាស់ដីរបស់ក្រុមហ៊ុន | |
| ▪ ក្នុងដំណាក់កាលដំបូងនេះ ក្រសួងស្ថាប័ន មានសមត្ថកិច្ច និងអាជ្ញាធរដែនដីមូលដ្ឋាន បានធ្វើការចុះពិនិត្យស្ថាន | ✓ ក្រុមហ៊ុននិងអាជ្ញាធរដែនដី ត្រូវជូនដំណឹងដល់ប្រជាជន ដែលរស់នៅក្បែរតំបន់ដីសម្បទានអំពីគោលបំណង នៃការធ្វើវិនិយោគដែលអាច |

Draft

| | |
|---|---|
| ភាពដីសម្បទាន ដែលក្រុមហ៊ុនស្នើសុំ។ កិច្ចការនេះអាចនឹងប៉ះពាល់ដល់សតិអារម្មណ៍របស់អ្នកភូមិដែល រស់នៅក្បែរតំបន់នោះ ដោយពួកគាត់មិនទាន់យល់ច្បាស់អំពី គោលបំណងអភិវឌ្ឍន៍ និងការខ្លាចក្រែងក្រុមហ៊ុនធ្វើសកម្មភាពរំលោភលើដី ដែលពួកគាត់បានកាន់កាប់។ | ចូលរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និងអាចជួយដល់ អ្នកភូមិក្នុងការផ្តល់ការងារធ្វើជាប្រចាំថ្ងៃ។ បង្ហាញពីផលប្រយោជន៍រួមផ្សេងៗទៀត ដូចជាការកសាង ផ្លូវគមនាគមន៍ក្នុងតំបន់ដីសម្បទានដែលអាចតភ្ជាប់បានពីផ្លូវជាតិទៅតាមបណ្តាភូមិឃុំនានាក្បែរតំបន់នោះ។ |
| ▪ ការព្រួយបារម្ភអំពី ការបាត់បង់អាជីពមុខរបរ របស់អ្នកភូមិមួយចំនួនប្រសិនបើការផ្តល់ដីសម្បទាននេះប៉ះចំដីដែលគាត់កំពុងធ្វើអាជីវកម្មចិញ្ចឹមជីវិត។ | ✓ ក្រុមហ៊ុនត្រូវជម្រាបជូនអ្នកភូមិ អំពីការធ្វើអាជីវកម្មដាំដុះ គឺមិនធ្វើនៅលើដីកម្មសិទ្ធិ របស់ប្រជាជនឡើយ |
| ▪ អ្នកភូមិមិនសប្បាយចិត្ត ចំពោះអ្នកចំណូលថ្មី ដែលមកបោះទីតាំងអាជីវកម្មក្បែរតំបន់ដែល ពួកគាត់រស់នៅ។ | ✓ ក្រុមហ៊ុនត្រូវឲ្យប្រជាពលរដ្ឋអ្នកភូមិ ដឹងជាមុនថានឹងអនុញ្ញាតឲ្យអ្នកភូមិចូលទៅរកអុស អនុផលព្រៃឈើ ឬរកស្មៅគោក្របីក្នុងតំបន់ដីសម្បទាន។ |
| ▪ ការបាត់បង់នូវឱកាសរុករកអនុផល ព្រៃឈើដូចជាជ័រ ផ្តៅ អុសវាលស្មៅធម្មជាតិសម្រាប់ គោក្របី របស់ពួកគាត់។ល។ | ✓ ក្រុមហ៊ុនត្រូវធានាថា គោរពថែរក្សាប្រពៃណីទំនៀមទំលាប់ នៃការរស់នៅ របស់ប្រជាជនរក្សាទុកកន្លែងគោរព សក្ការៈបូជាដូចជាកន្លែងអ្នកតា...ដែលគាត់មានកន្លងមក។ |
| ▪ អាចប៉ះពាល់ដល់សតិអារម្មណ៍របស់អ្នកភូមិដោយពួកគាត់ខ្លាចថា ទៅថ្ងៃអនាគតកូនចៅរបស់ពួកគាត់មិនអាចរានដីចំការស្រែតទៅទៀតបាន។ | |
| <u>ប្រពៃណីវប្បធម៌និងសាសនារបស់សហគមន៍មូលដ្ឋាន</u> | |
| ▪ នៅមុនកិច្ចដំណើរការអភិវឌ្ឍន៍ ដីសម្បទាននេះ កត្តាមួយចំនួនដូចជាប្រពៃណីវប្បធម៌ និង ជំនឿសាសនាដែលមានស្រាប់របស់ប្រជាជន នៅក្បែរតំបន់ដីសម្បទាននោះ អាចមានផលប៉ះពាល់តិចតួច។ | ✓ ក្រុមហ៊ុនត្រូវធ្វើការសិក្សា ឲ្យបានច្បាស់លាស់អំពីទំនៀមទំលាប់ប្រពៃណី និងជំនឿសាសនារបស់អ្នកភូមិដែលរស់នៅក្បែរតំបន់ដីសម្បទាន។<br>✓ ក្រុមហ៊ុនត្រូវរៀបចំផែនការផ្សព្វផ្សាយ និងអប់រំណែនាំជាមុនដល់បុគ្គលិក កម្មករដែលមកធ្វើការនៅក្នុងតំបន់ ដីសម្បទានឲ្យយល់ដឹងអំពីប្រពៃណី ទំនៀមទំលាប់ ជំនឿសាសនារបស់ប្រជាជនតំបន់ នោះដើម្បីជៀសវាងការថ្នាំងថ្នាក់សតិអារម្មណ៍ពីបញ្ហានេះ។ |

Draft

**ខ-ផលប៉ះពាល់បរិស្ថាន-សង្គម**ក្នុងដំណាក់កាលអនុវត្តសម្បទាន

| ធនធានបរិស្ថាននិងផលប៉ះពាល់ | វិធានការកាត់បន្ថយ |
|---|---|
| **បរិស្ថានរូបសាស្ត្រ**<br>សណ្ឋានដី និងឋានលេខា | |
| ▪ ក្នុងដំណាក់កាល នៃការអនុវត្តន៍គម្រោងក្រុមហ៊ុននឹងចាប់ផ្តើមឈូសឆាយនិងពង្រាបដីស្រទាប់លើ ដែលមានគម្របព្រៃ ដើម្បីធ្វើការដាំដុះក្នុងតំបន់ដីសម្បទាននេះ។ សកម្មភាពនេះអាចនឹងបង្កឲ្យមានការប្រែប្រួលនូវសណ្ឋានដីនៅក្នុងទីតាំងគម្រោង។<br>▪ អាចបណ្តាលឲ្យមាន ការប៉ះពាល់ឋានលេខា ដោយសារសកម្មភាពឈូសកៀរពង្រាបដី ដើម្បីកសាងប្រព័ន្ធផ្លូវគមនាគមន៍ សម្រាប់បែងចែកឡូត៍ដាំដុះក្នុងតំបន់ដីសម្បទាន | ✓ ក្រុមហ៊ុនត្រូវដំណើរការឈូសឆាយដើម្បីធ្វើការដាំដុះតាមការបែងចែក អនុតំបន់ដាំដុះតាមឆ្នាំនីមួយៗដោយធ្វើជាដំណាក់ៗ និងដោយប្រុងប្រយ័ត្ន។<br>✓ ក្នុងការកសាងផ្លូវ ក្នុងតំបន់ដីសម្បទានក្រុមហ៊ុនត្រូវពិចារណាឲ្យបានល្អិតល្អន់ លើសកម្មភាពឈូសកៀរដីធ្វើយ៉ាងណាកុំឲ្យមានការប្រែប្រួលខ្លាំងនៃឋានលេខា។ |
| ការហូរច្រោះដីនិងគុណភាពដី | |
| ▪ ការឈូសឆាយរុក្ខជាតិ គម្របដីបង្កឲ្យមានការបាក់ដី និងអាចមានការហូរច្រោះដី។ កន្លែងដែលប៉ះពាល់រុក្ខជាតិ ស្រទាប់ក្រោម ជាគម្របដីនាំឲ្យបាត់បង់ជីវជាតិដីនិងការលេចឬច្រោះជីវជាតិ។ កំណើនសីតុណ្ហភាពពេលដែលគម្របព្រៃឈើ ត្រូវបានធ្វើការឈូសឆាយនឹងអាចសម្លាប់មីក្រូសរីរាង្គ និងធ្វើឲ្យដីរឹងស្ងួតដែលបណ្តាលឲ្យដំណុះឈើនិងដំណាំដុះមិនបានល្អ។ | ✓ មិនឈូសឆាយកាប់ព្រៃតាមតំបន់ទ្រនាប់ ក្បែរប្រភពទឹក និងកាត់បន្ថយបរិមាណការដឹកជញ្ជូនដែលមានទម្ងន់ផ្ទុកធ្ងន់ហួស នាំឲ្យហូរដីចេញពីផ្លូវនិងខ្វងផ្លូវ។ ក្រុមហ៊ុននឹងរក្សាទុកផ្ទៃដីជាប់មាត់អូរចំងាយ១០០-១៥០ម៉ែត្រ សងខាងសម្រាប់ការពារទីជម្រាលនិងការហូរច្រោះ។<br>✓ រៀបចំទីតាំងចម្ការដំណាំដោយសាងសង់ប្រព័ន្ធចង្ហូរទឹកឲ្យបានត្រឹមត្រូវ និងអនុវត្តនូវបច្ចេកទេសភ្ជួររាស់។<br>✓ ការឈូសឆាយពង្រាបដី ត្រូវពិនិត្យទៅតាមសណ្ឋានដីជាក់ស្តែង និងការឈូសឆាយមិនឲ្យមានកម្រិតជម្រាលខ្ពស់។<br>✓ ការឈូសឆាយមិនស៊ីជម្រៅពេកទេ ដែលនាំឲ្យបាត់បង់គុណភាពដី និងបង្កករដីល្បាប់ |

| | |
|---|---|
| | ច្រើនដែល អាចហូរចាក់ទៅកាន់តំបន់ទំនាបឬអូរស្ទឹង។<br>✓ រៀបចំកំទេចកំទីកករដី និងគ្រប់គ្រងសំណល់រឹង-រាវដោយជីករណ្ដៅកប់ឬដុតចោល។ ចំពោះសំណល់រាវត្រូវយកចិត្តទុកដាក់មិន បង្កឲ្យហៀរធ្លាក់ទៅដីឬបង្ហូរទៅក្នុងដីឡើយ។ ត្រូវធ្វើការដាំដុះដើមឈើដំណាំផ្សេងៗ វិញភ្លាមក្រោយពេលឈូសឆាយនូវស្រទាប់រុក្ខជាតិ លើដីដែលមានស្រាប់ ដើម្បីឲ្យមានតុល្យភាពគម្របដី។<br>✓ ក្រុមហ៊ុននឹងដាំដុះនូវប្រភេទដំណាំ ដែលអាចធ្វើជាគម្របដីបានដូចជាពពួកសណ្ដែកបន្លែជាដើមដើម្បីកុំឲ្យដីស្ងួតនិងសឹករិចរិល។ |
| <u>ការបំពុលទឹក</u> | |
| ▪ ការប្រើថ្នាំគីមីកសិកម្ម ក្រុមហ៊ុននឹងអាចប្រើប្រាស់ នូវប្រភេទថ្នាំគិមីកសិកម្មមួយ ចំនួនក្នុងដំណើរការផលិតកម្ម។ សារធាតុគិមីនឹងអាចហូរចូលទៅក្នុងបឹង ស្ទឹងអូរ ក្នុងតំបន់ដីសម្បទាននៅពេលមានភ្លៀងធ្លាក់។<br>▪ សកម្មភាពប្រតិបត្តិការគម្រោងអាចបង្កភាពបំពុលផ្ទៃទឹក និងប្រភពទឹកក្រោមដី។ ការឈូសឆាយដី និងភ្ជួររាស់បង្កកករដីកំទេចកំទីហូរចាក់ទៅប្រភពទឹកដែលបណ្ដាលឲ្យខូចគុណភាពទឹក។ ទឹកភ្លៀងមិនអាចជ្រាបបានព្រោះបង្កើនចរន្តហូរខ្លាំងលើផ្ទៃដី។<br>▪ អាចមានទឹកកខ្វក់កាកសំណល់ពុលបញ្ចេញចោលពីរោងចក្រកែច្នៃ។ | ✓ ការប្រើថ្នាំគីមីកសិកម្មត្រូវប្រើប្រាស់ ទៅតាមកម្រិត បទដ្ឋានបច្ចេកទេស ដែលក្រសួងកសិកម្មបាន កំណត់ជៀសវាងការបំពុលទឹកនិងបរិស្ថាន។ ក្រុមហ៊ុននឹងស្នើឲ្យក្រសួងកសិកម្មជួយលើបញ្ហាបច្ចេកទេសនេះ។<br>✓ រៀបចំកំទេចកំទីកករដី និងគ្រប់គ្រងសំណល់រឹង-រាវដោយជីករណ្ដៅកប់ឬដុតចោល។ ក្រុមហ៊ុននឹង ត្រូវអប់រំដល់កម្មករ ចំពោះបញ្ហាកាកសំណល់នេះ ចៀសវាងការបំពុលទឹក។<br>✓ មិនឈូសឆាយដីមកគរនៅក្បែរប្រភពទឹក ឬបិទ ផ្លូវទឹកតាមដងអូរបឹងស្ទឹង។ ពិនិត្យកំទេចកំទី (មែក ស្លឹកសំបកនិងរុក្ខជាតិតូចៗ) ដែលបានបន្សល់ទុក ក្នុងតំបន់ដីសម្បទានជាឧបសគ្គរាំងស្ទះដល់ ប្រព័ន្ធបង្ហូរទឹកនិងខូចគុណភាពទឹក។<br>✓ ឧបករណ៍សម្អាតទឹកកខ្វក់ ដែលហូរចេញពីរោងចក្រនឹងត្រូវបានបំពាក់សំដៅ កែលម្អគុណភាពទឹកឲ្យបានប្រសើរឡើង។ |
| <u>ការបំពុលដី</u> | |

Draft

| | |
|---|---|
| ▪ អាចនឹងមានការបំពុលដីដោយសារការចាក់ចោលពាសវាលពាសកាល ឬការហៀរកំពុបប្រេងរំអិលនិងកាកសំណល់ផ្សេងៗ។<br>▪ អាចនឹងមានការបំពុលដីដោយសារការប្រើថ្នាំគិមីកសិកម្មច្រើនហួសកម្រិតកំណត់ដែលធ្វើឲ្យខូចគុណភាពដី និងបំផ្លាញជីវៈចម្រុះក្នុងដី។ | ✓ វិធានការណ៍ ក្នុងការប្រើប្រាស់ប្រេងឥន្ធនៈប្រេង រំអិលក្រុមហ៊ុននឹងត្រូវចាត់ការ យ៉ាងម៉ឺងម៉ាត់ ជៀសវាងការហៀរកំពុបប្រេងរំអិល និងកាកសំណល់ផ្សេងៗចូលទៅក្នុងដី។ ការអប់រំកម្មករ អំពីបញ្ហានេះគឺជាការចាំបាច់។<br>✓ ក្រុមហ៊ុននឹងរៀបចំទីកន្លែងទុកដាក់ប្រេងឥន្ធនៈប្រេងរំអិលឲ្យបានត្រឹមត្រូវបំផុត។<br>✓ ក្រុមហ៊ុននឹងត្រូវប្រើប្រាស់ជីធម្មជាតិ ឲ្យបានច្រើនតាមតែអាចធ្វើទៅបាន។<br>✓ ការប្រើជីគិមីថ្នាំសម្លាប់សត្វល្អិត ក្រុមហ៊ុននឹងត្រូវធ្វើទៅតាមការណែនាំ របស់មន្ត្រីបច្ចេកទេសនៃក្រសួងកសិកម្ម។ការនាំចូលជីគិមី ថ្នាំសម្លាប់សត្វល្អិតក្រុមហ៊ុន នឹងត្រូវសុំការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ |
| <u>ការបំពុលខ្យល់</u> | |
| ▪ សកម្មភាពឈូសឆាយដីការដុតកំទេចកំទីផ្សេងៗ និងចរាចរដឹកជញ្ជូនលើផ្លូវដីក្រហាមបង្កើតធូលីហុយ យ៉ាងខ្លាំងពិសេសនៅរដូវប្រាំង។ ការប្រើប្រាស់មធ្យោបាយដឹកជញ្ជូន ដូចជាការដឹកដីធ្វើផ្លូវមេផ្លូវបែងចែកឡូត៍ ក្នុងតំបន់ដីសម្បទានអាចនឹងមានបង្កឡើងនូវធូលីដីហុយផ្សេងចេញពីរថយន្ត ដែលជាកត្តាបំពុលខ្យល់ផងដែរ។ | ✓ សកម្មភាពប្រតិបត្តិការ មិនត្រូវបង្កឲ្យមានធូលី និងផ្សែងខ្លាំងហើយចរាចរដឹកជញ្ជូនត្រូវចៀសវាងឆ្លងកាត់តំបន់ទីប្រជុំជនកុះករ។ ករណីចាំបាច់ ត្រូវស្រោចទឹកលើផ្លូវដើម្បីកាត់បន្ថយធូលីហុយ។<br>✓ គ្រឿងចក្រដែលប្រើប្រាស់ត្រូវមាន សំឡេងតិច និងមិនបញ្ចេញឧស្ម័ន លើសបទដ្ឋានដែលក្រសួងបរិស្ថានបានកំណត់ ក្នុងអនុក្រឹត្យស្តីពីការបំពុលខ្យល់ឡើយ។ |
| <u>កត្តាភ្លើងឆេះ</u> | |
| ▪ អាចនឹងមានអគ្គីភ័យកើតឡើងបានអាស្រ័-យដោយកត្តាមនុស្សរួមនឹងកត្តាផ្សេងទៀត ដូចជាបរិមាណសំណើម ទាបកំណើន សីតុណ្ហភាពខ្ពស់ ចលនាខ្យល់បក់ខ្លាំង ភាពសោះកក្រោះ កំទេចឈើពុក-ស្មៅ | ✓ ការឆេះព្រៃឈើចម្ការដំណាំ គឺមានការពាក់ព័ន្ធសំខាន់ ជាមួយសកម្មភាពរបស់មនុស្ស ដូចនេះការអប់រំប្រជាពលរដ្ឋ ដែលរស់នៅក្នុងតំបន់ដីសម្បទានអំពី គ្រោះថ្នាក់បណ្តាលមកពីភ្លើងឆេះព្រៃ គឺជាការចាំបាច់បំផុត។ ជាគោលការណ៍រួម គឺការបង្ការការពារជាមុនជាមធ្យោបាយងាយ ស្រួលជាងនៅពេល ដែល |

| | |
|---|---|
| ងាប់ ស្លឹកឈើស្ងួត គឺជាវត្ថុធាតុអាចងាយបង្កឲ្យ ងាយឆេះ។ | មានភ្លើងឆាបឆេះ។ ការបង្ការទប់ទល់នឹងអគ្គីភ័យ គឺអាចធ្វើទៅបានតាមទម្រង់ដូចខាងក្រោម៖<br>✓ ទំនាក់ទំនង និងការអប់រំជាសាធារណៈបុគ្គលដែលមានលក្ខណៈសម្បត្តិសមស្រប មានចំណេះ ដឹងច្រើនលើការបង្ការអគ្គីភ័យគួរត្រូវបានចាត់តាំងជាអ្នកសម្របសម្រួល ជាមួយសាធារណៈជនក្នុងការងារទំនាក់ទំនង និងការអប់រំពាក់ព័ន្ធនឹងអគ្គីភ័យ។ ការងារអប់រំគួរធ្វើមុនរដូវដែលអាចមានភ្លើងឆេះព្រៃ និងធ្វើបន្តរហូត។<br>✓ ឥរិយាបថកម្មករ៖ កម្មករគួរត្រូវបានអប់រំផ្សព្វផ្សាយ អំពីគ្រោះថ្នាក់នៃអគ្គីភ័យផលវិបាកហេតុដែល បណ្តាលឲ្យមានភ្លើងឆេះព្រៃ ដូចជា ការចោល កន្ទុយ បារីឬការចម្អិនម្ហូបអាហារជាដើម។<br>✓ ទីវាលផ្តាច់អគ្គីភ័យ៖ គួរមានទីវាលមួយសមស្រប និងកសាងនៅតំបន់ដែលគិតថា អាចមានគ្រោះ អគ្គីភ័យកើតឡើង ពិសេសនៅព្រំប្រទល់ជាប់នឹង ភូមិរបស់ប្រជាពលរដ្ឋ។ ទទឹងនៃទីវាលអាចមាន ប្រវែង ០៥ម៉ែត្រ ដោយឆ្ការសម្អាតមិនឲ្យមានព្រៃដុះ ឬវត្ថុងាយឆេះនៅក្បែរនោះ។ ការថែរក្សាសម្អាតគួរធ្វើនៅរដូវប្រាំងច្រើនជាងរដូវវស្សា។<br>✓ រៀបចំធ្វើប៉មឃ្លាំមើលភ្លើងឆេះព្រៃ ចម្ការដំណាំរបស់ក្រុមហ៊ុន និងចាត់តាំងកម្លាំងកម្មករនៅប្រចាំការតាមចំណុចគោលដៅទាំងនោះ ជាប្រចាំ។ |
| <u>សំលេងនិងរំញ័រ</u> | |
| ▪ អាចនឹងមានការរំខាន ដោយសារសម្លេង រថយន្តដឹកជញ្ជូនគ្រឿងចក្រឈូសឆាយ ដែលចរាចរឆ្លងកាត់ភូមិប្រជាជនរស់នៅ ក្បែរតំបន់ដីសម្បទាន។ | ✓ ក្រុមហ៊ុននឹងប្រើប្រាស់ រថយន្តដឹកជញ្ជូនគ្រឿងចក្រឈូសឆាយផ្សេងៗដែលមានសម្លេងតិចកាត់បន្ថយការរំខានដល់ប្រជាជន ដែលរស់នៅក្បែរតំបន់ដីសម្បទាន។<br>✓ ការដឹកជញ្ជូន មិនត្រូវធ្វើពេលដែលប្រជាជនសម្រាកឡើយ គឺក្រុមហ៊ុនត្រូវកំណត់ពេល |

Draft

| | |
|---|---|
| | វេលាធ្វើការច្បាស់លាស់កុំឲ្យរំខានដល់ប្រជាជនដែលរស់នៅក្បែរតំបន់ដីសម្បទាន។ |
| <u>កត្តាព្រៃឈើ-រុក្ខជាតិ</u> | |
| ▪ អាចមានការបាត់បង់ និងខូចខាតគម្របព្រៃ នៅលើទីតាំងចម្ការដាំដំណាំដោយសកម្មភាព ឈូសឆាយ និងភ្ជួររាស់ដាំដុះ នៅក្នុងតំបន់ដីសម្បទានរបស់ក្រុមហ៊ុន។<br>▪ ប្រភេទព្រៃឈើធម្មជាតិអាចត្រូវបានបាត់បង់ដោយសារការធ្វើអាជីវកម្ម។ | ✓ តំបន់ទំនាបនៅតាមជ្រលងជង អូរថ្លុក ត្រពាំង បឹង ទោះបីពុំមានវត្តមានព្រៃឈើឬមានក្តី ក៏ក្រុមហ៊ុន មិនធ្វើការឈូសឆាយនិងកាប់ឆ្ការឡើយ។ រក្សាទុកព្រៃឈើយ៉ាងហោចចម្ងាយ ១០០-១៥០ ម៉ែត្រ ពីប្រភពទាំងនេះដើម្បីអភិរក្សព្រៃឈើ។ មុនឈូសឆាយក្រុមហ៊ុនស្នើសុំការអនុញ្ញាតពីក្រសួងកសិកម្មជាមុន។<br>✓ ក្រុមហ៊ុនត្រូវរក្សាការពារព្រៃឈើ ដែលបានកំណត់ឲ្យថែរក្សាដោយមិនធ្វើអាជីវកម្មឡើយ។ |
| <u>សត្វព្រៃនិងមច្ឆាជាតិ</u> | |
| ▪ អាចប៉ះពាល់ដល់សត្វព្រៃ ដោយជម្រករបស់វាត្រូវបានកាប់ឆ្ការឈូសឆាយ ដើម្បីធ្វើការដាំដុះ។<br>▪ កករដីល្បាប់កករដីជីជាតិ កំទេចកំទីកាកសំណល់ផ្សេងៗបម្រែបម្រួលចរន្តទឹកហូរបណ្តាលមកពី ការឈូសឆាយ ដីការគ្រប់គ្រងកាកសំណល់មិនបានល្អ នឹងបង្កឲ្យមានផលប៉ះពាល់ដល់មជ្ឈដ្ឋានមច្ឆាជាតិ | ✓ ក្រុមហ៊ុនត្រូវធ្វើការដាំដុះ តាមផែនការដាំដូចដែលបានបង្ហាញក្នុងផែនការមេពោល គឺមិនត្រូវឈូសឆាយលើផ្ទៃដីទាំងអស់ទេ ត្រូវដាំដុះតាមអនុតំបន់នីមួយៗឆ្លាស់គ្នា។ ធ្វើបានដូចនេះទើបសត្វដែលរស់នៅក្នុងតំបន់នោះ អាចមានឱកាសបំលាស់ទីជម្រក និងអាចរស់នៅបាន។<br>✓ ចូលរួមថែរក្សាប្រព័ន្ធទឹក អូរ ស្ទឹង បឹង និងគុណភាពទឹក។ គ្រប់គ្រងសំណល់រឹង-រាវឲ្យបានល្អពិសេសការប្រើប្រាស់ ប្រេងឥន្ធនៈប្រេងរំអិល ដោយមិនត្រូវចាក់ចោលនៅក្បែរប្រភពទឹកបឹង ស្ទឹង ត្រពាំង ដែលអាចប៉ះពាល់ដល់ជីវិត ត្រី និងជួយផ្សព្វផ្សាយដល់សាធារណៈហាមមិនឲ្យនេសាទ ដោយប្រើឧបករណ៍ខុសច្បាប់ជាពិសេស នៅរដូវត្រីពង។ |
| **<u>សេដ្ឋកិច្ច-សង្គម</u>**<br><u>ការតាំងទីលំនៅថ្មីរបស់អ្នកភូមិ</u> | |
| ▪ អ្នកភូមិបារម្ភថា តម្រូវឲ្យមានការរុះរើលំនៅដ្ឋាន និងមានការបណ្តេញពួកគាត់ឲ្យចាកចេញពីផ្ទះសម្បែង។ | ✓ ក្នុងការធ្វើផែនការអភិវឌ្ឍន៍ ក្រុមហ៊ុនធានាថាមិនអាចតម្រូវឱ្យមានការរុះរើលំនៅដ្ឋាន និង |

Draft

| | |
|---|---|
| | មិនមានការបណ្តេញប្រជាជន ឲ្យចាកចេញពីផ្ទះសម្បែងរបស់ពួកគាត់ឡើយ។ |
| ការប្រើប្រាស់ដី | |
| ▪ អាចប៉ះពាល់ដល់ការប្រើប្រាស់កាន់កាប់ដីរបស់ អ្នកភូមិរស់នៅក្បែរតំបន់ដីសម្បទានរបស់ក្រុមហ៊ុន ដែលនាំឲ្យបាត់បង់មុខរបរ និងជីវភាពរស់នៅរបស់ពួកគាត់។<br>▪ អាចបង្កឲ្យមានទំនាស់ដីធ្លី រវាងក្រុមហ៊ុន និងប្រជាពលរដ្ឋអាស្រ័យដោយក្រុមហ៊ុនធ្វើអាជីវកម្មដាំដុះចំដីកម្មសិទ្ធិរបស់ពួកគាត់។ | ✓ ក្រុមហ៊ុនធានា មិនទន្រ្ទានយកដីរបស់ប្រជាជនដែលកាន់កាប់ស្របច្បាប់ឡើយ។ ក្រុមហ៊ុននឹងកាត់ចេញផ្ទៃដីដែលពាក់ពន្ធ័ជាមួយ ប្រជាពលរដ្ឋជាដីស្រែចម្ការស្របច្បាប់។<br>✓ ក្រុមហ៊ុនត្រូវចូលរួមសហការ ជាមួយស្ថាប័នជំនាញពាក់ព័ន្ធអាជ្ញាធរមូលដ្ឋាន ដើម្បីដោះស្រាយរាល់វិវាទដែលកើតមានអំពី ការប្រើប្រាស់គ្រប់គ្រង ដីធ្លីនិងអនុវត្តតាមការសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជាសំដៅកាត់បន្ថយឲ្យបានជាអតិបរមានូវ ទំនាស់ដីធ្លីជាមួយប្រជាពលរដ្ឋ។ |
| ការរស់នៅនិងមុខរបរ | |
| ▪ អាចនឹងមាន ផលប៉ះពាល់ដល់មុខរបររបស់អ្នកភូមិដែល រស់នៅក្បែរតំបន់ដីសម្បទានដោយសារ ក្រុមហ៊ុនបិទផ្លូវ និង ហាមឃាត់មិនឲ្យចូលក្នុងតំបន់ដីសម្បទាននេះ។<br>▪ អាច នឹងប៉ះពាល់ដល់ការរស់នៅរបស់អ្នកភូមិផងដែរ អំពីអ្នកចំណូលថ្មីដែលមករស់នៅធ្វើការ ជាកម្មករក្រុមហ៊ុនព្រោះថា អ្នកភូមិមិនសូវចូលចិត្តរស់នៅជាមួយ អ្នកចំណូលថ្មីខ្លាច មានអំពើចោរកម្មកើនឡើងបញ្ហារំលោភផ្លូវភេទ ការប្រើប្រាស់គ្រឿងញៀនជាដើម។ល។ | ✓ ក្រុមហ៊ុនត្រូវអនុញ្ញាតឲ្យអ្នកភូមិ ដែលរស់នៅក្បែរតំបន់ដីសម្បទានបានចូលទៅរកអនុផលព្រៃឈើជ័រវ័រផ្តៅអុសរកស្មៅគោប្រើប្រាស់ទឹកបឹង ត្រពាំង ក្នុងតំបន់ដែលក្រុមហ៊ុនកាន់កាប់។ ក្រុមហ៊ុន គ្រាន់តែធ្វើការតាមដានសកម្មភាពអ្នកភូមិទាំងនោះ ខ្លាចក្រែងមានការកាប់បំផ្លាញ ដើមឈើដំណាំលួចផលិផល ឆក់ត្រី ...។ល។ តែប៉ុណ្ណោះ។<br>✓ ក្រុមហ៊ុនធានាថា នឹងជ្រើសរើសយក អ្នកភូមិដែលរស់នៅក្បែរនោះមកធ្វើជាកម្មករ បុគ្គលិកឲ្យបានច្រើនទៅតាមសម្ថភាព របស់ពួកគាត់តាមតែអាចធ្វើទៅបាន។<br>✓ ក្រុមហ៊ុនត្រូវណែនាំដល់បុគ្គលិកកម្មករ ឲ្យចេះស្រលាញ់រាប់អានទំនាក់ទំនងល្អ ជាមួយ អ្នកភូមិ មិនត្រូវប្រព្រឹត្តអំពើមិនល្អលួចឆក់ប្លន់ទ្រព្យសម្បត្តិ ឬរំលោភបំពានផ្លូវភេទ និងប្រើប្រាស់គ្រឿងញៀនឡើយ។ |
| ប្រពៃណីនិងវប្បធម៌ | |

Draft

| | |
|---|---|
| ▪ អាចនឹងមានការប៉ះពាល់ដល់ប្រពៃណីទំនៀមទំលាប់របស់អ្នកភូមិដែលរស់នៅក្បែរតំបន់ដីសម្បទាន។ | ✓ ក្រុមហ៊ុននឹងសិក្សាពីប្រពៃណីទំនៀមទំលាប់របស់អ្នកភូមិ និងត្រូវអប់រំណែនាំដល់បុគ្គលិកកម្មករ ក្រុមហ៊ុនឲ្យគោរពទៅតាមអ្វីដែលជាប្រពៃណីទំនៀមទំលាប់របស់ពួកគាត់។ |
| ផ្លូវគមនាគមន៍ | |
| ▪ អាចនឹងប៉ះពាល់ដល់ ការធ្វើដំណើររបស់ អ្នកភូមិនៅពេលដែលក្រុមហ៊ុនបិទផ្លូវឈូសឆាយ ស្របពេលនឹងប្រជាពលរដ្ឋ ត្រូវធ្វើដំណើរឆ្លងកាត់តំបន់ដីសម្បទាន ដើម្បីទៅប្រកបមុខរបររបស់ពួកគាត់។<br>▪ អាចនឹងមានការស្ទះចរាចរនៅពេលដែលក្រុមហ៊ុន ចល័តគ្រឿងចក្រឈូសឆាយ និងដឹកជញ្ជូនដីធ្វើផ្លូវឬដឹកជញ្ជូនផលិតផលផ្សេងៗ។ | ✓ ក្នុងការដឹកជញ្ជូនក្រុមហ៊ុន ត្រូវគោរពទៅតាមបទដ្ឋានដឹកជញ្ជូនពោល គឺដឹកមិនត្រូវដឹកលើសទម្ងន់នាំឲ្យខូចផ្លូវ។ ការដឹកជញ្ជូនត្រូវប្រុងប្រយ័ត្ន ខ្លាចក្រែងប៉ះពារគ្រោះថ្នាក់ដល់ប្រជាពលរដ្ឋរស់នៅក្បែរផ្លូវគមនាគមន៍ (ល្បឿនបើកបរមិនលើស ពី៤០គ.ម ក្នុងមួយម៉ោងនៅក្នុងតំបន់មានភូមិ អ្នកស្រុក និង២០ទៅ៣០គ.ម ក្នុងមួយម៉ោងនៅ តំបន់ទីប្រជុំជន)។<br>✓ ក្រុមហ៊ុនត្រូវដាក់សញ្ញា សម្គាល់ចរាចរដើម្បីជៀសវាងគ្រោះថ្នាក់ចរាចរ។<br>✓ ក្រុមហ៊ុនត្រូវមានផែនការច្បាស់លាស់ ក្នុងការជួសជុលផ្លូវក្នុងតំបន់ដីសម្បទាន ជាប្រចាំដើម្បីសម្រួលដល់ការដឹកជញ្ជូន និងការធ្វើដំណើរសម្រាប់ផលប្រយោជន៍ក្រុមហ៊ុន និងអ្នកភូមិដែលប្រើប្រាស់ផ្លូវ ក្នុងតំបន់ដីសម្បទាននេះ។ |

### គ-ផលប៉ះពាល់បរិស្ថាន-សង្គម ក្នុងដំណាក់កាលបញ្ចប់សម្បទាន

| ធនធានបរិស្ថាន និងផលប៉ះពាល់ | វិធានការកាត់បន្ថយ |
|---|---|
| បរិស្ថានរូបសាស្ត្រ | |
| **សណ្ឋានដី និងឋានលេខា** | ▪ ពេលបញ្ចប់គម្រោងក្រុមហ៊ុន មិនបានកាប់ដើមឈើដែលបានដាំទាំងនោះចោលទេ គឺនៅរក្សាទុកដដែល ហើយមិនប៉ះពាល់ដល់សណ្ឋានដី និងឋានលេខាទេ។ |
| **ការហូរច្រោះដី** | ▪ ពេលបញ្ចប់គម្រោងក្រុមហ៊ុន រក្សាទុកដើមឈើទាំងអស់ដែលបានដាំ ដើម្បីធានាកុំឲ្យមានការច្រោះដីក្នុងតំបន់នោះ។ |

Draft

| | |
|---|---|
| **កត្តាភ្លើងឆេះ**<br>▪ អាចនឹងមានភ្លើងឆេះចំការឈើ និង ដំណាំ ដែលក្រុមហ៊ុនបានដាំ ដោយ សារការបោះ បង់ចោល មិនមានការ ថែទាំបន្តទៀត ឬដោយមានការ ធ្វេសប្រហែស របស់អ្នក ចូលមករក អុសជរ័ផ្តៅស្មៅគោក្នុងចម្ការ (ភ្លើង បារីភ្លើងភ្នក់ដាំបាយ។ល។) | ▪ មុននឹងបញ្ចប់សម្បទាន ក្រុមហ៊ុនត្រូវធ្វើលិខិត បញ្ចប់គម្រោងមកស្ថាប័នពាក់ព័ន្ធដែលរួមមាន ក្រសួងដែលចុះហត្ថលេខាជាមួយ ក្រុមហ៊ុន អាជ្ញាធរដែនដីមូលដ្ឋានដើម្បីមានវិធានការថែ រក្សាតំបន់នេះឡើងវិញ។ |
| **ជីវសាស្ត្រមច្ឆាជាតិ**<br>▪ អាចបង្កឲ្យមានផលប៉ះពាល់ ដល់ជីវ-សាស្ត្រដែលរស់នៅក្នុងទឹក ដោយ សារទីតាំងបោះ ចោលកាកសំណល់ រឹង-រាវមិនទាន់បានលុបចោលឲ្យបាន ត្រឹមត្រូវនៅរដូវភ្លៀង ទឹកភ្លៀងហូរ ចូលក្នុងទីតាំងនេះ ហើយហៀរហូរ ចូលក្នុងបឹងអូរក្នុងតំបន់ដីសម្បទាន។ | ▪ មុននឹងបញ្ចប់សម្បទានក្រុមហ៊ុន ត្រូវលុប បំពេញ កន្លែងចាក់សម្រាម ឬកាកសំណល់ រឹង-រាវទាំងអស់ ឲ្យបានត្រឹមត្រូវតាមក្បួនខ្នាត បច្ចេកទេសសម្រាប់ការការពារបរិស្ថាន។<br>▪ ក្រុមហ៊ុនត្រូវពិភាក្សា ជាមួយស្ថាប័នជំនាញ ដើម្បីផ្ទេរការគ្រប់គ្រងបន្តឬចាត់វិធានការផ្សេងៗ ក្នុងដំណាក់កាលបិទគម្រោងនេះ។ |
| **ការបំពុលទឹក**<br>▪ អាចនឹងកើតមានឡើង នូវបញ្ហាដែល ធ្វើឲ្យទឹកបឹង ស្ទឹង ត្រពាំង ក្នុងតំបន់ ដីសម្បទាន មានការកខ្វក់ដែល បណ្តាលមកពីទីតាំង ចាក់សំរាមកាក សំណល់ផ្សេងៗ ដែលក្រុមហ៊ុនបាន បន្សល់ទុក និង មិនបានសម្អាតឬ លុបចោលឲ្យបានត្រឹមត្រូវ ដែលធ្វើ ឲ្យកាកសំណល់កខ្វក់ទាំងនោះ ហូរ ចូល ក្នុងទឹកបឹងស្ទឹងត្រពាំងនៅ ពេលភ្លៀងធ្លាក់នារដូវវស្សា | ▪ ក្រុមហ៊ុននឹងត្រូវគិតគូរពីបញ្ហានេះ នៅពេល សម្បទានត្រូវបានបញ្ចប់ ដោយត្រូវប្រមែ ប្រមូល នូវកាកសំណល់ផ្សេងៗ និងត្រូវលុប ចោលរណ្តៅ កប់សំរាមឬកន្លែងដែលមានដក់ ទឹកសំអុយ។ |
| **ការបំពុលខ្យល់**<br>▪ អាចនឹងមាន ការបំពុលខ្យល់តិចតួច អាស្រ័យដោយកន្លែង បោះចោល កាកសំណល់រឹង-រាវនៅមិនទាន់លុប បំពេញឲ្យបានត្រឹមត្រូវ ដែលបង្កឲ្យ ជះក្លិនស្អុយ កខ្វក់ខូចដល់បរិយា កាសជុំវិញតំបន់នោះ។ | ▪ ក្រុមហ៊ុនត្រូវលុបចោលកន្លែងចាក់សំរាមកាក សំណល់រឹង និងរាវសំអាតទីធ្លាដែលបន្សល់ ទុកនូវរបស់ចាស់ៗផ្សេងៗដែល ក្រុមហ៊ុន បោះបង់ចោល ដើម្បីធានាបាននូវបរិស្ថាន ខ្យល់ល្អបរិសុទ្ធ។ |

Draft

| | |
|---|---|
| **ការបំពុលដី** | |
| ▪ អាចនឹងមានការបំពុលដីនៅជុំវិញ ទីតាំងចោលកាកសំណល់រឹងរាវ ដោយសារកន្លែង ចោលកាកសំណល់ទាំងនោះមិនត្រូវបានសម្អាតឲ្យបានម៉ត់ចត់ត្រឹមត្រូវមុនពេល បញ្ចប់សម្បទាន។ | ▪ ក្រុមហ៊ុននឹងចាត់ចែងលុបបំបាត់កន្លែងចោលកាកសំណល់រឹងរាវទាំងអស់មុនពេលសម្បទានត្រូវបានបញ្ចប់ដើម្បីធានាថាគ្មានការបំពុលដីកើតមានឡើង។ |
| **សំលេងនិងរំញ័រ** | |
| ▪ បញ្ហាសំលេងដែលកើតឡើង ដោយសារគ្រឿងចក្រមធ្យោបាយដឹកជញ្ជូននឹងមិនមានបញ្ហាចោទទេ ព្រោះពុំមានសកម្មភាព អ្វីដោយសារគ្រឿងចក្រនិងមធ្យោបាយ ដឹកជញ្ជូនទៀតឡើយ។<br>▪ មិនមានរំញ័រកើតមានឡើងទេព្រោះក្រុមហ៊ុនពុំវាយកំទេចចោលនូវអាគារឃ្លាំង ឬហេដ្ឋារចនាសម្ព័ន្ធផ្សេងៗឡើយ។ | ▪ មុនពេលគម្រោងត្រូវបានបញ្ចប់ក្រុមហ៊ុន នឹងត្រូវប្រគល់នូវហេដ្ឋារចនាសម្ព័ន្ធ ដែលបានសាងសង់ ជូនដល់ភាគីក្រសួងជំនាញ ដើម្បីមានវិធានការគ្រប់គ្រងបន្ត។ |
| **បរិស្ថានសង្គម**<br>ការប្រើប្រាស់ដី | |
| ▪ អាចមានបញ្ហារំលោភចាប់យក ដីសម្បទានដែលនឹងត្រូវបញ្ចប់គម្រោងវិនិយោគពីសំណាក់ជនខិលខូចមួយចំនួនតូច។ | ▪ មុនពេលគម្រោងវិនិយោគត្រូវបានបញ្ចប់ក្រុមហ៊ុនត្រូវធ្វើលិខិតជាផ្លូវការជូនទៅ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអជ្ញាធរមូលដ្ឋានដើម្បីប្រគល់ដីសម្បទាននេះ ទៅឲ្យរាជរដ្ឋាភិបាលវិញសំដៅឲ្យស្ថាប័នជំនាញមានវិធានការគ្រប់គ្រងបន្ត និងធានាថាមិនមានករណីរំលោភបំពានយកដីសម្បទានជា កម្មសិទ្ធឯកជនរបស់ជនខិលខូចមួយចំនួនឡើយ |
| ការរស់នៅ និងមុខរបរ | |
| ▪ នៅពេលគម្រោងវិនិយោគ ត្រូវបានបញ្ចប់ទៅបុគ្គលិកកម្មករ គម្រោងពិសេសអ្នកភូមិដែល រស់នៅក្បែរដីសម្បទាននឹងត្រូវបាត់បង់ ការងារធ្វើ | ▪ រយៈពេលយ៉ាងតិច០៦ខែ មុនពេលបញ្ចប់គម្រោងក្រុមហ៊ុនត្រូវ ជូនដំណឹងជាមុនដល់បុគ្គលិកកម្មកររបស់ខ្លួន ដើម្បីពួកគាត់មានឱកាសគ្រប់គ្រាន់ក្នុងការស្វែងរកការងារធ្វើបន្ត។ |

Draft

| | |
|---|---|
| ដែលមានការប៉ះពាល់ដល់សេដ្ឋកិច្ចគ្រួសារ។<br>▪ អាចមានបញ្ហាទំនាស់រវាង ក្រុមហ៊ុន និងបុគ្គលិកកម្មករ ក្នុងករណីដែលប្រាក់បៀវត្ស ឬប្រាក់ឧបត្ថម្ភផ្សេងៗ មិនបានបើកផ្តល់ទាន់ពេល និងគ្រប់ចំនួននៅពេលគម្រោងបិទ។ | ▪ ប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភផ្សេងៗត្រូវតែទូទាត់សងដល់បុគ្គលិកកម្មករគ្រប់ចំនួន ដើម្បីជៀសវាងនូវបញ្ហាទំនាស់រវាងក្រុមហ៊ុន និងបុគ្គលិកកម្មករ។ |
| **ផ្លូវគមនាគមន៍** | |
| ▪ អាចនឹងមាន បញ្ហាផ្លូវគមនាគមន៍ ព្រោះថា នៅពេលក្រុមហ៊ុនឈប់ធ្វើអាជីវកម្មនៅក្នុង តំបន់ដីសម្បទានប្រព័ន្ធផ្លូវទាំងនោះ នឹងអាចខូចខាតលំបាកធ្វើដំណើរ។ | ▪ ក្រុមហ៊ុននឹងត្រូវប្រគល់តំបន់ដីសម្បទាន នេះជូនទៅរាជរដ្ឋាភិបាលវិញ ដើម្បីគ្រប់គ្រងបន្តជៀសវាងការធ្វើឲ្យផ្លូវកាន់តែខូចខ្លាំង ពិបាកធ្វើដំណើរដល់អ្នកភូមិ ដែលធ្លាប់តែធ្វើចរាចរដឹកជញ្ជូន ផលិតផលកសិកម្មរបស់ពួកគាត់កាត់តំបន់ដីសម្បទាននេះ។ |

Draft

## ២-ការពិនិត្យតាមដានហេតុប៉ះពាល់បរិស្ថាន-សង្គម

### ២-១-ស្ថានភាពទូទៅ

ការអង្កេតតាមដានហេតុប៉ះពាល់របស់គម្រោង គឺជាការធ្វើអត្តសញ្ញាណព្យាករណ៍ វាយតម្លៃ និង ទំនាក់ទំនងព័ត៌មានស្តីពីផលប៉ះពាល់ដល់បរិស្ថាន-សង្គម និងសិក្សាលម្អិតលើវិធានការកាត់បន្ថយផល ប៉ះពាល់មុនពេលគម្រោង និងហេតុប៉ះពាល់ទាំងឡាយណាដែលកើតឡើងថ្មីៗ។ ការតាមដានផលប៉ះពាល់មានសារៈសំខាន់ណាស់ក្នុងដំណើរការពិនិត្យផលប៉ះពាល់បរិស្ថានក្នុងកំឡុងពេលអនុវត្តការងារ ដើម្បីតម្រង់ទិសដៅតាមគោលការណ៍ និងដោះស្រាយផលប៉ះពាល់ដែលនឹងបង្កឡើង។ កម្មវិធីពិនិត្យតាមដានផលប៉ះពាល់បរិស្ថាន-សង្គម ត្រូវកំណត់ជាបីដំណាក់កាលៈ

- ដំណាក់កាលដំបូងតាមដានផលប៉ះពាល់បរិស្ថាន-សង្គម ក្នុងពេលចាប់ផ្តើមដំណើរការគម្រោង។
- ដំណាក់កាលទី២តាមដានប្រសិទ្ធភាព នៃការត្រួតពិនិត្យផលប៉ះពាល់បរិស្ថានសង្គម ក្នុងពេលគម្រោងកំពុងប្រតិបត្តិ។
- ដំណាក់កាលទី៣តាមដាននិងវាយតម្លៃអំពីការវិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម និងការប្រែប្រួលនៃប្រពន្ធ័អេកូឡូស៊ីពេលគម្រោងត្រូវបានបញ្ចប់។

### ២.២-សកម្មភាពតាមដានត្រួតពិនិត្យ

#### ២.២.១-ការចុះធ្វើអធិការកិច្ចតាមដានវិធានការការពារបរិស្ថាន

ការធ្វើអធិការកិច្ច ដើម្បីតាមដានបណ្តាវិធានការការពារបរិស្ថាននិងសង្គម គឺជាការចាំបាច់បំផុតដើម្បីពិនិត្យមើលថា ៖ វិធានការកាត់បន្ថយផលប៉ះពាល់នានាដូចដែលបានចែងនោះកំពុងត្រូវបានអនុវត្តដែរ ឬទេ និងដើម្បីរកឲ្យឃើញសកម្មភាពការពារបន្ថែមទៀតដែលចាំបាច់ហើយត្រូវចាត់ការជាបន្ទាន់ចំពោះ បញ្ហាដែលកំពុងកើតឡើងទាំងនោះ។

**ដំណាក់កាលដំបូង៖**ការត្រួតពិនិត្យនៅពេលគម្រោងអភិវឌ្ឍន៍ដំណាំកសិ-ឧស្សាហកម្មត្រូវបានចាប់ផ្តើមលើហេតុប៉ះពាល់បរិស្ថានសំខាន់ៗ ពិសេសលើធនធានធម្មជាតិនៅក្នុងតំបន់ដីសម្បទាននិងស្ថានភាពសេដ្ឋកិច្ចសង្គមក្នុងតំបន់ដែលបង្កឡើងដោយសកម្មភាពគម្រោងក្នុងដំណាក់កាលនេះ។

**ដំណាក់កាលប្រតិបត្តិការ៖** ការត្រួតពិនិត្យហេតុប៉ះពាល់បរិស្ថាន-សង្គមនៅដំណាក់កាលនេះមាន សារៈសំខាន់ណាស់ព្រោះហេតុប៉ះពាល់ផ្សេងៗ នឹងកកើតឡើងដោយសកម្មភាពអភិវឌ្ឍន៍ដូចជា៖ ដីស្រទាប់លើ និងវាយនភាពដីការហូរច្រោះទឹកអាកាសធាតុព្រៃឈើសត្វព្រៃ និងជីវភាពរស់នៅរបស់ប្រជាជនមូលដ្ឋាននឹងត្រូវបានពិនិត្យនិងអាចចាត់វិធានការទប់ស្កាត់ទាន់ពេលវេលា។

**ដំណាក់កាលបញ្ចប់ប្រតិបត្តិការ៖** ត្រួតពិនិត្យឲ្យបានច្បាស់លាស់នូវហេតុប៉ះពាល់អ្វីខ្លះពេលគម្រោងចប់ និងវិធានការកាត់បន្ថយក្នុង ដំណាក់កាលនោះដែលចាំបាច់ត្រូវអនុវត្ត។

ក្រុមហ៊ុននឹងត្រូវរួមសហការជាមួយស្ថាប័នមានសមត្ថកិច្ច ដែលពាក់ពន្ធ័នានា ដើម្បីចុះធ្វើការវាយតម្លៃនូវផលប៉ះពាល់បរិស្ថាន-សង្គម និងការត្រួតពិនិត្យវិធានការកាត់បន្ថយតាមកម្មវិធីដូចមានលម្អិតក្នុងចំណុច ២.២.២ ខាងក្រោមនេះ។

**២.២.២-កម្មវិធីត្រួតពិនិត្យបរិស្ថាន**

**ការហូរច្រោះដី**

- ត្រួតពិនិត្យទីតាំងចំការឈើដែលបានឈូសឆាយភ្ជួររាស់ និងសំណល់រឹង-រាវ។
- ត្រួតពិនិត្យការហូរច្រោះ និងកករដីដោយត្រូវពិនិត្យមើលព្រៃដែលរក្សាទុកតាមដងអូរនានា។
- ពិនិត្យមើលការពារធនធានធម្មជាតិ ដែលមានវត្តមាននៅតំបន់អភិវឌ្ឍន៍ និងពិនិត្យលើការដាំដុះតាមផែនការដែរឬទេ។
- ការត្រួតពិនិត្យត្រូវអនុវត្តនៅដំណាក់កាលគម្រោងចាប់ផ្តើម ០១ដង ដំណាក់កាលប្រតិបត្តិគម្រោង០១ដង/១ឆ្នាំ និងដំណាក់កាលបញ្ចប់គម្រោង០១ដង។

**គុណភាពទឹកលើទឹក**

- សិក្សាចរន្តទឹកនិងបរិមាណទឹកអូរត្រពាំងស្ទឹងអូរធម្មជាតិ។
- ពិនិត្យគុណភាពទឹកលើសារធាតុគីមីសារធាតុគីមីសរីរាង្គ និងភាពល្អក់កករនិងពិនិត្យការគ្រប់គ្រងប្រភពបំពុលទឹកពីសំណល់រឹង-រាវគ្រប់ប្រភេទ។
- ការត្រួតពិនិត្យត្រូវអនុវត្តនៅដំណាក់កាលកសាងគម្រោង០១ដង ដំណាក់កាលប្រតិបត្តិការគម្រោងពី០២ដង/ឆ្នាំ និងដំណាក់កាលបញ្ចប់គម្រោង០១ដង។

Draft

**ធនធានព្រៃឈើនិងសត្វព្រៃ**

- សិក្សាពីសារព័ន្ធព្រៃឈើអំបូរធនធានព្រៃឈើ និងប្រភេទសត្វព្រៃដែលមានវត្តមាននៅតំបន់នោះ។
- ប្រភេទរុក្ខជាតិនិងសត្វព្រៃដែលរងគ្រោះថ្នាក់កម្រនិងជិតផុតពូជ។
- ពិនិត្យតំបន់ព្រៃទ្រនាប់ដែលជាជម្រកសត្វព្រៃហើយការអភិរក្សធនធានព្រៃឈើ និងសត្វព្រៃ និងពិនិត្យពីការបរបាញ់សត្វព្រៃ។
- ការត្រួតពិនិត្យត្រូវអនុវត្តនៅដំណាក់កាលកសាងគម្រោង ០១ដង ដំណាក់កាលប្រតិបត្តិគម្រោង០១ដង/ឆ្នាំនិងដំណាក់កាលបញ្ចប់គម្រោង០១ដង។

**ផ្លូវគមនាគមន៍**

- ពិនិត្យការធ្វើចរាចរណ៍តាមដងផ្លូវនិងបញ្ហាដែលកកើតមានឡើងផ្សេងៗ។
- ត្រួតពិនិត្យការដាក់ផ្លាកសញ្ញាចរាចរតាមផ្លូវនិងថែរក្សាផ្លូវ។
- ការត្រួតពិនិត្យត្រូវអនុវត្តនៅដំណាក់កាលកសាងគម្រោង០១ដង ដំណាក់កាលប្រតិបត្តិគម្រោង ០១ដង/ឆ្នាំ និងដំណាក់កាលបញ្ចប់គម្រោង០១ដង។

**សុខភាពសាធារណៈ**

- ពិនិត្យការផ្តល់សេវាពិនិត្យ និងព្យាបាលសុខភាពបុគ្គលិកកម្មករព្រមទាំងស្រាវជ្រាវប្រភេទជំងឺដែលកើតមានថ្មីៗ។
- ពិនិត្យការចាក់ថ្នាំបង្ការោគរាតត្បាតផ្សេងៗដូចជាៈ ជំងឺរបេងអាសន្នរោគ និងគ្រុនចាញ់ និង ជំងឺផ្សេងៗទៀត។ល។
- ការងារអប់រំនិងណែនាំដល់បុគ្គលិក-កម្មករឲ្យយល់ដឹងពីជំងឺឆ្លងផ្សេងៗដូចជា ជំងឺថ្លើមអេដស៍។ល។
- ការត្រួតពិនិត្យត្រូវអនុវត្តនៅដំណាក់កាលគម្រោងចាប់ផ្តើម ០១ដង ដំណាក់កាលប្រតិបត្តិគម្រោង ០១ដង/ឆ្នាំ និងដំណាក់កាលបញ្ចប់គម្រោង០១ដង។

**សេដ្ឋកិច្ច-សង្គម**

- សិក្សាលើកំរិតជីវភាពប្រជាជនមូលដ្ឋាន និងហេតុប៉ះពាល់ផ្សេងៗដែលកើតឡើងជាយថាហេតុ។
- សកម្មភាពគម្រោងដែលជួយកាត់បន្ថយភាពក្រីក្រដោយបង្កើតការងារជូនប្រជាជនបង្កើនប្រភពចំណូលនិងផ្តល់បច្ចេកវិទ្យាផ្សេងៗ។
- ការត្រួតពិនិត្យត្រូវអនុវត្តនៅដំណាក់កាលកសាងគម្រោង ០១ដង ដំណាក់កាលប្រតិបត្តិគម្រោង ០១ដង/ឆ្នាំ និងដំណាក់កាលបញ្ចប់គម្រោង០១ដង។

Draft

## ៣-សេចក្តីសន្និដ្ឋាន

សកម្មភាពរៀបចំទីតាំង និងការធ្វើអាជីវកម្មនៃគម្រោងអភិវឌ្ឍន៍ដំណាំកសិ-ឧស្សាហកម្ម របស់ក្រុមហ៊ុនអាចមានផលប៉ះពាល់អវិជ្ជមាន និងវិជ្ជមាន។ ចំពោះផលប៉ះពាល់អវិជ្ជមានត្រូវកាត់បន្ថយតាមតែអាចធ្វើទៅបានដើម្បីសម្រេចតាមទិសដៅអភិវឌ្ឍន៍ដោយនិរន្តរភាព។

ពិនិត្យជារួម ផលប្រយោជន៍ជាវិជ្ជមាននៃគម្រោងអភិវឌ្ឍន៍នេះ មានទំហំធំធេងណាស់រីឯផលប៉ះពាល់ដែលបានលើកឡើង ក្នុងផែនការមេនេះជាផ្នែកមួយដែលអាចកាត់បន្ថយបានទាំងស្រុង ដោយបានរៀបចំ និងធ្វើអត្តសញ្ញាណស្រេចក្នុងផែនការសកម្មភាពនេះ ហើយដែលអាចដំណើរការបានដោយប្រើប្រាស់ឧបករណ៍វាស់វែងសំខាន់ៗ ដូចបានរៀបរាប់ខាងលើក្នុងសកម្មភាពប្រតិបត្តិការដាំដុះដោយពិចារណាលើប៉ារ៉ាម៉ែត្រដែលបង្កផលប៉ះពាល់ ហើយចាត់វិធានការកាត់បន្ថយឲ្យមានប្រសិទ្ធភាព។

ទោះបីជាយ៉ាងនេះក្តី ក្រុមហ៊ុនត្រៀមខ្លួនសហការយ៉ាងជិតស្និទ្ធជាមួយស្ថាប័នមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ជាពិសេសក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន អាជ្ញាធរដែនដី ដើម្បីពិភាក្សា និងធ្វើការកែប្រែនូវលក្ខណៈបច្ចេកទេសដើម្បីឲ្យសមស្របទៅតាមគោលការណ៍ណែនាំ និងកម្រិតកំណត់បទដ្ឋានបរិស្ថានធ្វើយ៉ាងណាការពារ និងជៀសវាងឲ្យបាននូវផលប៉ះពាល់បរិស្ថានដែលបង្កឡើង ដោយហេតុណាមួយក្នុងពេលប្រតិបត្តិការគម្រោង។ ម្យ៉ាងវិញទៀតក្រុមហ៊ុនយើងខ្ញុំនឹងចូលរួមសហការក្នុងការតាមដានត្រួតពិនិត្យ និងវាយតម្លៃសកម្មភាពអាជីវកម្ម និងផលប៉ះពាល់បរិស្ថានជាមួយស្ថាប័នជំនាញនានា។

**<u>បញ្ជាក់៖</u>** ជំពូកទីV នេះគ្រាន់តែជាទស្សនៈយល់ឃើញរបស់ក្រុមហ៊ុនអំពីផលប៉ះពាល់នានាទៅលើបរិស្ថាន សង្គម ដោយសារគម្រោងវិនិយោគនេះ និងវិធានការនានារបស់ក្រុមហ៊ុន ដើម្បីកាត់បន្ថយតែប៉ុណ្ណោះ។

### វិភាគលើភាពចៃដន្យ ( Risk Analysis )

ដើម្បីអនុវត្តបានដោយជោគជ័យប្រកបដោយប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ ក្រុមហ៊ុននឹងខិតខំប្រឹងប្រែងជំនះរាល់ឧបសគ្គដែលអាចនឹងកើតមានក្នុងប្រតិបត្តិការនៃសម្បទាននេះ។ កត្តារាំងស្ទះដល់ការវិនិយោគដែលអាចមិនទទួលបានជោគជ័យគឺ៖

- ការព្រួយបារម្ភពីការចាប់យកដីដោយអនាធិបតេយ្យ ពីសំណាក់ជនខិលខូចមួយចំនួនលើដីដែលរដ្ឋបានធ្វើសម្បទានឲ្យក្រុមហ៊ុន។
- ប្រសិនបើមានការមិនចូលរួមសហការ និងជួយអន្តរាគមន៍ពីស្ថាប័នមានសមត្ថកិច្ចដើម្បីដោះស្រាយក្នុងឧប្បត្តិហេតុណាមួយលើ ករណីដែលមានអ្នកប្រព្រឹត្តល្មើសរំលោភលើសិទ្ធិរបស់ក្រុមហ៊ុនក្នុងក្របខណ្ឌ នៃការអនុវត្តន៍កិច្ចសន្យាការរំលោភដី